# សៀវភៅជំនួយស្មារតីស្ដីពីការការពារសុវត្ថិភាពពីគ្រាប់មីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រឿងផ្ទុះកែច្នៃ (IED)



UNMAS

អង្គការសហប្រជាជាតិ និងអង្គការដែលរួមចំណែករៀបចំសៀវភៅនេះ
ពុំទទួលខុសត្រូវចំពោះការស្លាប់ ឬការរងរបួស
ចំពោះបុគ្គលិក និង/ឬការខូចខាតទ្រព្យសម្បត្តិដែលអាច
បណ្តាលមកពីការប្រើប្រាស់សៀវភៅជំនួយស្មារតីនេះឡើយ។

រាល់មតិយោបល់ ឬសំណួរទាក់ទងនឹងសៀវភៅជំនួយស្មារតីនេះ
អាចផ្ញើទៅកាន់៖

ផ្នែកសកម្មភាពកំចាត់មីននៃអង្គការសហប្រជាជាតិ (UNMAS)
New York, NY 10017 USA

អ៊ីមែល៖ mineaction@un.org
វិបសាយ៖ www.mineaction.org

© អង្គការសហប្រជាជាតិ ឆ្នាំ 2015 (បោះពុម្ពលើកទី 3)
រក្សាសិទ្ធិគ្រប់យ៉ាង

រូបថតក្រប
ផ្នែខាងក្រោយ រូបថតរបស់ អសប / Iason Foounten
អ្នកបោសសម្អាតមីន រូបថតរបស់ UNMAS / Marc Vaillant

រូបតំណាងមីន
ក្រប & ទំព័រទី 8, 9, 36, 37, 56, 57, 76, 77, 88, 89, 96, 97
Critical Mass

អ្នកត្រួតពិនិត្យ
Thomas Enke

ការរចនា & ប្លង់
Mackenzie Crone

# អង្គការសហប្រជាជាតិ
# គ្រាប់មីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រឿងផ្ទុះកែច្នៃ
## សៀវភៅជំនួយស្មារតីស្ដីពីការការពារសុវត្ថិភាពពី

អង្គការសហប្រជាជាតិ
ផ្នែកសកម្មភាពកំចាត់មីននៃអង្គការសហប្រជាតិ (UNMAS)
New York, NY 10017 USA
អ៊ីមែល៖ MineAction@un.org
វិបសាយ៖ www.mineaction.org

សៀវភៅជំនួយស្មារតីសម្រាប់អ្នកធ្វើការនៅតាមតំបន់ដែលញាំញីដោយគ្រាប់មីន
និងមានគ្រោះថ្នាក់នៃគ្រឿងផ្ទុះផ្សេងៗ រួមបញ្ចូលទាំងគ្រឿងផ្ទុះកែច្នៃ។

# មាតិកា


## សេចក្តីថ្លែងអំណរគុណ 5

## សេចក្តីផ្តើម 6

## 1 ការតំរាមកំហែង 9

1.1 គ្រាប់មីន 11
1.2 យុទ្ធភណ្ឌមិនទាន់ផ្ទុះ 21
1.3 យុទ្ធភណ្ឌដែលគេបោះបង់ចោល 34
1.4 គ្រឿងផ្ទុះកែច្នៃ (IEDs) និងអន្ទាក់/គ្រាប់បែកបង្កៃ 35

## 2 ការសម្គាល់ពីតំបន់គ្រោះថ្នាក់ 39

2.1 សញ្ញាព្រមាន 40
2.2 តម្រុយព្រមាន 44
2.3 សញ្ញានៃការប្រយុទ្ធគ្នា ឬសកម្មភាពយោធា 47
2.4 សញ្ញានៅក្នុងតំបន់ សត្វពាហនៈស្លាប់ ឬវត្ថុខុសប្រក្រតី 52
2.5 ទម្លាប់តាមមូលដ្ឋាន 57

## 3 ដំបូន្មានអំពីសុវត្ថិភាពជាមូលដ្ឋាន 61

3.1 ទម្លាប់ប្រថុយប្រថាន 63
3.2 ជំនឿសាមញ្ញអំពីគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម 66
3.3 ដំបូន្មានអំពីសុវត្ថិភាពសម្រាប់អង្គភាព 69
3.4 ដំបូន្មានអំពីសុវត្ថិភាពសម្រាប់បុគ្គល 72




## 4 នីតិវិធីសង្គ្រោះបន្ទាន់ 85

4.1 នីតិវិធីសង្គ្រោះបន្ទាន់នៅតំបន់ដែលញាំញីដោយជាតិផ្ទុះ ឬចម្ការមីន 86

4.2 នីតិវិធីសង្គ្រោះបន្ទាន់ករណីមានការវាយប្រហារដោយគ្រឿងផ្ទុះកែច្នៃ 93

## 5 ការជួយជនរងគ្រោះ 99

5.1 ការជម្លៀសខ្លួនចេញពីកន្លែងផ្ទុះដែលមិនស្គាល់ 101

5.2 ការផ្តល់ការសង្គ្រោះបឋម 102

## ឧបសម្ព័ន្ធ 109

A1 ការប្រើប្រាស់កាតធ្វើដំណើរ 110

A2 វិធានបង្កើនការការពារសុវត្ថិភាពដល់យានយន្ត 120

A3 ការពិនិត្យ 5/25 ម៉ែត្រ 122

A4 ការគំរាមកំហែងផ្សេងៗ 123

A4.1 អ៊ុយរ៉ានីញ៉ូមរឹង

A4.2 ការគំរាមកំហែងដោយអាវុធជីវសាស្រ្ត និងអាវុធគីមី

A5 ការណែនាំអំពីចម្ងាយត្រូវជម្លៀសខ្លួន 129

A6 ប្រាំបួនជាន់ថ្នាក់ 130

A7 សន្ទានុក្រម 131

A8 ពាក្យបំព្រួញ 136

A9 សម្រាប់ព័ត៌មានបន្ថែម 140

អ្នកដែលត្រូវទាក់ទងទៅនៅគ្រាមានអាសន្ន 141

ចំណាំ 142



**រូបភាពទី 0.1**
ការរក្សាចម្ងាយសុវត្ថិភាព អ្នកស្រុកនៅភូមិជនជាតិអាហ្វហ្គានីស្ថានសង្កេតមើលការកម្ទេចចោល។
រូបថតរបស់ UNMAS/Thomas Enke

# សេចក្តីថ្លែងអំណរគុណ

សៀវភៅជំនួយស្មារតីនេះ គឺជាការបោះពុម្ពលើកទី 3 នៃសៀវភៅជំនួយស្មារតីការពារសុវត្ថិភាពគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដែលបានផលិតកន្លងមកដោយអង្គការសហប្រជាជាតិនៅឆ្នាំ 2005 ដែលពីដើមឡើយយកលំនាំតាមសៀវភៅជំនួយស្មារតីការពារសុវត្ថិភាពពីគ្រាប់មីនដែលបានរៀបចំដោយ និងបោះពុម្ពផ្សាយដោយអង្គការ CARE នៅឆ្នាំ 1997។ ដោយសៀវភៅជំនួយស្មារតីនេះ ត្រូវបានកែសម្រួលជាច្រើនលើកច្រើនសាររួមទាំងចំណងជើងផង ដើម្បីឆ្លុះបញ្ចាំងនូវវាក្យស័ព្ទថ្មីចុងក្រោយបង្អស់។ លើសពីនេះ ការអភិវឌ្ឍថ្មីៗនៅក្នុងវិស័យបោសសម្អាតមីន កាកសំណល់ជាតិផ្ទុះ (EOD) និងកាកសំណល់ជាតិផ្ទុះកៃច្នៃ (IEDD) ក៏ដូចជាជំនួយផ្នែកពេទ្យសង្គ្រោះបន្ទាន់ ក៏ត្រូវបានលើកយកមកពិចារណាផងដែរ។ ការគំរាមកំហែងដែលកើនឡើងដោយគ្រឿងផ្ទុះកៃច្នៃ បណ្តាលឲ្យមានការបញ្ចូលបន្ថែមបណ្តាជំពូកបច្ចុប្បន្នជាច្រើនទៀត។

សៀវភៅជំនួយស្មារតីស្តីពីការការពារសុវត្ថិភាពពីគ្រាប់មីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រឿងផ្ទុះកៃច្នៃនេះ ដកស្រង់ចេញពីព័ត៌មានដែលមាននៅក្នុងគោលការណ៍ណែនាំជាអន្តរជាតិសម្រាប់ការអប់រំចំណេះដឹងស្តីពីគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដែលរៀបចំដោយដោយមូលនិធិសហប្រជាជាតិដើម្បីកុមារ (UNICEF) នៅឆ្នាំ 1999 និង ស្តង់ដារសកម្មភាពកម្ចាត់មីនអន្តរជាតិដែលបានបោះពុម្ពផ្សាយដោយអង្គការសហប្រជាជាតិ (www.mineactionstandards.org)។ សៀវភៅជំនួយស្មារតីស្តីពីការពារសុវត្ថិភាពពីគ្រាប់មីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រឿងផ្ទុះកៃច្នៃនេះ គឺជាផ្នែកមួយនៃគម្រោងការពារសុវត្ថិភាពពីគ្រាប់មីនរបស់ អង្គការសហប្រជាជាតិលើសកម្មភាពមីន (UNMAS)។

# សេចក្ដីផ្ដើម

គ្រាប់មីន និងគ្រឿងផ្ទុះបង្កគ្រោះថ្នាក់ផ្សេងទៀត ដូចជា គ្រាប់បែកដែលគេបោះបង់ចោល និងបរិក្ខារយោធា យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងសំណល់ជាតិផ្ទុះពីសង្គ្រាមផ្សេងៗ (ERW) ក៏ដូចជាគ្រឿងផ្ទុះកែច្នៃ (IEDs) បង្កឲ្យមានគ្រោះថ្នាក់នៅទូទាំងពិភពលោក។

សៀវភៅជំនួយស្មារតីនេះ ពុំមែនជាសៀវភៅបង្ហាត់បង្រៀនសម្រាប់ការធ្វើការជាមួយគ្រាប់មីន និងគ្រឿងផ្ទុះបង្កគ្រោះថ្នាក់ឡើយ។ វាក៏ពុំមែនជាសៀវភៅជំនួយស្មារតីសម្រាប់ការធ្វើការជាមួយសហគមន៍ដែលរងផលប៉ះពាល់ដោយសារគ្រាប់មីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រឿងផ្ទុះកែច្នៃនោះដែរ។ ផ្ទុយទៅវិញ សៀវភៅជំនួយស្មារតីមានគោលបំណងលើកកម្ពស់ការយល់ដឹង និងផ្ដល់នូវព័ត៌មានសុវត្ថិភាពជាមូលដ្ឋានពាក់ព័ន្ធនឹងការគំរាមកំហែងរបស់គ្រាប់មីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រឿងផ្ទុះកែច្នៃដល់បណ្ដាអង្គភាព និងបុគ្គលទាំងឡាយដែលធ្វើការនៅក្នុងតំបន់ដែលរងផលប៉ះពាល់ និងដើម្បីជួយដល់ពួកគេក្នុងការៈ

- បង្កើតនីតិវិធីសុវត្ថិភាពសមស្រប
- ជៀសវាងការប៉ះពាល់ជាមួយមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រឿងផ្ទុះកែច្នៃ និង
- ចាត់វិធានការសមស្របនៅក្នុងស្ថានភាពបន្ទាន់

ការស្ថិតនៅជិតគ្រឿងផ្ទុះ ជានិច្ចកាលតែងតែមានគ្រោះថ្នាក់ ហើយគួរតែជៀសវាង។ មានតែអ្នកឯកទេសដែលបានទទួលការបណ្ដុះបណ្ដាលប៉ុណ្ណោះដែលដែលគួរតែជាអ្នកទៅរក ឬចាប់កាន់គ្រាប់មីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រឿងផ្ទុះកែច្នៃបាន។

ព័ត៌មានដែលមាននៅក្នុងសៀវភៅជំនួយស្មារតីនេះមានលក្ខណៈទូទៅ ហើយព័ត៌មានមួយចំនួនពុំអាចយកទៅអនុវត្តបានគ្រប់ស្ថានភាពបានឡើយ។ អាស្រ័យហេតុនេះ វាត្រូវមានការបំពេញបន្ថែមដោយព័ត៌មានជាក់លាក់តាមប្រទេសនីមួយៗ និងការវិភាគទៅលើលក្ខណៈ និងវិសាលភាពនៃការគំរាមកំហែងតាមមូលដ្ឋាននីមួយៗ បន្ថែមពីលើនេះទៀត សៀវភៅជំនួយស្មារតីនេះ ពុំត្រូវបានរៀបចំឡើងជាឯកសារ

## តើអ្នកដឹងទេ?

ដោយគិតចាប់ពីខែមករា ឆ្នាំ 2015 មក បណ្ដារដ្ឋភាគីចំនួន 162 រដ្ឋ ដែលជាភាគីបានចុះហត្ថលេខា និងផ្ដល់សច្ចាប័នលើសន្ធិសញ្ញាហាមប្រាមមីនប្រឆាំងមនុស្ស (APMBT ឬហៅម្យ៉ាងទៀតថា អនុសញ្ញាទីក្រុងអូតាវ៉ា)។ មានរដ្ឋមួយមួយបានចុះហត្ថលេខា ប៉ុន្តែពុំទាន់បានផ្ដល់សច្ចាប័នលើសន្ធិសញ្ញានេះនៅឡើយ។ នៅក្នុងការធ្វើការងារនេះ បណ្ដារដ្ឋភាគីទាំងនេះបានយល់ព្រមបញ្ឈប់ការប្រើប្រាស់ ការស្តុក ការផលិត និងការផ្ទេរមីនប្រឆាំងមនុស្ស (AP) ហើយក៏បានព្រមព្រៀងធ្វើការបំផ្លាញវាចោលផងដែរ។ អនុសញ្ញានេះក៏មានបទបញ្ញត្តិសម្រាប់ឲ្យជនរងគ្រោះដោយសារគ្រាប់មីនទទួលបានជំនួយផងដែរ។ ចាប់តាំងពីអនុសញ្ញានេះបានចូលជាធរមាននៅឆ្នាំ 1999 ការប្រើប្រាស់មីនប្រឆាំងមនុស្សមានការថយចុះ។ ទោះជាយ៉ាងណា

ឯកឯងទ្បើយ ប៉ុន្តែគួរយកទៅប្រើប្រាស់សម្រាប់ជួយពន្យល់ដោយសង្ខេបអំពីគ្រឿងផ្ទុះដែលធ្វើឡើងគ្រូបង្ហាត់ដែលមានសមត្ថភាពគ្រប់គ្រាន់។

នៅពេលណាអាចធ្វើបាន អ្នកអានគួរស្វែងរកការណែនាំ និងដំបូន្មានពីអ្នកឯកទេសដែលធ្វើការនៅតំបន់ប្រតិបត្តិការរបស់ខ្លួន។

សៀវភៅជំនួយស្មារតីនេះបែងចែកទៅជាប្រាំផ្នែកធំៗ និងឧបសម្ព័ន្ធ។

## ផ្នែកទី 1

ផ្តល់នូវព័ត៌មានអំពីលក្ខណៈនៃការគំរាមកំហែង ដោយសារគ្រាប់មីន និងគ្រឿងផ្ទុះដែលអាចបង្កគ្រោះថ្នាក់ផ្សេងទៀត ដូចជា សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រឿងផ្ទុះកែច្នៃជាដើមច្នៃ

## ផ្នែកទី 2

ផ្តល់នូវដំបូន្មានអំពីរបៀបសម្គាល់ការគំរាមកំហែង

## ផ្នែកទី 3

ផ្តល់នូវដំបូន្មានការពារ និងព័ត៌មានសុវត្ថិភាពទូទៅអំពីការជៀសវាងបញ្ហាគំរាមកំហែង

## ផ្នែកទី 4

ពន្យល់អំពីអ្វីដែលត្រូវធ្វើ បើអ្នកយល់ថាខ្លួនអ្នកស្ថិតនៅក្នុងតំបន់ដែលញាំញីដោយគ្រាប់រំសេវ និង

## ផ្នែកទី 5

ផ្តល់នូវព័ត៌មានសំខាន់ៗអំពីអ្វីដែលត្រូវធ្វើនៅក្នុង ករណីមានគ្រោះថ្នាក់។

ឧបសម្ព័ន្ធផ្តល់នូវឧទាហរណ៍អំពីនីតិវិធីក្នុងការធ្វើដំណើរ ព័ត៌មានអំពីការគំរាមកំហែងផ្សេងៗ ដូចជា អ៊ុយរ៉ានីញ៉ូមរឹង គ្រាប់រំសេវគីមីសាស្ត្រ និងជីវសាស្ត្រ និងរៀបរាប់ពីធីបង្កើតឲ្យមានកន្លែងសុវត្ថិភាព។

មានតែរដ្ឋមួយចំនួនតូច (មិនមែនជាហត្ថលេខីនៃសន្ធិសញ្ញានេះ) ដែលបានបន្តប្រើប្រាស់ និងស្តុកមីនប្រឆាំងមនុស្ស ហើយរដ្ឋចំនួន 59 និងតំបន់ចំនួន 4 ផ្សេងទៀតបានស្ថិតក្រោមរូបភាពមួយចំនួននៃការញាំញីដោយគ្រាប់មីនពាសវាលពាសកាលដែលសល់ពីជម្លោះអតីតកាល និងជម្លោះដែលកំពុងបន្ត។[1] មីនប្រឆាំងមនុស្សបង្កគំរាមកំហែងធ្ងន់ធ្ងរបំផុតមួយចំនួនទៅលើអ្នកដែលធ្វើការនៅតាមតំបន់ក្រោយមានជម្លោះ ទោះសូម្បីរាប់ទសវត្សរ៍ក្រោយជម្លោះក៏ដោយ។

[1] ការត្រួតពិនិត្យគ្រាប់មីន និងគ្រាប់បែកចង្កោម (ខែមករា ឆ្នាំ 2015)



ប្រទេសលីប៊ី

រូបថតរបស់ UNMAS/Giovanni Diffidenti



# ផ្នែកទី 1

# ការគំរាមកំហែង

# ការគំរាមកំហែង

អ្នកធ្វើការនៅតាមតំបន់ដែលធ្លាប់មានជម្លោះប្រដាប់អាវុធ អាចប្រឈមជាមួយនឹងការគំរាមកំហែងដែលបង្កឡើងដោយគ្រាប់មីន និងគ្រឿងផ្ទុះបង្កគ្រោះថ្នាក់ផ្សេងទៀត ដូចជា យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ឬយុទ្ធភ័ណ្ឌដែលគេបោះបង់ចោល រថយន្ត និងបរិក្ខារយោធាដែលគេបោះបង់ចោល និងគ្រឿងផ្ទុះកែច្នៃជាដើម។ (សូមកត់ចំណាំថា ពាក្យថា សំណល់ជាតិផ្ទុះពីសង្គ្រាម (ERW) រាប់បញ្ចូលទាំង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (UXO) និងយុទ្ធភ័ណ្ឌដែលគេបោះបង់ចោល ប៉ុន្តែមិនរាប់បញ្ចូលគ្រាប់មីនឡើយ។ សូមមើលនិយមន័យនៅក្នុងសន្ទានុក្រមឧបសម្ព័ន្ធទី 6)។ គ្រឿងផ្ទុះគ្រប់ប្រភេទ អាចរារាំងដល់ការចូលទៅកាន់ទីតាំងគម្រោង ឬបង្កជាការគំរាមកំហែងចំពោះសុវត្ថិភាព ទោះបីជាជម្លោះបានបញ្ចប់ទៅអស់កាលជាច្រើនឆ្នាំហើយក៏ដោយ។ នៅពេលធ្វើការនៅក្នុងតំបន់ទាំងនេះ អង្គភាព និងបុគ្គលត្រូវតែមានការយល់ដឹងអំពីការគំរាមកំហែងជារូបវន្តដែលបង្កឡើងដោយគ្រឿងបរិក្ខារយោធាជាច្រើនប្រភេទដែលបានបន្សល់ទុកនៅអំឡុងពេល និងក្រោយពេលមានជម្លោះប្រដាប់អាវុធ។

ដើម្បីការពារខ្លួនអ្នកបាន អ្នកត្រូវតែមានការយល់ដឹងអំពីការគំរាមកំហែង និងចាត់វិធានការការពារឲ្យបានសមស្រប។ ផ្នែកនេះ មានគោលបំណងជួយកំណត់ប្រភេទមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រឿងផ្ទុះកែច្នៃ ព្រមទាំងពន្យល់អំពីដំណើរការ និងប្រសិទ្ធភាពរបស់វា។ សៀវភៅជំនួយស្មារតីមិនអាចបរិយាយអស់សេចក្តីអំពីមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រឿងផ្ទុះកែច្នៃគ្រប់ប្រភេទទាំងអស់ ដូច្នេះត្រូវតែអនុវត្តទៅតាមសុភវិនិច្ឆ័យ។ តាមវិធានទូទៅជានិច្ចកាលត្រូវចេះសង្ស័យលើវត្ថុដែលខុសប្រក្រតី។ ការបរិយាយអំពីការគំរាមកំហែងភាគច្រើនមួយចំនួនមានដូចខាងក្រោម។

## តើអ្នកដឹងទេ?

ពាក្យ មីន "mine" បានមកពីពាក្យឡាតាំងថា ***mina*** ខ្សែរ៉ែ "vein of ore" ហើយត្រូវបានអនុវត្តពីដើមរៀងមកចំពោះការជីករករ៉ែ ចេញពីដី។ ក្រោយមកទៀត ពាក្យនេះត្រូវបានខ្ចីប្រើប្រាស់ដោយវិស្វករយោធាដែលការងាររបស់ពួកគេគឺបង្កប់គ្រាប់មីនក្នុងដី ពេលពួកគេហ៊ុមព័ទ្ធបន្ទាយ និងប៉មយោធា ដោយជារឿយៗពួកគេបង្កប់គ្រាប់មីននេះតាមជញ្ជាំង ដើម្បីផ្តួលរំលំបន្ទាយ និងប៉មយោធាទាំងនោះ។ គ្រាប់មីនសម័យទំនើប គឺជាអន្ទាក់/គ្រាប់បែកបង្កប់ ប៉ុន្តែវាក៏យកលំនាំតាមពពួកគ្រឿងមិនផ្ទុះដែលមានជំពូកដូចគ្នាកាលពីសម័យមុន ដូចជា ដែកគោលធំៗ និងស្នឹងដែលប្រើប្រាស់ដោយទាហានសម័យបុរាណ កាលពី 2,500 ឆ្នាំមុន។

Croll, M. ប្រវត្តិគ្រាប់មីន 1998

## 1.1 គ្រាប់មីន

គ្រាប់មីន គឺជាគ្រឿងផ្ទុះម៉្យាងដែលត្រូវបានរចនាឡើងដើម្បីបំផ្លាញ ឬធ្វើឲ្យខូចខាតរថយន្ត ឬដើម្បីធ្វើឲ្យរងរបួស សម្លាប់ ឬកម្រិតសកម្មភាពរបស់មនុស្ស។ មីនអាចត្រូវបានបំផ្ទុះដោយជនរងគ្រោះ បំពោលគឺដោយសកម្មភាពរបស់ជនជាមុខសញ្ញារបស់វា តាមរយៈការជាន់ពីលើ ឬវាយ ឬអាចកេះកៃឲ្យផ្ទុះដោយការសង្កត់ផ្ទាល់ ខ្សែអន្ទាក់/គ្រាប់បែកបង្កៃ ដងមួល ការបញ្ជាបំផ្ទុះ ឬដោយ ឬដោយការប្រើប្រាស់វិធីទាំងនេះបញ្ចូលគ្នា។
ឧទាហរណ៍ វាអាចរៀបធ្វើជាអន្ទាក់/គ្រាប់បែកបង្កៃដោយប្រើឧបករណ៍ប្រឆាំងការប៉ះពាល់ដោយដៃ ដើម្បីធ្វើឲ្យការយកវាចេញរឹតតែមានការពិបាក។ វាក៏អាចបំផ្ទុះដោយការកំណត់ម៉ោងផងដែរ។

មីនត្រូវបានគេប្រើប្រាស់ជាសព្វាវុធការពារខ្លួន៖ វាផ្តល់ការការពារសម្រាប់ទីតាំងយោធាសំខាន់ៗ ឬទប់ទល់ចលនារបស់កងទាហានតាមរយៈការបង្កឲ្យមានការរងរបួសចំពោះខ្មាំងសត្រូវ និងបំផ្លាញគ្រឿងបរិក្ខារ។ វាក៏ត្រូវបានគេប្រើជាលក្ខណៈវាយលុកផងដែរ៖ ជាពិសេស នៅអំឡុងពេលសង្គ្រាម វាត្រូវបានគេប្រើប្រាស់ដើម្បីបំផ្លាញ ឬធ្វើឲ្យខូចខាតហេដ្ឋារចនាសម្ព័ន្ធ និងបង្កឲ្យមានការភិតភ័យដោយរារាំងមិនឲ្យប្រជាពលរដ្ឋប្រើប្រាស់ផ្ទះ ដីកសិកម្ម ទឹក ផ្លូវថ្នល់ សាលារៀន ទីតាំងផ្តល់សេវាសុខភាព និងធនធានផ្សេងទៀត។ ជារឿយៗ គ្រាប់មីនត្រូវបានគេប្រើប្រាស់ជាផ្នែកមួយនៃគ្រឿងផ្ទុះកែច្នៃ។ វិសេវផ្ទុះរបស់គ្រាប់មីនអាចត្រូវបានគេប្រើសម្រាប់ធ្វើជាវិសេវ ឬធ្វើជាគ្រាប់មីនខ្លួនវាក្នុងនាមជាគន្លឹះបញ្ជាសម្រាប់គ្រឿងផ្ទុះកែច្នៃដែលប្រតិបត្តិការដោយជនរងគ្រោះ (VOIED)។

ជានិច្ចកាល គ្រាប់មីនភាគច្រើនត្រូវបានគេលាក់កំបាំង និងក្លែងបន្លំឲ្យស៊ីគ្នានឹងមជ្ឈដ្ឋានជុំវិញវាដែលធ្វើឲ្យវាកម្រមានគេមើលឃើញ និងពិបាកកំណត់រកទីតាំង។ តាមធម្មតា គេកប់ ឬលាក់កំបាំងវានៅក្នុងស្មៅ ឬអគារ ភ្ជាប់នៅលើបង្គោល ឬដើមឈើ។ ក្នុងកំឡុងពេលមានសង្គ្រាមសម័យនេះ គេតែងតែដាក់ពង្រាយគ្រាប់មីនតាមលំនាំមួយដែលនឹងបង្កើតបានជារនាំងស្របគ្នា ឬ



រូបភាពទី 1.1
ចម្ការមីន អន្ទាក់/គ្រាប់បែកបង្កៃ សំណល់ជាតិផ្ទុះពីសង្គ្រាម គេអាចឃើញមាននៅទូទាំងពិភពលោក ជួនកាលក្រោយមានជម្លោះអស់រយៈពេលជាយូរ។ រូបថតរបស់

UNMAS/Thomas Enke

នៅតាមបណ្ដោយផ្លូវថ្នល់ និងនៅជុំវិញចំណុចយុទ្ធសាស្ត្រ។ ក្នុងករណីចម្ការមីនថ្មីៗ ត្រូវមានការកត់ត្រាទីតាំងនៅលើផែនទី[2] ប៉ុន្តែការធ្វើបែបនេះពុំមែនសុទ្ធតែអាចជឿទុកចិត្តបានរហូតឡើយ។ ជារឿយៗគ្រាប់មីនត្រូវបានដាក់ពាសវាលពាសកាល ដោយភាគីប្រដាប់អាវុធ ដែលបន្តចល័តពីកន្លែងមួយទៅកន្លែងមួយទៀត។ គ្រាប់មីនមួយចំនួនទៀត ថែមទាំងត្រូវបានទម្លាក់រាយប៉ាយដោយយន្តហោះ ឬកាំភ្លើងធំនៅលើផ្ទៃដីធំល្វឹងល្វើយ ដោយពុំមានលំនាំដែលអាចឃើញច្បាស់ ឬអាចឲ្យគេដឹងបាន។

បច្ចុប្បន្ននេះ មានគ្រាប់មីន ក៏ដូចជាមីនកែច្នៃជាង 600 ប្រភេទខុសៗគ្នាផលិតដោយកងកម្លាំងយោធា (ជាគូបដិបក្ខ)ដែលកំពុងប្រយុទ្ធគ្នា។ គេចែកវាជាក្រុមធំៗចំនួនពីរ៖ មីនប្រឆាំងមនុស្ស (AP) និងមីនប្រឆាំងរថយន្ត (AV) ហើយគេតែងតែហៅវាជាទូទៅថា មីនប្រឆាំងរថក្រោះ។

## 1.1.1 គ្រាប់មីនប្រឆាំងមនុស្ស

គ្រាប់មីនប្រឆាំងមនុស្ស (AP) ត្រូវបានផលិតឡើងដើម្បីបំផ្ទុះនៅពេលមានវត្តមានរបស់មនុស្ស ទោះសៀវភៅជំនួយស្មារតី ហើយវាមានគោលបំណងធ្វើឲ្យមនុស្សម្នាក់ ឬច្រើននាក់មិនអាចធ្វើអ្វីបាន រងរបួស ឬស្លាប់។ តាមធម្មតា មីនប្រឆាំងមនុស្សផ្ទុះនៅពេលណាមានគេដើរជាន់លើវា ឬនៅពេលចុចខ្សែអន្ទាក់/គ្រាប់បែកបង្កៃ ប៉ុន្តែគេក៏អាចបំផ្ទុះវាដោយការកំណត់ម៉ោង ឬដោយមធ្យោបាយគ្រប់គ្រងផ្សេងទៀត។

មីនប្រឆាំងមនុស្សអាចឃើញមាននៅលើដីផ្ទាល់ កប់ចូលក្នុងដី ឬដាក់នៅលើដី ហើយជាទូទៅវាគឺជាឧបករណ៍តូចៗដែលមានរូបរាងខុសៗគ្នា។ ជារឿយៗ គេក្លែងបន្លំវាដើម្បីឲ្យស៊ីគ្នាជាមួយនឹងមជ្ឈដ្ឋានជុំវិញវា ហើយអាចធ្វើពីឈើ ផ្លាស្ទិក ឬលោហៈ។

### បំផ្ទុះដោយការបញ្ជា

ដំណើរការមួយដែលជនទីពីរបំផ្ទុះមីនដោយប្រើតេឡេបញ្ជា។ គេហៅជននេះថាអ្នកបំផ្ទុះ។

### បំផ្ទុះដោយជនរងគ្រោះ

បំផ្ទុះឡើងដោយមានមនុស្សម្នាក់ដែលបានដើរជាន់ពីលើ បើកបរពីលើ ទាត់ ឬដោយសកម្មភាពមួយចំនួនស្រដៀងៗគ្នានេះ។

### ឧបករណ៍ប្រឆាំងការប៉ះពាល់ដោយដៃ

ឧបករណ៍ដែលបំពាក់នៅលើមីនប្រឆាំងរថយន្ត ឬប្រឆាំងមនុស្ស ដែលបណ្ដាលឲ្យមីនផ្ទុះនៅពេលមានគេប៉ះពាល់ ឬមានគេរំខានវា។ ឧបករណ៍ប្រឆាំងការប៉ះពាល់ដោយដៃ មានគោលបំណងទប់ស្កាត់ការបោសសម្អាតមីន។ ឧបករណ៍ប្រឆាំងការប៉ះពាល់ដោយដៃ ក៏អាចត្រូវបានបំពាក់នៅលើសំណល់ជាតិផ្ទុះពីសង្គ្រាម ឬគ្រឿងផ្ទុះកែច្នៃផងដែរ។

[2] វិសោធនកម្មពិធីសារស្ដីពីការហាមឃាត់ និងរឹតបន្តឹងលើការប្រើប្រាស់មីន អន្ទាក់/គ្រាប់បែកបង្កៃ និងឧបករណ៍ផ្សេងៗ នៅទីក្រុងហ្សឺណែវ ថ្ងៃទី 03 ខែវិច្ឆិកា ឆ្នាំ 1996

គួរតែជៀសវាងតំបន់ទាំងឡាយណាដែលសង្ស័យថាមានមីនប្រឆាំងមនុស្ស។

នៅពេលមានការផ្ទុះឡើង មីនប្រឆាំងមនុស្សបង្កឲ្យមានមនុស្សស្លាប់ ឬរងរបួសធ្ងន់ធ្ងរតាមរយៈការផ្ទុះឡើង និង/ឬជះអំបែង។ គេគេបែងចែកគ្រាប់មីនប្រភេទនេះជាក្រុម ទៅតាមរបៀបដែលវាបង្ករបួសស្នាម ដូចជា មីនប្រភេទផ្ទុះ ជះអំបែង ឬរំសេវមានរាងតូច[3]។

### 1.1.1.1 គ្រាប់មីនប្រឆាំងមនុស្សប្រភេទមីនខ្យល់ (មីនប្រើសន្ទុះខ្យល់)

ជារឿយៗ មីនប្រឆាំងមនុស្សប្រភេទមីនខ្យល់ (មីនប្រើសន្ទុះខ្យល់) មានតម្លៃ ហើយជាប្រភេទមីនដែលគេតែងឃើញមានច្រើនជាងគេនៅក្នុងពិភពលោក។ គេរចនាវាឡើងដើម្បីបំផ្ទុះដោយសម្ពាធដែលបង្កឡើងដោយការប៉ះពាល់ផ្ទាល់ជាមួយមីនដែលភាគច្រើនដោយការដើរជាន់លើវា។ ភាគច្រើននៃមីនប្រភេទនេះត្រូវបានរចនាឡើងដើម្បីបង្កឲ្យមានរបួសស្នាមធ្ងន់ធ្ងរដែលតាមធម្មតាត្រូវកាត់អវៈយវៈម្ខាង ឬទាំងសងខាងចេញ ជាជាងធ្វើឲ្យស្លាប់។

[3] ឧ. មីនប្រឆាំងមនុស្សរបស់កាណាដាធុន C3A2

## ករណីសិក្សា

គ្រាប់មីន និងគ្រឿងផ្ទុះបង្កគ្រោះថ្នាក់ដទៃទៀតបន្តធ្វើឲ្យពិការ និងសម្លាប់ជនស្លូតត្រង់នៅទូទាំងពិភពលោក។ ដើម្បីដឹងបន្ថែមពីបញ្ហានេះ អ្នកគ្រាន់តែស្វែងរកនៅលើ អ៊ីនធើណិត "Landmine Accidents 2015"។ Croll, M. ប្រវត្តិគ្រាប់មីន។ 1998

រូបភាពទី 1.2
មីនប្រឆាំងមនុស្សធុនតូចនេះ អាចធ្វើឲ្យប្រអប់ជើងដាច់រយៈចេញពីគ្នាបាន! វាមានទំហំវិជ្ឈមាត្រប្រហែល 10 សម ហើយនៅពេលកប់វាក្នុងដី ស្ទើរតែមើលវាមិនឃើញ (ឆ្វេង)។ មីនដូចគ្នានេះ ត្រូវបានដោះគម្របចេញដោយអ្នកបោសសម្អាតមីន (ស្តាំ)។
រូបថតរបស់ UNMAS/Thomas Enke





# 1.1 គ្រាប់មីន

## 1.1.1 គ្រាប់មីនប្រឆាំងមនុស្ស

ជាទូទៅ មីនប្រឆាំងមនុស្សប្រភេទមីនខ្យល់ (មីនប្រើសន្ទុះខ្យល់)មានរាងជាស៊ីឡាំង ហើយមានលំដាប់ទំហំវិជ្ជមាត្រចាប់ពី 7 ដល់ 16 សម និងកម្ពស់ចាប់ពី 5 ដល់ 10 សម។ ទោះជាយ៉ាងណា មីនប្រឆាំងមនុស្សប្រភេទមីនខ្យល់ (មីនប្រើសន្ទុះខ្យល់) មានរាងជាចតុកោណ ឬ"ប្រអប់ស្បែកជើង"។ បន្ទាប់មកទៀត វាមានលំដាប់ទំហំចាប់ពី 10 សម x 18 សម ដល់ 15 សម x 30 សម។ មីនប្រឆាំងមនុស្សភាគច្រើនមានរំសេវផ្ទុះតូចៗជាច្រើនដែលជារឿយៗមានទម្ងន់មិនលើសពី 100 ក្រាម។ ការផ្ទុះរំសេវដ៏ខ្លាំងក្លា គឺជាអ្វីដែលបង្កឲ្យមានអ្នកស្លាប់ ឬរងរបួស។

ខណៈដែលមីនប្រឆាំងមនុស្សប្រភេទមីនខ្យល់ (មីនប្រើសន្ទុះខ្យល់)មួយចំនួនផលិតពីលោហៈ ឬឈើ ក៏មានមីនភាគច្រើនទៀតដែលផលិតពីផ្លាស្ទិកផងដែរ។ លក្ខណៈបែបនេះធ្វើឲ្យវាធន់នឹងទឹក ឬមិនជ្រាបទឹក ហើយថែមទាំងមានគ្រោះថ្នាក់សូម្បីតែនៅពេលដែលគេដាក់វានៅក្នុងទឹក។ ក្រោយពីមានភ្លៀងធ្លាក់ខ្លាំងៗ វាពុំមែនជារឿងមិនធម្មតាឡើយសម្រាប់មីនមួយចំនួនដែលត្រូវហូរបកចេញពីចម្ការមីនទៅកាន់តំបន់ដែលពុំធ្លាប់មានមីនពីមុនមក ឬទៅកាន់ផ្លូវទឹកដែលវាអាចស្ថិតនៅរាយប៉ាយជាច្រើនគីឡូម៉ែត្រនៅតាមខ្សែទឹកខាងក្រោម មុនពេលហូរបកឡើងទៅលើគោក។ តាមធម្មតា មីនប្រឆាំងមនុស្សប្រភេទមីនខ្យល់ (មីនប្រើសន្ទុះខ្យល់) មានពណ៌ដាំដែង បៃតងភ្លាវ បៃតង ខ្មៅ ត្នោត ប្រផេះ ឬមានពណ៌លាយឡំគ្នា។

បន្ថែមពីលើមីនប្រឆាំងមនុស្សប្រភេទមីនខ្យល់ (មីនប្រើសន្ទុះខ្យល់)ដែលកប់ក្នុងដី ប្រភេទមីនពេញនិយមគឺ មីន "មេអំបៅ" (ឬក្លាយពីអ្វីមួយផ្សេងទៀតស្រដៀងគ្នានេះ)ដែលមានការទម្លាក់រាយប៉ាយនៅលើដីដោយយន្តហោះ ឬការបាញ់គ្រាប់កាំភ្លើងធំ (លើសពីនេះ សូមមើលជំពូកស្តីពីគ្រាប់បែកចង្កោម)។ បើមានការចែកចាយក្នុងពេលថ្មីៗនេះ តាមធម្មតាគេឃើញមានមីនទាំងនេះនៅរាយប៉ាយក្នុងចំនួនដ៏ច្រើន។ ទោះបីជាក្រោយរយៈពេលច្រើនខែ ឬច្រើនឆ្នាំក៏ដោយ ក៏គេនៅតែឃើញមានមីនដែលនៅដាច់តែឯងតាមតំបន់ដែលបានបោសសម្អាតរួចហើយ។ មីនមេអំបៅ មានរូបរាងប្លែកៗឡាយឡំគ្នាជាច្រើន ហើយជារឿយៗ







រូបភាពទី 1.3
មីនប្រឆាំងមនុស្សមានរាងជាប្រអប់។ មីនស្រដៀងគ្នានេះ អាចឃើញមាននៅទូទាំងពិភពលោក។ រូបថតរបស់ UNMAS/Thomas Enke

រូបភាពទី 1.4
"មីនមេអំបៅ"ជុន PFM-1ដែលទម្លាក់ពីលើអាកាសទាំងនេះ អាចផ្ទុះឡើងនៅពេលមានគេប៉ះពាល់វា នៅអាហ្វហ្គានីស្ថាន។ រូបថតរបស់ UNMAS/Thomas Enke

រូបភាពទី 1.5
ការបង្កើតសង្គ្រាមដោយប្រើមីនប្រឆាំងមនុស្សប្រភេទក្លេម៉រ (Claymore) ឃើញមាននៅតំបន់បាល់កង់។ រូបថតរបស់ UNMAS/Thomas Enke

មានពណ៌ភ្លឺៗដែលធ្វើឲ្យមានលក្ខណៈខុសប្លែក និងគួរឲ្យទាក់ទាញចំពោះកុមារ និងមនុស្សពេញវ័យដែលចង់ឃើញ ចង់ដឹង។

## 1.1.1.2 មីនប្រឆាំងមនុស្សប្រភេទជះអំបែង

ជាទូទៅ មីនប្រឆាំងមនុស្សប្រភេទជះអំបែង ត្រូវបានរចនាឡើងដើម្បីបង្កឲ្យមានចំនួនអ្នកស្លាប់ជាច្រើនដោយសារអំបែងដែលរុញចេញពីរំសេវផ្ទុះរបស់មីន។ ភាគច្រើននៃមីនទាំងនេះ មានសំបកធ្វើពីលោហៈ ឬមានកងឃ្លី ឬអំបែងលោហៈដែលប្រែក្លាយទៅជាក្បាលគ្រាប់បណ្តាលឲ្យស្លាប់ដោយសារការផ្ទុះមីន។

មីនប្រឆាំងមនុស្សប្រភេទជះអំបែង មានបីប្រភេទជាមូលដ្ឋាន៖ មីនស្នឹង មីនជះអំបែងតាមទិសដៅ និងមីនកង្កែប (មីនលោតហើយជះអំបែង)។

### > 1.1.1.2.1 មីនប្រឆាំងមនុស្សប្រភេទស្នឹង

មីនប្រឆាំងមនុស្សប្រភេទជះអំបែងដែលគេតែងតែឃើញមានច្រើនជាងគេគឺមីនស្នឹង ដែលត្រូវបានគេរចនាឡើងដើម្បីបំពាក់នៅលើស្នឹងឈើ ឬស្នឹងលោហៈដែលដំចូលទៅក្នុងដី រហូតដល់មីនមានកម្ពស់ស្ថិតនៅពីលើផ្ទៃដីប្រហែល 20 សម។ គេក៏បំពាក់វានៅតាមដើមឈើផងដែរ។ ភាគច្រើនមើលទៅដូចជាដំបងតូចមួយ៖ ស្នឹងឈើដែលនៅខាងលើវាមានស៊ីឡាំងលោហៈតូចមួយ និងមានកិបលៀនចេញមកខាងលើ។ គេតែងតែលាបពណ៌បៃតង ឬវាអាចជាឈើ ឬលោហៈដែលមិនលាបពណ៌។ ផ្ទៃលោហៈច្រេះ ធ្វើឲ្យវាយស្រួលនឹងមើលរំលងមីន ជាពិសេសនៅតំបន់ដែលមានគម្របរុក្ខជាតិចាស់ៗ។

មីនស្នឹង ត្រូវបានបំពាក់ជាមួយនឹងខ្សែអន្ទាក់/គ្រាប់បែកបង្កៃមួយ ឬច្រើនដែលធ្វើឲ្យមីនផ្ទុះនៅពេលទាញ ឬកាត់ខ្សែ។ ខ្សែអន្ទាក់/គ្រាប់បែកបង្កៃពិបាកនឹង

### ខ្សែអន្ទាក់/គ្រាប់បែកបង្កៃ

ខ្សែលោហៈស្តើង មិនឆ្លុះត្រឡប់ ឬខ្សែដែលអាចប្រើជាយន្តការសម្រាប់កេះកៃបំផ្ទុះមីន អន្ទាក់/គ្រាប់បែកបង្កៃ ឬគ្រឿងផ្ទុះកែច្នៃដែលប្រតិបត្តិការដោយជនរងគ្រោះ។ ខ្សែអន្ទាក់/គ្រាប់បែកបង្កៃ តាមធម្មតាលាតសន្ធឹងនៅកម្ពស់ទាប លើដីបន្តិច ដើម្បីឲ្យអ្នកដែលឆ្លងកាត់ "ដើរទាក់" ខ្សែនោះដែលធ្វើឲ្យផ្ទុះមីន។ នៅពេលប្រើខ្សែអន្ទាក់/គ្រាប់បែកបង្កៃ វាអាចរត់បានចម្ងាយដល់ 30 ម៉ែត្រពីមីន។



រូបភាពទី 1.6
ល្អបំផុតសម្រាប់ការប្រើប្រាស់មីនស្នឹងជាមួយខ្សែអន្ទាក់/គ្រាប់បែកបង្កៃ៖ សំបកសព្វាវុធដែលគេបោះបង់ចោលនៅខាងចុងផ្លូវលំ ជាមួយនឹងស្លឹកឈើដុះទ្រុបទ្រុល។ រូបថតរបស់ UNMAS/ Th0mas Enke

មើលឃើញណាស់ ហើយខ្សែនេះអាចមានចងកាត់ទទឹងផ្លូវ ឬផ្លូវចេញពីទ្វារ ហើយចងភ្ជាប់ទៅនឹងវត្ថុរឹងមួយ ដូចជា ដើមឈើ ឬមីនមួយផ្សេងទៀត។

នៅពេលគេចុចឲ្យផ្ទុះ អំបែងលោហៈជះក្នុងរង្វង់ 360 ដឺក្រេដែលបណ្ដាលឲ្យមានការរងរបួសរហូតដល់ស្លាប់ចំពោះជនណាម្នាក់ដែលស្ថិតនៅក្នុងរង្វង់ 4 ម៉ែត្រដែលគ្មានអ្វីបាំង ហើយបណ្ដាលឲ្យស្លាប់ ឬរងរបួសធ្ងន់ធ្ងរចំពោះមនុស្សដែលស្ថិតនៅចម្ងាយឆ្ងាយជាងនេះ។ មីនរុស្ស៊ីមួយប្រភេទដែលគេតែងតែឃើញ ឈ្មោះ POMZ-2M ផ្ទុះឡើង និងបែកខ្ទេកបង្កើតបានជាអំបែងជះដែលអាចបណ្ដាលឲ្យស្លាប់ក្នុងរង្វង់ 10 ម៉ែត្រ។ លើសពីនេះទៅទៀត ទំហំ និងការចែកចាយមិនស្មើគ្នានៃអំបែង ធ្វើឲ្យអនុភាពរបស់វាមិនអាចទាយស្មានបានឡើយ។ អំបែងធំៗអាចធ្វើឲ្យរងរបួស ឬស្លាប់ក្នុងលំដាប់ចម្ងាយ 100 ម៉ែត្រ ឬឆ្ងាយជាងនេះ។[4]

បន្ទាប់ពីមួយរយៈ មីនស្នឹងអាចនឹងដួលរលំ ឬស្នឹងដែលវាស្ថិតនៅអាចនឹងប្រេះបែកជាបំណែក។ ករណីនេះមិនធ្វើឲ្យវាថមថយគ្រោះថ្នាក់ឡើយ ហើយនៅក្នុងករណីមួយចំនួន ធ្វើឲ្យវារឹតតែគ្រោះថ្នាក់ខ្លាំងជាងមុនទៅវិញ។

### > 1.1.1.2.2 មីនប្រឆាំងមនុស្សប្រភេទជះអំបែងគ្រប់ទិស

មីនប្រឆាំងមនុស្សប្រភេទជះអំបែងគ្រប់ទិស (ឬប្រភេទ "ក្លេម័រ (Claymore)") ត្រូវបានរចនាឡើងដើម្បីឲ្យវាជះអំបែងតាមលំនាំក្រាស់ឃ្មឹកមួយក្នុងទិសដៅជាក់លាក់។ ភាគច្រើនមើលទៅដូចជាប្រអប់រាងចតុកោណរាងកោង ឬរាងមូលដែលមានកម្រាស់ប្រហែលសៀវភៅដែលមានគម្របស្តើង។ ប្រអប់នេះស្ថិតនៅលើជើង ឬទម្រពីរ ហើយជាទូទៅមានពណ៌បៃតងភ្លាវ ខ្មៅ ឬត្នោត។

តាមធម្មតា មីនប្រឆាំងមនុស្សប្រភេទជះអំបែងតាមទិសដៅ ត្រូវគេបញ្ជាបំផ្ទុះ

[4] ប្រភពសម្រាប់រយៈចម្ងាយ៖ Colin King អ្នកនិពន្ធសៀវភៅមីន និងការបោសសម្អាតមីនរបស់ Jane និងកាកសំណល់ជាតិផ្ទុះរបស់ Jane។







រូបភាពទី 1.7
មីនប្រឆាំងមនុស្សប្រភេទស្នឹង។ អ្នកអាចមើលឃើញខ្សែអន្ទាក់/គ្រាប់បែកបង្កៃ។
រូបថតរបស់ UNMAS

រូបភាពទី 1.8
កណ្ដាល៖ មីន "ក្លេម័រ (Claymore)" ប្រភេទ MON-50 ជះអំបែងតាមទិសដៅតែមួយ ជារឿយៗនៅតាមផ្លូវថ្នល់ ឬផ្លូវលំ។ មីនជាច្រើនអាចភ្ជាប់គ្នាទៅវិញទៅមក។ គេអាចដាក់វានៅតាមដើមឈើ! ក្រោម៖ សេនស័រសម្ពាធ Piezo របស់មីនក្លេម័រ (Claymore)។
រូបថតរបស់ UNMAS

ប៉ុន្តែវាក៏អាចបំផ្ទុះដោយប្រើខ្សែអន្ទាក់/គ្រាប់បែកបង្កៃ ឬចានសម្ពាធផងដែរ។ នៅពេលផ្ទុះ ភាគច្រើននៃមីនប្រភេទនេះជះអំបែងរបស់វាជារាងផ្កាភ្លើងផ្តេកជាចំណិតរង្វង់ក្នុងកម្រិតមុំ 60 ដឺក្រេ និងឡើងដល់កម្ពស់ប្រហែល 2 ម៉ែត្រ។ មីនភាគច្រើនត្រូវបានរចនាឡើងដើម្បីឲ្យមាន “ចម្ងាយមានប្រសិទ្ធភាព” មួយដែលបង្កឲ្យមានរបួសស្នាម ឬស្លាប់មនុស្សក្នុងរង្វង់លើសពី 50 ម៉ែត្រ។

មីនបែបនេះ តែផលិតក្នុងទម្រង់ផ្សេងទៀត មានទំហំធំៗ និងមានរាងជារង្វង់ ហើយជះកម្ទេចគ្រាប់ចេញជារាងកោណស្តួច ដូចជាកាំភ្លើងខ្លីដែរ។ វាមានសមត្ថភាពអាចសម្លាប់មនុស្ស ក៏ដូចជាបំផ្លាញ ឬធ្វើឲ្យរថយន្តដឹកអ្នកដំណើរគ្មានពាសដែកប្រើការលែងកើត។



រូបភាពទី 1.9
មីនជះអំបែង ដំបូង “លោត” ដល់កម្ពស់ប្រហែល 1 ម៉ែត្រ នៅពេលគេបំផ្ទុះ ហើយបន្ទាប់មកផ្ទុះដែលអាចបណ្តាលឲ្យមានមនុស្សស្លាប់យ៉ាងខ្លាំង។ រូបថតរបស់ UNMAS/Thomas Enke

### > 1.1.1.2.3 មីនប្រឆាំងមនុស្សប្រភេទលោតហើយជះអំបែង

មីនលោតហើយជះអំបែង (មីនកង្កែប) តាមធម្មតាត្រូវបានគេកប់ក្នុងដី ហើយជារឿយៗត្រូវបានតភ្ជាប់ទៅនឹងខ្សែអន្ទាក់/គ្រាប់បែកបង្កៃ។ មីនកង្កែប (មីនលោតហើយជះអំបែង)ភាគច្រើនមានរាងជាស៊ីឡាំងដែលមានគីប/ផ្ទួនបំពង់តែមួយ ឬមានខ្នែងមួយចំនួនលៀនចេញមកខាងក្រៅពីផ្នែកខាងលើ។ ជាទូទៅ វាមានវិជ្ជមាត្រប្រហែល 10 សម និងកម្ពស់ 28 សម។ មីនកង្កែប (មីនលោតហើយជះអំបែង) តាមធម្មតាមានពណ៌ដាំដែង បៃតងភ្លាវ ខ្មៅ ត្នោត ឬគ្មានលាបពណ៌អ្វីឡើយ។ ក្រោយរយៈពេលជាច្រើនឆ្នាំ ផ្ទៃខាងក្រៅនៃលោហៈមើលដូចជាច្រេះ ដើម្បីឲ្យមីនទាំងនោះពិបាកនឹងមើលឃើញ។

**សម្គាល់៖ ហាមប៉ះពាល់ ចូលទៅជិត ឬជាន់លើ ខ្សែអន្ទាក់/គ្រាប់បែកបង្កៃ**

មីនកង្កែប (មីនប្រឆាំងមនុស្សប្រភេទលោតហើយជះអំបែង) ជាទូទៅត្រូវបានបំផ្ទុះដោយខ្សែអន្ទាក់/គ្រាប់បែកបង្កៃ ឬសង្កត់ដោយផ្ទាល់។ នៅពេលចុចឲ្យផ្ទុះ បន្ទុះដំបូងលើកមីនចេញពីក្នុងដីឲ្យឡើងដល់កម្ពស់ត្រឹមចង្កេះ មុនពេលដែលវិសេវធំផ្ទុះឡើង។ នៅពេលផ្ទុះ បន្ទុះបាញ់ចេញមកក្រៅនូវអំបែងលោហៈក្នុងរង្វង់ផ្តេក 360 ដឺក្រេ។ ភាពខុសៗគ្នានៃការរចនារូបរាងមានន័យថា ចំនួន

ទំហំ និងការចែកចាយអំបែងខុសគ្នាយ៉ាងច្រើន ប៉ុន្តែមីនលោតហើយជះអំបែងទូទៅ អាចបណ្តាលឲ្យមានអ្នកស្លាប់ក្នុងរង្វង់ 25 ម៉ែត្រ ហើយមានសមត្ថភាពអាចបង្កឲ្យមានរបួសធ្ងន់ធ្ងរក្នុងលំដាប់ចម្ងាយរហូតដល់ 100 ម៉ែត្រ។



រូបភាព 1.10
មីនប្រឆាំងមនុស្សរបស់កាណាដាប្រភេទ C3A2 ជាមួយនឹងអនុភាពរំសេវមានរាង។
រូបថតរបស់ UNMAS/Thomas Enke

#### > 1.1.1.2.4 មីនប្រឆាំងមនុស្សដែលមានរំសេវមានរាងដួន

មីនប្រឆាំងមនុស្សដែលមានរំសេវមានរាងដួន ជាទូទៅគេកប់វាក្នុងដី។ វាមានរាងជាស៊ីឡាំងជាមួយនឹងចុងរាងជាកោណ ដើម្បីឲ្យងាយស្រួលបុកចូលទៅក្នុងដី និងចានរាងមូលដើម្បីឲ្យវាស្ថិតនៅក្នុងដីបានណែនល្អ។ ជាមួយនឹងវិជ្ជមាត្រប្រហែល 5 សម និងកម្ពស់ប្រហែល 12 សម គេលាបពណ៌វាខុសៗគ្នា ភាគច្រើនគឺពណ៌ទឹកក្រូចលឿង បៃតង ឬខ្មៅ។

ការដើរជាន់លើមីនប្រឆាំងមនុស្ស នឹងធ្វើឲ្យគីប/ឆ្នួនផ្ទុះ (ធ្វើឲ្យផ្ទុះដោយជនរងគ្រោះ)។ ជាទូទៅ មីនប្រឆាំងមនុស្សប្រភេទនេះ ពុំត្រូវបានរចនាឡើងដើម្បីសម្លាប់ជនរងគ្រោះឡើយ។ បរិមាណតិចតួចនៃរំសេវផ្ទុះ បាញ់រំសេវដែលមានរាងកាត់តាមបាតជើង និងកែងជើង ឡើងទៅដល់ក្បាលជង្គង់ដែលបង្កការខូចខាតដល់ជើងផ្នែកខាងក្រោម។ ជាលទ្ធផល អាចបណ្តាលឲ្យជនរងគ្រោះត្រូវកាត់ជើងដល់លើក្បាលជង្គង់ និងត្រូវព្យាបាលរយៈពេលយូរ។

## 1.1.2 គ្រាប់មីនប្រឆាំងរថយន្ត

មីនប្រឆាំងរថយន្ត (AV) ជាញឹកញាប់សំដៅទៅលើមីនប្រឆាំងរថក្រោះ ត្រូវបានរចនាឡើងដើម្បីបំផ្លាញ ឬធ្វើឲ្យរថយន្តប្រើការលែងកើត។ ដូចគ្នានឹងមីនប្រឆាំងមនុស្សដែរ មីនប្រឆាំងរថយន្តអាចត្រូវបានបំផ្ទុះដោយកម្លាំងសម្ពាធ ប៉ុន្តែវាត្រូវការទម្ងន់ច្រើនជាងធម្មតា ដោយបញ្ជាពីចម្ងាយ ដោយឥទ្ធិពលម៉ាញេទិច ឬតាមរយៈការរំខានពីដងមួល (ខ្សែអន្ទាក់/គ្រាប់បែកបង្កៃបញ្ឆេះមួយប្រភេទ – សូមមើលប្រអប់និយមន័យ)។ ខ្សែកាបធ្វើពីជាតិសរសៃកែវដែលគេដាក់នៅតាមដងផ្លូវ ក៏អាចយកមកប្រើក្នុងការបំផ្ទុះមីនប្រឆាំងរថយន្តលើផ្លូវ

កំណត់សម្គាល់
ហាមចូលទៅជិត ប៉ះពាល់ ឬកកេះរុករើលេង ជាមួយយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ! យុទ្ធភ័ណ្ឌអាចទម្លុះដីដោយមិនចាំបាច់ផ្ទុះ ហើយនៅតែអាចមានគ្រោះថ្នាក់។

លំបាកតាមទិសដៅ ដោយបាញ់គ្រាប់រ៉ុក្កែតប្រឆាំងរថក្រោះដែលរក្សាលំនឹងដោយស្លាបតូចមួយ។ គេអាចដាក់វានៅចន្លោះពី 2 ទៅ 40 ម៉ែត្រ នៅលើផ្លូវខាងណាក៏បាន ដោយដាក់នៅលើចន្ទល់តូចមានជើងបី ឬភ្ជាប់ទៅនឹងដើមឈើ។ ដោយសារមីនប្រឆាំងរថយន្តត្រូវបានបង្កើតឡើងដើម្បីបំផ្លាញរថយន្ត ជាទូទៅគេតែងតែឃើញវានៅលើដងផ្លូវ គែមផ្លូវ ផ្លូវលំ ដានផ្លូវ និងនៅតាមជាយៗផ្លូវ។ ទោះបីជាផ្លូវនោះធ្លាប់មានគេបើកបរមួយរយៈកាលកន្លងមកហើយក៏ដោយ ក៏វានៅតែអាចមានមីនប្រឆាំងរថយន្តដែរ។

មីនប្រឆាំងរថយន្ត មានទំហំធំជាងមីនប្រឆាំងមនុស្សឆ្ងាយ ហើយមានរំសេវផ្ទុះច្រើនជាងឆ្ងាយ។ ជាទូទៅ វាមានរាងមូល ឬបួនជ្រុង ហើយមានលំដាប់ទំហំវិជ្ឈមាត្រចាប់ពី  40 សម និងកម្ពស់ 16 សម រហូតដល់វិជ្ឈមាត្រ 23 សម និងកម្ពស់ 10 សម។ វាអាចផលិតពីឈើ ផ្លាស្ទិក ឬលោហៈ ហើយមាន

### ដងមូល

បង្គោលស្តើងដែលភ្ជាប់ទៅនឹងយន្តការគីប/ផ្ទួននៅផ្ទៃខាងលើរបស់មីន។ សម្ពាធដែលប្រើ ទៅលើដងមូលធ្វើឲ្យ មីនផ្ទុះ។

**រូបភាពទី 1.11**
មីនប្រឆាំងរថយន្តរបស់អាល់បានីប្រភេទ MKT Mod.72 រកឃើញនៅក្នុងសំបក កូសូវ៉ូ ឆ្នាំ 2009។
រូបថតរបស់ UNMAS/Thomas Enke



## 1.1.2 គ្រាប់មីនប្រឆាំងរថយន្ត

ពណ៌ច្រើនសម្បូរបែប។ រំសេវមីនប្រឆាំងរថយន្ត មានទម្ងន់រំសេវផ្ទុះខ្លាំងប្រមាណ 6 គក្រ ប៉ុន្តែវាក៏អាចមានរំសេវដែលគេដាក់ជាងរាងជាក់លាក់មួយផងដែរ។

បន្ថែមពីលើនេះទៀត ជារឿយៗមីនប្រឆាំងរថយន្តតែងតែត្រូវបានគេប្រើត្រូវបានគេប្រើប្រាស់ជារំសេវសំខាន់របស់គ្រឿងផ្ទុះកែច្នៃ។ គីប/ផ្ទួនអាចត្រូវបានគេលាក់មិនឲ្យឃើញ ឬបំពាក់នៅខាងក្នុងមីន។ នេះមានន័យថា ការលើកមីនដែលសង្ឃឹមថាគ្មានគីប/ផ្ទួនអាចបង្កឲ្យមានគ្រោះថ្នាក់។

តាមធម្មតា វាត្រូវការសម្ពាធសង្កត់យ៉ាងច្រើនគួរសមដើម្បីបំផ្ទុះមីនប្រឆាំងរថយន្តដែលមានលក្ខណៈស្តង់ដា ពោលគឺ ប្រហែលពី 120 គក្រ ទៅ 150 គក្រ។ ប៉ុន្តែវាមិនមែនមានន័យថា មនុស្សមានទម្ងន់ស្រាលជាងនេះ អាចដើរជាន់ដោយសុវត្ថិភាពលើមីនប្រឆាំងរថយន្តណាមួយបានឡើយ។ ប្រព័ន្ធគីប/ផ្ទួនអាចមានសភាពទ្រុឌទ្រោម ឬមានការលៃតម្រូវដោយចេតនាដែលបណ្តាលឲ្យមានការថយចុះនូវសម្ពាធសង្កត់ដែលត្រូវការដើម្បីបំផ្ទុះមីនប្រឆាំងរថយន្ត។ ជួនកាលមីនប្រឆាំងរថយន្ត គឺជាអន្ទាក់/គ្រាប់បែកបង្កប់ដែលនឹងបំផ្ទុះនៅពេលមានអ្វីមួយមករំខានវា។ នៅក្នុងករណីមួយចំនួន គេដាក់មីនប្រឆាំងមនុស្សនៅខាងលើមីនប្រឆាំងរថយន្ត ហើយនៅពេលវាចាប់ផ្តើមផ្ទុះ ជាទូទៅវាក៏បណ្តាលឲ្យមីនប្រឆាំងរថយន្តផ្ទុះផងដែរ។ ត្រូវប្រយ័ត្នផងដែរថា ជារឿយៗមីនប្រឆាំងមនុស្សត្រូវបានគេប្រើសម្រាប់ការពារកុំឲ្យមានគេដោះយកមីនប្រឆាំងរថយន្តចេញ ហើយគេនិយមប្រើបច្ចេកទេសដាក់មីនប្រឆាំងមនុស្ស និងមីនប្រឆាំងរថយន្តជាចង្កោមជាមួយគ្នា។

ជារឿយៗ ដោយសារមីនប្រឆាំងរថយន្តត្រូវបានរចនាឡើងដើម្បីធ្វើឲ្យរថយន្តយោធាធំៗប្រើការលែងកើត ដូចជារថក្រោះជាដើម ផលប៉ះពាល់របស់វាទៅលើរថយន្តធុនតូចរបស់ប្រជាពលរដ្ឋ តាមធម្មតាគឺជាមហន្តរាយមួយ ហើយបណ្តាលឲ្យមានខូចខាតរថយន្ត និងបង្កឲ្យអ្នកជិះក្នុងនោះស្លាប់ ឬរងរបួស។



រូបភាពទី 1.12
សំបកគ្រាប់ Krupp ប្រភេទ 77 មម x 229 នៅទីក្រុងអិសសិន (Essen)/អាល្លឺម៉ង់ ឆ្នាំ 1906 កសាងសម្រាប់កងកម្លាំងទួគី កូសូវ៉ូ។ រូបថតរបស់ UNMAS/Thomas Enke



រូបភាពទី 1.13
យុទ្ធភណ្ឌមិនទាន់ផ្ទុះ គ្រាប់រ៉ុក្កែតទម្លាក់ពីលើអាកាសមកលើដី ប្រភេទ S-24 អាហ្វហ្គានីស្ថាន។ រូបថតរបស់ UNMAS/Thomas Enke



រូបភាពទី 1.14
គ្រាន់តែជាមួកការពារចាស់មួយមែនទេ? កុំលើកវាឡើង! រូបថតរបស់ UNMAS/Thomas Enke

## 1.2 យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ គឺជាគ្រាប់បែកផ្ទុះទាំងឡាយណាដែលធ្លាប់ត្រូវបានបាញ់ឲ្យផ្ទុះ គប់ ទម្លាក់ ឬបាញ់បង្ហោះឡើងលើ ប៉ុន្តែមិនផ្ទុះតាមបំណង។ យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះមានជាអាទិ៍ គ្រាប់កាំភ្លើងធំ គ្រាប់បាញ់រថក្រោះ គីប/ផ្ទួនគ្រាប់បែកដៃ និងគ្រាប់បែកធុនតូច និងធុនធំ រួមទាំងគ្រាប់បែកចង្កោម គ្រាប់រ៉ុក្កែត និងមីស៊ីល។

យុទ្ធភ័ណ្ឌមិនផ្ទុះដោយសារមូលហេតុជាច្រើន៖ គីប/ផ្ទួន និងឧបករណ៍បញ្ឆេះពន្យារពេលអាចមានកំហូច ក្រិតខ្នាតពុំបានត្រឹមត្រូវ ឬដីទន់អាចស្រូបយកកម្លាំងទង្គិចដែលត្រូវការសម្រាប់ផ្ទុះ។ ទោះជាស្ថិតក្នុងហេតុផលណាក៏ដោយ យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅតែជាគ្រោះថ្នាក់ធ្ងន់ធ្ងរដល់អាយុជីវិត និងសុខភាពដែរ។ ប្រទេសមួយចំនួន បានរងផលប៉ះពាល់ពីយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះអស់រយៈពេលជាង 150 ឆ្នាំមកហើយ។

នៅតាមតំបន់ទាំងឡាយណាដែលធ្លាប់ឆ្លងកាត់ការទម្លាក់គ្រាប់បែក ឬសមរភូមិរ៉ាំរ៉ៃ បរិមាណដ៏ច្រើននៃយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះអាចញាំញីដីធ្លីនៅតំបន់នោះ។ ឧទាហរណ៍ នៅក្នុងករណីគ្រាប់បែកចង្កោម មានច្រើនរហូតដល់ 30 ភាគរយដែលមិនអាចផ្ទុះនៅពេលរងកម្លាំងទង្គិច ហើយនៅតែជាគ្រោះថ្នាក់ធ្ងន់ធ្ងរអស់រយៈពេលជាច្រើនឆ្នាំក្រោយពីមានជម្លោះ។ នៅបណ្តាប្រទេសជាច្រើន គេតែងតែឃើញមានយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះច្រើនជាងគ្រាប់មីន ហើយអាចមានរាយប៉ាយគ្រប់ទីកន្លែងច្រើនជាង។ សូមកត់សម្គាល់ផងដែរថា យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការគំរាមកំហែងរបស់វាអាចមាននៅតាមតំបន់ទាំងឡាយ ទោះបីជាធ្លាប់ បានបោសសម្អាតរួចហើយក៏ដោយ ជាពិសេសនៅបណ្តាប្រទេសដែលរងទុក្ខដោយសារជម្លោះដែលអូសបន្លាយយូរ។

ជារឿយៗ យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះអាចមានអស្ថេរភាពយ៉ាងខ្លាំងបំផុត ហើយអាចផ្ទុះនៅពេលប៉ះវាតែបន្តិចប៉ុណ្ណោះ។ ការរងរបួសជារឿយៗអាចកើតឡើងនៅពេល

### ករណីសិក្សា

កម្ពុជា គឺជាប្រទេសមួយដែលរងគ្រោះដោយសារមីនច្រើនជាងគេក្នុងពិភពលោក ប៉ុន្តែបច្ចុប្បន្ននេះ យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះសម្លាប់ និងបង្ករបួសស្នាមប្រជាពលរដ្ឋកម្ពុជាជារៀងរាល់ឆ្នាំច្រើនជាងគ្រាប់មីន។ កុមារ តែងតែងាយរងគ្រោះដោយសារភាពចង់ឃើញចង់ដឹងពីធម្មជាតិ និងទំនោរចង់ប៉ះរបស់ពួកគេ។ គ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងមនុស្សពេញវ័យ ក៏ជាលទ្ធផលនៃការកកាយរុករើលេង ឬប៉ះពាល់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះផងដែរ។

### សម្គាល់

បើមានមីនប្រឆាំងរថយន្ត ត្រូវសន្មត់ថាក៏មានមីនប្រឆាំងមនុស្សផងដែរ។

# 1.2 យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

មានមនុស្សធ្វើកសិកម្ម ឬធ្វើការងារសំណង់នៅក្នុងតំបន់ដែលញាំញីដោយយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ហើយប៉ះពាល់ ផ្លាស់ទី ឬកកាយរុករើវាលេង។ យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះមួយចំនួន អាចមានគីប/ឆ្នួនរំញោចចលនា ឬសែនស័រម៉ាញេទិច។ យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះផ្សេងទៀត អាចមានលក្ខណៈបំផ្លាញដោយខ្លួនឯងតាមពេលកំណត់ដែលអាចដំណើរការមុខងារដោយពុំត្រឹមត្រូវ។ ដោយសារគេមិនអាចកំណត់សភាព ឬលក្ខណៈរបស់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះបានដោយងាយស្រួលនោះ គេត្រូវតែចាត់ទុកថាវាសុទ្ធតែមានគ្រោះថ្នាក់បំផុត ហើយមិនត្រូវប៉ះពាល់វា ឬមានអ្នករំខានវាឡើយ លើកលែងតែអ្នកដែលមានអាជីពខាងកាកសំណល់ជាតិផ្ទុះ។ គ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ជារឿយៗបណ្ដាលឲ្យស្លាប់ច្រើនជាងគ្រាប់មីន ដោយសារតែការផ្ទុះ និងការជះអំបែងរបស់វាមានកម្រិតខ្ពស់ជាង។

តាមធម្មតា គេតែងតែឃើញមានយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅតាមតំបន់ទាំងឡាយណាដែលធ្លាប់មានការប្រយុទ្ធគ្នា ឬទីលានហាត់បាញ់គ្រាប់ពិតរបស់យោធា។ គេអាចរុករកឃើញយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅផ្នែកខាងក្នុង និងផ្នែកខាងក្រៅនៃអគារ។ វាអាចជាត្រូវបានគេកប់នៅខាងក្រោមដី ឬលាក់នៅក្រោមកម្ទេចថ្ម ឬជញ្ជាំងដែលដួលរំលំបាក់បែក។ យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះក៏អាចឃើញមានបង្កប់នៅក្នុងដើមឈើ ឬព្យួរទម្លាក់ចុះពីមែកឈើ របងឈើរស់ របងថ្ម ក៏ដូចជាវត្ថុអនុស្សាវរីយ៍នៅក្នុងផ្ទះផងដែរ។

យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះមាន "ពណ៌យោធា" ជាច្រើនប្រភេទដូចជា ពណ៌កាគី បៃតង ត្នោត ពណ៌ដាំដែង ប្រផេះ ឬអាចនឹងគ្មានលាបពណ៌អ្វីឡើយ។ តាមធម្មតា គេផលិតវាពីលោហៈ ប៉ុន្តែគេក៏អាចផលិតវាពីផ្លាស្ទិកផងដែរ។ បើទុកវាចោលនៅកណ្ដាលវាលអស់រយៈពេលយូរ យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះអាចនឹងច្រេះស៊ី ហើយប្រែពណ៌ ចាំងបាត់ដោយផ្នែក មានពណ៌ស្រអាប់ដោយសារធូលីដី និងភក់ជ្រាំ ហើយពិបាកនឹងមើលស្គាល់។ ទោះបីជាមើលទៅហាក់ដូចជាកម្ទេចដែកដែលគ្មានគ្រោះថ្នាក់ក៏ដោយ វានៅតែមានគ្រោះថ្នាក់បំផុត។



រូបភាពទី 1.15
គ្រាប់បែកដៃរំសេវផ្ទុះខ្លាំងមានគោលបំណងពីរយ៉ាងធុន 40 មម x 46 M430A1 ឃើញមាននៅលើកន្លែងហាត់បាញ់នៅអាហ្វហ្គានីស្ថាន - កងទ័ពចេញពីកងរក្សាស្ថេរភាព ឬកងរក្សាសន្តិភាព មានទំនួលខុសត្រូវក្នុងការដោះសំណល់ជាតិផ្ទុះរបស់ពួកគេ ក្រោយពេលបណ្ដុះបណ្ដាល ឬហ្វឹកហាត់។ រូបថតរបស់ UNMAS/Thomas Enke

រូបភាព 1.16 & 1.17 >
(ទំព័របន្ទាប់ បាតក្រោមផ្នែកខាងស្ដាំ)
គ្រាប់បែកដៃ ថ្មី និងចាស់ អាចគ្មានលំនឹង ទោះបីជាវាបានស្ថិតនៅលើដីអស់រយៈពេលយូរប៉ុណ្ណាក៏ដោយ។ នៅទីនេះគឺជាគ្រាប់បែកដៃរុស្ស៊ីប្រភេទ F1 និងគ្រាប់បែកដៃរបស់អតីតៈយូហ្គោស្លាវី ប្រភេទ M-50។ រូបថតរបស់ UNMAS/Thomas Enke



រូបភាពទី 1.18
ត្រូវប្រយ័ត្នពេលអ្នកឈានជើងដើរ៖ គ្រាប់បែកប្រើកាំភ្លើងបាញ់បញ្ចូនធុនធំដែលមិនផ្ទុះ។ កាំភ្លើងរំសេវផ្ទុះខ្លាំងប្រឆាំងរថក្រោះរបស់យូហ្គោស្លាវីប្រភេទ M-60P1 គ្រាប់បែកលៀនចេញមកក្រៅដី។ រូបថតរបស់ UNMAS/ Thomas Enke

## 1.2.1 គ្រាប់បែកដៃ

គ្រាប់បែកដៃ គឺជាគ្រឿងផ្ទុះដែលជាធម្មតាត្រូវបានគេគប់ដោយដៃ ឬបាញ់ចេញពីកាំភ្លើងធម្មតា ឬកាណុងបាញ់គ្រាប់បែក។ គ្រាប់បែកដៃផ្ទុះដោយសារកម្លាំងទង្គិច ឬតាមរយៈយន្តការពន្យារពេល (យន្តការទាំងពីរនេះក៏អាចគាំងផងដែរ)។ គ្រាប់បែកដៃជះអំបែង "ការពារខ្លួន" គឺជាគ្រាប់បែកដែលគេនិយមប្រើជាងគេ ប៉ុន្តែក៏មានគ្រាប់បែកដៃបំផ្ទុះ "វាយប្រហារ" គ្រាប់បែកដៃផ្ទុះឆេះ គ្រាប់បែកគីមី ឬឧស្ម័ន និងគ្រាប់បែកផ្សេង។ គ្រាប់បែកដៃ ឬគ្រាប់បែកប្រើកាំភ្លើងបាញ់បញ្ចូនប្រភេទជះអំបែងទូទៅ អាចបណ្តាលឲ្យមានមនុស្សស្លាប់ក្នុងរង្វង់ 10 ម៉ែត្រដែលអាចមានតំបន់គ្រោះថ្នាក់បន្តរហូតដល់ 50 ម៉ែត្រ ឬលើសពីនេះ។

គ្រាប់បែកដៃ មានរូបរាងដូចផ្លែម្នាស់ មានរាងជាស៊ីឡាំង ឬរាងមូល ទំហំប្រហែលគ្នានឹងកណ្តាប់ដៃមនុស្សពេញវ័យ ហើយមានប្រវែងរហូតដល់ 10 សម។ គ្រាប់បែកដៃ មានជាច្រើនពណ៌។ គ្រាប់បែកដៃប្រភេទដំបង គឺជាគ្រាប់បែកដៃដែលគេដាក់នៅលើដំបងខ្លីមួយដែលបង្កើនចម្ងាយក្នុងការគប់។ លោហៈគឺជាវត្ថុធាតុដើមដ៏សំខាន់ដែលប្រើសម្រាប់ផលិតគ្រាប់បែកដៃ ប៉ុន្តែគ្រាប់បែកគីមី និងឧស្ម័ន (ផ្សេង) ក៏អាចផលិតពីផ្លាស្ទិកផងដែរ។





គ្រាប់បែកកាំភ្លើង មានតួរាងជាស៊ីឡាំង ភាគច្រើនមានក្បាលរាងមូល ហើយមានលំនឹងស្លាប។ វាពុំមានផ្ទុកសារធាតុរុញនៅផ្នែកកន្ទុយវាឡើយ ប៉ុន្តែបើពុំទាន់បានបោកវាឲ្យផ្ទុះទេនោះ ផ្នែកកន្ទុយអាចត្រូវបានខ្ចាស់នៅខាងក្នុងជាមួយនឹងសំបកពិសេស (ដែលផ្ទុកចូលទៅក្នុងកាំភ្លើងសម្រាប់បាញ់)។ វត្ថុបំពេញចន្លោះទាំងអស់សុទ្ធតែអាចធ្វើទៅបាន ឧ. របាំងផ្សែង ការបំភ្លឺ ឧស្ម័នបង្ហូរទឹកភ្នែក និងរំសេវផ្ទុះខ្លាំង។ ដោយសារល្បឿនយឺតរបស់គ្រាប់បែកប្រើកាំភ្លើងបាញ់បញ្ជូន គឺប/ផ្ទួនងាយរងរំញោចជាទីបំផុត ហើយគួរជៀសវាងការចូលទៅជិតគ្រាប់បែកប្រើកាំភ្លើងបាញ់បញ្ជូន។

ជាមួយនឹងអាដាប់ទ័រពិសេស គេអាចបាញ់គ្រាប់បែកដៃចេញពីកាំភ្លើងបាន។ ត្រូវតែគិតគូរដល់ចំណុចនេះ នៅក្នុងការវាយតម្លៃទៅលើការបោសសម្អាតសមរភូមិ។

គ្រាប់បែកដែលជំនួយដោយគ្រាប់រ៉ុក្កែតដូចជា គ្រាប់បែកប្រឆាំងរថក្រោះ PG-7 មានម៉ូទ័រគ្រាប់រ៉ុក្កែតបន្ថែមមួយទៀតសម្រាប់បន្ថែមរយៈចម្ងាយ។ គ្រាប់រំសេវប្រភេទនេះ មានគោលបំណងចម្រុះ ហើយមានរាយប៉ាយគ្រប់ទីកន្លែង ឃើញមានក្នុងចំនួនដ៏ច្រើនសន្ធឹកសន្ធាប់ ហើយមានជាច្រើនប្រភេទ។ គ្រាប់បែកដៃអាចបំពាក់ជាមួយនឹងមុខងាររំសេវផ្ទុះខ្លាំង (HE) អំបែង (FRAG) រំសេវផ្ទុះខ្លាំងប្រឆាំងរថក្រោះ (HEAT ឬរំសេវផ្ទុះដោយឥន្ធនៈ ឬខ្យល់ (FAE)។ គ្រាប់រំសេវប្រឆាំងរថក្រោះធុនស្រាល មានគឺប/ផ្ទួនដែលងាយរងរំញោចជាទីបំផុត។ ការប្រែប្រួលសីតុណ្ហភាពឆាប់រហ័ស អាចធ្វើឲ្យផ្ទុះគឺប/ផ្ទួនបាន។ គ្រាប់រំសេវដែលគេបោះបង់ចោល ឬគ្រាប់រំសេវស្ទាយ ក៏អាចផ្ទុកនូវសារធាតុរុញពីម៉ូទ័រគ្រាប់រ៉ុក្កែតផងដែរ។

## 1.2.2 គ្រាប់កាំភ្លើងត្បាល់មូល

គ្រាប់កាំភ្លើងត្បាល់មូល គឺជាក្បាលគ្រាប់ដែលភាគច្រើនបាញ់បង្ហោះចេញពីកាណុងលោហៈដែលមានប្រវែងប្រហែលពី 90 សម ដល់ 170 សមដែល





រូបភាពទី 1.19
គ្រាប់កាំភ្លើងត្បាល់មូល ប្រភេទ 82 មមធុន HE O-832D ចំនួនពីរគ្រាប់ស្ថិតនៅក្នុងរថពាសដែកប្រយុទ្ធដែលគេបោះបង់ចោល។ រូបថតរបស់ UNMAS/Thomas Enke

រូបភាពទី 1.20
ធុងគ្រាប់បែកចង្កោមប្រភេទ CBU-87។ ប្រភេទខ្លះអាចផ្ទុកគ្រាប់បែករហូតដល់ 800 គ្រាប់។ រូបថតរបស់ UNMAS /Thomas Enke

គេហៅវាថា កាំភ្លើងត្បាល់។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រព័ន្ធគ្រាប់កាំភ្លើងត្បាល់ដ៏ស្មុគស្មាញត្រូវបានអភិវឌ្ឍន៍ឡើង ដើដែលធ្វើឲ្យគេពិបាកសម្គាល់ដឹងពីភាពខុសគ្នារវាងកាំភ្លើងបាញ់គ្រាប់បែក និងកាំភ្លើងត្បាល់។ កាំភ្លើងត្បាល់ទំនើប អាចបាញ់ដោយផ្ទាល់ និងដោយប្រយោល ហើយអាចផ្ទុកគ្រាប់បានដូចគ្នានឹងកាំភ្លើងធម្មតាផងដែរ។ លក្ខណៈដ៏សំខាន់មួយគឺ គ្រាប់កាំភ្លើងត្បាល់មូលប្រើរំសេវរុញតិចជាង នៅពេលធ្វើជាក្បាលគ្រាប់កាំភ្លើងធម្មតា ឬកាំភ្លើងបាញ់គ្រាប់បែក។ គ្រាប់កាំភ្លើងត្បាល់មូល ត្រូវបានផ្ទុកចូលទៅក្នុងកាណុងពីផ្នែកខាងមុខ ឬផ្នែកខាងក្រោយ (អាស្រ័យទៅលើប្រព័ន្ធ) ហើយបាញ់បង្ហោះដោយរំសេវរុញរបស់វាផ្ទាល់។ ជារឿយៗ គ្រាប់កាំភ្លើងត្បាល់មូលមានច្រមុះស្រួចនៅផ្នែកខាងមុខ និងមានស្លាបនៅផ្នែកខាងក្រោយ។ តួលោហៈអាចមានលំដាប់វិជ្ជមាត្រទទឹងចាប់ពី 45 មម រហូតដល់បច្ចុប្បន្ន 240 មម និងមានបណ្តោយប្រហែលចាប់ពី 30 សម រហូតដល់ជាងមួយម៉ែត្រ។[5] ដោយសារតែវាមានភាពងាយស្រួលក្នុងការប្រើប្រាស់ មានតម្លៃថោក និងងាយស្រួលវេចខ្ចប់ជាងគេនោះ កាំភ្លើងត្បាល់ គឺជាសព្វាវុធដែលមានការប្រើប្រាស់ជាទូទៅច្រើនជាងគេបំផុតនៅក្នុងសង្គ្រាម។

តាមធម្មតា គ្រាប់បែកត្បាល់ត្រូវបានផលិតឡើងពីលោហៈ ហើយនៅពេលគេរកឃើញ វាអាចមានសភាពច្រេះ និងប្រែពណ៌ទៅតាមអាយុកាលរបស់វា។ នៅពេលប៉ះទង្គិចឲ្យផ្ទុះ វាបង្កើតបានជាក្រហូងដី ហើយជាធម្មតាគេអាចមើលឃើញទីតាំងផ្ទុះយ៉ាងច្បាស់ក្រឡែត។ នៅលើផ្លូវក្រាលកៅស៊ូ វាបង្កើតបានជាអ្វីមួយដែលមើលទៅដូចជា “ស្នាមខ្លាត” នៅលើផ្លូវបេតុង ឬផ្លូវកៅស៊ូ។

រយៈចម្ងាយដែលបណ្តាលឲ្យស្លាប់ ឬបង្កគ្រោះថ្នាក់របស់គ្រាប់បែកត្បាល់អាស្រ័យទាំងស្រុងទៅលើបន្ទាត់ទ្រូងកណ្តាលរបស់សព្វាវុធនោះ។ គ្រាប់បែកត្បាល់តូចមួយដែលមានរំសេវខ្ពស់ខ្លាំង អាចបំផ្លាញរថយន្តតូចមួយ ចំណែកគ្រាប់បែកត្បាល់ដែលធំជាងនេះ អាចបំផ្លាញអគារដែលមានទំហំចាប់ពីតូច

[5] ប្រព័ន្ធកាំភ្លើងត្បាល់ដ៏តូចបំផុត គួរតែជាកាំភ្លើងត្បាល់ BRIXIA របស់អ៊ីតាលីធុន M35ដែលមានបន្ទាត់ទ្រូងកណ្តាល 45 មម ប្រព័ន្ធដែលធំជាងគេបំផុតគឺប្រព័ន្ធ KARL របស់អាល្លឺម៉ង់ដែលមានបន្ទាត់ទ្រូងកណ្តាល 600 មម។ ប្រព័ន្ធទាំងពីរនេះលែងមានគេប្រើទៀតហើយ ប៉ុន្តែគេអាចឃើញមានសំណល់ជាតិផ្ទុះពីសង្គ្រាមបច្ចុប្បន្ននៅអឺរ៉ុប។

## ករណីសិក្សា

នៅឆ្នាំ 2006 ជនជាតិអ៊ីស្រាអែលប្រើប្រាស់គ្រាប់បែកចង្កោម ប្រឆាំងនឹងកងកម្លាំងហេហ្សបូឡា (Hezbollah) នៅប្រទេសលីបង់ដែលបណ្តាលឲ្យមានការរិះគន់ជាលក្ខណៈ អន្តរជាតិ។ អ៊ីស្រាអែលត្រូវបានគេនិយាយថាបានបាញ់គ្រាប់បែកចង្កោមក្នុងបរិមាណដ៏ច្រើនសន្ធឹកសន្ធាប់ជាពិសេស នៅអំឡុង 3 ថ្ងៃចុងក្រោយនៃសង្គ្រាមដែលអូសបន្លាយ 34 ថ្ងៃ។ របាយការណ៍នោះបានប្រាប់ទៀតថាក្រុម Hezbollah 113 "គ្រាប់រ៉ុក្កែត ចង្កោម" នៅអ៊ីស្រាអែលភាគខាងជើង ហើយជាការតបតវិញពួកអ៊ីស្រាអែលបានបាញ់គ្រាប់បែកចង្កោមដែលប៉ះពាល់ដល់ 26 ភាគរយនៃផ្ទៃដីដែលអាចដាំដំណាំបានរបស់ប្រទេសលីបង់ភាគខាងត្បូង ហើយញាំញីដីធ្លីប្រហែល 13 ម៉ែល៍ការ៉េ ដោយសារតែគ្រាប់បែកមិនទាន់ផ្ទុះ។ របាយការណ៍មួយបានបញ្ជាក់ថាមាសព្វាវុធចង្កោមរបស់អ៊ីស្រាអែលមានអត្រាមិនផ្ទុះរហូតដល់ ៧0 ភាគរយ។[8]

[8] គ្រាប់បែកចង្កោម៖ សារតា និងបញ្ហាសម្រាប់ការធ្វើសន្និសីទ Andrew Feickert អ្នកឯកទេសផ្នែក កងកម្លាំងយោធាក្រោមដី Paul K. Kerr អ្នកវិភាគ ក្នុងសន្ធិសញ្ញាមិនរីកសាយភាយអាវុធនុយក្លេអ៊ែរ 29 មេសា 2014

ដល់មធ្យម។ វត្ថុបំពេញចន្លោះផ្សេងៗដូចជា របាំងផ្សែង និងការបំភ្លឺ សុទ្ធតែអាចធ្វើបាន ក៏ដូចជាខិតប័ណ្ណ ឬគ្រាប់បែកតូចៗផងដែរ។ គ្រាប់កាំភ្លើងត្បាល់មូលសម័យទំនើប អាចបំពាក់ជាមួយនឹងគីប/ផ្ទួនអេឡិចត្រូនិចដែលនៅជិត ឬគីប/ផ្ទួនមេកានិចដែលអាចដំណើរការបានរហ័ស។ គ្រាប់កាំភ្លើងត្បាល់មូលប្រឆាំងរថក្រោះមានអ្នកនាំមុខ ក៏កំពុងមានការប្រើប្រាស់ផងដែរ។[6]

គ្រាប់កាំភ្លើងត្បាល់មូលមិនទាន់ផ្ទុះ ក៏នៅតែអាចផ្ទុកនូវរំសេវរុញ ក៏ដូចជាចំណុះដែលមានបរិយាយខាងលើផងដែរ។ មិនត្រូវចូលទៅជិតគ្រាប់កាំភ្លើងត្បាល់មូលឡើយ។ កាំភ្លើងត្បាល់ ភាគច្រើនគឺជាសព្វាវុធបាញ់ដោយប្រយោលដែលក្នុងនោះ អ្នកបាញ់សព្វាវុធជារឿយៗពុំអាចមើលឃើញគោលដៅរបស់ខ្លួនឡើយ ហើយបាញ់វាតាមគន្លងគ្រាប់បាញ់ខ្ពស់មួយ។ ជាលទ្ធផល លំនាំនៃការបាញ់អាចអាចត្រូវគោលដៅមិនរើសមុខ ហើយគេឃើញមានគ្រាប់កាំភ្លើងត្បាល់មូលមិនទាន់ផ្ទុះនៅរាយប៉ាយតាមតំបន់សមរភូមិជាច្រើន។ គ្រាប់កាំភ្លើងត្បាល់មូលដែលមិនទាន់ផ្ទុះ ឬត្រូវគេបោះបង់ចោល  ក៏អាចប្រើជារំសេវសំខាន់របស់គ្រឿងផ្ទុះកែច្នៃផងដែរ។

## 1.2.3 គ្រាប់បែកចង្កោម គ្រាប់បែក និងគ្រាប់បែកតូចៗ (ប្រភេទគ្រាប់បុមប៊ី)

យោងតាមសន្និសីទការទូតសម្រាប់ការអនុម័តអនុសញ្ញាស្តីពីគ្រាប់បែកចង្កោម[7] គ្រាប់បែកចង្កោម មានន័យថា គ្រាប់បែកធម្មតាដែលត្រូវបានរចនាឡើងដើម្បីបំបែក ឬបញ្ចេញគ្រាប់បែករំសេវផ្ទុះដែលគ្រាប់បែកនីមួយៗមានទម្ងន់តិចជាង 20 គីឡូក្រាម ហើយរួមបញ្ចូលទាំងគ្រាប់បែករំសេវផ្ទុះទាំងនោះផងដែរ។ វាពុំមានន័យដូចខាងក្រោមនេះឡើយ៖

- គ្រាប់បែក ឬគ្រាប់បែកចង្កោមដែលត្រូវបានរចនាឡើងដើម្បីចែកចាយអណ្តាតភ្លើង ផ្សែង រំសេវកាំជ្រួច ឬសាស់



រូបភាពទី 1.21
គ្រាប់បែកមិនទាន់ផ្ទុះជាច្រើន។ គ្មានលំនឹងជាទីបំផុត៖ BLU-97, DM1385, PTAB-2.5KO។ រូបថតរបស់ UNMAS/Thomas Enke

[6] ឧ. គ្រាប់កាំភ្លើងត្បាល់មូលមានរំសេវផ្ទុះខ្លាំងប្រឆាំងរថក្រោះទំហំ 120 មម ឈ្មោះ "បាសាដ (Bussard)"

[7] សន្និសីទការទូតសម្រាប់ការអនុម័តអនុសញ្ញាស្តីពីគ្រាប់បែកចង្កោម ទីក្រុងឌុប្លីន (DUBLIN) ថ្ងៃទី 19 – 30 ឧសភា 2008

# 1.2 យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

## 1.2.3 គ្រាប់បែកចង្កោម គ្រាប់បែក និងគ្រាប់បែកតូចៗ (ប្រភេទគ្រាប់បុមប៊ី)

- គ្រាប់បែកដែលត្រូវបានរចនាឡើងសម្រាប់តួនាទីការពារខ្យល់តែម្យ៉ាងគត់
- គ្រាប់បែក ឬគ្រាប់បែកចង្កោមដែលត្រូវបានរចនាឡើងដើម្បីបង្កើតអានុភាពអគ្គិសនី ឬអេឡិចត្រូនិច
- ដើម្បីជៀសវាងអានុភាពតំបន់ប្រហូកប្រហល់ និងហានិភ័យដែលបង្កឡើងដោយគ្រាប់បែកមិនទាន់ផ្ទុះ គ្រាប់បែកត្រូវមានលក្ខណៈទាំងអស់ដូចខាងក្រោមនេះ៖
  - គ្រាប់បែកនីមួយៗមានផ្ទុកគ្រាប់រំសេវផ្ទុះតិចជាងដប់
  - គ្រាប់រំសេវផ្ទុះនីមួយៗ មានទម្ងន់លើសពីបួនគីឡូក្រាម
  - គ្រាប់រំសេវផ្ទុះនីមួយៗ ត្រូវបានរចនាឡើងដើម្បីរក និងពាក់ព័ន្ធនឹងវត្ថុគោលដៅតែមួយ
  - គ្រាប់រំសេវផ្ទុះនីមួយៗ មានបំពាក់ដោយឧបករណ៍អេឡិចត្រូនិចដែលបំផ្លាញខ្លួនឯងបាន
  - គ្រាប់រំសេវផ្ទុះនីមួយៗ មានបំពាក់ជាមួយនឹងលក្ខណៈពិសេសដែលធ្វើឲ្យអសកម្មខ្លួនឯងដោយអេឡិចត្រូនិច។

គ្រាប់បែក និងគ្រាប់បែកតូចៗ (ប្រភេទគ្រាប់បុមប៊ី) ត្រូវបាននាំទៅកាន់តំបន់គោលដៅនៅក្នុងគ្រាប់បែកចង្កោម ក្បាលគ្រាប់រ៉ុក្កែតកាំភ្លើងធំ ឬគ្រាប់កាំភ្លើងធំមូល។ ឡូតគ្រាប់កាំភ្លើងទាំងនេះ ផ្ទុះនៅកណ្តាលនៅកណ្តាលអាកាសដែលស្ថិតនៅពីលើតំបន់គោលដៅ ហើយបាចសាចគ្រាប់បែកពីលើតំបន់ធំទូលាយមួយ។ គ្រាប់បែក អាចជាមីនប្រឆាំងមនុស្ស គ្រាប់បែកតូចៗ (ប្រភេទគ្រាប់បុមប៊ី)រំសេវផ្ទុះខ្លាំងប្រឆាំងរថក្រោះ ឬជាគ្រាប់បែកតូចមួយដែលមានវត្ថុបំពេញចន្លោះខុសៗគ្នាជាច្រើន។ គ្រាប់បែកមានរូបរាង និងពណ៌ជាច្រើនដូចជា រូបរាង និងទំហំរបស់កូនសំឡី មេអំបៅ ឬកំប៉ុងភេសជ្ជៈ។ ជារឿយៗ វាក៏មានពណ៌ភ្លឺឆ្លុះផងដែរ។

ក្នុងចំណោមយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ គ្រាប់បែកបង្កការគំរាមកំហែងគ្រោះថ្នាក់ពិសេស ដោយសារតែភាពឆាប់ប្រែប្រួលខ្លាំង និងការបែកសាចនៅលើតំបន់ធំទូលាយរបស់វា។ ជារឿយៗ គ្រាប់បែកអាចមិនផ្ទុះ ហើយនៅតែបង្កគ្រោះថ្នាក់រយៈពេលជាច្រើនឆ្នាំ។ មានការរាយការណ៍មកថា អត្រាប៉ាន់ស្មានអំពីការមិន







រូបទាពទី 1.22
គ្រាប់រ៉ុក្កែតរំសេវផ្ទុះខ្លាំងទំហំ 122 មម ប្រភេទ 9M22U ចំនួនពីរគ្រាប់ស្ថិតនៅក្នុងភូមិមួយនៃប្រទេសអាហ្វហ្គានីស្ថាន។ រូបថតរបស់ UNMAS/Thomas Enke

រូបទាពទី 1.23
សំណល់គ្រាប់មីស៊ីលប្រឆាំងរថក្រោះផ្ទុះរួចធុន BGM-71A/TOW-1B។ កំណាត់គ្រាប់នេះក៏មានផ្នែកដែលគ្រោះថ្នាក់ ដូចគ្នានឹងដបឧស្ម័នដែលបានបញ្ចូលពេញផងដែរ។ រូបថតរបស់ UNMAS/Thomas Enke

រូបទាពទី 1.24
នេះគឺជាមីស៊ីលធុន S-75 Dwina/SA-2 ដូចមានឃើញនៅក្នុងករណីសិក្សា នៅប្រទេសអ៊ីរ៉ាក់។ រូបថតរបស់ UN

ផ្ទុះរបស់វានៅលើសមរភូមិជាច្រើន គឺនៅចន្លោះប្រាំ និង 30 ភាគរយ។ អត្រានេះ គឺអាស្រ័យទៅលើកត្តាជាច្រើន ប៉ុន្តែជាទូទៅ កាលណាដីកាន់តែទន់ អត្រាមិនផ្ទុះកាន់តែខ្ពស់។ គ្រាប់បែកមិនទាន់ផ្ទុះងាយរងរំញោចបំផុត ហើយអាចផ្ទុះដោយការប៉ះពាល់តែបន្តិចប៉ុណ្ណោះ។ គ្រាប់បែកនេះមានគ្រោះថ្នាក់ខ្លាំងជាទីបំផុត ហើយមិនត្រូវចូលទៅជិតវាឡើយ។ គេអាចឃើញមានវានៅលើដី ឬក្រោមដី និងស្ថិតនៅក្នុង ឬជុំវិញអគារ។ ជួនកាល គេអាចឃើញមានគ្រាប់បែកព្យួរ ឬចងនៅលើដើមឈើ របង ឬនៅលើដំបូលអគារ។

នៅពេលតំបន់ណាមួយត្រូវបានកំណត់ជាតំបន់គោលដៅសម្រាប់ដាក់គ្រាប់បែក ជួនកាលមានស្លាកសញ្ញា និងតម្រុយប្រាប់ ដូចជា កញ្ចប់ ឆ័ត្រយោងតូចៗ ឬ"ស្មាមខ្មៅ" យ៉ាងច្បាស់ក្រឡែតនៅលើដី ឬអគារ។ បន្ថែមពីលើនេះទៀត ដើមឈើដែលនៅជិតៗនោះ នឹងបង្ហាញឲ្យឃើញនូវសញ្ញាប្រាប់លក្ខណៈ ដូចជា ចុងឈើមានដាច់មែក និងស្លឹកជាដើម។ នៅកណ្ដាលវាល តាមធម្មតាតែងតែមានរន្ធតូចៗ និងកម្ទេចកម្ទីជាច្រើនបន្សល់ទុកនៅខាងក្រោយ ដូចជា សំបកលោហៈ និងផ្លាស្ទិក ឬឆ័ត្រយោងតូចៗ ក៏ដូចជាកម្ទេចកម្ទីពីគោលដៅផងដែរ។

## 1.2.4 គ្រាប់រ៉ុក្កែត និងមីស៊ីល

គ្រាប់រ៉ុក្កែត ឬមីស៊ីល គឺជាគ្រឿងផ្ទុះដែលផ្ទុកមធ្យោបាយរុញច្រាន (ម៉ូទ័រគ្រាប់រ៉ុក្កែត) របស់វាផ្ទាល់ ក៏ដូចជារំសេវផ្ទុះ ឬវត្ថុបំពេញចន្លោះផ្សេងៗ (ក្បាលគ្រាប់)។ មីស៊ីលមានលក្ខណៈស្រដៀងគ្នាទៅនឹងគ្រាប់រ៉ុក្កែតដែរ ប៉ុន្តែវាមានប្រព័ន្ធសម្រាប់នាំផ្លូវក្នុងគន្លងបាញ់របស់វា។ គ្រាប់រ៉ុក្កែត និងមីស៊ីល អាចបាញ់ចេញពីរថយន្ត កាំភ្លើងបាញ់គ្រាប់ចេញពីដី ឬចេញពីលើស្មា។ គេក៏អាចបាញ់វាចេញពីយន្តហោះ នាវាធម្មតា និងនាវាមុជទឹកផងដែរ។ គ្រាប់រ៉ុក្កែត និងមីស៊ីលត្រូវបានគេប្រើសម្រាប់បញ្ជូនរំសេវផ្ទុះខ្លាំង ឬទម្ងន់ផ្សេងៗទៀតដូចជា គ្រាប់បែកចង្កោម ខិតប័ណ្ណ វត្ថុធាតុគីមី ឬជីវសាស្ត្រនៅចម្ងាយឆ្ងាយ និងមានភាពត្រឹមត្រូវខ្លាំងជាងសព្វាវុធប្រភេទផ្សេងៗ។ រយៈចម្ងាយបណ្ដាលឲ្យស្លាប់របស់ក្បាលគ្រាប់មានរំសេវផ្ទុះខ្លាំងរបស់គ្រាប់រ៉ុក្កែត ឬមីស៊ីល មានភាពខុសគ្នា

### ករណីសិក្សា

មីស៊ីលចាស់ៗរបស់សូវៀត ប្រភេទបាញ់ពីដីទៅលើអាកាស ជាង 100 គ្រាប់ ត្រូវបានគេឃើញនៅបោះបង់ចោលនៅតំបន់ បាជាត នៅឆ្នាំ 2003។ ដាក់នៅលើកន្ទុយសណ្ដោងរថយន្ត និងមានប្រវែងជិត 11 ម៉ែត្រ រ៉ឺម៉កដឹកមីស៊ីលធ្លាប់ធ្លាប់ត្រូវបានអ្នកស្រុកលួច ហើយគេឃើញមានកុមារកំពុងលេងនៅតាមទីតាំងខុសៗគ្នា។ សារធាតុរុញដែលមានសភាពច្រេះស៊ីខ្លាំង ផ្ទុះរលាកទៅលើកុមារម្នាក់។ មានមីស៊ីលចំនួនពីរត្រូវបានគេរាយការណ៍ថាបានឆេះ ក្រោយពីមានគេកកាយរុករើលេងជាបន្តបន្ទាប់ ហើយមួយគ្រាប់នោះស្ទើរតែបានបំផ្លាញផ្ទះបីខ្នង និងសម្លាប់មនុស្សមួយចំនួន។ បន្ថែមពីលើការបំផ្លាញ មីស៊ីលនោះមានឥន្ធនៈពេញដែលបណ្ដាលឲ្យផ្ទុះជិតប្រាំដងច្រើនជាងក្បាលគ្រាប់តែឯង។

របាយការណ៍ស្ដីពីមីស៊ីលធុន SA-2 នៅអ៊ីរ៉ាក់ (Hess)។ R. ប្រធានកម្មវិធី WFP/FSD ក្រុមឆ្លើយតបសកម្មភាពកម្ចាត់មីន ទីក្រុង Baghdad អ៊ីរ៉ាក់ ឆ្នាំ 2003

# 1.2 យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

## 1.2.4 គ្រាប់រ៉ុក្កែត និងមីស៊ីល

យ៉ាងខ្លាំង អាស្រ័យទៅលើទំហំ និងលក្ខណៈនៃក្បាលគ្រាប់ ប៉ុន្តែជាធម្មតា គ្រាប់រ៉ុក្កែត និងមីស៊ីល មានម្សៅរំសេវបំផ្លាញយ៉ាងច្រើនសន្ធឹកសន្ធាប់ដែល អាចបង្កការខូចខាត និងបំផ្លាញរថយន្ត អគារ ថែមទាំងតំបន់ជិតខាងទាំងមូល ផងដែរ។



រូបភាពទី 1.25
គ្រាប់បែកអង់គ្លេសធុន 12,000 ផោនដ៏ HE សល់ពីសង្គ្រាមលោក លើកទីពីរ ឃើញនៅទំនប់ទឹកមួយ របស់អាល្លឺម៉ង់។ រូបថតរបស់ UNMAS/ Thomas Enke

គ្រាប់រ៉ុក្កែត និងមីស៊ីល មានរូបរាង និងទំហំជាច្រើន ចាប់ពីគ្រាប់រ៉ុក្កែតធុនតូច បាញ់ពីលើអាកាសទៅកាន់ដីធុន S-5 មានប្រវែងប្រហែល 80 សម រហូតដល់ មីស៊ីលកាំភ្លើងធំដែលមានបណ្តោយចាប់ពី 15 ម៉ែត្រឡើងទៅ ដូចជា មីស៊ីលធុន RSD-10/SS-20 ដែលមានប្រវែង 16,5 ម៉ែត្រជាដើម។ គ្រាប់រ៉ុក្កែត និងមីស៊ីល ត្រូវបានផលិតឡើងពីលោហៈ ហើយតាមធម្មតាគេអាចសម្គាល់បាននូវភាព ខុសគ្នាតាមរយៈរូបរាងជាស៊ីឡាំងស្តើងទ្រវែងរបស់វា។ គេហៅគ្រាប់រ៉ុក្កែត/ មីស៊ីល អាស្រ័យទៅលើវិជ្ជមាត្ររបស់វា។ ឧទាហរណ៍ គ្រាប់រ៉ុក្កែតធុន BM-21 ប្រវែង 122 មម មានវិជ្ជមាត្រ 122 មម ប៉ុន្តែអាស្រ័យទៅលើប្រវែងបណ្តោយ 2.87 ម៉ែត្រ ឬវែងជាងនេះ។

គ្រាប់រ៉ុក្កែត និងមីស៊ីលមិនទាន់ផ្ទុះ អាចមានគ្រោះថ្នាក់ជាទីបំផុត ដោយសារតែ ការរំខានអាចបង្កឡើងដោយឥន្ធនៈគ្រាប់រ៉ុក្កែតដែលមិនទាន់បានប្រើអស់ ហើយ

រូបភាពទី 1.26
(ក្រោម) ឧទាហរណ៍អំពីគ្រាប់ កាំភ្លើងធំមូល និង គ្រាប់មូលបាញ់រថក្រោះ។ រូបថតរបស់ UNMAS /Thomas Enke



រុញច្រានគ្រាប់រ៉ុក្កែតតាមលំនាំមួយដែលគ្មានប្រព័ន្ធសម្រាប់នាំផ្លូវ។ បើក្បាលគ្រាប់នៅមិនទាន់ខូចខាតទេនោះ សក្តានុពលផ្ទុះគឺស្មើនឹងពេលដែលគ្រាប់រ៉ុក្កែត ឬមីស៊ីលត្រូវបានបាញ់បង្ហោះជាលើកដំបូងដែរ ហើយថែមទាំងខ្លាំងជាងនេះទៅទៀត បើគ្រាប់រ៉ុក្កែត ឬមីស៊ីលមិនហោះឡើង ប៉ុន្តែផ្ទុះជាមួយនឹងបន្ទុកឥន្ធនៈពេញ។

ឥន្ធនៈគ្រាប់រ៉ុក្កែត ងាយនឹងច្រេះកាត់ និងហើរជាទីបំផុត ហើយនឹងធ្វើឲ្យរលាកស្បែកដែលប៉ះពាល់វា ហើយអាចធ្វើឲ្យមនុស្សម្នាក់ស្លាប់បាន បើបានស្រូបចំហាយផ្សែងវាចូលក្នុងខ្លួន។ ឥន្ធនៈគ្រាប់រ៉ុក្កែត ច្បាស់ជាផ្ទុះបើដុតវាឲ្យឆេះ។ ឥន្ធនៈប្រភេទខ្លះ នឹងឆេះដោយខ្លួនឯងនៅពេលប៉ះជាមួយខ្យល់។ ដោយសារមូលហេតុទាំងនេះហើយ គេមិនត្រូវចូលទៅជិតគ្រាប់រ៉ុក្កែត និងមីស៊ីលឡើយ។

សំណល់គ្រាប់រ៉ុក្កែត និងមីស៊ីលដែលបានផ្ទុះរួច អាចផ្ទុកនូវដបឧស្ម័នដែលមានឧស្ម័នបង្ហាប់ដែលត្រូវការសម្រាប់ប្រព័ន្ធនាំផ្លូវ ឬបន្លយកម្តៅឧបករណ៍ស្វែងរកអ៊ីនហ្វ្រារ៉េដ។ គេក៏អាចឃើញមានគ្រឿងកាំជ្រួចគ្រោះថ្នាក់សម្រាប់នាំផ្លូវ និងបាញ់ចេញផងដែរ។

ដោយសារតែរូបរាងតូចច្រឡឹងរបស់វា គ្រាប់រ៉ុក្កែត និងមីស៊ីលមិនទាន់ផ្ទុះ (ជារឿយៗបែកខ្ចាយទៅជាបំណែកៗ) ក៏អាចមើលទៅច្រឡំគ្នាជាមួយនឹងបំពង់ដែលខូចផងដែរ។ នៅក្នុងជម្លោះមួយចំនួនដែលពាក់ព័ន្ធនឹងប្រទេសមហាអំណាចដែលជាប្រទេសផលិតអាវុធធុនធ្ងន់ និងបច្ចេកវិទ្យាទំនើប គ្រាប់រ៉ុក្កែត និងមីស៊ីលមិនទាន់ផ្ទុះ អាចមានទំហំធំសម្បើម ប៉ុន្តែករណីទាំងនេះមិនសូវមានចំនួនច្រើនទេ។

### 1.2.5 គ្រាប់រំសេវសម្រាប់កាំភ្លើង

បច្ចុប្បន្ន គ្រាប់រំសេវនេះត្រូវបានប្រើប្រាស់ ជាបន្ទាត់ទ្រូងកណ្តាលយ៉ាងសម្បូរបែប ចាប់ពី 20 មម រហូតដល់ 203 មម (8 អ៊ីញ)។ ក្នុងសម័យអតីតកាល គេប្រើ

## ករណីសិក្សា

គ្រាប់បែកមិនទាន់ផ្ទុះប្រហែល 100,000 គ្រាប់ ទុកចោលកណ្តាលវាលនៅអាល្លឺម៉ង់ តាំងពីចប់សង្គ្រាមលោកលើកទីពីរ។ ជារឿយៗ គ្រាប់បែកទាំងនោះមានទម្ងន់រហូតដល់ 250 គក្រ។ គ្រាប់បែកខ្លះទៀត មានទំហំធំជាងនេះឆ្ងាយ។ គ្រាប់បែកដែលមានម៉ាស់មាឌ 10 តោន ត្រូវបានប្រើសម្រាប់បំផ្លាញស្ពាន និងរបាំងការពារ។ គ្រាប់បែករាប់ពាន់គ្រាប់បានទម្លុះដីយ៉ាងជ្រៅ ដូច្នេះហើយទើបគេរកវាមិនទាន់ឃើញអស់រយៈពេលជាច្រើនឆ្នាំ។ បច្ចេកវិទ្យាថ្មី និងការចេញរូបភាព និងផែនទីដែលមានអាជ្ញាប័ណ្ណនាំមកនូវការរកឃើញថ្មីជារៀងរាល់ឆ្នាំ។ បច្ចុប្បន្ននេះ គ្រាប់បែកចំនួន 5,500 គ្រាប់ ត្រូវបានគេរកឃើញ និងកម្ទេចចោលជារៀងរាល់ឆ្នាំ។

បន្ទាត់ទ្រូងកណ្តាលធំជាងនេះ រហូតដល់ 80 សម។[9] គេប្រើវាចេញពីសព្វាវុធដែលមានគោលបំណងខុសៗគ្នា ដូចជា កាំភ្លើងធំបាញ់គ្រាប់បែក កាំភ្លើងប្រឆាំងយន្តហោះ កាំភ្លើងបាញ់រថក្រោះ ឬកាំភ្លើងធំធុនស្រាលជាដើម។

គ្រាប់កាំភ្លើងធំមូល គឺជាគ្រឿងផ្ទុះដែលត្រូវបានរចនាឡើងដើម្បីបាញ់នៅចម្ងាយឆ្ងាយមួយ (ជាង 100 គីឡូម៉ែត្រ) និងដើម្បីឲ្យផ្ទុះនៅលើអាកាសពីលើចំណុចគោលដៅ ឬផ្ទុះនៅពេលប៉ះវា។ គ្រាប់កាំភ្លើងធំមូល ក៏អាចបាញ់ចេញពីដី សមុទ្រ ក៏ដូចជាកាំភ្លើង/កាំភ្លើងបាញ់គ្រាប់បែក [10] ពីលើអាកាសផងដែរ។ កាំភ្លើងធំអាចបាញ់ដោយផ្ទាល់ ឬដោយប្រយោល ប៉ុន្តែដោយសារតែមានចម្ងាយឆ្ងាយទៅកាន់ចំណុចគោលដៅ អ្នកប្រើប្រាស់សព្វាវុធមិនអាចមើលឃើញចំណុចគោលដៅរបស់ខ្លួនបានឡើយ។ សមត្ថភាពបំផ្លាញរបស់គ្រាប់កាំភ្លើងធំមូលធម្មតា ភាគច្រើនគឺអាស្រ័យទៅលើទំហំរបស់វា។

ក្បាលគ្រាប់នៃគ្រាប់រំសេវប្រឆាំងរថក្រោះ ភាគច្រើនគឺជាគ្រឿងផ្ទុះដែលត្រូវបានរចនាឡើងដើម្បីបំផ្លាញរថក្រោះ លេណដ្ឋាន ឬកងទ័ពដែលបោះទីតាំងនៅកណ្តាលវាល។ គ្រាប់មូលបាញ់រថក្រោះ តាមធម្មតាត្រូវបានគេប្រើប្រាស់ជាសព្វាវុធបាញ់ដោយផ្ទាល់ ប៉ុន្តែអាចត្រូវបានគេប្រើប្រាស់ជាសព្វាវុធបាញ់ដោយប្រយោលដែលបាញ់ចេញពីចម្ងាយឆ្ងាយពីចំណុចគោលដៅដែលបានគ្រោងទុកផងដែរ។

គ្រាប់កាំភ្លើងធំ និងគ្រាប់មូលបាញ់រថក្រោះ ដូចគ្នានឹងគ្រាប់ធំៗដទៃទៀតដែរ មានរាងជាឪណាមិចអាកាស ជាមួយនឹងតួរាងស៊ីឡាំងមានច្រមុះស្រួច និងគល់រាបស្មើ។ គ្រាប់ភាគច្រើនផលិតពីលោហៈ។ គ្រាប់មូលបាញ់រថក្រោះ ក៏មានស្លាបនៅផ្នែកខាងក្រោយនៃក្បាលគ្រាប់ និង/ឬគីប/ផ្នូនត្រង់ លៀនចេញមកក្រៅមួយផងដែរ។

ទៅតាមរបៀបដែលគេផលិតកាំភ្លើង និងគោលបំណងរបស់កាំភ្លើង គ្រាប់មូល និងសារធាតុរុញ អាចត្រូវបានផ្ទុកដាច់ដោយឡែកពីគ្នា ឬដាក់ក្នុងសំបកគ្រាប់។

[9] កាំភ្លើងបាញ់ផ្លូវរថភ្លើងអាល្លឺម៉ង់ឈ្មោះ DORA ប្រើនៅក្នុង សង្គ្រាមលោកលើកទី II។
[10] AC-130 SPECTRE មានកាំភ្លើងបាញ់គ្រាប់បែកធុន 105 មម (ស.រ.អ)







រូបភាពទី 1.27
ទីលានទុកគ្រាប់បែកមិនទាន់ប្រើ (ហ្វឹកហាត់) ធុន P-50Sh នៅអាហ្វហ្គានីស្ថាន។ រូបថតរបស់ UNMAS/Thomas Enke

រូបភាព 1.28
ឧទាហរណ៍អំពីគ្រាប់កាំភ្លើងធំមូល និងគ្រាប់មូលបាញ់រថក្រោះ។
រូបថតរបស់ UNMAS/Thomas Enke

រូបភាពទី 1.29
យុទ្ធភ័ណ្ឌដែលគេបោះបង់ចោល រកឃើញនៅអាហ្វហ្គានីស្ថាន។
រូបថតរបស់ UNMAS/Thomas Enke

គ្រាប់មូលមិនទាន់ផ្ទុះ ក៏អាចឃើញមាននៅលើ ឬក្រោមដី ឬនៅក្នុងកម្ទេចថ្ម ផងដែរ ហើយដូចគ្នានឹងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដទៃទៀតដែរ អាចនឹងច្រេះស៊ីទៅតាមអាយុកាល និងពិបាកសម្គាល់ដឹង។ គ្រាប់មូលភាគច្រើន ផ្ទុករំសេវផ្ទុះខ្លាំង ប៉ុន្តែគ្រាប់មួយចំនួនអាចផ្ទុកផូស្វ័រពណ៌ស ឬថែមទាំងអាវុធគីមី និងជីវសាស្រ្ត ទៀតផង។ គ្រាប់កាំភ្លើងធំមូល ក៏អាចមានផ្ទុកគ្រាប់បែកចង្កោម ដូចជាគ្រាប់បែកតូចៗផងដែរ។ គ្រាប់មូលបាញ់រថក្រោះ អាចផលិតពីអ៊ុយរ៉ានីញ៉ូមរឹង។

ត្រូវប្រយ័ត្នផងដែរថា ដោយសារតែការរមួល យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះក៏នឹងបាត់បង់ពណ៌មួយភាគធំរបស់វាផងដែរ នៅពេលប៉ះទង្គិចនៅលើដី។ ច្រេះ និងធូលីធ្វើឲ្យយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះមើលកាន់តែដូចគ្នានឹងថ្ម ជាជាងគ្រាប់រំសេវ។ ហាមប៉ះពាល់វត្ថុដែលគួរឲ្យសង្ស័យ។

គ្រាប់កាំភ្លើងធំមូលមិនទាន់ផ្ទុះ ឬដែលគេបោះបង់ចោល អាចធ្វើជារំសេវសំខាន់របស់គ្រឿងផ្ទុះកៃច្នៃ។

## 1.2.6 គ្រាប់បែក

គ្រាប់បែក គឺជាគ្រឿងផ្ទុះមួយប្រភេទដែលជាធម្មតាគេទម្លាក់វាពីលើយន្តហោះ ប៉ុន្តែគេដឹងថាវាត្រូវបានបម្លែងទៅជាក្បាលគ្រាប់របស់គ្រាប់រ៉ុក្កែតកាំភ្លើងធំ[11]។ គ្រាប់បែក មានរូបរាង និងទំហំខុសៗគ្នាជាច្រើន។

តាមធម្មតា គ្រាប់បែកត្រូវបានផលិតពីលោហៈ ហើយមានរាងកោងរលោងដែលតាមធម្មតាគឺរាងជាឌីណាមិកអាកាស។ គ្រាប់បែកដែលទម្លាក់ពីលើអាកាស អាចមានលំដាប់ទំហំចាប់ពី 25 គក្រ ដល់ 5,000 គក្រ ហើយអាចមានប្រវែងរហូតដល់បីម៉ែត្រកន្លះ (ប្រហែល 12 ហ្វីត)។ ជាទូទៅ វាមានពណ៌ប្រផេះ បៃតង ឬត្នោត។ ភាគច្រើន គ្រាប់បែកមានផ្ទុកទៅដោយរំសេវផ្ទុះខ្លាំង ប៉ុន្តែអាចមានទម្ងន់ផ្សេងៗ ដូចជា សំណុំដែលមានពិល ភ្នាក់ងារគីមី ឬផូស្វ័រពណ៌សជាដើម។

[11] KREMA I, KREMA II និង KREMA IV ជាមួយគ្រាប់បែកធុនចាប់ពី 50 ផោនដ៍ រហូតដល់ 500 ផោនដ៍





រូបភាពទី 1.30
កាណុងបាញ់គ្រាប់រ៉ុក្កែតធុន 122 មមដែលគេបោះបង់ចោល មានផ្ទុកគ្រាប់ដោយផ្នែក នៅអាហ្វហ្គានីស្ថាន។ រូបថតរបស់ UNMAS/Thomas Enke

រូបភាពទី 1.31
ការអប់រំអំពីហានិភ័យនៃគ្រាប់បែកធម្មតានៅតំបន់រ៉ាចាហ្វ (Rejaf) ប្រទេសស៊ូដង់ខាងត្បូង។ រូបថតរបស់ UN/JC McIlwaine

ដូចគ្នានឹងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះផ្សេងទៀតដែរ គ្រាប់បែកសឹករេចរិលទៅតាមអាយុកាល និងការប៉ះនឹងសមាសធាតុមួយចំនួន។ វាអាចច្រេះស៊ី ហើយប្រែពណ៌ បាំងបាត់ដោយផ្នែក ដោយសារដោយសារធូលីដី និងកម្ទេចកម្ទី។

សញ្ញាជាទូទៅរបស់សកម្មភាពបំផ្ទុះគ្រាប់បែករួមមានដូចជា ក្រហូងដីធំៗជាដើម។ គ្រាប់បែកមិនទាន់ផ្ទុះ អាចឃើញមាននៅលើ ឬក្រោមដី។ វាអាចទម្លុះរហូតដល់ជម្រៅ 35 ម៉ែត្រ ចូលទៅក្នុងដីដោយមិនផ្ទុះ។

## 1.2.7 គីប/ឆ្នួន

គីប/ឆ្នួនគឺជាធាតុផ្សំនៃគ្រាប់រំសេវដំណើរការមុខងារដែលអនុញ្ញាតឲ្យគ្រាប់រំសេវផ្ទុះ ឬដំណើរការមុខងារតាមការរចនានៅពេលមានការប្រើប្រាស់។ ប្រភេទសំខាន់ៗនៃគីប/ឆ្នួនមានដូចជា៖

- គីប/ឆ្នួនប៉ះទង្គិច (ចំណុចផ្ទុះ)
- គីប/ឆ្នួនកំណត់ម៉ោង និង
- គីប/ឆ្នួននៅជិត។

គីប/ឆ្នួនអាច ឬមិនអាចមានលក្ខណៈបំផ្លាញដោយខ្លួនឯង។ អាចមានការរួមបញ្ចូលគ្នាជាច្រើន ឧ. គីប/ឆ្នួនដែលមានមុខងារកំណត់ម៉ោង និងប៉ះទង្គិច។

គីប/ឆ្នួនត្រូវបានបំពាក់សម្រាប់វត្ថុបំពេញចន្លោះគ្រាប់ប្រភេទដែលមាននៅក្នុងគ្រាប់រំសេវ។ វាបង្កើតបានជាចុង ឬ"ច្រមុះ" របស់គ្រាប់កាំភ្លើងត្បាល់ ឬគ្រាប់កាំភ្លើងត្បាល់មូលដែលមានសណ្ឋានដូចគ្នានឹងកោណ។ គីប/ឆ្នួនធ្វើឲ្យផ្ទុះបាស នឹងត្រូវបានគេប្រើនៅក្នុងគ្រាប់រំសេវទម្លុះ ដូចជាគ្រាប់បែកទម្លុះជ្រៅ ឬរំសេវមានរាងដែលផ្ទុកនៅក្នុងគ្រាប់រំសេវប្រឆាំងរថក្រោះជាដើម។ នៅក្នុងករណីគ្រាប់មីន វាអាចជា "គម្រប" រាងមូលតូចមួយដែលស្ថិតនៅផ្នែកខាងលើ ឬខាងក្នុងគ្រាប់មីន។ គីប/ឆ្នួនអាចមានវ៉ែស្ស៊ុរ និងកន្លាស់ដែលអាចមើលឃើញ។

## តើអ្នកដឹងទេ?

ការប្រើអន្ទាក់/គ្រាប់បែកបង្កៃ ត្រូវបានធ្វើនិយ័តកម្មដោយច្បាប់មនុស្សធម៌អន្តរជាតិ។ ពិធីសារទី II នៃអនុសញ្ញាស្តីពីគ្រឿងសព្វាវុធធម្មតាមួយចំនួន (CCW) រៀបរាប់អំពីស្ថានភាពដែលគ្រឿងផ្ទុះទាំងនេះមិនអាចប្រើប្រាស់បាន និងចែងអំពីបទបញ្ញត្តិទាំងឡាយស្តីពីការកត់ត្រា និងការដោះអន្ទាក់/គ្រាប់បែកបង្កៃក្រោយពីប្រទូសរ៉ាយបានបញ្ចប់។



រូបភាពទី 1.32
គ្រឿងផ្ទុះកែច្នៃដែលធ្វើពីឆ្នាំងដាំបាយ
នៅអាហ្វហ្កានីស្ថាន។
រូបថតរបស់ UNMAS/Thomas Enke

គីប/ផ្ទួនអាចនៅដាច់តែឯងពីគ្រឿងផ្ទុះ ឬគ្រាប់រំសេវសំខាន់របស់វា ហើយជាធម្មតាតែងតែបន្សល់ទុកនៅពាសវាលពាសកាល។ គីប/ផ្ទួន អាចមានទំហំតូច ប៉ុន្តែអាចបង្កឲ្យមានគ្រោះថ្នាក់ ហើយថែមទាំងបណ្ដាលឲ្យមនុស្សស្លាប់បាន។

គីប/ផ្ទួន អាចមានទំហំតូច ឬធំ ហើយដំណើរការតាមគោលការណ៍ខុសៗគ្នាមួយចំនួន៖ សម្ពាធ ការបញ្ចេញសម្ពាធ រង្វិល ឬលំងាកមេកានិច រំញោចដោយភ្លើង រំញោចដោយកម្ដៅ។ល។ ជាមួយនឹងរូបរាង និងពណ៌ខុសៗគ្នា គីប/ផ្ទួនពុំបង្ហាញឲ្យឃើញនូវគ្រោះថ្នាក់ភ្លាមៗឡើយ ប៉ុន្តែអាចមើលស្គាល់បានថាជាគ្រឿងបរិក្ខារយោធាណាមួយ។ តាមធម្មតា វាផលិតពីលោហៈ និងមានពណ៌ដូចលោហៈ ប៉ុន្តែក៏អាចមានពណ៌បៃតង ត្នោត និងពណ៌យោធាផ្សេងៗទៀតដែរ។

## 1.3 យុទ្ធភ័ណ្ឌដែលគេបោះបង់ចោល

ទីតាំងក្រោយមានជម្លោះ អាចជាទីតាំងលាក់អាវុធ និងឃ្លាំងទុកសព្វាវុធ ឬកន្លែងចាក់សំរាមដែលពោរពេញទៅដោយយុទ្ធភ័ណ្ឌដែលគេបោះបង់ចោល (AO)។ យុទ្ធភ័ណ្ឌដែលគេបោះបង់ចោល គឺជាយុទ្ធភ័ណ្ឌដែលនៅពុំទាន់បានប្រើប្រាស់ ប៉ុន្តែលែងស្ថិតក្រោមការគ្រប់គ្រងដោយកងកម្លាំងណាមួយហើយ។ យុទ្ធភ័ណ្ឌដែលគេបោះបង់ចោល រួមមានជាអាទិ៍ដូចជា គ្រាប់រំសេវគ្រប់ប្រភេទដូចជា គ្រាប់កាំភ្លើងត្បាល់មូល គ្រាប់បែកដៃ គ្រាប់បែក គ្រាប់រ៉ុក្កែត គ្រាប់កាំភ្លើងធំមូល ។ល។

សំបកយុទ្ធភ័ណ្ឌដែលគេបោះបង់ចោល និងគ្រាប់បែកដែលគេបានស្តុកទុកដោយពុំសូវមានការរក្សាសន្តិសុខ ឬការថែទាំបានល្អ ជួនកាលមាននៅក្នុង ឬនៅជិតសហគមន៍ នៅក្នុងអគារយោធា អគារសាធារណៈ សាលារៀន ផ្ទះ។ល។ អាចនាំឲ្យមានការផ្ទុះដែលបង្កជាគ្រោះមហន្តរាយ។ គ្រាប់បែកដែលត្រូវបានគេបានរក្សាទុក ឬថែទាំពុំសូវបានល្អ អាចកាន់តែងាយរងរំញោច ហើយផ្ទុះភ្លាមៗ។ អវត្តមាននៃបង្គោលការពាររន្ធះ ឬការគ្រប់គ្រងសុវត្ថិភាព សីតុណ្ហភាព និង





រូបភាពទី 1.33
ឧបករណ៍ប្រឆាំងការប៉ះពាល់ដោយដៃ៖ គ្រាប់បែកដៃ ត្រូវបានគេដាក់នៅពីក្រោមស្នឹងមីនជះអំបែងនេះ។ គ្រាន់តែប្រាប់ឲ្យទាហាន ឬអ្នកបោសសម្អាតមីនជួយដោះគីប/ផ្ទួនមីន និងទាញស្នឹងដែលគាត់នឹងធ្វើឲ្យសកម្មគ្រាប់បែកដៃ នៅបាល់កង់។
រូបថត/កងកម្លាំងអាល្លឺម៉ង់

រូបភាពទី 1.34
អ្នកដែលចូលទៅក្នុងបន្ទប់នេះកាត់តាមទ្វារ នឹងធ្វើឲ្យសកម្មគ្រាប់បែកដៃដែលតភ្ជាប់ជាមួយនឹងខ្សែអន្ទាក់/គ្រាប់បែកបង្កៃ នៅបាល់កង់។
រូបថត/កងកម្លាំងអាល្លឺម៉ង់

សំណើមខ្ពស់ សុទ្ធតែអាចបង្កើននូវហានិភ័យនាំឲ្យការផ្ទុះអាចកើតឡើង។ កម្តៅដ៏ខ្លាំងចេញពីភ្លើង ក៏អាចបណ្តាលឲ្យយុទ្ធភ័ណ្ឌដែលគេបោះបង់ចោលផ្ទុះបានដែរ។ សំបកយុទ្ធភ័ណ្ឌតូចៗដែលគេបោះបង់ចោល អាចបន្តរកឃើញក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយពីបានបញ្ចប់ជម្លោះ។ ឧទាហរណ៍ នៅប្រទេសកម្ពុជា សំបកយុទ្ធភ័ណ្ឌតូចៗដែលគេបោះបង់ចោល បំភ្លេចចោល ឬបាត់បង់ នៅតែមានការបន្តរកឃើញក្នុងរយៈពេលជាង 30 ឆ្នាំកន្លងមកនេះនៅឡើយ។

ការពង្រាយអាជ្ញាធរឲ្យទៅរក្សាសន្តិសុខនៅទីតាំងទាំងនេះ គឺជារឿងសំខាន់ ប៉ុន្តែពិបាកនឹងធ្វើបានក្នុងរយៈពេលខ្លី។ ការបោះចោល ឬការរក្សាសន្តិសុខយុទ្ធភ័ណ្ឌដែលគេបោះបង់ចោលក្នុងបរិមាណដ៏ច្រើន ក៏មានភាពស្មុគស្មាញផងដែរ ហើយជាធម្មតាគឺជាទំនួលខុសត្រូវរបស់កងកម្លាំងរក្សាសន្តិសុខ។ ការងារនេះអាចស្ថិតក្រៅទំនួលខុសត្រូវរបស់កម្មវិធីសកម្មភាពកម្ចាត់មីនដែលមានលក្ខណៈស្តង់ដា។

រថយន្ត សព្វាវុធរបស់យោធាដែលគេបោះបង់ចោល (ដូចជា កាំភ្លើងធំ និងរថក្រោះ) និងអគារទាំងឡាយ ក៏អាចមានផ្ទុកនូវយុទ្ធភ័ណ្ឌដែលគេបោះបង់ចោល ឥន្ធនៈគ្រាប់រ៉ុក្កែត និងគ្រឿងផ្សំដែលហើរខ្លាំងបំផុតផងដែរ ដូចជា សារធាតុគីមី និងអ៊ុយរ៉ានីញ៉ូមរឹងជាដើម។ បន្ថែមពីលើគ្រោះថ្នាក់នៃគ្រាប់រំសេវ គេក៏ត្រូវរក្សាសន្តិសុខសព្វាវុធ និងសំបកគ្រាប់រំសេវដែលមានអន្ទាក់/គ្រាប់បែកបង្កៃផងដែរ។



រូបភាពទី 1.35
គ្រាប់បែកប្រើកាំភ្លើងបាញ់បញ្ចូនកែច្នៃ និងគ្រាប់បែកដៃដែលធ្វើពីសំបកគ្មានរំសេវ នៅតំបន់បាល់កង់។ រូបថតរបស់ UNMAS/Thomas Enke

## 1.4 គ្រឿងផ្ទុះកែច្នៃ និងអន្ទាក់/គ្រាប់បែកបង្កៃ

គ្រឿងផ្ទុះកែច្នៃ គឺជាគ្រឿងផ្ទុះដាក់ដោយដៃ តាមធម្មតាគេផលិតវានៅតាមផ្ទះ ហើយយកតាមលំនាំមួយចំនួនដើម្បីសម្លាប់ បង្ករបួសស្នាម បង្កការខូចខាតដល់ទ្រព្យសម្បត្តិ ឬបង្កភេរវកម្ម។ ជារឿយៗ យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ឬគ្រាប់បែកដែល

**បើអ្នកនៅមិនបានទម្លាក់វាចុះក្រោមទេនោះ កុំលើកវាឡើងវិញ! ត្រូវប្រយ័ត្នវត្ថុដែលគួរឲ្យចាប់អារម្មណ៍ក្រៅពីផ្លូវថ្នល់។**

# 1.4 គ្រឿងផ្ទុះកែច្នៃ និងអន្ទាក់/គ្រាប់បែកបង្កៃ

គេបោះបង់ចោល ត្រូវបានកែតម្រូវដើម្បីបង្កើតបានជាគ្រឿងផ្ទុះកែច្នៃដែលបន្ទាប់មកអាចបំផ្ទុះដោយចៃដន្យដោយជនរងគ្រោះ ដោយមធ្យោបាយបញ្ជាពីចម្ងាយ (គ្រប់គ្រងដោយវិទ្យុ ខ្សែបញ្ជា។ល។) ឬជាការវាយប្រហារអត្តឃាត។

អន្ទាក់/គ្រាប់បែកបង្កៃ គឺជាគ្រឿងផ្ទុះ ឬគ្រឿងមិនផ្ទុះមួយដែលគោលបំណងគឺដាក់ដើម្បីបង្កឲ្យមានមនុស្សរងគ្រោះ នៅពេលវត្ថុដែលមើលទៅហាក់ដូចជាគ្មានគ្រោះថ្នាក់មានគេមករំខាន ឬធ្វើសកម្មភាពសុវត្ថិភាពតាមធម្មតា ដូចជា បើកទ្វារ ឬបើកទូរទស្សន៍។ អន្ទាក់/គ្រាប់បែកបង្កៃ ដែលជារឿយៗប្រតិបត្តិការដោយជនរងគ្រោះ គឺជាវត្ថុសាមញ្ញដែលគេឃើញនៅកន្លែងខុសពីប្រក្រតី ឬនិយាយម្យ៉ាងទៀតថា វាស្ថិតនៅខុសកន្លែងដើម។

ជារឿយៗ គ្រឿងផ្ទុះកែច្នៃ និងអន្ទាក់/គ្រាប់បែកបង្កៃត្រូវបានបង្កើតឡើងដោយកងកម្លាំងយោធាជាគូបដិបក្ខដែលអាចមានសព្វាវុធតិចតួច ឬអ្នកដែលចង់រារាំងមិនឲ្យមានការវាយប្រហារមកលើខ្លួន។ ជួនកាល គេដាក់វាដោយមានចេតនាបង្កគ្រោះថ្នាក់ ឬប្រួសស្នាមចំពោះអ្នកប្រយុទ្ធ និងអ្នកអ្នកមិនមានតួនាទីប្រយុទ្ធ ដោយលាក់ទុកនៅក្នុងរថយន្ត នៅតាមគែមផ្លូវ ឬនៅក្នុងផ្ទះរបស់អ្នកណាម្នាក់។ល។

ការប្រើប្រាស់រំសេវផ្ទុះផលិតនៅផ្ទះ (HME) បអាចបង្កើនគ្រោះថ្នាក់របស់គ្រឿងផ្ទុះកែច្នៃបន្ថែមទៀត។ ជាទូទៅរំសេវផ្ទុះផលិតនៅផ្ទះ ងាយរងរំញោចដោយសារការកកិត និងជាប់បានយូរជាងរំសេវផ្ទុះដែលលក់លើទីផ្សារ ឬរំសេវផ្ទុះរបស់យោធា។ ដោយសារពុំមានវត្ថុធាតុដើម និងឧបករណ៍សមស្រប ការផលិតគ្រឿងផ្ទុះកែច្នៃ ពុំ

# 1.4 គ្រឿងផ្ទុះកែច្នៃ និងអន្ទាក់/គ្រាប់បែកបង្កៃ

មានស្តង់ដារសុវត្ថិភាពដូចគ្រាប់រំសេវដែលបានផលិតជាលក្ខណៈឧស្សាហកម្មឡើយ។ មិនត្រូវចូលទៅជិត ប៉ះពាល់ ឬកកាយរុករើលេងជាមួយអន្ទាក់/គ្រាប់បែកបង្កៃ ឬគ្រឿងផ្ទុះកែច្នៃឡើយ។

វត្ថុស្ទើរតែទាំងអស់ អាចយកមកធ្វើជាអន្ទាក់/គ្រាប់បែកបង្កៃ ឬជាគ្រឿងផ្ទុះកែច្នៃ។ មិនអាចធ្វើជាអន្ទាក់/គ្រាប់បែកបង្កៃ ដើម្បីធ្វើឲ្យការយកវាចេញកាន់តែពិបាក។ អន្ទាក់/គ្រាប់បែកបង្កៃ និងគ្រឿងផ្ទុះកែច្នៃ អាចឃើញមាននៅគ្រប់ទីកន្លែង ហើយអាចមើលទៅដូចជាវត្ថុធម្មតាដែរ។ សូម្បីតែសាកសពក៏ដោយ ក៏គេអាចយកមកធ្វើជាអន្ទាក់/គ្រាប់បែកបង្កៃបានផងដែរ ដោយមានចេតនាបង្ករបួសស្នាមចំពោះអ្នកដែលប៉ុនប៉ងយកវាចេញ។ តាមធម្មតា អន្ទាក់/គ្រាប់បែកបង្កៃ និងគ្រឿងផ្ទុះកែច្នៃ មានគោលបំណងមិនឲ្យគេរកឃើញ។ វាត្រូវបានរចនាឡើងដើម្បីសម្លាក់អ្នកដែលមកជួយ អ្នកដែលមិនប្រយ័ត្នខ្លួន និងអ្នកដែលចង់ឃើញចង់ដឹង។

គ្រាប់កាំភ្លើងត្បាល់មូល និងគ្រាប់រំសេវផ្សេងៗទៀត អាចផលិតដោយបុគ្គលម្នាក់ៗចេញពីផលិតផលខុសៗគ្នា ដូចជា ប្រអប់គ្រាប់រំសេវទទេ គ្រាប់រំសេវខូង និងវត្ថុដែលលក់លើទីផ្សារ។ គ្រាប់កាំភ្លើងដ៏សាមញ្ញបំផុតគឺ គ្រាប់បែកដបដែលមួយផ្នែកគឺគេរចនាវាឡើងដើម្បីបាញ់គ្រាប់ដូចគ្នានឹងគ្រាប់បែកប្រើកាំភ្លើងបាញ់បញ្ជូនដែរ។ ជួនកាល វាមានការលំបាកក្នុងការកំណត់ភាពខុសគ្នារវាងវត្ថុដែលបង្កគ្រោះថ្នាក់ និងសម្ភារៈប្រើប្រាស់ធម្មតា។




ស៊ូដង់ខាងត្បូង
រូបថតរបស់ UNMAS




ផ្នែកទី 2

# ការសម្គាល់ តំបន់គ្រោះថ្នាក់

# ការសម្គាល់តំបន់គ្រោះថ្នាក់

តំបន់ដែលមានមីន ជារឿយៗតែងតែពុំអាចមើលឃើញខុសគ្នាពីតំបន់ដែលគ្មានមីន ព្រោះវាអាចពុំមានសញ្ញាព្រមានប្រាប់ជាក់លាក់ណាមួយឡើយ។ ជាគោលការណ៍ ជារឿយៗគេមិនអាចមើលឃើញមីនឡើយ។ តាមធម្មតា គេកប់ ឬលាក់វានៅក្រោមរុក្ខជាតិតូចៗ។[12] តំបន់ដែលញាំញីដោយសំណល់ជាតិផ្ទុះពីសង្គ្រាមផ្សេងៗ អាចមើលឃើញជាក់ស្ដែង ពីព្រោះវាអាចមានឃើញសំបកគ្រាប់រំសេវនៅលើដី យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។ល។ អន្ទាក់/គ្រាប់បែកបង្កៃ និងគ្រឿងផ្ទុះកៃច្នៃ ភាគច្រើនពុំអាចមើលឃើញឡើយ ប៉ុន្តែការប្រព្រឹត្តរបស់ប្រជាពលរដ្ឋ និងការស្គាល់គំនូសសញ្ញា និងស្លាកសញ្ញានៅលើដី អាចជួយដល់ការជៀសវាងពីតំបន់ដែលអាចបង្កឲ្យមានគ្រោះថ្នាក់បាន។ ផ្នែកនេះ មានគោលបំណងជួយអ្នកអានចេះសម្គាល់សញ្ញាព្រមាន និងតម្រុយនានា។ ការប្រុងប្រយ័ត្នជានិច្ច នឹងជួយដល់អ្នកក្នុងការកំណត់អត្តសញ្ញាណ និងជៀសវាងពីតំបន់ដែលអាចបង្កគ្រោះថ្នាក់។

## 2.1 សញ្ញាព្រមាន

តាមធម្មតា អ្នកដែលដាក់មីនពុំបានបន្សល់ទុកសញ្ញាច្បាស់លាស់ដើម្បីសម្គាល់វត្តមានមីនឡើយ ប៉ុន្តែអ្នកផ្សេងទៀតអាចបន្សល់ទុកនូវសញ្ញាបណ្ដោះអាសន្នមួយជាការព្រមានសម្រាប់អ្នកដទៃទៀត ឬភ្នាក់ងារបោសសម្អាតមីន អាចនឹងលើកស្លាកសញ្ញាជាផ្លូវការ។

អ្នកត្រូវដឹងពីប្រភេទសាមញ្ញបំផុតនៃសញ្ញាព្រមានដែលប្រើប្រាស់នៅតំបន់ដែលអ្នករស់នៅ និងធ្វើការ ហើយជានិច្ចកាលត្រូវរំពៃរកមើលសញ្ញាទាំងនេះ។ ប៉ុន្តែ

[12] ផ្នែកទី 2-3 យកលំនាំតាមម៉ូឌុលបណ្ដុះបណ្ដាលរបស់អង្គការសហប្រជាជាតិសម្រាប់អ្នកសម្របសម្រួល និងប្រធានកម្មវិធីសហគមន៍យល់ដឹងពីមីន អង្គការ UNICEF ឆ្នាំ 1999 ដែលបានកែសម្រួល ពី UNMAS ឆ្នាំ 2015។

## តើអ្នកដឹងទេ?

កងកម្លាំងប្រដាប់អាវុធ ត្រូវកត់ត្រានូវចម្ការមីន តំបន់ដែលបានដាក់មីន មីន និងអន្ទាក់/គ្រាប់បែកបង្កៃទាំងអស់ក្រោមពិធីសារទី II នៃអនុសញ្ញាស្ដីពីគ្រឿងសព្វាវុធធម្មតាមួយចំនួន។ អនុសញ្ញាហាមឃាត់មីន និងពិធីសារទី V នៃអនុសញ្ញាស្ដីពីគ្រឿងសព្វាវុធធម្មតាមួយចំនួនក៏មានរៀបរាប់ផងដែរនូវវិធានការទាំងឡាយសម្រាប់កត់ត្រា និងដាក់សញ្ញាសម្គាល់តំបន់ដែលបានដាក់មីនមុនពេលធ្វើការបោសសម្អាតមីន។



រូបថតរបស់ UN



រូបថត/កងកម្លាំងអាល្លឺម៉ង់



រូបថត/កងកម្លាំងអាល្លឺម៉ង់

# 2.1 សញ្ញាព្រមាន

2.1.1 សញ្ញាព្រមានប្រាប់ជាផ្លូវការ

កង្វះសញ្ញាព្រមានច្បាស់លាស់ ពុំមែនមានន័យថា តំបន់ទាំងនោះមានសុវត្ថិភាពពីមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ សំណល់ជាតិផ្ទុះពីសង្គ្រាម អន្ទាក់/គ្រាប់បែកបង្កៃ ឬគ្រឿងផ្ទុះកែច្នៃឡើយ។ ជួនកាលមានអ្នកយកសញ្ញាព្រមានចេញ សញ្ញានោះអាចត្រូវបានដាក់ជាបណ្ដោះអាសន្ន អាចពុំមានគេថែរក្សា ឬអាចពុំមានសញ្ញាព្រមានពីដំបូងតែម្ដង។

## 2.1.1 សញ្ញាព្រមានប្រាប់ជាផ្លូវការ

ជួនកាល អ្នកនឹងឃើញសញ្ញាព្រមានប្រាប់ជាផ្លូវការដែលបានលើកឡើងដោយរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល (NGO) ទីភ្នាក់ងារអង្គការសហប្រជាជាតិ ឬដោយអង្គការណាមួយផ្សេងទៀត ដើម្បីព្រមានប្រាប់អ្នកថា មីន ឬគ្រោះថ្នាក់នៃគ្រឿងផ្ទុះផ្សេងទៀតមាននៅតំបន់នោះ។ សញ្ញាព្រមានទាំងនេះ អាចមានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ប៉ុន្តែតាមធម្មតាមានពណ៌ក្រហមភ្លឺ មានរាងបួនជ្រុង ឬរាងជាត្រីកោណ ហើយធ្វើពីលោហៈ បេតុង ឈើ ឬផ្លាស្ទិក។ វិធីដ៏សាមញ្ញបំផុតក្នុងការដាក់សញ្ញាសម្គាល់តំបន់ដែលប៉ះពាល់ដោយប្រើមីន ឬសំណល់ជាតិផ្ទុះពីសង្គ្រាមដោយប្រើសញ្ញាព្រមានប្រាប់ជាផ្លូវការមានដូចតទៅ៖

- សញ្ញាក្បាលខ្មោចដែលមានពណ៌ក្រហម និង ស កម្រមានពណ៌លឿង និងពណ៌ខ្មៅណាស់ ហើយជារឿយៗមានពាក្យថា៖ “ប្រយ័ត្នគ្រាប់មីន” ជាភាសាអង់គ្លេស និង/ឬជាភាសាក្នុងស្រុក
- ពាក្យថា៖ “មីន” ឬ“គ្រឿងផ្ទុះ” ជាភាសាអង់គ្លេស និង/ឬជាភាសាក្នុងស្រុក
- ខ្សែ ឬស្កុត តាមធម្មតាមានពណ៌លឿង ក្រហម ឬខៀវ
- ស្លាករាងត្រីកោណមានពណ៌ក្រហម ជួនកាលមានចំណុចពណ៌ខ្មៅ ឬពាក្យថា៖ “មីន” នៅចំកណ្ដាល និង
- បង្គោលបេតុង ឬឈើ ម្ខាងលាបពណ៌ក្រហម និងម្ខាងទៀតពណ៌ស។ ផ្នែកដែលមានលាបពណ៌ក្រហម បញ្ជាក់ថាជាផ្នែកដែលមានគ្រោះថ្នាក់។



រូបថតរបស់ UN


រូបថតរបស់ UN


រូបថតរបស់ UNMAS


រូបថតរបស់ UNMAS/Thomas Enke


រូបថតរបស់ UNMAS/Thomas Enke

រូបភាពទី 2.1
សញ្ញាមីនផ្លូវការ។

កងទ័ពជម្មតា ជួនកាលប្រើខ្សែលួសបន្លា ឬរបងខ្ពស់ៗដើម្បីខ័ណ្ឌចែកតំបន់សំខាន់ៗដែលមានផលប្រយោជន៍ផ្នែកយោធា ជាពិសេសនៅជុំវិញចំណុចយុទ្ធសាស្ត្រអចិន្ត្រៃយ៍ ដូចជា ព្រលានយន្តហោះ ឬឃ្លាំងគ្រាប់រំសេវជាដើម។ លើសពីនេះទៀត របងទាំងនេះអាចការពារបានដោយប្រើមីន។

ករណីពុំមានសម្ភារសមស្របសម្រាប់ធ្វើជាសញ្ញាព្រមានប្រាប់ជាផ្លូវការទេ គួររកសម្ភារដែលមានការកែច្នៃជាងនេះ។ ថ្មដែលមានលាបពណ៌ក្រហម ឬខៀវ ក៏អាចជាសញ្ញាព្រមានច្បាស់ផងដែរ។

សញ្ញាព្រមានទាំងអស់ អាចរងការទ្រុឌទ្រោមទៅតាមពេលវេលា មានន័យថាអ្នកត្រូវតែមានការប្រុងប្រយ័ត្នជានិច្ច។ សញ្ញាទាំងនោះអាចដួលរលំ ច្រេះស៊ីអស់ ឬមានរុក្ខជាតិ ឬព្រិល (តាមរដូវ) គ្របជិត។ គ្រឿងសំណង់អន់ៗ ព្រមទាំងថ្នាំដែលមានគុណភាពទាប តែងតែធ្វើឲ្យសញ្ញាទាំងនោះរបូតធ្លាក់ បាក់បែក ឬសាកពណ៌យ៉ាងអាក្រក់។ សញ្ញាទាំងនោះក៏អាចមានអ្នកលួចយក ឬពុំមានការថែទាំ ឬដាក់ជំនួសថ្មីឲ្យបានត្រឹមត្រូវផងដែរ។

កម្មវិធីសកម្មភាពមីន គួរប្រើខ្សែលួសបន្លា ឬរបង ដើម្បីព្រមានប្រាប់ជាមុន និងរក្សាកុំឲ្យប្រជាពលរដ្ឋក្នុងមូលដ្ឋានចូលទៅកាន់តំបន់គ្រោះថ្នាក់។

## 2.1.2 សញ្ញាព្រមានប្រាប់ មិនផ្លូវការ (កែច្នៃ)

បន្ថែមពីលើសញ្ញាផ្លូវការដែលបានរចនាឡើងដើម្បីព្រមានប្រជាពលរដ្ឋ កងទ័ព និងអ្នកទទួលខុសត្រូវផ្លូវការដទៃទៀត អាចប្រើប្រាស់សញ្ញាបញ្ជាក់ប្រាប់អំពីតំបន់ដែលពួកគេបានស្ទង់មើលឃើញថាមានគ្រោះថ្នាក់ និងតំបន់ដែលពួកគេមានផែនការបោសសម្អាត ឬកំពុងស្ថិតក្នុងដំណើរការបោសសម្អាត។ នៅអាហ្វហ្កានីស្ថាន តំបន់ទាំងនេះមានដាក់សញ្ញាសម្គាល់ដោយប្រើថ្មដែលលាបពណ៌ក្រហម ដើម្បីបញ្ជាក់ប្រាប់ថាជាតំបន់ដែលមិនទាន់បោសសម្អាត និងលាបពណ៌ស ដើម្បីបញ្ជាក់ប្រាប់ថាជាតំបន់ដែលបានបោសសម្អាតហើយ ដូចគ្នាដែរ អគារ ផ្លូវថ្នល់ និងដើមឈើ អាចលាបពណ៌ក្រហម ឬពណ៌ស ដោយមាន


រូបថតរបស់ UNMAS/Thomas Enke


រូបថតរបស់ UNMAS/Thomas Enke

រូបភាពទី 2.1 (ត)
សញ្ញាមីនផ្លូវការ។



រូបភាពទី 2.2
ទីតាំងយោធាមួយចំនួន មានការរក្សាសន្តិសុខដោយប្រើមីន ដែលនៅទីនេះ “របងមីន” ត្រូវបានគេឃើញមាននៅប្រទេសអាហ្វហ្កានីស្ថាន។ រូបថតរបស់ UNMAS/Thomas Enke

កូអរដោនេផែនទី និងលេខចម្ការមីនដែលបញ្ជាក់ប្រាប់ថាជាតំបន់ដែលអាចមានគ្រោះថ្នាក់ និងបានស្ទង់មើលរួចហើយ។

ករណីគ្មានសញ្ញាផ្លូវការ ប្រជាពលរដ្ឋក្នុងមូលដ្ឋានតែងតែបង្កើតបច្ចេកទេស និងសញ្ញាផ្ទាល់ខ្លួនរបស់ពួកគេសម្រាប់សម្គាល់តំបន់ដែលមានគ្រោះថ្នាក់។ បច្ចេកទេសទាំងនេះ មានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ហើយថែមទាំងមានភាពខុសគ្នាទៅតាមតំបន់ខុសៗគ្នានៅក្នុងប្រទេសតែមួយទៀតផង។ ពាក់ព័ន្ធនឹងសញ្ញាប្រើប្រាស់ក្នុងមូលដ្ឋាន ពុំមានវិធានជាក់ច្បាស់ឡើយ ហើយជារឿយៗអាចយល់បានតែចំពោះប្រជាពលរដ្ឋក្នុងមូលដ្ឋានប៉ុណ្ណោះ។ ទោះជាយ៉ាងណា សញ្ញាទាំងនេះមានសញ្ញារួមមួយចំនួនដែលតំណាងឲ្យគ្រោះថ្នាក់ដែលនៅខាងមុខ ហើយអាចមានជាអាទិ៍៖

- ក្រណាត់ ឬចង់ផ្លាស្ទិកមួយកំណាត់ចងភ្ជាប់ទៅនឹងរបង ឬដើមឈើ
- កំប៉ុងមួយនៅលើបង្គោល
- គំនរតូចៗ ឬរង្វង់នៃដុំថ្មជាច្រើន
- ថ្មក្រាលកាត់តាមផ្លូវលំ
- ស្មៅមួយគុម្ពមានចងនៅកណ្ដាល
- ឈើចងជាសញ្ញាខ្វែង រួចយកមកដាក់កាត់តាមផ្លូវ ឬដាក់នៅក្នុងដីដែលនៅជាប់នឹងផ្លូវលំនោះ
- សញ្ញាដែលបានកាត់ទៅជាបន្ទាដើមឈើ និង
- មែកឈើរយៈ

ដោយសារលក្ខណៈកែច្នៃរបស់វា ជារឿយៗសញ្ញាប្រើប្រាស់ក្នុងមូលដ្ឋានពុំបានផ្ដល់ជាតម្រុយប្រាប់អំពីទីតាំងច្បាស់លាស់ ឬលក្ខណៈជាក់លាក់នៃការគំរាមកំហែងនោះឡើយ។ ស្រមៃថា អ្នកកំពុងធ្វើដំណើរតាមបណ្ដោយផ្លូវថ្នល់ ឬផ្លូវលំមួយដែលអ្នកជួបនឹងឧបសគ្គ។ តើអ្នកធ្វើដូចម្ដេចទើបដឹងថាតើអ្នកកំពុងតែស្ថិតនៅពីមុខការគំរាមកំហែង ឬបានស្ថិតក្នុងតំបន់មានគ្រោះថ្នាក់រួចទៅហើយ? រកមើលតម្រុយប្រាប់ផ្សេងៗ និងប្រឹក្សាជាមួយប្រជាពលរដ្ឋមូលដ្ឋាន។ ជារឿយៗសញ្ញាទាំងនេះក៏អាចប្រើសម្រាប់តំណាងឲ្យគ្រោះថ្នាក់ប្រភេទផ្សេងៗទៀត




រូបភាពទី 2.3
សញ្ញាមីនក្រៅផ្លូវការដែលបានកែច្នៃ។
រូបថតរបស់ UNMAS/Thomas Enke

**ហាមចូលទៅកាន់តំបន់ដែលមានដាក់សញ្ញាសម្គាល់ ដោយសញ្ញាព្រមានប្រាប់ អំពីមីន ខ្សែលួស ឬស្លាក! ជានិច្ចកាល ត្រូវគោរពសញ្ញាព្រមានប្រាប់អំពីមីន!**

**ធ្វើបច្ចុប្បន្នភាពព័ត៌មានអំពីមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមរបស់អ្នកឲ្យបានទៀងទាត់។**

បានដែរ ដូចជា ស្លាកខូចខាត ជង្ហុកនៅតាមផ្លូវ។ល។ ទោះបីវាមានអត្ថន័យយ៉ាងណាក៏ដោយ សញ្ញាប្រើប្រាស់ក្នុងមូលដ្ឋានទាំងនេះសុទ្ធតែតំណាងឲ្យគ្រោះថ្នាក់ ហើយគួរមានការប្រុងប្រយ័ត្នជាប់ជានិច្ច។

## 2.2 តម្រុយព្រមានប្រាប់ជាមុន

មីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រឿងផ្ទុះកែច្នៃ អាចឃើញមាននៅតាមតំបន់ជាច្រើនប្រភេទដែលធ្លាប់មានសមរភូមិ ឬមានសារៈសំខាន់ផ្នែកយុទ្ធសាស្ត្រសម្រាប់ក្រុមប្រយុទ្ធ។ ដោយសារតែតំបន់គ្រោះថ្នាក់ភាគច្រើនពុំមានសម្គាល់ដោយសញ្ញាព្រមានប្រាប់ជាផ្លូវការ ជារឿយៗអ្នកត្រូវរកមើលតម្រុយផ្សេងៗដែលប្រាប់អ្នកថាតំបន់នោះអាចមានគ្រោះថ្នាក់។ ខាងក្រោមនេះ គឺជាសញ្ញាប្រាប់ដំណឹងមួយចំនួនសម្រាប់សម្គាល់តំបន់ដែលមានគ្រោះថ្នាក់៖

- មីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រឿងផ្ទុះកែច្នៃដែលអាចមើលឃើញ
- សញ្ញានៃការប្រយុទ្ធគ្នា ឬសកម្មភាពយោធា
- សញ្ញានៅក្នុងតំបន់ សត្វពាហនៈងាប់ វត្ថុខុសប្រក្រតី និង
- ការប្រព្រឹត្តក្នុងមូលដ្ឋាន

### 2.2.1 មីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រឿងផ្ទុះកែច្នៃដែលមើលឃើញ

#### 2.2.1.1 តែមនៃមីនដែលបានកប់ ស្នឹងលោហ: និង ស្នឹងឈើខាងក្រៅ

បន្ថែមពីលើភាពលំបាកក្នុងការមើលឃើញបំផុត (បើមិនមែនមិនអាចធ្វើទៅបាន) គេតែងតែមានចេតនាក្លែងបន្លំមីនស្ទើរជាប់ជានិច្ច និងដើម្បីឲ្យ




រូបភាពទី 2.3 (ក)
សញ្ញាមីនក្រៅផ្លូវការដែលបានកែច្នៃ។

## 2.2.1 មីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រឿងផ្ទុះកែច្នៃដែលអាចមើលឃើញ

កាន់តែពិបាកសម្គាល់ដឹង ជារឿយៗទីតាំងរបស់វាត្រូវបានគេកប់ បិទបាំងដោយស្មៅវែងៗ ឬគុម្ពោតព្រៃក្រាស់ៗ។ ទោះជាយ៉ាងណា គ្រាប់មីនដែលដាក់នៅលើដីអាចមើលឃើញបាន ក្រោយពីបានពិនិត្យពិច័យតំបន់នោះដោយប្រុងប្រយ័ត្ន។ សំណឹក ឬកម្លាំងធម្មជាតិ ក៏អាចបើកចំហឲ្យឃើញគ្រាប់មីនទាំងមូល ឬដោយផ្នែកផងដែរ។ ព្រិលអាចលាក់កំបាំងមិនឲ្យគេឃើញគ្រាប់មីន ប៉ុន្តែនៅពេលដែលព្រិលរលាយ គេនឹងអាចមើលឃើញមីនបន្តិចម្តងៗ។ ប៉ុន្តែត្រូវប្រុងប្រយ័ត្ន សំណឹក និងកម្លាំងធម្មជាតិក៏អាចមានអានុភាពកប់គ្រាប់មីនបានដែរ។ បើអ្នកកំពុងស្ថិតក្នុងតំបន់ដែលអ្នកសង្ស័យថាញាំញីដោយគ្រាប់មីន ហើយអ្នកមិនអាចមើលឃើញចំណែកណាមួយនៃវត្ថុដែលផលិតពីផ្លាស្ទិក ឬលោហៈ ហើយមិនអាចកំណត់បានថាមានសុវត្ថិភាពទេនោះ អ្នកត្រូវសន្មត់ថាតំបន់នោះគឺជាតំបន់មានមីន ឬយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។ ស្នឹងឈើ ឬស្នឹងលោហៈដែលមានប្រវែងប្រហែល 30 សម ក៏អាចបញ្ជាក់ប្រាប់ពីលទ្ធភាពមានមីនច្រើនប្រភេទលើដីមួយចំនួនផងដែរ។



រូបភាពទី 2.4
មីនប្រឆាំងមនុស្សប្រភេទស្នឹង ជួនកាលអាចមើលឃើញ សូមកត់ចំណាំខ្សែល្អួស PMR-U នៅបាល់កង់។ រូបថតរបស់ អសប

គេកម្រដាក់គ្រាប់មីននៅដាច់តែឯងណាស់ ដូច្នេះភស្តុតាងនៃមីនមួយគ្រាប់នឹងបញ្ជាក់ប្រាប់ពីលទ្ធភាពមានមីនផ្សេងៗទៀតនៅក្នុងតំបន់នោះផងដែរ។

សូមកុំព្យាយាមដាក់សញ្ញាសម្គាល់ បើអ្នកពុំទាន់បាន ទទួលការបណ្តុះបណ្តាលត្រឹមត្រូវតាមរយៈ ការហ្វឹកហាត់ជាក់ស្តែង! ជានិច្ចកាលត្រូវប្រុងប្រយ័ត្ន ចំពោះវត្ថុទាំងឡាយដែលមើលទៅ "នៅខុសពីកន្លែងដើម"! កុំ ប្រថុយនឹងគ្រោះថ្នាក់! បើ អ្នកមានការសង្ស័យណាមួយ សូម ត្រឡប់ក្រោយវិញ!

### 2.2.1.2 យុទ្ធភ័ណ្ឌដែលគេបោះបង់ចោល និងមិនទាន់ផ្ទុះ

តំបន់ដែលញាំញីដោយយុទ្ធភ័ណ្ឌដែលគេបោះបង់ចោល និងមិនទាន់ផ្ទុះ ក៏អាចមើលឃើញជាក់ស្តែងច្រើនជាងតំបន់ដែលរងផលប៉ះពាល់ដោយមីនផងដែរ ប៉ុន្តែវត្តមាននៃគ្រឿងផ្ទុះទាំងនេះតែងតែបញ្ជាក់ប្រាប់ពីវត្តមាននៃមីនផងដែរ។ អ្នកអាចនឹងមើលឃើញសំបកគ្រាប់រំសេវនៅលើដី គ្រាប់កាំភ្លើងត្បាល់ ឬកាំភ្លើងធំមូលដែលមិនទាន់ផ្ទុះ និងគ្រាប់បែក ប្រអប់ដែលមានផ្ទុកគ្រាប់រំសេវ និងសព្វាវុធដែលមិនទាន់បានប្រើប្រាស់។ ទាំងនេះគឺជាសញ្ញាដែលប្រាប់ថា ធ្លាប់មានសមរភូមិកើតឡើង ហើយជាការបញ្ជាក់ប្រាប់ថា ប្រហែលជាមានមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមនៅតំបន់នោះ។

### 2.2.2.2 បំណែកខ្សែលួស ឬស្លុតដែលនៅរាយប៉ាយ

មីនប្រភេទមួយចំនួន ក៏ដូចជាគ្រឿងផ្ទុះកែច្នៃ និងអន្ទាក់/គ្រាប់បែកបង្កប្រភេទមួយចំនួន តម្រូវឲ្យប្រើខ្សែអន្ទាក់/គ្រាប់បែកបង្កៃ ឬខ្សែភ្លើង។ បើអ្នកឃើញមានបំណែកខ្សែលួសនៅរាយប៉ាយនៅក្នុងតំបន់ ដែលគេដឹងថាធ្លាប់មានការប្រយុទ្ធគ្នា វាបញ្ជាក់ប្រាប់ថាអាចមានការប្រើប្រាស់មីន គ្រឿងផ្ទុះកែច្នៃ ឬអន្ទាក់/គ្រាប់បែកបង្កៃ។ តាមធម្មតា គេតែងតែចងខ្សែអន្ទាក់/គ្រាប់បែកបង្កៃកាត់ទទឹងផ្លូវលំ ផ្លូវរថភ្លើង ផ្លូវថ្នល់ វាលស្រែ ឬតំបន់ផ្សេងៗដែលរំពឹងថាមានចរាចរណ៍ដោយថ្មើរជើង។ សូមចងចាំថា ខ្សែអន្ទាក់/គ្រាប់បែកបង្កៃពិបាកនឹងមើលឃើញខ្លាំងណាស់ ហើយដោយសារតែមិនអាចមើលវាឃើញ មិនមែនមានន័យថាគ្មានវានៅជុំវិញទីនោះឡើយ។

### 2.2.2.3 ដងមូល និងគីប/ឆ្នួន

ជួនកាល អ្នកអាចមើលឃើញដងមូល ឬគីប/ឆ្នួននៅខាងលើដី។ តាមធម្មតា ការណ៍នេះបញ្ជាក់ប្រាប់ពីវត្តមាននៃមីនប្រឆាំងរថយន្ត ប៉ុន្តែក៏អាចបញ្ជាក់ប្រាប់ថាមានមីនប្រឆាំងមនុស្សនៅក្នុងតំបន់នោះផងដែរ។

គីប/ឆ្នួនអាចនឹងដាច់ចេញពីគ្រឿងផ្ទុះ ឬគ្រាប់បែក ឬគេគ្រាន់តែទុកវាចោលនៅលើដីដោយពុំបានបំពាក់វានៅលើគ្រឿងផ្ទុះ។ គីប/ឆ្នួនអាចមានទំហំតូច ប៉ុន្តែលើសពីនេះវាពិតជានឹងមានគ្រោះថ្នាក់ ហើយអាចជាបណ្តាលឲ្យស្លាប់ថែមទៀតផង។ វាបញ្ជាក់ប្រាប់ពីការប្រយុទ្ធគ្នា វត្តមាននៃមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម។

### 2.2.2.4 សំបក កញ្ចប់ និងកម្ទេចកម្ទីដែលបន្សល់ទុកដោយយោធា

ម្តងម្កាល កងកម្លាំងរាយមីនដោយប្រញាប់ប្រញាល់ ហើយតែងតែបន្សល់ទុកកញ្ចប់ ស្លាបព្រាខ្សែអន្ទាក់/គ្រាប់បែកបង្កៃ និងកន្លាស់សុវត្ថិភាពរបស់មីន។

**ហាមចូលទៅជិត ប៉ះពាល់ ឬកកាយរុករើ លេងដោយប្រើសំណល់ជាតិផ្ទុះ ពីសង្គ្រាម!**





រូបភាពទី 2.5
គម្របគ្រាប់ធុន BLU-97 ជាសញ្ញាល្អបំផុត សម្រាប់តំបន់ដែលគ្មានសុវត្ថិភាព។ រូបថតរបស់ UNMAS/Thomas Enke

រូបភាពទី 2.6
ជារឿយៗ យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះតែងតែអាចមើលឃើញ។ នៅទីនេះ ផ្នែកដែលមានគ្រោះថ្នាក់នៃគ្រាប់កាំភ្លើងត្បាល់មូលទំហំ 82 mmធុន HE83LD ប្រទេសអាហ្វហ្គានីស្ថាន។ រូបថតរបស់ UNMAS/Thomas Enke

**នៅឲ្យឆ្ងាយពីបរិក្ខារយោធាដែលគេបោះបង់ចោល!**

បើអ្នកឃើញធុងឈើ ផ្លាស្ទិក ឬលោហៈដែលមានសញ្ញាសម្គាល់យោធានៅរាយប៉ាយ ជានិច្ចកាលត្រូវសង្ស័យថាមានមីននៅតំបន់នោះ។ ដូចគ្នាដែរ រាល់កងលោហៈតូចៗដែលមានភ្ជាប់មកជាមួយនូវកន្លាស់លោហៈមួយ គួរតែចាត់ទុកថាជាសញ្ញាប្រាប់ពីសកម្មភាពមីនដែលអាចមាននៅតំបន់នោះ។ សំបកគ្រាប់បែកចង្កោមទទេដែលរកឃើញនៅតំបន់នោះ ក៏បញ្ជាក់ប្រាប់ពីគ្រោះថ្នាក់ផងដែរ។







## 2.3 សញ្ញានៃការប្រយុទ្ធគ្នា ឬ សកម្មភាពយោធា

### 2.3.1 លេណដ្ឋាន ទំនប់ ត្រង់សេ ឬទីតាំងសមរភូមិ

តំបន់ទាំងឡាយដែលកាន់កាប់ដោយយុទ្ធជន ជាពិសេសលេណដ្ឋាន ត្រង់សេ ឬទីតាំងសមរភូមិ ក៏ទំនងជាមានការដាក់មីនធ្វើជារបាំងការពារពីការវាយប្រហារផងដែរ។ ទីកន្លែងយោធាដែលគេបោះបង់ចោល អាចមានអន្ទាក់/គ្រាប់បែកបង្កៃដាក់អន្ទាក់/គ្រាប់បែកបង្កៃ ឬបង្កៃគ្រាប់បែកដើម្បីបដិសេធការប្រើប្រាស់របស់វា។ ដូចគ្នាដែរ ពិតជានឹងអាចមានយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងយុទ្ធភ័ណ្ឌដែលគេបោះបង់ចោល។

### 2.3.2 រថយន្តស៊ីវិល និងរថយន្តយោធាដែលបានខូចខាត បោះបង់ចោល ឬបំផ្លាញចោល

រថយន្តស៊ីវិល និងរថយន្តយោធាដែលបានខូចខាត បោះបង់ចោល ឬបំផ្លាញចោល អាចបញ្ជាក់ប្រាប់ពីវត្តមាននៃយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ មីនប្រឆាំងរថយន្ត ឬមីនប្រឆាំងមនុស្សថែមទៀតផង។ នៅកន្លែងដែលមានមីនមួយគ្រាប់តាមធម្មតាក៏មានមីនផ្សេងទៀតជាច្រើនគ្រាប់ផងដែរ។ អ្នកក៏អាចប្រទះឃើញផងដែរនូវបំណែកលោហៈ ឬកម្ទេចកម្ទីដែលមើលទៅដូចគ្នានឹងលទ្ធផលនៃការផ្ទុះគ្រាប់ផងដែរ។ រថយន្តដែលគេបោះបង់ចោល ក៏អាចមានគេអន្ទាក់/គ្រាប់បែកបង្កៃដាក់អន្ទាក់/គ្រាប់បែកបង្កៃ ឬបង្កៃគ្រាប់បែកផងដែរ។ រថយន្ត

រូបភាពទី 2.7
ប្រអប់គ្រាប់រំសេវដែលបានបោះចោលនៅក្នុងផ្ទះដែលគេបោះបង់ចោល តំបន់បាល់កង់។
រូបថតរបស់ UNMAS/Thomas Enke

រូបភាពទី 2.8
លេណដ្ឋានដែលគេបោះបង់ចោល។ សូមកត់ចំណាំថា មីនជះអំបែងប្រភេទស្នឹង ម៉ាក PMR-Uដែលមានខ្សែអន្ទាក់/គ្រាប់បែកបង្កៃ តំបន់បាល់កង់។
រូបថតរបស់ UN

រូបភាពទី 2.9
សញ្ញានៃការប្រយុទ្ធគ្នា៖ សំបកគ្រាប់គ្មានរំសេវរបស់កាំភ្លើងបាញ់មិនធាក់ថយធុន 75 mm x 406 នៅតំបន់បាល់កង់។
រូបថតរបស់ UNMAS/Thomas Enke

អាចមានយុទ្ធភ័ណ្ឌដែលគេបោះបង់ចោល ឥន្ទនៈពុល ឬកាកសំណល់គីមី។ ការខូចខាតដោយអគ្គីភ័យ អាចជាការបញ្ជាក់ប្រាប់ពីគ្រាប់រំសេវដែលមានផ្ទុកអ៊ុយរ៉ានីញ៉ូមរឹង។ សំណល់រំសេវផ្ទុះមិនត្រូវមិនរាប់បញ្ចូលឡើយ។ ទាំងនេះគឺជាការបញ្ជាក់ប្រាប់យ៉ាងច្បាស់ពីគ្រោះថ្នាក់ ហើយគួរតែជៀសវាង។







## 2.3.3 សព្វាវុធដែលបានបោះចោល និងបោះបង់ចោល

សព្វាវុធដែលបានបោះចោល បញ្ជាក់ប្រាប់ពីការប្រយុទ្ធគ្នាថ្មីៗនៅតំបន់នោះ ហើយមានផ្ទុកនូវសារធាតុបង្កគ្រោះថ្នាក់ដូចគ្នានឹងរថយន្តដែលគេបោះបង់ចោល ឬបំផ្លាញចោលដែរ។ ជួនកាល មានផ្ទុកសព្វាវុធ ទុកត្រៀមសម្រាប់សម្រាប់បាញ់ ហើយគ្រាប់រំសេវអាចមានការខូចខាត។ ហាមចូលទៅជិតសព្វាវុធទាំងនេះ។

## 2.3.4 ប៉ុស្តិ៍ត្រួតពិនិត្យយោធា និង តំបន់ព្រំដែន

កាលណាក្រុមប្រយុទ្ធកាន់កាប់តំបន់ណាមួយកាន់តែយូរ ពួកគេកាន់តែទំនងក្នុងការការពារខ្លួនតាមរយៈដាក់មីននៅក្នុងតំបន់ព័ទ្ធជុំវិញជិតៗនោះ។ នៅបណ្តាប្រទេសជាច្រើន ចម្ការមីនត្រូវបានគេដាក់នៅតាមបណ្តោយព្រំដែនអន្តរជាតិ និងជួនកាលព្រំប្រទល់រដ្ឋបាលផ្ទៃក្នុង (ដូចជា ព្រំប្រទល់ខេត្ត ស្រុក) ដើម្បីទប់ស្កាត់ការលបចូល។ ជារឿយៗ តំបន់ទាំងនេះគឺជាតំបន់ចុងក្រោយដែលត្រូវបោសសម្អាតគ្រាប់មីន ជាពិសេស បើភាពតានតឹងរវាងបណ្តាប្រទេសជិតខាង ឬជម្លោះផ្ទៃក្នុងនៅពុំទាន់បានដោះស្រាយចប់ជាស្ថាពរ។

## 2.3.5 ជុំវិញអគារ និងទីតាំងយោធា

ជារឿយៗ គេប្រើប្រាស់មីនភាគច្រើនធ្វើជាសព្វាវុធការពារខ្លួន។ ដូច្នេះ អគារ ឬទីតាំងយោធា ឬតំបន់ណាមួយដែលកាន់កាប់ដោយក្រុមប្រយុទ្ធ អាចមានដាក់មីន ឬអន្ទាក់/គ្រាប់បែកបង្កៃដាក់អន្ទាក់/គ្រាប់បែកបង្កៃ ឬបង្កៃគ្រាប់បែកដើម្បីធ្វើជាវិធានការការពារប្រឆាំងនឹងការវាយប្រហារ ឬដាក់មីនក្រោយពេលកាន់កាប់

រូបភាពទី 2.10
រថក្រោះនៅសមរភូមិធំដែលគេបោះបង់ចោល មានសុវត្ថិភាពទេ? នៅអាហ្វហ្កានីស្ថាន។ រូបថតរបស់ UNMAS/Thomas Enke

រូបភាពទី 2.11
ចំណុចសង្កេតនេះ អាចមានព័ទ្ធជុំវិញដោយមីន។ រូបថតរបស់ UNMAS/Thomas Enke

រូបភាពទី 2.12
ត្រូវដឹងថា ទីកន្លែងយោធា អាចត្រូវបានពង្រឹងដោយប្រើរបង និងជាច្រើនទៀត នៅអតីតយូហ្គោស្លាវី។ រូបថតរបស់ UNMAS/Thomas Enke

ដើម្បីទប់ស្កាត់កុំឲ្យមានការប្រើប្រាស់ទីកន្លែងនោះដោយភាគីបដិបក្ខ។ របង ច្រកចូល និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗនៅក្នុងជំរុំ (ដូចជា ស្ថានីយ៍ថាមពល) អាចមានការពង្រឹងបន្ថែមដោយចម្ការមីន។ ទីកន្លែងទាំងនេះ ក៏អាចមានផ្ទុកនូវឃ្លាំងស្តុកយុទ្ធភ័ណ្ឌដែលគេបោះបង់ចោលផងដែរ។

## 2.3.6 ស្ពាន ទំនប់ និងតំបន់ជុំវិញ

មីនក៏ត្រូវបានគេប្រើប្រាស់ដើម្បីបញ្ឈប់ ឬផ្លាស់ប្តូរចលនារបស់កងកម្លាំងបដិបក្ខផងដែរ។ ការដាក់មីននៅតាមស្ពាន ទំនប់ និងតំបន់ជុំវិញ អាចរារាំងផ្លូវធ្វើដំណើររបស់ទាហានបដិបក្ខ និងរារាំងមិនឲ្យពួកគេបានប្រើប្រាស់ធនធានដែលមានតម្លៃផងដែរ។ ជាការសំខាន់ណាស់ដែលមិនត្រូវដើរជុំវិញ ឬក្រោមច្រកចូលរបស់ស្ពានដែលស្ថិតក្នុងតំបន់ដែលមានដាក់មីនច្រើន។

ជារឿយៗ គ្រឿងផ្ទុះកែច្នៃត្រូវបានគេដាក់នៅកន្លែងដែលមានឈ្មោះថា៖ "ចំណុចគ្រោះថ្នាក់ខ្លាំង"។ ចំណុចទាំងនេះ ក៏មានឈ្មោះថា៖ "ចំណុចបន្ថយល្បឿន" ផងដែរ។ ស្ពានគឺជាចំណុចបន្ថយល្បឿនដែលមានកន្លែងទំនេរជាច្រើនសម្រាប់រំសេវផ្ទុះដ៏ច្រើនសន្ធឹកសន្ធាប់ ក៏ដូចជាលូទឹកកាត់ថ្នល់ និងធាតុផ្សេងៗ

រូបភាពទី 2.13
(ឆ្វេង) ហេតុអ្វីបានជាមានរនាំងបាំងផ្លូវនេះ? ដើម្បីបង្ខំឲ្យអ្នកបើករថយន្តចុះទៅតាមដានផ្លូវលំបាក និងទៅលើដីទន់ដែលងាយស្រួលដាក់មីន។ តើអ្នកអាចមើលឃើញមីននៅចម្ងាយប្រហែលពីរម៉ែត្រខាងឆ្វេងដៃរបស់អ្នកទេ? អតីតៈយូហ្គោស្លាវី។ រូបថតរបស់ UN

រូបភាពទី 2.14
(ស្តាំ) ការប្រើគ្រាប់រំសេវធ្វើជាសម្ភារសាងសង់អគារ គឺជាវិធីទូទៅនៅតាមបណ្តាប្រទេសក្រោយមានជម្លោះ។ នៅទីនេះ គ្រាប់រ៉ុក្កែតកាំភ្លើងធំធុន 122 mm ត្រូវបានប្រើធ្វើជាធ្នឹម នៅអាហ្វហ្គានីស្ថាន។ រូបថតរបស់ UNMAS/Thomas Enke





ទៀតដែលអាចប្រើសម្រាប់ធ្វើជាសញ្ញាសម្គាល់ផងដែរ។ ពាក់ព័ន្ធនឹងខ្សែដែលមើលឃើញច្បាស់ និងចំណុចបំផ្ទុះ/បាញ់ចេញដែលមានសុវត្ថិភាព ស្ពានគឺជាទីតាំងល្អឥតខ្ចោះសម្រាប់ការវាយឆ្មក់។

## 2.3.7 ផ្លូវថ្នល់ និងផ្លូវលំ

ផ្លូវថ្នល់ និងដានផ្លូវយុទ្ធសាស្ត្រ ជារឿយៗមានគេដាក់មីនដើម្បីបញ្ឈប់ចលនារបស់កងទាហាន ឬចរាចរណ៍ពាណិជ្ជកម្ម។ ផ្លូវដែលខូចខាត ឬមានវត្ថុរាំងដំណើរ តែងតែបង្ខំឲ្យរថយន្តចុះពីផ្លូវ និងបើកនៅលើជាយផ្លូវ។ គែម និងជាយផ្លូវជួនកាលមានគេដាក់មីនដើម្បីធ្វើជាចំណុចបញ្ឈប់។ ជួនកាលកៅស៊ូក្រាលថ្នល់ត្រូវបានផ្សើមឲ្យជោគដោយប្រើប្រេងម៉ាស៊ីន ដើម្បីជីកជារណ្ដៅ និងដាក់បញ្ចូលមីន ឬគ្រឿងផ្ទុះកែច្នៃទៅក្នុងផ្លូវថ្នល់នោះ។ បំណះរាងមូលរបស់វា (ហើយអាចជាខ្សែបន្ទាត់ដែលប្រើធ្វើជាខ្សែបញ្ជា) ក៏អាចមើលឃើញនៅលើកៅស៊ូក្រាលផ្លូវនោះផងដែរ។ ស្រដៀងគ្នានេះដែរ ផ្លូវលំតូចៗដែលកាត់ទទឹងតំបន់ជម្លោះ ក៏អាចត្រូវបានគេដាក់មីនផងដែរ។

កំណាត់ផ្លូវចង្អៀត គឺជាចំណុចបន្ថយល្បឿន (ដូចជា ផ្លូវកែងមើលមិនឃើញម្ខាងទៀត) ផ្លូវតូចចង្អៀត និងផ្លូវលំដែលមានរុក្ខជាតិដុះក្រាស់ឃ្មឹក ឬថ្មជាច្រើន។ ពាក់ព័ន្ធនឹងខ្សែដែលមើលឃើញច្បាស់ និងចំណុចបំផ្ទុះ/បាញ់ចេញដែលមានសុវត្ថិភាព កំណាត់ផ្លូវចង្អៀត គឺជាទីតាំងល្អឥតខ្ចោះសម្រាប់ការវាយឆ្មក់។

## 2.3.8 ព្រលានយន្តហោះ និងផ្លូវរថភ្លើង

ដូចគ្នានឹងករណីស្ពានដែរ ព្រលានយន្តហោះ និងផ្លូវរថភ្លើង គឺជាមធ្យោបាយដឹកជញ្ជូនសំខាន់ៗ និងជាតំបន់យុទ្ធសាស្ត្រគន្លឹះសម្រាប់យោធា។ ដូច្នេះហើយ គេតែងតែដាក់មីននៅតាមកន្លែងទាំងនេះ។ របង និងសញ្ញាផ្សេងៗ អាចបាក់បែក ឬមានគេយកចេញ ទ្វាររបង និងច្រកចូលផ្លូវការត្រូវបានគេបានបោះបង់ចោល ប៉ុន្តែមានការរក្សាសន្តិសុខដោយប្រើមីន ឬអន្ទាក់/គ្រាប់បែកបង្កប់។

**កុំបើកបរ នៅលើជាយផ្លូវ។**





រូបភាពទី 2.15
ស្ពានដែលគេបោះបង់ចោល និងកន្លែងលុយឆ្លងទឹក តើមានសុវត្ថិភាពទេ? នៅបាល់កង់។
រូបថតរបស់ UNMAS/Thomas Enke

រូបភាពទី 2.16
សំបកគ្រាប់ធុន 100 mm x 695 ប្រើធ្វើជាសម្ភារសាងសង់ស្ពាន នៅអាហ្វហ្គានីស្ថាន។ រូបថតរបស់ UNMAS/Thomas Enke

## 2.3.9 ប្រព័ន្ធផ្គត់ផ្គង់ថាមពលអគ្គិសនី និងទឹក

រោងចក្រថាមពលអគ្គិសនី ខ្សែបញ្ជូនថាមពល និងអនុស្ថានីយ៍ មានសារៈសំខាន់ផ្នែកយុទ្ធសាស្ត្រយ៉ាងខ្លាំងនៅអំឡុងពេលសង្គ្រាម។ ការផ្តាច់ប្រព័ន្ធផ្គត់ផ្គង់ថាមពលរបស់ខ្មាំងសត្រូវ អាចប៉ះពាល់ធ្ងន់ធ្ងរដល់សមត្ថភាពក្នុងការចល័ត និងប្រាស្រ័យទាក់ទងគ្នា។ ដូចគ្នាដែរ ទំនប់ទឹក និងបណ្តាញចែកចាយទឹកក្នុងក្រុង អាចប្រើសម្រាប់ផ្គត់ផ្គង់ប្រជាពលរដ្ឋ ឬសម្រាប់ពន្លិចតំបន់ណាមួយដើម្បីរារាំងមិនឲ្យខ្មាំងសត្រូវចូលមកកាន់តំបន់នេះ។ ដូច្នេះ តំបន់ទាំងនេះតែងតែត្រូវបានគេការពារដោយប្រើប្រាស់មីន។

## 2.3.10 កន្លែងមានម្លប់ ដើមឈើហូបផ្លែ ប្រភពទឹក អណ្តូងទឹក និងច្រាំងទន្លេ និងច្រកចូលរូងថ្ម

ទាហាន សមាជិកកងកម្លាំងយោធាបដិបក្ខ ក៏ដូចជាជនស៊ីវិលក្នុងសមរភូមិ តែងតែរកកន្លែងមានម្លប់ ឬជម្រកពីសមាសភាពទាំងឡាយ ក៏ដូចជាដើម្បីកាត់បន្ថយភាពអាចមើលឃើញរបស់ពួកគេ។ ពួកគេក៏ព្យាយាមរក្សាសន្តិសុខផ្លូវទៅកាន់ប្រភពទឹក និងស្បៀងអាហារផងដែរ ហើយតែងតែការពារតំបន់ទាំងនេះដោយប្រើមីន។

កន្លែងដែលមានការប្រមូលផ្តុំមនុស្សច្រើនៗ ចំណុចប្រជុំដែលល្បី និងតំបន់ដែលមានកម្រិតចរាចរណ៍ខ្ពស់ អាចមានភាពសមស្របសម្រាប់ជាគោលដៅគ្រឿងផ្ទុះកែច្នៃ។

## 2.3.11 តំបន់អតិវឌ្ឍន៍

គ្រឿងសំណង់អគារ ដូចជាថ្មឹម តែងតែត្រូវបានប្រើប្រាស់ជាវត្ថុធាតុដើម។ ជួនកាល ប្រជាពលរដ្ឋប្រើសំណល់ជាតិផ្ទុះពីសង្គ្រាម ឬយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះធំៗ (ដូចជា គ្រាប់រ៉ុក្កែតកាំភ្លើងធំ ឬសំបកគ្រាប់) ធ្វើជាវត្ថុធាតុដើមសម្រាប់ថៃទាំ ឬ





រូបភាពទី 2.17
រថយន្តរបស់ អសប បុកមីនប្រឆាំងរថយន្ត នៅម៉ាលី។
រូបថតរបស់ អសប

រូបភាពទី 2.18
ផ្ទះដែលត្រូវបានបំផ្លាញចោល ឬបោះបង់ចោល អាចមានគេដាក់មីន ឬអន្ទាក់/គ្រាប់បែកបង្កប់នៅកូសូវ៉ូ។ រូបថតរបស់ UNMAS/Thomas Enke

កែលម្អអគាររបស់ពួកគេ។ ធ្នឹម ជណ្តើរ និងជញ្ជាំង សុទ្ធតែអាចផ្ទុកនូវគ្រាប់រំសេវដែលបង្កគ្រោះថ្នាក់។





## 2.4 សញ្ញានៅក្នុងតំបន់ សត្វពាហនៈងាប់ វត្ថុខុសប្រក្រតី

### 2.4.1 សញ្ញានៅលើដី៖ បម្រែបម្រួលគម្របរុក្ខជាតិ និងដី

សញ្ញានៅលើដី អាចបញ្ជាក់ប្រាប់ពីវត្តមាននៃមីន។ ពណ៌នៃរុក្ខជាតិ បង្ហាញឲ្យឃើញនូវបំណែករុក្ខជាតិស្ងួត។ នៅតំបន់ខ្សាច់ ដីអាចបង្ហាញឲ្យឃើញនូវបំណែកនៃកំណាដីធម្មតា។ បើកន្លែងនោះធ្លាប់មានចម្ការមីនមួយរយៈ អាចនឹងមានស្នាមផតចូលក្នុងបន្តិចដែលអាចមើលឃើញនៅលើមីន នៅពេលដែលដីធូរបានហាប់ណែនក្រោយពីមានភ្លៀងធ្លាក់មួយមេរួចមក។ នៅក្នុងករណីមួយចំនួន អាចឃើញមានវត្តមានពំនូកដីតូចៗដែលអាចបញ្ជាក់ប្រាប់ថាមានសកម្មភាពជីកដីថ្មីៗ ប៉ុន្តែភស្តុតាងបែបនេះនឹងបាត់ទៅវិញភ្លាមៗ។

បើមីននោះត្រូវបានគេដាក់កាលពីពេលថ្មីៗ អាចមានបំណែកស្មៅងាប់ ដោយឃើញមានដាច់ឫសស្មៅនៅពេលកប់មីន។ បើមីននោះត្រូវបានគេដាក់កាលពីពេលថ្មីៗបំផុត ដីសើមដែលគេប្រើវាដើម្បីបិទបាំងគ្រាប់មីននៅពេលកប់វា អាចមានសភាពស្រអាប់ជាងតំបន់ជុំវិញ។

ដូចគ្នាដែរ គ្រឿងផ្ទុះកែច្នៃ ក៏អាចមានគេកប់នៅជិតផ្លូវថ្នល់នៅត្រង់ចំណុចគ្រោះថ្នាក់ខ្លាំង (ចំណុចបញ្ឈប់) និងបង្ហាញឲ្យឃើញនូវសញ្ញានៅលើដីដែលស្រដៀងគ្នានេះផងដែរ។

រូបភាពទី 2.19
មិនមែនស្នាមគ្រាប់បែកផ្ទុះទាំងអស់សុទ្ធតែមានសញ្ញាព្រមានឡើយ។ នៅកន្លែងដែលមានមីនសំណល់ជាតិផ្ទុះពីសង្គ្រាម ឬគ្រឿងផ្ទុះកែច្នៃបានផ្ទុះមួយគ្រាប់ អ្នកត្រូវតែសន្មត់ថា មានមីន ឬគ្រឿងផ្ទុះផ្សេងៗទៀតនៅជិតៗ នៅអាហ្វហ្កានីស្ថាន។ រូបថតរបស់ UNMAS/Thomas Enke

រូបភាពទី 2.20
ការវាយប្រហារដោយគ្រាប់បែកចង្កោមទូទៅដែលមានយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះជាច្រើន នៅកូសូវ៉ូ។ រូបថតរបស់ UNMAS/Thomas Enke

## 2.4.2 ភូមិដែលត្រូវគេបោះបង់ចោល និង តំបន់ដែលមានរុក្ខជាតិដុះទ្រុបទ្រុល

ភូមិ និងទីក្រុងដែលត្រូវគេបោះបង់ចោល ឬវាលស្រែដែលលែងមានការប្រើប្រាស់ បញ្ជាក់ប្រាប់នូវភាពទំនងជាខ្លាំងថាមានមីន ឬសំណល់ជាតិផ្ទុះពីសង្គ្រាមនៅក្នុងតំបន់នោះ។ ក្រោយពីមានការវាយប្រហារដោយគ្រាប់បែកចង្កោម ឬការវាយប្រហារដោយកាំភ្លើងធំដែលមានគ្រាប់រំសេវគ្រាប់បែកតូចៗ តំបន់នោះនឹងត្រូវបានញាំញីដូចគ្នានឹងចម្ការមីនដែរ។

## 2.4.3 អគារ និងផ្ទះដែលគេបោះបង់ចោល និងរងការបំផ្លាញ

ជារឿយៗ ទាហាន ឬក្រុមប្រយុទ្ធរបស់កងកម្លាំងយោធាបដិបក្ខ ដាក់មីននៅតាមផ្ទះដើម្បីការពារ ឬបន្សល់ទុកនូវមីន ឬអន្ទាក់/គ្រាប់បែកបង្កៃនៅក្នុងផ្ទះដែលគេបោះបង់ចោល ដើម្បីបោកបញ្ឆោតទាហាន ឬយុទ្ធជនភាគីម្ខាងទៀតដែលកំពុងស្វែងរកទីជម្រក។ បើផ្ទះណាមួយរងការខូចខាត ឬរងការបំផ្លាញខ្ទេចខ្ទីដោយសារការប្រយុទ្ធគ្នា ហើយពុំមានមនុស្សរស់នៅទេនោះ មានលទ្ធភាពគ្រប់យ៉ាងដែលថា យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះក៏នៅតែមានផងដែរ។ អគារ និងផ្ទះដែលគេបោះបង់ចោល និងនៅដាច់តែឯង អាចប្រើជាកន្លែងលាក់សព្វាវុធ និងគ្រាប់រំសេវ ហើយអាចនឹងមានការរក្សាសន្តិសុខដោយប្រើមីន ឬអន្ទាក់/គ្រាប់បែកបង្កៃ។

## 2.4.4 ឈើហ៊ុប ឬមែកឈើដែលគេដាក់កាត់ទទឹងផ្លូវថ្នល់ និងផ្លូវលំ (របាំងវាយឆ្មក់)

ជួនកាល យុទ្ធជនដាក់របាំងកាត់ទទឹងផ្លូវថ្នល់ដើម្បីបញ្ឈប់រថយន្តនៅចំណុចខុសច្បាប់មួយ ឬថែមទាំងបង្ខំឲ្យពួកគេចុះពីផ្លូវទៅកាន់តំបន់ជុំវិញនោះដែលអាចមានការដាក់មីន ឬញាំញីដោយយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។





រូបភាព 2.21
អានុភាពនៃមីនប្រឆាំងរថយន្តធុន MRUD ចំពោះរថយន្ត នៅបាល់កង់។ រូបថតរបស់ UN

រូបភាពទី 2.22
ផលវិបាកនៃករណីគ្រោះថ្នាក់មីនជាមួយនឹងមីនប្រឆាំងរថយន្តធុន TM-58 នៅលើគែមផ្លូវមួយនៅអាហ្វហ្គានីស្ថាន។ រូបថតរបស់ UNMAS/Thomas Enke

ម្យ៉ាងវិញទៀត របាំងនេះអាចប្រើសម្រាប់ទប់ស្កាត់កុំឲ្យមនុស្សចូល ទៅកាន់ផ្លូវថ្នល់ ឬផ្លូវលំដែលគ្មានសុវត្ថិភាព។ ការសម្រេចចិត្តដែលមានសុវត្ថិភាព គឺត្រូវប្រើផ្លូវថ្នល់ ឬផ្លូវលំមួយផ្សេងទៀត។

## 2.4.5 ស្នាមគ្រាប់បែកផ្ទុះ

ស្នាមគ្រាប់បែកផ្ទុះ ឬសញ្ញាជាធម្មតានៃការជួសជុលនៅលើផ្លូវកៅស៊ូ អាចជាសញ្ញាដែលអាចមើលឃើញបាន តាមធម្មតាគឺសម្រាប់មីនប្រឆាំងរថយន្ត ឬសញ្ញាបង្ហាញពីសមរភូមិ។ ត្រូវមានការប្រុងប្រយ័ត្ននៅក្នុងតំបន់ជុំវិញ ពីព្រោះមីនផ្សេងទៀតអាចនៅពុំទាន់បានបោសសម្អាត ឬអាចត្រូវបានមើលរំលង។ ដោយឡែក ហាមដើរខុសផ្លូវកៅស៊ូទៅកាន់ជាយផ្លូវទន់ៗ ឬដីដែលនៅជិតគ្នានោះ។

ការផ្ទោងគ្រាប់ដោយប្រើគ្រាប់កាំភ្លើងត្បាល់មូល គ្រាប់បែក ឬប្រើគ្រាប់បែកចង្កោម ក៏បន្សល់ទុកនូវសញ្ញានៃការខូចខាតជាក់លាក់នៅលើអគារ នៅលើកៅស៊ូក្រាលថ្នល់ ឬដើមឈើ "ដែលដាច់ចុង" ផងដែរ។ ជួនកាលស្នាមជិតនៅមើលទៅដូចជាស្នាមខ្វាតមួយចូលទៅក្នុងកៅស៊ូក្រាលថ្នល់។

ការថែទាំនៅលើកៅស៊ូក្រាលថ្នល់ ឬផ្លូវថ្នល់ ក៏អាចជាស្នាមបង្កប់គ្រឿងផ្ទុះកែច្នៃប្រើខ្សែបញ្ជា (CW) ផងដែរ។  បើមានចង្អូរតូចៗបន្ថែមទៀតដែលចេញពីបំណះ "ដែលបានជួសជុល" ទៅកាន់ជាយផ្លូវថ្នល់ វាគឺជាសញ្ញាយ៉ាងច្បាស់លាស់សម្រាប់គ្រឿងផ្ទុះកែច្នៃប្រើខ្សែបញ្ជា។

## 2.4.6 បំណែកដែលមានរុក្ខជាតិដុះ

នៅតំបន់ស្ងួត កន្លែងខ្លះដែលមានកប់មីនមានសភាពកាន់តែបែតងជាងមុន ឬមានស្មៅ និងរុក្ខជាតិដុះនៅពីលើវា។ នេះគឺដោយសារតែមីនដែលមានសំបកធ្វើ

ពីលោហៈ បង្កទៅជាញើសនៅលើវានៅពេលយប់ ហើយបន្ទាប់មកផ្តល់ជាតិទឹក ទៅឲ្យរុក្ខជាតិច្រើនជាងដីដែលនៅជុំវិញនោះ។

## 2.4.7 ផ្លូវលំ ផ្លូវថ្នល់ ឬវាលស្រែដែលមិនប្រើប្រាស់ ឬមានរុក្ខជាតិដុះទ្រុបទ្រុល

បើតំបន់ណាមួយច្បាស់ថាគ្មានការប្រើប្រាស់ និងមានរុក្ខជាតិដុះទ្រុបទ្រុល ឬ ពុំមាននរណាម្នាក់បានធ្វើដំណើរឆ្លងកាត់តំបន់នោះមួយរយៈ មូលហេតុគឺ អាចដោយសារតែមានមីន ឬយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។ បើតំបន់នោះពុំមានការ បង្កបង្កើនផល ផ្ទុយស្រឡះពីក្បាលដីដែលនៅជុំវិញវាដែលមានការដាំដុះ ត្រូវ សន្មត់ថា តំបន់នោះមានការដាក់មីន ឬញាំញីដោយយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។ ដូចគ្នាដែរ សំបកសព្វាវុធ និងគ្រាប់រំសេវដែលគេបោះបង់ចោល អាចឃើញមាន គេកប់នៅក្នុងវាលស្រែដែលមានរុក្ខជាតិដុះទ្រុបទ្រុល ជួនកាលមានការធានា សន្តិសុខដោយប្រើអន្ទាក់/គ្រាប់បែកបង្កៃ និងមីន។ នៅពេលមានការសង្ស័យ សូមប្រើតែដានផ្លូវ ឬផ្លូវថ្នល់ដែលឃើញមានគេធ្វើដំណើរច្រើនប៉ុណ្ណោះ។



សាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ
រូបថតរបស់ UNMAS/Marc Vaillant

## 2.4.8 សាកសព ឬគ្រោងឆ្អឹងសត្វពាហនៈ

គ្រោងឆ្អឹង ឬសាកសពសត្វពាហនៈ ឬមនុស្សដែលបានបន្សល់ទុក អាចបញ្ជាក់ប្រាប់ពីចម្ការមីន។ ត្រូវដឹងថា សត្វពាហនៈ ឬមនុស្សដែលរងរបួសអាចចល័តក្នុងចម្ងាយឆ្ងាយក្រោយពីគ្រោះថ្នាក់កើតឡើង។ រកមើលតម្រុយបន្ថែមទៀត។ ត្រូវដឹងថា សាកសពអាចមានការបំពាក់ជាប់នឹងខ្លួននូវគ្រាប់រំសេវ ដូចជា គ្រាប់បែកដៃដែលអាចស្ថិតក្នុងស្ថានភាពគ្មានសុវត្ថិភាពក្រោយពីផ្ទុះ។ ដូចគ្នាដែរ សាកសពក៏អាចត្រូវបានគេយកធ្វើជាអន្ទាក់/គ្រាប់បែកបង្កប់ដើម្បីធានាសន្តិសុខប្រឆាំងនឹងការយកសាកសពចេញផងដែរ។

## 2.4.9 វត្ថុណាមួយដែលឃើញ "នៅខុសកន្លែងដើម"

នៅតំបន់ដែលកំពុងមានជម្លោះ បើអ្នកឃើញអ្វីមួយខុសពីធម្មតា គួរឲ្យចាប់អារម្មណ៍ ឬមានតម្លៃនៅចំហៀងផ្លូវ ត្រូវចងចាំជានិច្ចថា វាអាចមានការដាក់អន្ទាក់/គ្រាប់បែកបង្កប់។ គោលបំណងនៃអន្ទាក់/គ្រាប់បែកបង្កប់ គឺដើម្បីល្បួង និងបោកបញ្ឆោតនរណាម្នាក់ឲ្យចល័តវត្ថុអ្វីមួយ និងធ្វើឲ្យអន្ទាក់/គ្រាប់បែកបង្កប់ផ្ទុះ។ បើអ្នកមិនដឹងថាវត្ថុនោះជាកម្មសិទ្ធិរបស់នរណាម្នាក់ ហើយអ្នកកំពុងធ្វើដំណើរឆ្លងកាត់តំបន់សង្ស័យ វិធីដ៏ឆ្លាតវៃគឺ កុំចូលទៅជិតវាឲ្យសោះ។

គំនរយុទ្ធភ័ណ្ឌដែលគេបោះបង់ចោល អាចផ្ទុកនូវគ្រាប់រំសេវដែលគ្មានសុវត្ថិភាព ឬដែលគេដឹងថាមានការកែច្នៃទៅជាគ្រឿងផ្ទុះតែមួយដែលអាចបំផ្ទុះដោយការបញ្ជាពីចម្ងាយ។ អ្នកដែលចង់ដឹងចង់ឃើញ ជួនកាលខិតចូលទៅកាន់តែជិតដើម្បីអង្កេតមើលវត្ថុទាំងនេះដែលការធ្វើដូច្នេះអាចមានគ្រោះថ្នាក់ជាទីបំផុត។





រូបភាពទី 2.23
ផ្លូវថ្នល់ "ទទេ" ខុសធម្មតានៅថ្ងៃធ្វើការ? តើប្រជាពលរដ្ឋដឹងអ្វីមួយអំពីការវាយឆ្មក់ដែរឬទេ? បាល់កង់ និងអាហ្វហ្គានីស្ថាន។

UNMAS

Photo/Thomas Enke

## 2.5 ទម្លាប់នៅតាមមូលដ្ឋាន

ទម្លាប់នៅតាមមូលដ្ឋាន អាចផ្តល់នូវតម្រុយជាច្រើនអំពីចម្ការមីន តំបន់ដែលញាំញីដោយយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ឬអាចមានការវាយប្រហារដោយគ្រឿងផ្ទុះកែច្នៃ។ ការសង្កេតមើលយ៉ាងជិតដល់ទៅលើពលរដ្ឋក្នុងមូលដ្ឋាន បន្ថែមពីលើតម្រុយផ្សេងៗទៀត អាចជួយដល់ការវាយតម្លៃតំបន់ អគារ ឬស្ថានភាពណាមួយ។

### 2.5.1 តំបន់ហាមឃាត់ និងអ្នកបោសសម្អាតមីនក្នុងភូមិ

ហាមទៅកន្លែងណាដែលពលរដ្ឋក្នុងមូលដ្ឋានបដិសេធមិនទៅ ទោះបីជានៅតាមបណ្តោយផ្លូវថ្នល់ ឬផ្លូវលំក្តី ឬទៅកាន់ភូមិ ឬវាលស្រែក្តី។ តំបន់ទាំងនេះតាមធម្មតាបង្ហាញឲ្យឃើញថាមានគេបោះបង់ គ្មានការប្រើប្រាស់ ឬគ្មានមនុស្សរស់នៅ។ ពលរដ្ឋក្នុងមូលដ្ឋាន ជាញឹកញាប់ (ប៉ុន្តែមិនជានិច្ចកាល) ដឹងថាតំបន់ណាខ្លះមានគ្រោះថ្នាក់ ពីព្រោះពួកគេបានឃើញផ្ទាល់ភ្នែកថាមានការប្រយុទ្ធគ្នាធ្លាប់រងរបួស ឃើញមានគេដាក់មីន និង/ឬដោយសារតែពួកគេបានដាក់មីនដោយខ្លួនពួកគេផ្ទាល់។ ជនភៀសខ្លួន ឬជនជម្លៀសដែលធ្វើមាតុភូមិនិវត្តន៍ អាចនឹងពុំមានព័ត៌មានចាំបាច់ ផ្ទុយពីពលរដ្ឋក្នុងមូលដ្ឋានដែលបានរស់នៅក្នុងតំបន់មានហានិភ័យនៅអំឡុងមានជម្លោះ។ ជាការល្អ គួរស្វែងរកដំបូន្មានពីអ្នកដែលធ្លាប់បានរស់នៅតំបន់នោះយូរជាងគេ។

នៅក្នុងករណីមួយចំនួន អ្នកប្រហែលជាត្រូវជួបជាមួយអ្នកភូមិដែលកំពុងធ្វើការងារបោសសម្អាតមីន ដោយពុំមានជំនួយពីអង្គការបោសសម្អាតមីនថែមទៀតផង។ ការទទួលបានព័ត៌មានពីបុគ្គលទាំងនេះ អំពីតំបន់ដែលអាចរងផលប៉ះពាល់ សំខាន់ណាស់ចំពោះការស្ថិតនៅឲ្យឆ្ងាយពីការងារបោសសម្អាតមីនរបស់ពួកគេ មានសារៈសំខាន់ណាស់។





រូបភាពទី 2.24
អ្នកប្រមូលកម្ទេចយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ នៅទីតាំងកម្ទេចគ្រាប់នៅអាហ្វហ្គានីស្ថាន។ UNMAS Photo/Thomas Enke

រូបភាពទី 2.25
ទីធ្លាប្រមូលកម្ទេចដែក អាចផ្ទុកនូវសំណល់ជាតិផ្ទុះពីសង្គ្រាម ហើយអាចជាកន្លែងដែលមានគ្រោះថ្នាក់នៅអាហ្វហ្គានីស្ថាន។
រូបថតរបស់ UNMAS/Thomas Enke

## 2.5.2 ទម្លាប់មិនទូទៅ

ពលរដ្ឋក្នុងមូលដ្ឋាន មានប្រតិកម្មទៅនឹងបម្រែបម្រួលមជ្ឈដ្ឋានជុំវិញពួកគេ។ បើមានគ្រោះថ្នាក់ ពួកគេនឹងជៀសវាងវា។ ផ្លូវទទេដែលមានអ្នកថ្មើរជើងតិចជាងធម្មតា ឬគ្មានទាល់តែសោះ និងមានចរាចរណ៍តិចតួចនៅលើផ្លូវថ្នល់ដែលមានការប្រើប្រាស់ល្អតាមធម្មតា មានលក្ខណៈមិនទូទៅនៅគ្រប់តំបន់ទាំងអស់ក្នុងពិភពលោក។ តំបន់លក់ដូរទំនិញ និងស្ថានីយ៍ប្រេងឥន្ធនៈដែលគ្មានអតិថិជននៅម៉ោងដែលគេនិយមលក់ដូរទំនិញ អាចនាំឲ្យមានចម្ងល់មួយចំនួនអំពីទម្លាប់នៅតាមមូលដ្ឋាន និងមូលហេតុ។ អាចមានការវាយប្រហារដោយគ្រឿងផ្ទុះកែច្នៃ ឬការវាយឆ្មក់ នៅគ្រប់ពេល។

## 2.5.3 ទីផ្លាទុកដែកអេតចាយ និងការនេសាទ

យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងសំណល់ជាតិផ្ទុះពីសង្គ្រាម គឺជាវត្ថុធាតុដើមដែលមានតម្លៃថ្លៃបំផុត។ ឧទាហរណ៍ គ្រាប់កាំភ្លើងធំមូល មានផ្ទុកដែកថែប ទង់ដែង និងរំសេវផ្ទុះ។ នៅតាមបណ្តាប្រទេសក្រីក្របំផុត និងនៅកន្លែងដែលមានបរិមាណយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ/សំណល់ជាតិផ្ទុះពីសង្គ្រាមជាច្រើន ប្រជាពលរដ្ឋតែងតែដើររើស និងប្រើប្រាស់ឡើងវិញនូវសំបកលោហៈរបស់គ្រាប់រំសេវ និងព្យាយាមទាញយករំសេវផ្ទុះនោះ។ ជាលទ្ធផល ទីផ្លាទុកដែកអេតចាយមួយចំនួនអាចផ្ទុកនូវយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ឬសំណល់ជាតិផ្ទុះពីសង្គ្រាម ក្រោយពីមានការគ្រប់គ្រងដោយប្រជាពលរដ្ឋដែលស្ថិតក្នុងស្ថានភាពដែលគ្មានសុវត្ថិភាព។

អ្នកអ្នកប្រហែលជាធ្លាប់បានឮរឿងរ៉ាវអំពីការនេសាទដោយប្រើគ្រាប់មីនសំណល់ជាតិផ្ទុះពីសង្គ្រាម និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។ រឿងរ៉ាវទាំងនោះគឺជាការបញ្ជាក់ប្រាប់យ៉ាងច្បាស់អំពីដីដែលមានមីន និងសំបកគ្រាប់រំសេវដែលបានបោះបង់ចោលនៅក្នុងតំបន់នោះ។



សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ
រូបថតរបស់ UNMAS/Marc Vailant



## ផ្នែកទី 3

# ដំបូន្មានការពារសុវត្ថិភាពជាមូលដ្ឋាន

# ដំបូន្មានការពារ សុវត្ថិភាពជាមូលដ្ឋាន

ពេល អ្នកបានប្រទះឃើញវត្ថុទាំងនេះអំឡុងពេលធ្វើដំណើរកាត់តាមជនបទ ឬតំបន់ជាក់លាក់ណាមួយ អ្នកប្រហែលជាកំពុងជួបនឹងហានិភ័យហើយ។ វិធានការបង្ការ មានសារៈសំខាន់ណាស់ចំពោះការរក្សាសុវត្ថិភាពសម្រាប់អ្នក និងបុគ្គលិករបស់អ្នក។

- គ្រាប់រំសេវដែលគេបោះបង់ចោលគ្រប់ប្រភេទ ដូចជា គ្រាប់មីន សំណល់ជាតិផ្ទុះពីសង្គ្រាម យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ឬគ្រឿងផ្ទុះកៃច្នៃ (ឬធាតុផ្សំរបស់វា)
- តម្រុយព្រមានប្រាប់អំពីមីន ដូចជា សញ្ញាព្រមានប្រាប់ជាផ្លូវការ ឬក្រៅផ្លូវការ (កំប៉ុងនៅលើបង្គោល ឬរង្វង់ដុំថ្ម)
- សញ្ញាសម្គាល់សមរភូមិ ដូចជា ទីតាំងសមរភូមិ ឬអគារដែលគេបោះបង់ចោល និងបំផ្លាញចោល ឬ
- ការប្រព្រឹត្តមិនទូទៅណាមួយរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

មានយុទ្ធសាស្ត្រមូលដ្ឋានមួយចំនួន សម្រាប់ជៀសវាងពីការប្រឈមនឹងការគំរាមកំហែងទាំងនេះ។ ផ្នែកនេះផ្តោតទៅលើវិធានការបង្ការដែលត្រូវប្រកាន់ខ្ជាប់ដោយអង្គភាព និងបុគ្គលទាំងឡាយដែលធ្វើការនៅក្នុងតំបន់ដែលមានហានិភ័យខ្ពស់។

សរុបមក ទាំងនេះគឺជាដំបូន្មានមូលដ្ឋានមួយចំនួនដែលបន្តពីផ្នែកមុនៗដែលសង្ខេបអំពីលក្ខណៈនៃការគំរាមកំហែង៖

- រាល់គ្រោះថ្នាក់នៃគ្រឿងផ្ទុះទាំងអស់ មីន យុទ្ធភ័ណ្ឌដែលគេបោះបង់ចោល និងមិនទាន់ផ្ទុះ អន្ទាក់/គ្រាប់បែកបង្កប់ គ្រឿងផ្ទុះកៃច្នៃ និងគីប/ធ្នូនដែលគេបោះបង់ចោល គឺជារំសេវផ្ទុះដែលមានថាមពលខ្លាំងបំផុតដែល





រូបភាពទី 3.1
រូបថតមួយសន្លឹកសម្រាប់មួយអាល់ប៊ុម? ទាហានអ៊ីស្រាអែល (ISAF) ម្នាក់ កំពុងថតរូបហានិភ័យមួយដែលមិនអាចទទួលយកបាន (នៅអាហ្វហ្គានីស្ថាន)។ រូបថតរបស់ UNMAS/Thomas Enke

រូបភាពទី 3.2
បរិក្ខារយោធាដែលគេបោះបង់ចោល។ ជាអន្ទាក់/គ្រាប់បែកបង្កប់មែនទេ? នៅបាល់កង់។ រូបថតរបស់ UNMAS/Thomas Enke

អាចសម្លាប់ ឬបង្កឲ្យមានរបួសស្នាមធ្ងន់ធ្ងរចំពោះមនុស្ស និងបំផ្លាញរថយន្តបាន

- វាអាចបង្កជាការគំរាមកំហែងរយៈពេលច្រើនឆ្នាំ ក្រោយពីជម្លោះបានបញ្ចប់
- វាអាចផ្ទុះបាន សូម្បីតែមានការប៉ះពាល់វាស្រាលៗបំផុតក៏ដោយ
- ឆ្លងកាត់មួយរយៈពេល វាអាចប្រែប្រួលពណ៌ ឡើងច្រេះចាប់ និងផ្លាស់ប្តូរទីតាំងដោយសារការប៉ះនឹងអាកាសធាតុ និងដោយសារអានុភាពនៃអាកាសធាតុ
- តំបន់ដែលរងផលប៉ះពាល់ខ្លាំងបំផុត ពុំមានដាក់សញ្ញាសម្គាល់ដោយសញ្ញាព្រមានប្រាប់ជាផ្លូវការ ឬសញ្ញាកែច្នៃឡើយ
- មីន សំណល់ជាតិផ្ទុះពីសង្គ្រាម (ERW) និងគ្រឿងផ្ទុះកែច្នៃ (ដែលគេបោះបង់ចោល) ពិបាកក្នុងការប្រទះឃើញ
- វាអាចកប់នៅក្រោមដី ឬលាក់បង្កប់នៅក្នុងស្មៅ ឬដើមឈើខ្ពស់ៗ នៅតាមបណ្តោយច្រាំងទន្លេ ឬស្ទឹង នៅក្នុងអគារ និងរថយន្ត និងថែមទាំងនៅក្រោមទឹកផងដែរ
- គេឃើញមានវានៅកន្លែងដែលធ្លាប់មានការប្រយុទ្ធគ្នា ឬនៅទីតាំងយុទ្ធសាស្ត្ររបស់យោធា
- រឿងដែលថា មាននរណាម្នាក់បានមកបោសសម្អាតមីន ឬសំណល់ជាតិផ្ទុះពីសង្គ្រាម ឬធ្លាប់ធ្វើដំណើរនៅក្នុងតំបន់ដែលរងផលប៉ះពាល់ ពុំមានន័យថាវាមានសុវត្ថិភាពឡើយ។

## 3.1 ការប្រព្រឹត្តដែលប្រថុយនឹងគ្រោះថ្នាក់

គ្រាប់មីន គឺជាគ្រឿងផ្ទុះដែលត្រូវបានរចនាឡើងដើម្បីបំផ្លាញ ឬបង្កការខូចខាត។ ដើម្បីស្វែងយល់ពីការប្រព្រឹត្តដែលមានសុវត្ថិភាពនៅក្នុងតំបន់ដែលមានគ្រោះថ្នាក់ និងរៀបបង្ការការប្រឈមនឹងហានិភ័យ វាជាការសំខាន់ណាស់ដែលត្រូវមានគំនិតអំពីមូលហេតុសំខាន់ៗមួយចំនួន ថាតើហេតុអ្វីបានជាមានគ្រោះថ្នាក់កើតឡើងចំពោះអ្នកដែលធ្វើការនៅក្នុងតំបន់ដែលរងផលប៉ះពាល់

### ករណីសិក្សា

នៅខែមេសា ឆ្នាំ 2003 អ្នកសារព័ត៌មានម្នាក់ អាយុ 31 ឆ្នាំ ដែលធ្វើដំណើរជាមួយអ្នកថតរូបម្នាក់នៅប្រទេសអ៊ីរ៉ាក់ភាគខាងជើង បានដើរជាន់មីន ខណៈពេលដែលទាហានឃើដ (Kurdish) ម្នាក់បាននាំគាត់ទៅកាន់លេណដ្ឋានដែលគេបោះបង់ចោលរបស់អ៊ីរ៉ាក់។ អ្នកថតរូបបានស្លាប់ភ្លាមៗ ចំណែកអ្នកសារព័ត៌មាននោះបានរងរបួសធ្ងន់ធ្ងរដែលជើងផ្នែកខាងក្រោមរបស់គាត់ត្រូវកាត់ចោល។

ដោយសារសង្គ្រាម។ ជានិច្ចកាល វាមិនមែនជារឿងចៃដន្យធម្មតាឡើយ ហើយ សម្រាប់អ្នកធ្វើការនៅតំបន់គ្រោះថ្នាក់ មានមូលហេតុជាច្រើន ដែលនាំឲ្យមានគ្រោះថ្នាក់កើតឡើង។

## 3.1.1 អ្នកមានចេតនាប្រថុយនឹងគ្រោះថ្នាក់

នេះគឺជាក្រុមអ្នកដែលមានចេតនាចូលទៅក្នុងតំបន់មានគ្រោះថ្នាក់ ឬបានប៉ុនប៉ងប៉ះពាល់វត្ថុណាមួយដែលគេដឹងថាមានគ្រោះថ្នាក់។ មានហេតុផលមួយចំនួនដែលធ្វើឲ្យបុគ្គលណាម្នាក់ប្រថុយនឹងគ្រោះថ្នាក់បែបនេះ។

អ្នកខ្លះដែលធ្វើការនៅក្នុងតំបន់ដែលរងផលប៉ះពាល់ដោយជម្លោះប្រដាប់អាវុធ ប្រមូលវត្ថុអនុស្សាវរីយ៍ពីសង្គ្រាម ដើម្បីយកមកបង្ហាញក្រុមគ្រួសារ និងមិត្តភក្តិរបស់ពួកគេ។ វត្ថុដែលគេប្រមូលមានជាអាទិ៍ សញ្ញាព្រមានប្រាប់អំពីមីន និងធាតុផ្សំនៃមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដែលពួកគេជឿជាក់ថាមិនបង្កគ្រោះថ្នាក់។ មនុស្សទាំងនេះក៏ចូលចិត្តថតរូបរថក្រោះដែលគេបោះបង់ចោល ឬបំផ្លាញចោល និងនៅជុំវិញអាវុធធុនធ្ងន់របស់យោធាផងដែរ។ ការប្រព្រឹត្តបែបនេះ បើទោះបីជាអាចមានគ្រោះថ្នាក់ក៏ដោយ គឺជារឿងធម្មតាបំផុតក្នុងចំណោមអ្នកដែលធ្វើការនៅក្នុងតំបន់ដែលរងផលប៉ះពាល់ ជាពិសេសបុគ្គលិកដែលមានបទពិសោធន៍តិចតួចនៅតំបន់ជម្លោះ។ ពួកគេមានការទាក់ទាញអារម្មណ៍ជាមួយនឹងភាពថ្មីប្លែករបស់បរិក្ខារយោធាដែលគេបោះបង់ចោល និងបំផ្លាញចោល។

នៅបណ្តាបស្ចឹមប្រទេស មានទីផ្សារដ៏ធំសម្បើមសម្រាប់បរិក្ខារយោធា ជាពិសេសសម្រាប់គ្រាប់រំសេវគ្រប់ប្រភេទ។ នៅទីផ្សារលក់ទំនិញជជុះ គេចំណាយខ្ពស់ទៅលើសំបកគ្រាប់ គ្រាប់កាំភ្លើងធំមូល និងគីប/ឆ្នូន។ ភាគច្រើនគ្រាប់រំសេវនេះ ពុំមែនគ្មានសមាសភាគបង្កគ្រោះថ្នាក់ជាផ្លូវការឡើយ ហើយក៏ពុំមានការបញ្ជាក់ទទួលស្គាល់ពីអ្នកផ្តល់វិញ្ញាបនប័ត្របញ្ជាក់ជាផ្លូវការថា 'គ្មានរំសេវផ្ទុះ' ផងដែរ។







រូបភាពទី 3.3
ហេតុអ្វីរុករករថក្រោះនេះ? វាអាចផ្ទុកនូវគ្រាប់រំសេវដែលគ្មានសុវត្ថិភាព និងមានហានិភ័យញាំញីដោយអ៊ុយរ៉ានីញ៉ូមរឹង។
រូបថតរបស់ UNMAS/Thomas Enke

រូបភាពទី 3.4
ត្រូវប្រុងប្រយ័ត្នចំពោះវត្ថុចម្លែកនៅតាមជាយផ្លូវ។ សូមកត់សម្គាល់ខ្សែដែលចេញមកខាងក្រៅ នេះគឺជាគ្រឿងផ្ទុះកែច្នៃនៅអ៊ីរ៉ាក់។ រូបថតរបស់ UN

រូបភាពទី 3.5
តើការបើកបរជាន់ពីលើវា មានសុវត្ថិភាពដែរឬទេ? តើគ្រាប់ ឬគ្រាប់បែកទាំងនោះត្រូវបានបោសសម្អាតហើយឬនៅ? ត្រូវធ្វើឲ្យប្រាកដថា  អ្នក និងរថយន្តរបស់អ្នកស្ថិតនៅលើផ្លូវក្រាលកៅស៊ូ នៅក្នុងតំបន់ដែលរងផលប៉ះពាល់ដោយសំណល់ជាតិផ្ទុះពីសង្គ្រាមបែបនេះ។
រូបថត/កងកម្លាំងអាល្លឺម៉ង់

អ្នកដទៃទៀត អាចនឹងគ្មានការប្រុងប្រយ័ត្ន ឬជាអ្នកដើរផ្សងព្រេង។ ពួកគេពុំយល់ពេញលេញពីវិសាលភាពនៃការគំរាមកំហែងឡើយ ហើយព្រងើយកន្តើយចំពោះលទ្ធភាពដែលគ្រោះថ្នាក់អាចកើតឡើងចំពោះពួកគេ។ ជារឿយៗ ក្រុមនេះមានជាអាទិ៍៖

- អ្នកដែលអាចធ្លាប់ប្រឈមនឹងការគំរាមកំហែងរយៈពេលយូរ
- អ្នកដែលលែងមានទស្សនវិស័យច្បាស់លាស់អំពីការគំរាមកំហែង និង
- អ្នកដែលមានទំនុកចិត្តក្នុងការគ្រប់គ្រងហានិភ័យជ្រុលពេក។

បុគ្គលទាំងនេះ តែងតែប្រឈមខ្លួននឹងហានិភ័យ ជាមួយនឹងការធ្វើឫកពារក្លាហាន និងគ្មានការពិចារណាច្បាស់លាស់ទៅលើគ្រោះថ្នាក់។

មនុស្សមួយប្រភេទទៀត (ទោះបីជាមិនសូវមានក្រុមអ្នកធ្វើការដែលមានបទពិសោធន៍ក៏ដោយ) គឺជាអ្នកដែលអះអាងថាពួកគេចេះដឹងទាំងអស់អំពីមីន សំណល់ជាតិផ្ទុះពីសង្គ្រាម យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងគ្រឿងផ្ទុះកែច្នៃ។ មនុស្សទាំងនេះ តែងតែជាអ្នកដែលរំភើបចិត្តនឹងការងារយោធាដែលជួនកាលចូលចិត្តបង្ហាញ ឬសម្តែងឲ្យអ្នកដទៃឃើញពីវិសាលភាពនៃចំណេះដឹងរបស់ពួកគេអំពីគ្រាប់រំសេវ។ ជារឿយៗ អ្នកដែលរំភើបចិត្តទាំងនេះ ចូលចិត្តទៅលេង និងរុករកនៅតាមអតីតទីតាំងយោធា និងប្រមូលវត្ថុអនុស្សាវរីយ៍។ សូមកត់ចំណាំថា មនុស្សដែលមានសុភវិនិច្ឆ័យ តែងតែបង្ការគ្រោះថ្នាក់បានល្អប្រសើរជាងអ្នកដែលតែងតែអះអាងថាខ្លួនចេះដឹងទាំងអស់។

### 3.1.2 អ្នកគ្មានចេតនាប្រថុយគ្រោះថ្នាក់

អ្នកដែលជួបប្រទះនឹងមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រឿងផ្ទុះកែច្នៃជារឿយៗ ជួបនឹងមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រឿងផ្ទុះកែច្នៃទាំងនេះដោយចៃដន្យ ឬដោយសារភាពចាំបាច់។ មនុស្សជាច្រើនពុំមានចេតនាចូលទៅកាន់តំបន់មានគ្រោះថ្នាក់ ឬប៉ះពាល់វត្ថុដែលមានគ្រោះថ្នាក់ឡើយ។ ការងារ

## ករណីសិក្សា

នៅឆ្នាំ 2003 អ្នកសារព័ត៌មានម្នាក់ដែលត្រឡប់មកផ្ទះវិញក្រោយពីបានទៅកាន់ប្រទេសអ៊ីរ៉ាក់ បានសម្រេចចិត្តរក្សាទុកគ្រាប់ពីរគ្រាប់ជាវត្ថុអនុស្សាវរីយ៍របស់គាត់នៅទីនោះ។ គាត់បានរកឃើញគ្រាប់នោះនៅជិតរថយន្តដែលគេបំផ្ទុះគ្រាប់បែកនៅ បាកដាដ ហើយបានរក្សាទុកគ្រាប់ទាំងពីរនោះជាមួយគាត់រយៈពេលយ៉ាងតិច 20 ថ្ងៃ មុនពេលគាត់ចាកចេញពីប្រទេសនោះ។ នៅតាមផ្លូវត្រឡប់ទៅផ្ទះវិញ បុគ្គលិកសន្តិសុខនៅព្រលានយន្តហោះអន្តរជាតិនៅប្រទេសហុងកុង បានរកឃើញគ្រាប់មួយក្នុងចំណោមគ្រាប់ទាំងពីរនោះដោយប្រើម៉ាស៊ីនឆ្លុះកាំរស្មីអ៊ិច។ អំឡុងពេលរកមើលដោយដៃទៅលើវ៉ាលីរបស់គាត់ គ្រាប់នោះបានផ្ទុះ។ សមាជិកបុគ្គលិកព្រលានយន្តហោះម្នាក់បានស្លាប់ភ្លាមៗ ដោយសារតែគ្រោះថ្នាក់នោះ ចំណែកបុគ្គលិកបីនាក់ផ្សេងទៀតបានរងរបួស។ គ្រាប់ទីពីរ កាន់កាប់ដោយសហការីរបស់គាត់ ហើយត្រូវបានដោះយកគីប/ផ្នូនចេញដោយសុវត្ថិភាពនៅក្នុងការបញ្ជាបំផ្ទុះ។ អ្នកសារព័ត៌មាននោះ ជឿជាក់ថាគ្រាប់នោះមិនផ្ទុះ និងមានសុវត្ថិភាព។

# 3.2 អាថ៌កំបាំងទូទៅអំពីមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

របស់ពួកគេ អាចតម្រូវឲ្យពួកគេចូលទៅកាន់តំបន់គ្រោះថ្នាក់។ ឧទាហរណ៍ វាអាចជាតម្រូវឲ្យពួកគេធ្វើការងារសំណង់ដែលធ្វើឲ្យពួកគេប្រឈមនឹងលទ្ធភាពនៃការប៉ះទង្គិចនឹងមីនជាមួយនឹងគ្រឿងបរិក្ខារជីកដី។ អ្នកប្រថុយនឹងគ្រោះថ្នាក់គ្មានចេតនាប្រថុយគ្រោះថ្នាក់ គឺជាមនុស្សដែលងាយស្រួលអប់រំផ្សព្វផ្សាយជាមួយនឹងសារសុវត្ថិភាព និងផែនការសុវត្ថិភាព ពីព្រោះពួកគេមានទំនោរទទួលខុសត្រូវច្រើនជាង ចង់ចេះចង់ដឹង ហើយមានការព្រួយបារម្ភពីសុខុមាលភាពរបស់ពួកគេ និងសហការីរបស់ពួកគេ។

ខណៈដែលមនុស្សចង់ចេះចង់ចេះចង់ដឹងអំពីតំបន់ និងវត្ថុមួយចំនួនដោយពុំបានយល់ច្បាស់ពីគ្រោះថ្នាក់ ភាពចង់ចេះចង់ដឹងបែបនេះអាចធ្វើឲ្យមនុស្សជាច្រើនប្រឈមនឹងហានិភ័យ។ ជួនកាល មនុស្សទទួលបានព័ត៌មានមិនត្រឹមត្រូវ ហើយជឿទុកចិត្តលើព័ត៌មានមិនត្រឹមត្រូវអំពីលក្ខណៈនៃការគំរាមកំហែងនោះ។ មានអាថ៌កំបាំងជាច្រើនទាក់ទងនឹងមីន សំណល់ជាតិផ្ទុះពីសង្គ្រាម យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងគ្រឿងផ្ទុះកែច្នៃដែលអាចនាំឲ្យមនុស្សប្រព្រឹត្តដោយគ្មានសុវត្ថិភាព។ អាថ៌កំបាំងទូទៅមួយចំនួនមានដូចតទៅ៖

## 3.2 អាថ៌កំបាំងទូទៅអំពីមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

**អាថ៌កំបាំង** មានមីនមួយប្រភេទដែលនឹងផ្ទុះឡើង នៅពេលអ្នកដើរជាន់លើវា ហើយផ្ទុះបែកតែនៅពេលដែលអ្នកដកជើងអ្នកចេញប៉ុណ្ណោះ។ ការណ៍នេះអាចទុកពេលឲ្យអ្នកស្វែងរកវត្ថុដែលមានទម្ងន់ធ្ងន់មកដាក់ពីលើមីន ខណៈពេលអ្នកដកជើងអ្នកចេញ។
**ការពិត** រឿងនេះកើតឡើងតែនៅក្នុងខ្សែភាពយន្តប៉ុណ្ណោះ។

**អាថ៌កំបាំង** បើអ្នកដឹងថាតំបន់ដែលញាំញីដោយគ្រាប់មីន ឬយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះមានគេដើររួចហើយ អ្នកអាចដើរពីលើវាដោយសុវត្ថិភាព ពីព្រោះបើមីន/





រូបភាពទី 3.6
ការចង់ដឹងចង់ឃើញ ការយកធ្វើជាវត្ថុអនុស្សាវរីយ៍ ឬដាក់តាំងថតរូប? បើអ្នកមិនបានធ្វើឲ្យវាធ្លាក់ទេនោះ សូមកុំរើសវាឡើង!
រូបថតរបស់ អសប/Thomas Enke

រូបភាពទី 3.7
គ្រាប់កាំភ្លើងធំមូល គ្រាប់កាំភ្លើងត្បាល់មូល និងធាតុផ្សេងៗទៀតរបស់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ គឺជាវត្ថុធាតុដើមសម្រាប់បង្កើតគ្រឿងផ្ទុះកែច្នៃនៅអាហ្វហ្គានីស្ថាន។ រូបថតរបស់ UNMAS/Thomas Enke

# 3.2 អាថ៌កំបាំងទូទៅអំពីមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ មិនបានផ្ទុះកាលពីដំបូងនោះ វានឹងមិនផ្ទុះនៅពេលក្រោយទៀតឡើយ។
**ការពិត** ឆ្លងកាត់មួយរយៈពេល ដីអាចហាប់ណែន (ជាពិសេសតាមរយៈដំណើរការកក/រលាយទឹកកក ឬទឹកជំនន់)។ ដូច្នេះ ភាពងាយផ្ទុះរបស់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះអាចមានការផ្លាស់ប្តូរ ហើយក្រោមលក្ខខណ្ឌទាំងនេះ វាអាចទាមទារឲ្យមានការដើរជាន់ជាច្រើនលើកច្រើនសារដើម្បីធ្វើឲ្យមីននោះសកម្ម។

**អាថ៌កំបាំង** វិធីតែមួយគត់ក្នុងការជៀសវាងការរងរបួសស្នាមនៅតំបន់គ្រោះថ្នាក់ គឺ រត់ ឬបើកបរឲ្យបានលឿនតាមដែលអាចធ្វើបាន។ បើអ្នករត់ ឬបើកបរឲ្យបានលឿនបំផុត អ្នកអាចជៀសវាងបន្ទុះនៃមីនដែលផ្ទុះ។
**ការពិត** អ្នកមិនអាចរត់លឿនជាងតីប/ផ្ទួនរបស់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ឬរលកផ្ទុះរំជួយនោះបានឡើយ។

**អាថ៌កំបាំង** សំណាងល្អ គ្រាប់មីនគ្មានអាយុកាលយូរអង្វែងទេ ហើយក្រោយពីនៅក្នុងដីរយៈពេលពីរឬបីឆ្នាំ វាទំនងជានឹងរលួយខូច ហើយមិនដំណើរការទេ។
**ការពិត** មីនភាគច្រើន ព្រមទាំងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងគ្រឿងផ្ទុះកែច្នៃនៅតែមានគ្រោះថ្នាក់ជាច្រើនទសវត្សរ៍ដដែល។ វត្ថុដែលគេប្រើសម្រាប់រុំគ្រឿងផ្ទុះទាំងនេះភាគច្រើនគឺ ផលិតពីផ្លាស្ទិក ហើយគ្មានការជ្រាបទឹក។

**អាថ៌កំបាំង** ការកាត់ខ្សែអន្ទាក់/គ្រាប់បែកបង្កៃ នឹងធ្វើឲ្យមីន អន្ទាក់/គ្រាប់បែកបង្កៃ ឬគ្រឿងផ្ទុះកែច្នៃលែងដំណើរការ។
**ការពិត** គ្រាប់រំសេវភាគច្រើនដែលធ្វើឲ្យសកម្មដោយសារខ្សែអន្ទាក់/គ្រាប់បែកបង្កៃ ត្រូវបានបំផ្ទុះដោយការកើនឡើង ឬការបញ្ចេញតង់ស្យុងតិចតួចបំផុតនៅក្នុងខ្សែ ដូច្នេះគ្មានវិធីច្បាស់លាស់ណាមួយដែលអាចធ្វើឲ្យវាលែងដំណើរការបានឡើយ លុះត្រាតែធ្វើឡើងដោយបុគ្គលិកឯកទេសផ្នែកបោសសម្អាតមីន។





**រូបភាពទី 3.8**
គ្រាប់បែកដៃមានរំសេវផ្ទុះខ្លាំង ត្រូវបានដុតឲ្យខ្លោច ប៉ុន្តែនៅតែមានគ្រោះថ្នាក់ នៅបាល់កង់។ រូបថតរបស់ UNMAS/Thomas Enke

**រូបភាពទី 3.9**
សំបកគ្រាប់ផុន 7,62 mm x 51 (គ្រាប់គ្មានរំសេវ) ក្រោយពីដាក់នៅក្នុងភ្នក់ភ្លើងប្រហែល 20 នាទី។ សូមកត់សម្គាល់គែមដ៏មុតស្រួច។ រូបថត/កងកម្លាំងអាល្លឺម៉ង់

# 3.2 អាថ៌កំបាំងទូទៅអំពីមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

**អាថ៌កំបាំង** យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ បង្កឲ្យមានការគំរាមកំហែងតិចតួច ពីព្រោះអ្នកអាចមើលឃើញវា ហើយអាចយកវាចេញពីផ្លូវរបស់អ្នកបានដោយងាយ។
**ការពិត** អ្នកមិនត្រូវចូលទៅជិត ឬប៉ះពាល់យុទ្ធភ័ណ្ឌណាមួយដូចជា មីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ សំណល់ជាតិផ្ទុះពីសង្គ្រាម ឬគ្រឿងផ្ទុះកែច្នៃឡើយ។ ទោះបីជាធ្លាប់មានគេចល័តវាម្តងហើយក៏ដោយ វានៅតែអាចផ្ទុះបានដោយសារការរំខានជាបន្តបន្ទាប់។ យុទ្ធភ័ណ្ឌមួយចំនួន មានការប្រែប្រួលយ៉ាងឆាប់រហ័សបំផុតដែលវាអាចផ្ទុះបាននៅពេលមានការប៉ះពាល់វាថ្មមៗបំផុត។

**អាថ៌កំបាំង** ការដុតតំបន់ណាមួយ នឹងបោសសម្អាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងគ្រឿងផ្ទុះកែច្នៃ។
**ការពិត** តំបន់មួយពុំមានសុវត្ថិភាព ដោយគ្រាន់តែឮអ្នកភូមិនិយាយថាពួកគេបានដុតតំបន់នោះឡើយ។ តាមពិតទៅ វានៅតែអាចមានសេសសល់យុទ្ធភ័ណ្ឌណាមួយដែលមានការប្រែប្រួលខ្លាំងជាងមុនទៅទៀត។

**អាថ៌កំបាំង** យុទ្ធភ័ណ្ឌដែលគេបោះបង់ចោល មានសុវត្ថិភាពបំផុត ពីព្រោះពុំធ្លាប់មានគេប្រកបំរសេវដើម្បីយកវាទៅប្រើប្រាស់ឡើយ។
**ការពិត** យុទ្ធភ័ណ្ឌដែលគេបោះបង់ចោល តែងតែត្រូវបានគេទុកចោលនៅក្នុងលក្ខខណ្ឌបរិយាកាសដែលធ្វើឲ្យវាគ្មានស្ថេរភាពជាទីបំផុត។ ការប៉ះនឹងកម្ដៅអាចធ្វើឲ្យគ្រឿងផ្ទុះងាយប្រែប្រួលខ្លាំងបំផុត ហើយងាយនឹងផ្ទុះឡើង ឬពុំដូច្នោះទេ ការចាប់កាន់វាដោយពុំបានប្រុងប្រយ័ត្នអាចធ្វើឲ្យគ្រាប់រំសេវដែលបានវេចខ្ចប់ផ្ទុះឡើងបានដែរ។

**អាថ៌កំបាំង** សត្វចិញ្ចឹមនៅក្នុងវាលស្រែ ធ្វើឲ្យវាលស្រែនោះមានសុវត្ថិភាពពីមីន ឬគ្រាប់។
**ការពិត** ទោះបីជាពេលខ្លះ អ្នកភូមិបានធ្វើការបោសសម្អាតមីន ឬគ្រាប់ក៏ដោយ វិធីសាស្ត្រនេះពុំមានសុវត្ថិភាពឡើយ។ វាអាចបំផ្ទុះគ្រាប់រំសេវមួយចំនួន ប៉ុន្តែមិនចាំបាច់ទាំងអស់ឡើយ។





**រូបភាពទី 3.10**
រំសេវមានប្រតិកម្មជាមួយនឹងការកកិត។ ដូច្នេះវានឹងមានគ្រោះថ្នាក់ខ្លាំងបំផុតនៅពេលកកិតប៉ះជាមួយនឹងសំបកគ្រាប់ទាំងនេះ និងដើរចូលទៅកាន់តំបន់នោះ (នៅអាហ្វហ្គានីស្ថាន)។ រូបថតរបស់ UNMAS/Thomas Enke

**រូបភាពទី 3.11**
គ្រាប់បែកចង្កោមនេះ BLU-755 មិនផ្ទុះទេ ប៉ុន្តែនៅតែមានគ្រោះថ្នាក់ (នៅបាល់កង់)។ រូបថតរបស់ UNMAS/Thomas Enke

**អាថ៌កំបាំង** បើអ្នកដឹងថាផ្លូវថ្នល់មួយខ្សែមានការប្រើប្រាស់ប្រកបដោយសុវត្ថិភាពក្នុងរយៈពេលយ៉ាងហោចណាស់ប្រាំមួយខែ អ្នកអាចសន្និដ្ឋានបានថា លែងមានហានិភ័យមីន ឬគ្រាប់ទៀតហើយ។
**ការពិត** មីន និងគ្រាប់ អាចរលើងចេញពីដីដោយសារការប្រើប្រាស់ជាប់ជានិច្ចនូវផ្ទៃដីផ្នែកខាងលើដែលគេធ្វើដំណើរ។ ផ្នែកនៃផ្លូវថ្នល់ដែលគេធ្វើដំណើរពីលើវាអាចលែងប្រើប្រាស់កើតនៅរដូវភ្លៀងដែលបង្ខំឲ្យអ្នកបើកបរប្រើប្រាស់ជាយផ្លូវដែលអាចមានការបង្កប់មីន។

ត្រូវធ្វើឲ្យប្រាកដថា អ្នកដឹងពីរបៀបទាក់ទងសុំជំនួយក្នុងករណីមានគ្រោះអាសន្នមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម។

**អាថ៌កំបាំង** ជានិច្ចកាល គេដាក់មីនតាមលំនាំមួយដែលអាចប៉ាន់ស្មានបាន ដើម្បីបង្កើតបានជារនាំងឧបសគ្គធម្មតាមួយ។
**ការពិត** ខណៈដែលកងទ័ពធម្មតា តែងតែដាក់មីននៅក្នុងចម្ការមីនតាមលំនាំធម្មតា តំបន់ជាច្រើនដែលបានដាក់មីនពុំមានលំនាំណាមួយដែលអាចមើលឃើញ និងដឹងបាន ហើយប្រហែលជាគេពុំអាចប៉ាន់ស្មានដឹងកន្លែងដែលផ្នែកគ្រោះថ្នាក់ចាប់ផ្តើម ឬបញ្ឈប់បានឡើយ ជាពិសេសនៅបណ្តាប្រទេសដែលធ្លាប់មានជម្លោះស៊ីវិល និងកន្លែងដែលគ្មានខ្សែបន្ទាត់សមរភូមិច្បាស់លាស់។

## 3.3 ដំបូន្មានការពារសុវត្ថិភាពសម្រាប់អង្គការនានា

វាមានសារៈសំខាន់សម្រាប់អង្គការនានាដែលប្រតិបត្តិការនៅក្នុងតំបន់ដែលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រឿងផ្ទុះកៃច្នៃដែលត្រូវប្រុងប្រយ័ត្នជាទីបំផុតចំពោះគ្រោះថ្នាក់នៃការគំរាមកំហែងទាំងនេះ នៅពេលធ្វើផែនការ និងអនុវត្តគម្រោងដែលអាចធ្វើឲ្យបុគ្គលិកប្រឈមនឹងហានិភ័យ រួមទាំងបុគ្គលិករបស់ដៃគូអនុវត្តគម្រោងក្នុងស្រុក។ ការណ៍នេះតម្រូវឲ្យមានការរៀបចំនីតិវិធីការពារសុវត្ថិភាពដែលមានប្រសិទ្ធភាព ការបណ្តុះបណ្តាលសមស្រប គ្រឿងបរិក្ខារសមស្រប និងព័ត៌មានបច្ចុប្បន្នភាព។ ការជៀសវាងគ្រោះថ្នាក់តែមួយ តាមរយៈការបណ្តុះបណ្តាល និងការធ្វើផែនការសុវត្ថិភាព នឹងធ្វើឲ្យការវិនិយោគមានតម្លៃ។

# 3.3 ជំហានការពារសុវត្ថិភាពសម្រាប់អង្គការនានា

វិធានការសុវត្ថិភាព គួរត្រូវបានចាត់ទុកថាជាវិធានការបន្ថែមពីលើនីតិវិធីសន្តិសុខដែលមានស្រាប់សម្រាប់ប្រតិបត្តិការនៅក្នុងតំបន់ជម្លោះ ទោះបីជាជម្លោះនោះបានកន្លងផុតមួយរយៈកាលហើយក៏ដោយ។ វិធានការទាំងនេះគួរគួរតែជាវិធានការដែលអាចអាចអនុវត្តបាន ហើយផ្អែកទៅលើវង្វាយតម្លៃវិសាលភាព និងលក្ខណៈនៃការគំរាមកំហែងក្នុងមូលដ្ឋាន វិធានការទាំងនេះអាចមានជាអាទិ៍៖

- ការប្រមូលព័ត៌មានលម្អិតអំពីការគំរាមកំហែងដោយសារមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម/គ្រឿងផ្ទុះកែច្នៃនៅក្នុងតំបន់ប្រតិបត្តិការរបស់អ្នក ហើយធ្វើបច្ចុប្បន្នភាពព័ត៌មាននេះឲ្យបានទៀងទាត់។ ត្រូវគិតគូរពីការផ្តល់ព័ត៌មានសង្ខេបខ្លីក្នុងទម្រង់ជារូបភាព (ផែនទី ឬតារាងបង្ហាញពីតំបន់គ្រោះថ្នាក់)
- ការការដាក់ចេញនីតិវិធីការពារសុវត្ថិភាពមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម/គ្រឿងផ្ទុះកែច្នៃយោងទៅតាមព័ត៌មានដែលមាននៅក្នុងសៀវភៅជំនួយស្មារតីនេះ ហើយកែសម្រួលទៅតាមតំបន់ប្រតិបត្តិការរបស់អ្នក។ ដោយឡែក ត្រូវបង្កើតប្រព័ន្ធរាយការណ៍អំពីរថយន្ត និងការធ្វើដំណើរ (សូមមើល ឧបសម្ព័ន្ធ 1 អំពីការប្រើប្រាស់លម្អិតបញ្ជាក់កម្មវិធីធ្វើដំណើរ)
- ការរក្សាឲ្យមានព័ត៌មានទំនាក់ទំនងដែលមានបច្ចុប្បន្នភាព និងមានការផ្ទៀងផ្ទាត់ត្រឹមត្រូវរបស់មជ្ឈមណ្ឌល និងទីភ្នាក់ងារសកម្មភាពមីន មន្ត្រីសន្តិសុខនៃអង្គការសហប្រជាជាតិ ក្រុមសម្របសម្រួលការកម្ទេចសំណល់ជាតិផ្ទុះពហុជាតិសាសន៍ (MN EOD CC) និងការិយាល័យទំនាក់ទំនងថ្នាក់ជាតិសម្រាប់ការកម្ទេចសំណល់ជាតិផ្ទុះ (NPOC EOD) នៃក្រុមបេសកកម្មរក្សាសន្តិភាព សង្កេតការណ៍ ឬហ្វឹកហ្វឺន នគរបាលក្នុងស្រុក និងបន្ទប់ថែទាំវេជ្ជសាស្ត្រ។
- ស្នើសុំព័ត៌មានដែលបានបញ្ចូលក្នុងមូលដ្ឋានទិន្នន័យ "ប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្រាប់សកម្មភាពមីន (IMSMA)" ពីមជ្ឈមណ្ឌលជាតិសកម្មភាពកម្ចាត់មីន។





រូបភាពទី 3.12
ការបណ្តុះបណ្តាលអំពីការកម្ទេចគ្រាប់បែកធម្មតា (នៅស៊ូដង់ខាងត្បូង)។ រូបថតរបស់ UN

រូបភាពទី 3.13
កុំទៅកាន់ទីតាំងយោធាដែលគេបោះបង់ចោល អន្ទាក់/គ្រាប់បែកបង្កៃ មីន គ្រឿងផ្ទុះកែច្នៃ និងសំណល់ជាតិផ្ទុះពីសង្គ្រាមដែលគ្មានសុវត្ថិភាព។ មិនត្រូវមើលស្រាលវត្ថុទាំងនេះឡើយ (នៅអាហ្វហ្គានីស្ថាន)។ UNMAS Photo/Thomas Enke

# 3.3 ដំបូន្មានការពារសុវត្ថិភាពសម្រាប់អង្គការនានា

- ផ្តល់ព័ត៌មានដែលទាក់ទងនឹងមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម/គ្រឿងផ្ទុះកែច្នៃដល់បុគ្គលិករបស់អ្នកតាមទ្រង់ទ្រាយមួយដែលមានភាពងាយស្រួល រួមទាំងព័ត៌មានអំពីផ្លូវមានសុវត្ថិភាព និងតំបន់មានគ្រោះថ្នាក់នៅក្នុងតំបន់ប្រតិបត្តិការរបស់អ្នក ក៏ដូចជាព័ត៌មានទំនាក់ទំនងគ្រាមានអាសន្ន។
- ធានាថា បុគ្គលិកទាំងអស់របស់អ្នកដែលអាចមានហានិភ័យ (រួមមាន អ្នកបើកបរ អ្នកបកប្រែ និងអ្នកនាំផ្លូវ) បានទទួលការបណ្តុះបណ្តាលអំពីមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម/គ្រឿងផ្ទុះកែច្នៃ ហើយមានការយល់ដឹងអំពីនីតិវិធីការពារសុវត្ថិភាពមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម/គ្រឿងផ្ទុះកែច្នៃ។
- យល់ដឹងថា កម្រិតនៃភាពប្រុងប្រយ័ត្នចំពោះការគំរាមកំហែងដោយសារមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម/គ្រឿងផ្ទុះកែច្នៃ នឹងមានការថយចុះទៅតាមពេលវេលា ហើយអាចនឹងតម្រូវឲ្យមានការបណ្តុះបណ្តាលបំប៉នអំពីសុវត្ថិភាព។
- ធានាថា បុគ្គលិករបស់អ្នកបានទទួលការបណ្តុះបណ្តាលអំពីការសង្គ្រោះបឋម ដោយមានការផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការថែទាំរបួស និងធានាឲ្យបានថា រថយន្តមានបំពាក់មកជាមួយនូវឈុតគ្រឿងសង្គ្រោះបឋម និងថែទាំរបួស។
- បំពាក់ឲ្យរថយន្ត និងបុគ្គលិករបស់អ្នកជាមួយនឹងគ្រឿងបរិក្ខារទំនាក់ទំនងមានប្រសិទ្ធភាព ព្រមទាំងផែនទី និងផ្តល់ការបណ្តុះបណ្តាលអំពីការប្រើប្រាស់គ្រឿងបរិក្ខារទាំងនោះ។

នៅតាមតំបន់ដែលមានហានិភ័យខ្ពស់ និងមានការប្រឈមខ្ពស់ សូមពិចារណាអំពីការកែសម្រួលរថយន្ត ដើម្បីផ្តល់នូវការការពារបន្ថែមពីការផ្ទុះ។ សូមមើលឧបសម្ព័ន្ធ 2 ស្តីពីវិធានការទូទៅសម្រាប់ផ្តល់ការការពារបន្ថែមឲ្យរថយន្ត។

**កុំប៉ះពាល់! កត់ត្រា និងរាយការណ៍។**
**កុំប្រមូលវត្ថុអនុស្សាវរីយ៍ពីសង្គ្រាម!**
**កុំយកចេញនូវសញ្ញាព្រមានប្រាប់អំពីមីនទោះដោយហេតុផលអ្វីក៏ដោយ!**

**នៅឲ្យឆ្ងាយពី បរិក្ខារយោធាដែលគេបោះបង់ចោល!**

## 3.4 ដំបូន្មានការពារសុវត្ថិភាពសម្រាប់បុគ្គល

ការទទួលបានព័ត៌មានគ្រប់គ្រាន់ ការប្រើសុភវិនិច្ឆ័យ និងការរក្សានូវវិធីដោះស្រាយត្រឹមត្រូវអំពីបញ្ហាមីន សំណល់ជាតិផ្ទុះពីសង្គ្រាម យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងគ្រឿងផ្ទុះកែច្នៃ អាចជួយដល់ការដោះស្រាយបញ្ហាសុវត្ថិភាព និងធ្វើឲ្យមនុស្សមានសុវត្ថិភាពបាន។ ផ្នែកនៃដំបូន្មានមួយចំនួនសម្រាប់ការការពារផ្ទាល់ខ្លួន និងសម្រាប់ការការពារសហការីរបស់អ្នកមានដូចតទៅ៖

### 3.4.1 សារការពារសុវត្ថិភាពទូទៅ៖

- ហាមប៉ះពាល់ ឬចូលទៅជិតមីន សំណល់ជាតិផ្ទុះពីសង្គ្រាម យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ឬគ្រឿងផ្ទុះកែច្នៃ
- មុនពេលធ្វើដំណើរ ត្រូវទទួលបានព័ត៌មានអំពីតំបន់ដែលមានគ្រោះថ្នាក់
- ហាមផ្សងគ្រោះថ្នាក់ទៅក្នុងតំបន់ដែលគេដឹងថាមានគ្រោះថ្នាក់ រុករកទីតាំង ឬគ្រឿងបរិក្ខារយោធា
- ហាមចូលទៅជិត ឬប៉ះពាល់មីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ឬដែលគេបោះបង់ចោល គ្រឿងផ្ទុះកែច្នៃ ឬវត្ថុដែលគួរឲ្យសង្ស័យផ្សេងទៀត ទោះដោយហេតុផលអ្វីក៏ដោយ
- ហាមប្រមូលមីន សំណល់ជាតិផ្ទុះពីសង្គ្រាម យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ គ្រឿងផ្ទុះកែច្នៃ ឬអាវុធយុទ្ធភ័ណ្ឌរបស់យោធា
- កុំប៉ះពាល់អ្វីមួយដែលមើលទៅហាក់ដូចជាចម្លែក ឬនៅខុសពីកន្លែងដើមដែលនៅរាយប៉ាយលើដី ឬព្យួរនៅលើដើមឈើ
- ត្រូវដឹងពីសញ្ញាព្រមានក្នុងមូលដ្ឋាន ហើយត្រូវគោរពសញ្ញានោះជានិច្ច
- ជានិច្ចកាល ត្រូវប្រយ័ត្នចំពោះតម្រុយដែលអាចមានគ្រោះថ្នាក់កើតឡើង
- ផ្តល់ព័ត៌មានសុវត្ថិភាពដល់អ្នកដទៃ
- ផ្តល់ព័ត៌មានដល់អ្នកដទៃអំពីផែនការធ្វើដំណើររបស់អ្នកជានិច្ច។

## តើអ្នកដឹងទេ?

ទោះបីប្រជាពលរដ្ឋក្នុងមូលដ្ឋានតែងតែជាប្រភពល្អបំផុតមួយក្នុងការទទួលបានព័ត៌មានអំពីការគំរាមកំហែងដោយសារមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមក៏ដោយ គ្រោះថ្នាក់ជាច្រើនកើតឡើងដោយសារតែប្រជាពលរដ្ឋក្នុងមូលដ្ឋានមានការយល់ឃើញខុសគ្នាទៅលើហានិភ័យ។ ការដើរ និងការបើកបរឆ្លងកាត់តំបន់របស់ពួកគេជារៀងរាល់ថ្ងៃដោយគ្មានករណីគ្រោះថ្នាក់ អាចបង្កើតបានជាចំណាប់អារម្មណ៍ខុសឆ្គងមួយទៅលើស្ថានភាពជាក់ស្តែង។

បុគ្គលិកផ្តល់ជំនួយ ឬអ្នកសារព័ត៌មានបរទេស តែងតែជឿទុកចិត្តទៅលើសមភាគីក្នុងមូលដ្ឋាន ដូចជា អ្នកបើកបរ អ្នកបកប្រែ ឬអ្នករាយការណ៍ នៅពេលធ្វើការវាយតម្លៃសុវត្ថិភាពរបស់តំបន់ណាមួយ។ បុគ្គលិកផ្តល់ជំនួយ និងអ្នកសារព័ត៌មាន តាមធម្មតាតែងតែមិនចោទសួរទៅលើការវាយតម្លៃទាំងនេះទេ ពីព្រោះ “អ្វីៗដូចជាត្រឹមត្រូវអស់ហើយ” ឬពីព្រោះពួកគេមិនចង់ឲ្យគេឃើញថាមានការប្រុងប្រយ័ត្នដោយបើកចំហ ឬ “សួញសាញច្រើនពេក” ទេ។

## 3.4.2 ត្រូវមានការត្រៀមខ្លួន

### 3.4.2.1 ការបង្កើនការយល់ដឹងអំពីសុវត្ថិភាពសំណល់ជាតិផ្ទុះ/គ្រឿងផ្ទុះកែច្នៃ និងការសង្គ្រោះបឋម

ធានាឲ្យបានថា អ្នកបានទទួលចំណេះដឹងអំពីមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម/គ្រឿងផ្ទុះកែច្នៃ និងការបណ្តុះបណ្តាលអំពីការសង្គ្រោះបឋម និងយល់ដឹងពីនីតិវិធីការពារសុវត្ថិភាពរបស់អង្គការអ្នក។ បើអ្នកពុំទាន់បានទទួលការបណ្តុះបណ្តាលបែបនេះទេ ចូរស្នើសុំឲ្យមានការរៀបចំការបណ្តុះបណ្តាលទាំងនេះ។

### 3.4.2.1 ព័ត៌មានទំនាក់ទំនង

រក្សាឲ្យមានក្នុងដៃជានិច្ចនូវព័ត៌មានទំនាក់ទំនងរបស់មជ្ឈមណ្ឌល និងទីភ្នាក់ងារសកម្មភាពមីន មន្ត្រីសន្តិសុខនៃអង្គការសហប្រជាជាតិ ក្រុមសម្របសម្រួលការកម្ទេចសំណល់ជាតិផ្ទុះពហុជាតិសាសន៍ (MN EOD CC) និងការិយាល័យទំនាក់ទំនងថ្នាក់ជាតិសម្រាប់ការកម្ទេចសំណល់ជាតិផ្ទុះ (NPOC EOD) នៃក្រុមបេសកកម្មរក្សាសន្តិភាព សង្កេតការណ៍ ឬហ្វឹកហ្វឺន សេវាសង្គ្រោះបន្ទាន់ និងបន្ទប់ថែទាំវេជ្ជសាស្ត្រ។ ផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពព័ត៌មានទំនាក់ទំនងពេលមានអាសន្នឲ្យបានទៀងទាត់។

### 3.4.2.2 កញ្ចប់សង្គ្រោះបឋម

ធានាថា កញ្ចប់ធ្វើដំណើរដែលមានកញ្ចប់សង្គ្រោះបឋមស្ថិតនៅលើរថយន្តរបស់អ្នកគ្រប់ពេលវេលា។ ពិនិត្យមើលថ្ងៃផុតកំណត់ប្រើប្រាស់ និងលទ្ធភាពប្រើបាននៃមុខរបស់ទាំងអស់ ហើយត្រូវចេះប្រើប្រាស់វា។

(ត)

ចូរចងចាំថា៖ នៅតំបន់ដែលរងផលប៉ះពាល់ដោយសារមីន អ្នកគួរតែមានការប្រុងប្រយ័ត្នរាប់រយដងច្រើនជាងការធ្វើខុសត្រឹមតែមួយដង។ ទទួលព័ត៌មានសង្ខេបអំពីសុវត្ថិភាពមីន ហើយត្រូវធ្វើឲ្យប្រាកដថា សមាជិកក្នុងមូលដ្ឋានរបស់អ្នកក៏មានដែរ!



រូបភាពទី 3.14
ស្ពានគឺជាចំណុចយុទ្ធសាស្ត្រ ហើយក៏ជាចំណុចគ្រោះថ្នាក់ផងដែរ។ ត្រូវប្រុងប្រយ័ត្នចំពោះមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងគ្រឿងផ្ទុះកែច្នៃ (នៅបាល់កង់)។ រូបថតរបស់ UNMAS/Thomas Enke

### 3.4.2.3 ការប្រាស្រ័យទាក់ទង

កុំធ្វើដំណើរដោយគ្មានវិទ្យុទាក់ទង ទូរស័ព្ទ ហើយត្រូវចេះប្រើប្រាស់វា។ ត្រូវទទួលបានព័ត៌មានគ្រប់គ្រាន់អំពីជម្រើសប្រេកង់ស៍ ឬលេខទូរសព្ទទាំងអស់ដែលអ្នកអាចនឹងត្រូវការប្រើ (ឧ. ទីភ្នាក់ងារសកម្មភាពមីន មន្ត្រីសន្តិសុខនៃអង្គការសហប្រជាជាតិ មជ្ឈមណ្ឌលប្រតិបត្តិការយុទ្ធសាស្ត្រនៃក្រុមបេសកកម្មរក្សាសន្តិភាព សង្កេតការណ៍ ឬហ្វឹកហ្វឺន)។

### 3.4.2.4 ផែនទីបង្ហាញតំបន់គ្រោះថ្នាក់

អង្គការបោសសម្អាតមីនផ្សេងៗគ្នាជាច្រើនដូចជា មជ្ឈមណ្ឌលអន្តរជាតិក្រុងហ្សឺណែវសម្រាប់ការបោសសម្អាតមីនមនុស្សធម៌ ឬក្រុមសម្របសម្រួលការកម្ទេចសំណល់ជាតិផ្ទុះពហុជាតិសាសន៍ ការិយាល័យទំនាក់ទំនងថ្នាក់ជាតិសម្រាប់ការកម្ទេចសំណល់ជាតិផ្ទុះនៃក្រុមបេសកកម្មរក្សាសន្តិភាព សង្កេតការណ៍ ឬហ្វឹកហ្វឺន អាចផ្តល់លម្អិតបញ្ជាក់កម្មវិធីធ្វើដំណើរដែលមានព័ត៌មានអំពីចម្ការមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម និងតំបន់មានគ្រោះថ្នាក់ផ្សេងៗទៀត។ បើអាចរកបាន ត្រូវកាន់ផែនទីដែលមានសម្គាល់ដោយព័ត៌មានដែលអាចរកបានល្អបំផុតអំពីផ្លូវដែលគ្មានមីន សំណល់ជាតិផ្ទុះពីសង្គ្រាម ឬគ្រោះថ្នាក់ផ្សេងៗដូចជា ការគំរាមកំហែងដោយគ្រឿងផ្ទុះកែច្នៃជាដើម។ ធ្វើបច្ចុប្បន្នភាពព័ត៌មាននេះ ដោយផ្ទៀងផ្ទាត់ជាមួយប្រជាពលរដ្ឋក្នុងមូលដ្ឋាននៅពេលអ្នកធ្វើដំណើរ ហើយយកចិត្តទុកដាក់នឹងការព្រមានរបស់ពួកគេ។

## 3.4.3 វាយតម្លៃការគំរាមកំហែងក្នុងមូលដ្ឋាន

ទទួលព័ត៌មានលម្អិតអំពីស្ថានភាពមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម/គ្រឿងផ្ទុះកែច្នៃ មុនពេលចល័តទៅកាន់តំបន់ណាមួយដែលមានមីន ឬសំណល់ជាតិផ្ទុះពីសង្គ្រាម ឬការគំរាមកំហែងពីការវាយប្រហារដោយគ្រឿងផ្ទុះកែច្នៃ។ អ្នកក៏ត្រូវដឹង

## មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីន

នៅបណ្តាប្រទេសជាច្រើនដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារ មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ រដ្ឋាភិបាល ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាលបាន ជួយបង្កើតឲ្យមានមជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីន។ មជ្ឈមណ្ឌលទាំងនេះដើរតួជាភាគីប/ឆ្នូនង្គោលសម្រាប់ការសម្របសម្រួល ដល់កិច្ចប្រឹងប្រែងក្នុងការបោសសម្អាត យុទ្ធភ័ណ្ឌ ដាក់សញ្ញាសម្គាល់ តំបន់ដែលមានគ្រោះថ្នាក់ ផ្តល់ការអប់រំអំពីហានិភ័យ និងធ្វើការតស៊ូមតិសម្រាប់អ្នកដែលរួចផុតជីវិតពីគ្រោះថ្នាក់។

មជ្ឈមណ្ឌលទាំងនេះ តាមធម្មតាដំណើរការដោយអង្គភាពស៊ីវិលប្រដាប់អាវុធរបស់រដ្ឋាភិបាល ហើយគាំទ្រប្រតិបត្តិការមនុស្សធម៌ និងអភិវឌ្ឍន៍។ មជ្ឈមណ្ឌលទាំងនេះតែងតែនៅដាច់ដោយឡែក ពីកិច្ចប្រឹងប្រែងផ្នែកយោធាក្នុងការបោសសម្អាតយុទ្ធភ័ណ្ឌ ឬកងកម្លាំងសន្តិសុខ និងនគរបាលដែលដោះស្រាយបញ្ហាគ្រឿងផ្ទុះកែច្នៃ។

អំពីសញ្ញាព្រមានប្រាប់ជាផ្លូវការ និងក្រៅផ្លូវការនៅក្នុងតំបន់របស់អ្នកផងដែរ។ នៅពេលអាចរកបាន សូមទាក់ទងសុំព័ត៌មានពីអង្គភាព ឬមន្ត្រីដូចខាងក្រោម៖

- មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីន (MAC) និងទីភ្នាក់ងារសកម្មភាពមីនក្នុងស្រុក
- មន្ត្រីសន្តិសុខនៃអង្គការសហប្រជាជាតិ
- មន្ត្រីសង្កេតការណ៍ ឬទំនាក់ទំនងផ្នែកយោធានៃអង្គការសហប្រជាជាតិ
- អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារផ្តល់ជំនួយដែលធ្វើការនៅតំបន់នោះ
- ក្រុមសម្របសម្រួលការកម្ទេចសំណល់ជាតិផ្ទុះពហុជាតិសាសន៍ ការិយាល័យទំនាក់ទំនងថ្នាក់ជាតិសម្រាប់ការកម្ទេចសំណល់ជាតិផ្ទុះនៃក្រុមបេសកកម្មរក្សាសន្តិភាព សង្កេតការណ៍ ឬហ្វឹកហ្វឺន និង/ឬ
- អាជ្ញាធរមូលដ្ឋាន។

ជាមួយគ្នានេះដែរ ត្រូវស្នើសុំព័ត៌មានបន្ថែមពីប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដោយត្រូវពិគ្រោះយោបល់ជាមួយបុរសផង ស្ត្រីផង និងកុមារផង ដោយសារពួកគេមានចំណេះដឹងខុសៗគ្នាអំពីការគំរាមកំហែងក្នុងមូលដ្ឋាន ដោយសារតែសកម្មភាពប្រចាំថ្ងៃខុសៗគ្នារបស់ពួកគេ។ ទោះជាយ៉ាងណា ត្រូវចងចាំក្នុងចិត្តជានិច្ចថា ប្រជាពលរដ្ឋដែលធ្វើមាតុភូមិនិវត្តន៍ ប្រហែលជាមិនបានដឹងពីការគំរាមកំហែងក្នុងមូលដ្ឋាននោះឡើយ។ បើអ្នកធ្វើដំណើរនៅក្នុងតំបន់ដែលមានហានិភ័យខ្ពស់ សូមស្នើឲ្យអង្គភាពស៊ីវិល និងអង្គភាពយោធា ព្រមទាំងពលរដ្ឋក្នុងមូលដ្ឋាននូវសំណួរមួយចំនួនដូចខាងក្រោម ដើម្បីចងក្រងជាព័ត៌មានអំពីការគំរាមកំហែងនោះ៖

- តើធ្លាប់មានគ្រោះថ្នាក់ដោយសារមីន ឬយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅក្នុងតំបន់នេះដែលពាក់ព័ន្ធនឹងមនុស្ស សត្វពាហនៈ ឬរថយន្តដែរឬទេ? តើអ្វីខ្លះដែលបានបង្កឲ្យមានគ្រោះថ្នាក់នោះ (មីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ឬអន្ទាក់/គ្រាប់បែកបង្កប់/គ្រឿងផ្ទុះកែច្នៃ)? តើគ្រោះថ្នាក់បានកើតឡើងនៅកន្លែងណា និងពេលណា?

- តើនៅកន្លែងណាខ្លះដែលអ្នកសង្ស័យ ឬដឹងថាមានមីន ឬយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ?
- តើធ្លាប់មានការប្រយុទ្ធគ្នានៅក្នុងតំបន់នេះដែរឬទេ? នៅកន្លែងណា?
- តើធ្លាប់មានទាហានរស់នៅ/ធ្វើការ/ឆ្លងកាត់តាមតំបន់នេះដែរឬទេ?
- តើធ្លាប់មានការផ្ទុះគ្រាប់នៅតំបន់នេះដែរឬទេ? នៅកន្លែងណាខ្លះ?
- តើមានផ្លូវថ្នល់ ដានផ្លូវ ផ្លូវកាត់ខ្វែងគ្នា វាលស្រែ អណ្តូងទឹក ឬផ្ទះដែលអ្នកមិនប្រើប្រាស់ដោយសារតែបារម្ភពីសុវត្ថិភាពរបស់វាដែរឬទេ?
- តើផ្លូវថ្នល់ដែលមានសុវត្ថិភាពនៅឯណាខ្លះ?
- តើមានជំរុំយោធាថ្មី ឬចាស់នៅក្នុងតំបន់នេះដែលអ្នកគួរតែជៀសវាងដែរឬទេ? នៅកន្លែងណាខ្លះ?
- តើអ្នកដាក់សញ្ញាសម្គាល់តំបន់គ្រោះថ្នាក់ ឬមានសញ្ញាសម្គាល់ផ្លូវការដែរឬទេ?
- តើវាមើលទៅមានរូបរាងដូចម្តេច?

ជារឿយៗ ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ពុំបានវែកញែកឲ្យឃើញភាពខុសគ្នារវាងមីន និងយុទ្ធភ័ណ្ឌផ្សេងៗទៀតឡើយ។ ពួកគេប្រហែលជានិយាយសំដៅទៅលើគ្រាប់បែកទូទៅ ឬគ្រាប់មីនទូទៅតែប៉ុណ្ណោះ។ ការកំណត់ប្រភេទនៃយុទ្ធភ័ណ្ឌដែលពួកគេសំដៅទៅលើ អាចធ្វើឲ្យមានភាពខុសគ្នាយ៉ាងច្រើនចំពោះផែនការធ្វើដំណើររបស់អ្នក។ តំបន់ដែលញាំញីដោយមីន ឬគ្រាប់ តែងតែបង្កឲ្យមានគ្រោះថ្នាក់ចំពោះការធ្វើដំណើរច្រើនជាងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។ ទោះជាយ៉ាងណា បើមានការសង្ស័យ ត្រូវសន្មត់ថាវាអាក្រក់បំផុត ហើយត្រូវជៀសវាងតំបន់នោះ។ ទោះបីជាមានប្រភពតែមួយបញ្ជាក់ប្រាប់ថាតំបន់នោះគ្រោះថ្នាក់ក៏ដោយ ត្រូវតែជៀសវាងវា!

បើអ្នកទទួលព័ត៌មានថ្មីទាក់ទងនឹងការគំរាមកំហែងក្នុងមូលដ្ឋានដោយសារមីន ឬសំណល់ជាតិផ្ទុះពីសង្គ្រាម សូមផ្តល់ព័ត៌មាននោះដល់ការិយាល័យកណ្តាលរបស់អ្នក មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនក្នុងស្រុក ទីភ្នាក់ងារសកម្មភាពមីន  មន្ត្រីសន្តិសុខនៃអង្គការសហប្រជាជាតិ ឬក្រុមសម្របសម្រួលការកម្ចេច

ប្រើសុភវិនិច្ឆ័យ។ នៅពេលមានការសង្ស័យ ត្រូវនៅខាងក្រៅ! មុនពេលបើកបរនៅក្នុងតំបន់ជម្លោះ ត្រូវពិនិត្យជាមួយអាជ្ញាធរមូលដ្ឋានអំពីមីនប្រឆាំងរថយន្ត។ កុំបើកបរនៅលើជាយផ្លូវ! នៅលើដានផ្លូវដែលមានសំណឹកច្រើន។ នៅលើផ្លូវថ្នល់ ឬផ្លូវលំដែលមានការប្រើប្រាស់ច្រើន និងនៅលើផ្លូវក្រាលកៅស៊ូ នៅពេលណាអាចធ្វើបាន។ ត្រូវប្រយ័ត្នចំពោះវត្ថុរាំងដំណើរនៅលើផ្លូវថ្នល់ ឬ លើផ្លូវលំ។

សំណល់ជាតិផ្ទុះពហុជាតិសាសន៍ ការិយាល័យទំនាក់ទំនងថ្នាក់ជាតិសម្រាប់ការកម្ចេចសំណល់ជាតិផ្ទុះនៃក្រុមបេសកកម្មរក្សាសន្តិភាព សង្កេតការណ៍ ឬហ្វឹកហ្វឺន ដើម្បីឲ្យពួកគេអាចចែករំលែកវាជាមួយអង្គការ និងសមាជិកបុគ្គលិកដទៃទៀត។

ហើយកុំភ្លេចជូនដំណឹងដល់អ្នកដទៃទៀតអំពីផែនការធ្វើដំណើររបស់អ្នក ទោះបីជាការធ្វើដំណើររបស់អ្នកមានលក្ខណៈជាឯកជន ឬសម្រាប់គោលបំណងការងារក៏ដោយ។

## 3.4.4 ប្រើសុភវិនិច្ឆ័យ

- កុំចូលទៅកាន់តំបន់ដែលគេដឹង ឬសង្ស័យថាញាំញីដោយសារមីន ហើយត្រូវប្រើប្រាស់តែផ្លូវដែលបានបោសសម្អាតមីន និងមានការអនុញ្ញាតប៉ុណ្ណោះ។
- កុំប៉ះពាល់ ឬចូលទៅជិតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ឬដែលគេបោះបង់ចោល ឬគ្រឿងផ្ទុះកែច្នៃ។ កុំចូលទៅជិតទីតាំង ឬគ្រឿងបរិក្ខារយោធា។
- កុំចូលទៅជិតយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ឬយុទ្ធភ័ណ្ឌដែលគេបោះបង់ចោល កាំភ្លើង ឬសម្ភារដែលគេបោះបង់ចោល ដែលមើលទៅឃើញនៅខុសកន្លែងដើម ពីព្រោះវាអាចជាអន្ទាក់/គ្រាប់បែកបង្កៃ។ នៅក្នុងស្ថានភាពជម្លោះ ជាការប្រសើរគួរតែសន្មត់ថា រថយន្ត និងទីតាំងយោធាដែលគេបោះចោលទាំងអស់ យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងយុទ្ធភ័ណ្ឌដែលគេបោះបង់ចោល សុទ្ធតែជាអន្ទាក់/គ្រាប់បែកបង្កៃ។ ត្រូវមានអ្នកឯកទេសត្រួតពិនិត្យឲ្យបានហ្មត់ចត់រកមើលវត្ថុមានអន្ទាក់/គ្រាប់បែកបង្កៃ និងគ្រឿងផ្ទុះកែច្នៃ។ ត្រូវប្រយ័ត្នចំពោះអ្វីមួយដែលមានខ្សែខុសធម្មតាចូលមកកាន់វា ឬចេញពីវា។ ដូចគ្នាដែរ សព្វាវុធដែលគេបោះបង់ចោល ក៏អាចត្រូវបានគេផ្ទុក និងស្ថិតក្នុងស្ថានភាពដែលគ្មានស្ថេរភាព ឬគ្មានអ្នកដឹងផងដែរ។
- កុំរើសយកវត្ថុអ្វីមួយដែលចាប់អារម្មណ៍ លុះត្រាតែអ្នកបានធ្វើឲ្យជ្រុះវាដោយខ្លួនអ្នក។







រូបភាពទី 3.15
(រូបភាពពីរដំបូង) នៅលើតំបន់ដែលបានធ្វើដំណើរ។ ត្រូវមានការត្រៀមខ្លួនក្នុងការត្រឡប់ក្រោយវិញ (នៅបាល់កង់)។ រូបថតរបស់ UNMAS/ Thomas Enke

រូបភាពទី 3.16
កុំបើកបរនៅលើគែមផ្លូវ ឬជាយផ្លូវ។ អ្នកបើកបររថយន្តកំពុងប្រថុយនឹងគ្រោះថ្នាក់ដែលមិនចាំបាច់។ រូបថតរបស់ UNMAS/ Thomas Enke

## 3.4.4 ប្រើសុភវិនិច្ឆ័យ

- ត្រូវដឹងថាត្រូវរាយការណ៍ជូននរណា និងរាយការណ៍អំពីអ្វីខ្លះ។ តាមធម្មតា មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីន និងអង្គការសកម្មភាពមីន តែងតែដោះស្រាយបញ្ហាគំរាមកំហែងដោយសារគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមដែលបង្កជាការគំរាមកំហែងមនុស្ស ឬវត្ថុរាំងដំណើរដល់ការអភិវឌ្ឍ ចំណែកយោធា និងនគរបាលតែងតែដោះស្រាយបញ្ហាយុទ្ធភ័ណ្ឌដែលគេបោះបង់ចោល និងគ្រឿងផ្ទុះកៃច្នៃដែលបង្កជាការគំរាមកំហែងផ្នែកសន្តិសុខ។
- ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ចំពោះចម្ការមីន តំបន់ដែលញាំញីដោយសំណល់ជាតិផ្ទុះពីសង្គ្រាម ឬគ្រឿងផ្ទុះកៃច្នៃដែលគេដឹង ឬមានការសង្ស័យនៅជិតៗនោះ ទោះបីជាតំបន់នោះមានដាក់សញ្ញាសម្គាល់ក្តី ឬគ្មានក្តី។ អំឡុងពេលស្ទង់មើលតំបន់ដែលបានដាក់មីន តំបន់ដែលមានគ្រោះថ្នាក់តូចតាចជាងនេះ អាចត្រូវបានគេមើលរំលង។ មីន ឬយុទ្ធភ័ណ្ឌក៏អាចចល័តដោយសារភ្លៀង និងសំណឹកដីផងដែរ។ បើអ្នកស្ថិតនៅជុំវិញតំបន់ដែលបានបោសសម្អាតមីន ឬសំណល់ជាតិផ្ទុះពីសង្គ្រាម សូមកុំទៅជិតក្រុមបោសសម្អាតមីន លុះត្រាតែមានគេអញ្ជើញឲ្យអ្នកចូលទៅ ហើយបន្ទាប់មកត្រូវគោរពតាមការណែនាំរបស់ពួកគេគ្រប់ពេលវេលា។
- ការបញ្ជូនព័ត៌មានតាមវិទ្យុទាក់ទង ឬទូរសព្ទដៃ បញ្ចេញនូវរលកវិទ្យុដែលអាចបង្កើតបានជាកិបអគ្គិសនីរបស់គ្រឿងឧបករណ៍ដែលបញ្ជាដោយវិទ្យុទាក់ទង ឬយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះប្រភេទមួយចំនួន។ ជៀសវាងធ្វើការបញ្ជូនព័ត៌មានតាមវិទ្យុទាក់ទង ឬទូរសព្ទដៃនៅជុំវិញយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ អន្ទាក់/គ្រាប់បែកបង្កៃ ឬគ្រឿងផ្ទុះកៃច្នៃ នៅចម្ងាយជិតជាង 50 ម៉ែត្រ។
- បើអ្នកកំពុងធ្វើសកម្មភាពសាងសង់ ជីកអណ្តូង ឬសាងសង់ស្ពាន ឬព្រែកជីក នៅតំបន់ទាំងឡាយដែលជាកម្មវត្ថុនៃការបំផ្ទុះគ្រាប់បែកទ្រង់ទ្រាយធំ ត្រូវដឹងថា អ្នកអាចជីកឃើញគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។ បើដូច្នោះមែន សូមបញ្ឈប់សកម្មភាពជីកភ្លាម រួចបោសសម្អាតការដ្ឋានរបស់កម្មករទាំងអស់ ហើយជូនដំណឹងដល់អាជ្ញាធរមូលដ្ឋាន។ កុំព្យាយាមចល័តយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ឬមីនទាំងនោះ។
- បើអ្នកគ្រោងបង្កើតការិយាល័យ ឬផ្ទះនៅក្នុងតំបន់ជម្លោះ ឬក្រោយជម្លោះ





រូបភាពទី 3.17
យុទ្ធភ័ណ្ឌដែលគេបោះបង់ចោល នៅជិតផ្លូវថ្នល់ មើលទៅចម្លែក (នៅអាហ្វហ្គានីស្ថាន)។ រូបថតរបស់ UNMAS/Thomas Enke

រូបភាពទី 3.18
យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ៖ គ្រាប់ផ្លោងប្រឆាំងយន្តហោះមានរំសេវផ្ទុះខ្លាំង ធុន 20 mmដែលមើលទៅដូចថ្មមួយដុំ (នៅអាហ្វហ្គានីស្ថាន)។ រូបថតរបស់ UNMAS/Thomas Enke

ត្រូវពិនិត្យឲ្យដឹងថាតំបន់ដែលនៅជិតៗនោះពុំមានឃ្លាំងទុកសព្វាវុធ ឬ គ្រាប់រំសេវដែលគេបានបោះបង់ចោល ឬផ្សេងពីនេះឡើយ។ ការនៅក្បែរ ឃ្លាំងទុកសព្វាវុធ ឬគ្រាប់រំសេវ តែងតែបង្កហានិភ័យ ហើយបើមានការ ប្រើប្រាស់យ៉ាងសកម្ម អាចនឹងរងការវាយប្រហារ។



រូបភាពទី 3.19 ផ្លូវថ្នល់នៅអាហ្វហ្គានីស្ថាន ដែលមានថ្មជាសញ្ញាសម្គាល់ពណ៌ក្រហម និងពណ៌ស។ នៅខាងពណ៌សជានិច្ច! រូបថតរបស់ UNMAS/Thomas Enke

### 3.4.4.1 ការធ្វើដំណើរតាមរថយន្ត

- ជូនដំណឹងដល់ការិយាល័យរបស់អ្នកអំពីកាលបរិច្ឆេទ ពេលម៉ោង និង ផ្លូវធ្វើដំណើរដែលអ្នកបានធ្វើផែនការទុក ដោយបំពេញនៅលើលម្អិតបញ្ជាក់កម្មវិធីធ្វើដំណើរ។ (ឧទាហរណ៍អំពីផែនទីបង្ហាញផ្លូវ មាននៅក្នុង ឧបសម្ព័ន្ធ 1 ព្រមទាំងការបរិយាយអំពីរបៀបប្រើប្រាស់វាផងដែរ។) បើអ្នក ផ្លាស់ប្តូរផ្លូវរបស់អ្នក សូមជូនដំណឹងដល់ការិយាល័យរបស់អ្នក។ បើអ្នក មិនអាចប្រាស្រ័យទាក់ទងបានទេនោះ យកល្អត្រូវកុំងាកចេញពីផ្លូវដែល បានគ្រោងទុក។ ត្រូវដឹងថា បើអ្នកមិនអាចមកដល់គោលដៅរបស់អ្នក ឬ ត្រឡប់មកវិញតាមម៉ោងកំណត់ អង្គការរបស់អ្នកនឹងមកតាមរកអ្នក។
- នៅពេលណាអាចធ្វើបាន ត្រូវធ្វើដំណើរដោយមានអ្នកអមដំណើរម្នាក់ យកល្អត្រូវជាអ្នកដែលស្គាល់តំបន់ និងផ្លូវដែលអ្នកត្រូវការប្រើ បើអ្នកមិន ស្គាល់តំបន់ ឬផ្លូវនោះ។ ភាគច្រើន ការធ្វើដំណើរតាមរថយន្តពីរគ្រឿង គឺ ជាការប្រសើរបំផុត។
- បើកបរដោយប្រុងប្រយ័ត្ន គោរពតាមវិន័យ និងតាមលំដាប់លំដោយដែល បានបញ្ជា។ រក្សាចម្ងាយចន្លោះពីរថយន្តមួយទៅមួយទៀត និងត្រូវមាន ការប្រុងប្រយ័ត្នក្នុងការឈប់ភ្លាមៗ អាស្រ័យទៅលើការគំរាមកំហែងដោយ គ្រឿងផ្ទុះ និងការប្រើប្រាស់វិធានការទប់ទល់ប្រឆាំងអេឡិចត្រូនិច។
- នៅពេលចាប់ផ្តើមការធ្វើដំណើរនៅពេលព្រឹក ត្រូវទុកពេលគ្រប់គ្រាន់ ដើម្បីឲ្យចរាចរណ៍ក្នុងមូលដ្ឋានមានការថយចុះ មុនពេលចេញដំណើរ របស់អ្នក។ ប្រកាន់ខ្ជាប់ទៅនឹងផ្លូវដែលមានគេធ្វើដំណើរច្រើន ហើយត្រូវ ស្ថិតនៅក្នុងតំបន់ផ្លូវដែលមានគេធ្វើដំណើរ។ រៀបចំផែនការសម្រាប់ការធ្វើ ដំណើររបស់អ្នកឲ្យបានល្អ ជៀសវាងការប្រើប្រាស់ផ្លូវដែលមានគ្រោះថ្នាក់

ក្រោយពីមានភ្លៀងធ្លាក់ជោគជាំ និងពេញមួយរដូវវស្សា៖ ជង្ហុកផ្លូវមានលិចទឹកជ្រៅៗ អាចជំរុញឲ្យអ្នកចាកចេញពីតំបន់ "សុវត្ថិភាព"។ មីនអាចត្រូវបានចល័ត ឬបង្ហាញឲ្យឃើញដោយសារភ្លៀង។

- កុំធ្វើដំណើរនៅពេលយប់។ ធ្វើផែនការដំណើររបស់អ្នកឲ្យចប់ក្នុងរយៈពេលពីរម៉ោង មុនពេលថ្ងៃលិច។ ការណ៍នេះ នឹងធ្វើឲ្យអ្នក និងទីបញ្ជាការរបស់អ្នកមានរយៈពេលពីរម៉ោងដែលនៅភ្លឺក្នុងការឆ្លើយតបទៅនឹងគ្រោះអាសន្នណាមួយ។ បន្ថែមពីលើនេះទៀត សញ្ញា និងតម្រុយព្រមានប្រាប់អំពីមីន មិនអាចមើលឃើញនៅពេលយប់បានឡើយ។
- នៅពេលណាអាចធ្វើបាន ត្រូវស្ថិតនៅលើផ្លូវក្រាលកៅស៊ូជានិច្ច ទោះបីជាវាមានន័យថា ការធ្វើដំណើរនឹងកាន់តែយូរក៏ដោយ។ ជាទូទៅ ផ្លូវក្រាលកៅស៊ូទំនងជាមិនសូវមានគេដាក់មីនជាងផ្លូវមិនក្រាលកៅស៊ូ។ ទោះជាយ៉ាងណា ជង្ហុកផ្លូវ និងជាយផ្លូវ (ឬគែមផ្លូវ) របស់ផ្លូវក្រាលកៅស៊ូ ផ្ដល់ឱកាសក្នុងការលាក់បង្កប់មីន ដូច្នេះត្រូវជៀសវាងជង្ហុកផ្លូវ និងជៀសវាងការបើកបរចុះពីផ្លូវក្រាលកៅស៊ូ។ កុំចាកចេញពីផ្លូវថ្នល់ ឬដានផ្លូវសំខាន់នៅពេលបត់រថយន្តរបស់អ្នក។ បើរថយន្តរបស់អ្នកធ្លាយកង់ ឬរថយន្តនោះខូច កុំអូសមកអែបខាងផ្លូវ ប៉ុន្តែគួរតែជួសជុលវានៅលើចំណែកផ្លូវដែលឃើញមានការប្រើប្រាស់ជាក់ស្ដែង ឬមានក្រាលកៅស៊ូ។
- នៅលើផ្លូវដីភក់ ត្រូវស្ថិតនៅលើដានផ្លូវដែលធ្វើដំណើរបានស្រួលជានិច្ច។ ដានផ្លូវត្រូវមានទំហំធំល្មមសម្រាប់រថយន្តរបស់អ្នក។ ឧទាហរណ៍ កង់រថយន្តធុនធំ មានទំហំទូលាយជាងកង់រថយន្តដែលដំណើរការដោយកង់បួន។ វាអាចពង្រីកចេញក្រៅដានផ្លូវដែលមានស្រាប់។
- ត្រូវប្រយ័ត្នឧបសគ្គនៅលើផ្លូវថ្នល់ ឬផ្លូវលំ។ ឧបសគ្គនៅលើផ្លូវថ្នល់ អាចជាផ្លូវវាងដែលត្រូវបានរៀបចំឡើងដើម្បីធ្វើឲ្យអ្នកដើរជាន់ពីលើ ឬបើកបរចុះពីផ្លូវថ្នល់ទៅកាន់ចម្ការមីន។ កុំចេញពីផ្លូវថ្នល់ដើម្បីឲ្យរថយន្តឆ្លងកាត់ ទៅឲ្យទាន់គេ ឆ្លងកាត់ឧបសគ្គ ឬផ្ទៃលជុំវិញ។ បើចាំបាច់ ត្រូវត្រឡប់ក្រោយវិញ រហូតដល់រកឃើញមានចំណែកផ្លូវដែលមានសុវត្ថិភាព។ ត្រូវប្រយ័ត្នចំពោះការចេញពីទ្រូងផ្លូវទៅកាន់កន្លែងចតនៅចំហៀងផ្លូវ ពីព្រោះវាអាចមានគេដាក់មីន។

- កំណត់មុំ និងចំណែកផ្លូវដែលមើលឃើញនៅចន្លោះអ្នកធ្វើដំណើរនៅក្នុងរថយន្ត។
- រកមើលសញ្ញាសម្គាល់ និងសញ្ញានៅលើដី។ សម្លៀកបំពាក់ខុសប្លែកពីធម្មតានៅលើដើមឈើ ថ្មពីរឬបីដុំ អាចជាតម្រុយប្រាប់ថាមានការវាយប្រហារដោយគ្រឿងផ្ទុះកែច្នៃ។
- ត្រូវមានការប្រុងប្រយ័ត្នជាពិសេសនៅចំណុចគ្រោះថ្នាក់ខ្លាំងដូចជា ស្ពាន ផ្លូវបំបែក ចំណុចឈប់ និងចំណុចបន្ថយល្បឿន។ ចំណុចទាំងនេះ មានការទាក់ទាញបំផុតសម្រាប់ការវាយប្រហារដោយគ្រឿងផ្ទុះកែច្នៃ។ កុំបើកបរជុំវិញរនាំងបិទផ្លូវរបស់អតីតទីតាំងយោធា។ កុំបើកបរពីលើវត្ថុណាមួយនៅលើផ្លូវថ្នល់។ ថង់ក្រដាស ក្រណាត់មួយកំណាត់ ឬក្តារឈើសុទ្ធតែអាចលាក់កំបាំងមីន អន្ទាក់/គ្រាប់បែកបង្កៃ ឬគ្រឿងផ្ទុះកែច្នៃ។ បើកបរដោយយកចិត្តទុកដាក់ ក្នុងល្បឿនយឺតៗ។
- កុំចេញពីផ្លូវថ្នល់ដោយហេតុផលណាមួយ ទោះបីជាត្រូវសម្រាកឲ្យបាត់ហត់ក៏ដោយ។ ឈប់នៅកន្លែងដែលបានធ្វើដំណើរ និងដើរនៅពីក្រោយរថយន្តរបស់អ្នក។
- ជៀសវាងផ្លូវ ឬតំបន់ដែលធ្លាប់រងការវាយប្រហារដោយប្រើគ្រឿងផ្ទុះកែច្នៃ ហើយត្រូវជៀសវាងតំបន់ទាំងនេះ ពីព្រោះយើងមិនអាចប៉ាន់ស្មានថានឹងមានការវាយប្រហារលើកក្រោយនៅពេលណាបានឡើយ។
- ផ្លូវថ្នល់ដែលប្រើប្រាស់បានស្រួលនៅពេលថ្ងៃ អាចជាពុំស្រួលនៅពេលយប់ឡើយ បើមានក្រុមដែលមានជម្លោះកំពុងតែមានសកម្មភាពនៅក្នុងតំបន់នោះ។ គួរយកចិត្តទុកដាក់នៅពេលចូលទៅកាន់ទីប្រជុំជន ឬភូមិនៅពេលព្រឹកព្រលឹម ឬពេលព្រលប់ ពីព្រោះជួនកាលមានគេដាក់មីនដើម្បីការពារនៅពេលយប់ងងឹត។ គ្រាន់តែគោរពតាមវិធាននេះ ដោយទុកឲ្យចរាចរណ៍នាំមុខអ្នកនៅពេលព្រឹក ហើយមិនត្រូវធ្វើដំណើរក្រោយពេលងងឹតនៅតំបន់ដែលរងផលប៉ះពាល់ដោយសារមីនឡើយ។
- ពាក់ខ្សែក្រវ៉ាត់ការពារសុវត្ថិភាពគ្រប់ពេលវេលា។ បន្ទុះរបស់មីន ឬគ្រឿងផ្ទុះកែច្នៃ អាចរុញច្រានអ្នកដំណើរទៅបុកនឹងដំបូលរថយន្តដែលបង្កឲ្យមានរបួសធ្ងន់ធ្ងរនៅត្រង់ក្បាល ឬត្រង់ក ឬវាអាចធ្វើឲ្យរថយន្តក្រឡាប់

ដោយគ្រវែងអ្នកដំណើរជុំវិញកាប៊ីន ជួនកាលអាចបណ្តាលឲ្យស្លាប់ ឬ របួសបើគ្មានការបង្ការ។

- មុនពេលអ្នកឈប់រថយន្ត ត្រូវរកមើលដងចបជីកសម្រាប់ជីករណ្តៅ ឬ ស្នាមជីកនៅលើដី។ ហាមចតរថយន្តរបស់អ្នកនៅត្រង់ចំណុចនេះ។ នៅពេលឈប់ម្តងៗ (ដោយគ្រោងទុក ឬពុំបានគ្រោងទុក) ធ្វើការត្រួតពិនិត្យក្នុងចម្ងាយ 5/25 ម ដូចមានបង្ហាញនៅក្នុង ឧបសម្ព័ន្ធ A3។
- ធានាថា អ្នកបើកបររបស់អ្នក បានទទួលការបណ្តុះបណ្តាលអំពីសុវត្ថិភាពសម្រាប់អ្នកបើកបរ។

### 3.4.4.2 ការធ្វើដំណើរដោយថ្មើរជើង

- ទុកឲ្យអ្នកនាំផ្លូវជាអ្នកនាំផ្លូវអ្នក។ ទុកឲ្យមានចម្ងាយយ៉ាងហោចណាស់ប្រាំម៉ែត្រ ប៉ុន្តែយកល្អគួរតែ 25 ម៉ែត្រ ចន្លោះពីសមាជិកម្នាក់ទៅសមាជិកម្នាក់ទៀតក្នុងក្រុម។
- កុំដើរកាត់តាមតំបន់ដែលមានរុក្ខជាតិដុះទ្រុបទ្រុល។ ជំនួសមកវិញ ត្រូវប្រកាន់ខ្ជាប់ទៅនឹងចិញ្ចើមផ្លូវដែលមានក្រាលកៅស៊ូ និងផ្លូវលំដែលមានអ្នកប្រើប្រាស់ច្រើន។
- ត្រូវកាន់គ្រឿងបរិក្ខារ/វិទ្យុទាក់ទង និងឈុតគ្រឿងសង្គ្រោះបឋមគ្រប់ពេលវេលា។ កុំទុកវាចោលនៅក្នុងរថយន្តរបស់អ្នក។ សម្ភារទាំងនេះគួរតែកាន់ដោយមនុស្សម្នាក់ដែលដើរនៅចំកណ្តាលក្រុម ឬឆ្ពោះទៅខាងក្រោយ ហើយមិនមែនកាន់ដោយអ្នកនាំផ្លូវឡើយ។
- កុំចល័តវត្ថុរារាំងដំណើរ ពីព្រោះអាចមានគេដាក់មីន ឬអន្ទាក់/គ្រាប់បែកបង្កប់។

- កុំចូលទៅកាន់អគារដែលគេបោះបង់ចោល កុំដើរក្រោមស្ពាន ឬទៅទស្សនកិច្ចទីតាំងដែលគេបោះបង់ចោល។ ប្រឹក្សាជាមួយប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងសង្កេតមើលការប្រព្រឹត្តរបស់ពួកគេ ដើម្បីស្វែងយល់បន្ថែមអំពីតំបន់មានសុវត្ថិភាពនៅក្នុងសហគមន៍។
- បដិសេធនៅពេលដែលអ្នកណាម្នាក់ចង់យកមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ឬគ្រឿងផ្ទុះកែច្នៃមកបង្ហាញអ្នក។
- កុំប៉ះពាល់វត្ថុដែលមិនស្គាល់ ឬមិនដឹងនៅក្នុងតំបន់ដែលញាំញីដោយមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម/គ្រឿងផ្ទុះកែច្នៃ។ កុំប្រមូលវត្ថុអនុស្សាវរីយ៍ពីសង្គ្រាម ហើយកុំចូលទៅជិតរថយន្ត ឬទីកន្លែងយោធាដែលគេបានបោះបង់ចោល។
- កំណត់មុំ និងចំណែកផ្លូវដែលមើលឃើញនៅចន្លោះសមាជិកក្រុម។
- រកមើលសញ្ញាសម្គាល់ និងសញ្ញាលើដី។ សម្លៀកបំពាក់ខុសប្លែកពីធម្មតានៅលើដើមឈើ ថ្មពីរឬបីដុំ អាចជាតម្រុយប្រាប់ថាមានការវាយប្រហារដោយគ្រឿងផ្ទុះកែច្នៃ។
- ត្រូវមានការប្រុងប្រយ័ត្នជាពិសេសនៅចំណុចគ្រោះថ្នាក់ខ្លាំងដូចជា ស្ពានផ្លូវបំបែក ចំណុចឈប់ និងចំណុចបន្ថយល្បឿន។ ចំណុចទាំងនេះ មានការទាក់ទាញបំផុតសម្រាប់ការវាយប្រហារដោយគ្រឿងផ្ទុះកែច្នៃ។
- កុំដើរជាន់ពីលើដងចបជីក និងរណ្តៅ ឬស្នាមជីកនៅលើដី។
- គោរពតាមវិធានសម្រាប់ការងារ និងការធ្វើដំណើរជាលក្ខណៈឯកជនទាំងនេះ នៅក្នុងតំបន់ដែលគេដឹង ឬសង្ស័យថាមានគ្រោះថ្នាក់។

  ជានិច្ចកាល ត្រូវធានាឲ្យបានថា អ្នកបានជូនដំណឹងដល់នរណាម្នាក់អំពីផែនការធ្វើដំណើររបស់អ្នក។
- សរុបមក ត្រូវមានការប្រុងប្រយ័ត្នជានិច្ច។



សាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ
រូបថតរបស់ UNMAS/Marc Vailant



# ផ្នែកទី 4

# នីតិវិធី គ្រាមានអាសន្ន

# នីតិវិធីគ្រាមានអាសន្ន

## 4.1 នីតិវិធីគ្រាមានអាសន្ននៅក្នុងតំបន់ដែលញាំញីដោយវត្ថុផ្ទុះ ឬចម្ការមីន

នៅពេលស្ថិតនៅក្នុងតំបន់ដែលមានយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងដែលគេបោះបង់ចោល "ការមិនចូលទៅជិត" និង "ការមិនប៉ះពាល់" គឺជាគោលការណ៍សុវត្ថិភាពមូលដ្ឋានដែលត្រូវរក្សាឲ្យអ្នកមានសុវត្ថិភាព។ បើអ្នកឃើញយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះណាមួយ ឬអ្នកបានចូលទៅកាន់តំបន់ណាមួយដែលពោរពេញដោយយុទ្ធភ័ណ្ឌ វាមិនមែនត្រូវតែមានន័យថាអ្នកស្ថិតនៅក្នុងចម្ការមីនឡើយ។ តាមធម្មតា អ្នកឯកទេសតែងតែហៅតំបន់នេះថាជាសមរភូមិ។ នៅក្នុងតំបន់បែបនេះ យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដូចជា គ្រាប់បែកតូចៗ ឬគ្រាប់ផ្សេងៗទៀត អាចឃើញមាននៅលើដីនៅលើដើមឈើ ឬនៅកន្លែងផ្សេងទៀត។ កន្លែងទាំងនេះមិនមែនមានគ្រោះថ្នាក់តិចជាងចម្ការមីនឡើយ ហើយភាគច្រើននៃសេចក្តីណែនាំនៅពេលខាងមុខគឺដូចគ្នា។ គោលការណ៍ដែលល្អបំផុតគឺ ត្រូវជៀសវាងតំបន់ទាំងនេះ ប៉ុន្តែត្រូវរាយការណ៍អំពីអ្វីដែលអ្នកសង្កេតឃើញដើម្បីធានាថា មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីន (MAC) ឬអាជ្ញាធរពាក់ព័ន្ធផ្សេងទៀត ដូចមានរៀបរាប់ពីខាងដើមមកបានដឹងអំពីការគំរាមកំហែងជាក់លាក់នោះ។

ទោះជាយ៉ាងណា បើអ្នកប្រទះឃើញតម្រុយព្រមានអំពីមីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ/គ្រឿងផ្ទុះកែច្នៃ (ឧទាហរណ៍ មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដែលបង្ហាញឲ្យឃើញ ឬរណ្តៅដែលមានផ្ទុះមីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ) អ្នកគួរតែសន្មត់ថា អ្នកស្ថិតនៅក្នុងតំបន់គ្រោះថ្នាក់ លើកលែងតែអ្នកប្រាកដក្នុងចិត្តថាអ្នកស្ថិតនៅលើផ្លូវថ្នល់ ឬផ្លូវលំដែលមានសុវត្ថិភាព។ នៅពេលណាស្ថិតនៅក្នុងតំបន់បែបនេះ មានកិច្ចការតិចតួចបំផុតដែលអ្នកមិនមែនឯកទេសអាចធ្វើបាន ហើយជំនាញដែលត្រូវការសម្រាប់ដោះស្រាយជាមួយនឹងគ្រឿងផ្ទុះទាំងនេះ និងស្ថានភាពនៅក្នុងចម្ការមីនមិនអាចបង្រៀនបាន ឬរៀនបានដោយចៃដន្យបានឡើយ។



រូបភាពទី 4.1
សំណល់ជាតិផ្ទុះពីសង្គ្រាមដែលគ្របដណ្តប់ដោយឫសឈើ និងស្លឹកឈើ ពុំមានភាពងាយស្រួលក្នុងការរកឡើយ (នៅបាល់កង់)។ រូបថតរបស់ UNMAS/Thomas Enke

ផ្នែកនេះ បង្ហាញពីនីតិវិធីគ្រាមានអាសន្នទូទៅមួយចំនួន បើអ្នកគិតថាអ្នកស្ថិតនៅក្នុងតំបន់ដែលញាំញីដោយជាតិផ្ទុះ ឬចម្ការមីន។

## 4.1.1 នីតិវិធីគ្រាមានអាសន្នដោយថ្មើរជើង

មធ្យោបាយពីរដែលទំនងបំផុតដែលអ្នកនឹងដឹងថាអ្នកកំពុងស្ថិតនៅក្នុងតំបន់មានមីនគឺ មានការផ្ទុះ ឬអ្នកឃើញមានមីន ឬសញ្ញាមីន។ បើមាននរណាម្នាក់រងរបួស អ្នកមិនត្រូវរត់ទៅជួយដោយតក់ក្រហល់ពេកទេ ពីព្រោះអាចជានឹងបង្កគ្រោះថ្នាក់ដល់ខ្លួនឯង និងអ្នកដទៃដែលនៅជុំវិញអ្នក។ បើអ្នកយល់ថាអ្នកកំពុងស្ថិតនៅក្នុងចម្ការមីន តាំងចិត្តឲ្យស្ងប់ ហើយធ្វើតាមវិធានទាំងនេះ។

ឈ ឈប់ចលនាភ្លាមៗ។ ឈប់! នៅឲ្យស្ងៀម ហើយកុំកម្រើកជើងរបស់អ្នក។
ជូ ជូនដំណឹង និងព្រមានអ្នកដែលនៅជុំវិញខ្លួនអ្នក។ ទូរស័ព្ទសុំជំនួយ ប៉ុន្តែរក្សាឲ្យអ្នកដទៃទៀតនៅឆ្ងាយ។
ក កត់ចំណាំតំបន់នោះ។ តើអ្នកអាចមើលឃើញអ្វីខ្លះទៀត៖ មីន ខ្សែអន្ទាក់/គ្រាប់បែកបង្កៃ សញ្ញាមីន? ប្រើភ្នែកកំណត់រកទីតាំងតំបន់សុវត្ថិភាពដែលនៅជិតបំផុត៖ កន្លែងចុងក្រោយដែលអ្នកបានដឹងថាអ្នកស្ថិតនៅលើផ្ទៃដីដែលមានសុវត្ថិភាព ដូចជា ផ្លូវក្រាលកៅស៊ូ ផ្លូវលំដែលមានការប្រើប្រាស់ច្រើន គ្រឿងបង្គុំបេតុង ឬដែក។
វា វាយតម្លៃសកម្មភាពរបស់អ្នក។ ត្រៀមគ្រប់គ្រងស្ថានការណ៍។
កុំ កុំកម្រើក បើពុំមានការបញ្ជាក់ប្រាប់ណាមួយអំពីតំបន់សុវត្ថិភាព ឬបើអ្នកមិនអាចឈានទៅដល់វាដោយពុំបានដើរជាន់លើដីដែលមិនបានស្គាល់។ រង់ចាំជំនួយមកដល់។

ខណៈពេលរង់ចាំជំនួយ អ្នកឃើញហាក់ដូចជាមានការឆ្លើយតបដែលមិនគ្រប់គ្រាន់។ បើអ្នកបានគោរពតាមនីតិវិធីការពារសុវត្ថិភាពត្រឹមត្រូវទាក់ទងនឹងការធ្វើដំណើរនោះ វាគ្រាន់តែជាបញ្ហាពេលវេលាប៉ុណ្ណោះ មុនពេលដែលបុគ្គលិកដែលមានសមត្ថភាពគ្រប់គ្រាន់បានមកជួយអ្នក។ ប្រសិនបើអ្នកមិនធ្វើបែបនេះទេ ផលវិបាកអាចជា ការស្លាប់ ឬរបួសធ្ងន់ធ្ងរ។

ត្រូវប្រុងប្រយ័ត្នចំពោះអ្នកមិនមែនឯកទេសដែលមកជួយអ្នក។ ពួកគេអាចជាមិនបានដឹងអំពីវិសាលភាពទាំងស្រុងនៃគ្រោះថ្នាក់ ឬមានទំនុកច្រើនហួសទៅលើចំណេះដឹងដែលមានកម្រិតរបស់ខ្លួន។ ជួនកាល មនុស្សប្រថុយនឹងហានិភ័យដែលមិនអាចទទួលយកបានក្នុងការជួយសង្គ្រោះអ្នករងរបួសណាម្នាក់។

### 4.1.1.1 ដាក់សញ្ញាសម្គាល់ និងរាយការណ៍

បើអ្នកជួបប្រទះមីន ឬយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ អ្នកគួររាយការណ៍អំពីទីតាំងនោះប្រាប់មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីន និងអាជ្ញាធរពាក់ព័ន្ធផ្សេងទៀត (មេភូមិ នគរបាល បុគ្គលិកយោធា ឬអង្គការបោសសម្អាតមីនដែលនៅជិតបំផុត) ដូចមានរៀបរាប់ខាងលើ។

កម្មវិធីមួយចំនួន ផ្ដល់ដំបូន្មានឲ្យប្រជាពលរដ្ឋដាក់សញ្ញាសម្គាល់តំបន់ដែលមានមីន ដើម្បីព្រមានដល់អ្នកដទៃទៀតអំពីគ្រោះថ្នាក់នោះ។ នៅក្នុងករណីមួយចំនួន ការដាក់សញ្ញាសម្គាល់អាចមានគ្រោះថ្នាក់ ពីព្រោះអ្នកត្រូវតែស្វែងរក និងដាក់សញ្ញាសម្គាល់ដែលសមស្រប ដូច្នេះហើយ នៅតែស្ថិតក្នុងតំបន់មីនមួយនោះ

រូបទាពទី 4.2
ការដាក់សញ្ញាសម្គាល់តំបន់គ្រោះថ្នាក់ គួរតែធ្វើឡើងដោយការយកចិត្តទុកដាក់ និងប្រកបដោយសុវត្ថិភាព (នៅបាល់កង់)។
រូបថតរបស់ UNMAS/Thomas Enke



និងប្រហែលជាមីនផ្សេងៗទៀតផងដែរ។ បន្ថែមពីលើនេះទៀត វាអាចជាពុំមានភាពច្បាស់លាស់ចំពោះអ្នកដទៃ នៅពេលមីនពាក់ព័ន្ធនឹងសញ្ញាសម្គាល់។

ចំណុចសំខាន់ៗមួយចំនួនអំពីការដាក់សញ្ញាសម្គាល់ដែលត្រូវចងចាំមានជាអាទិ៍៖

- កុំចាកចេញពីផ្លូវដែលមានសុវត្ថិភាព ឬពុំដូច្នោះទេត្រូវដាក់សញ្ញាព្រមាន
- សញ្ញាដែលអ្នកបង្កើត ត្រូវតែអាចមើលឃើញ និងអាចស្គាល់ដោយមនុស្សពេញវ័យ និងកុមារ។ អ្នកត្រូវដឹងអំពីការដាក់សញ្ញាដែលគេនិយមប្រើប្រាស់នៅក្នុងតំបន់នោះ
- សញ្ញាគួរដាក់នៅតំបន់ដែលមានសុវត្ថិភាព មិនមែននៅលើដីដែលមានមីននោះឡើយ
- កុំដាក់សញ្ញាសម្គាល់លើមីននីមួយៗ ប៉ុន្តែត្រូវផ្តល់ការបញ្ជាក់ប្រាប់ច្បាស់លាស់ថា មានគ្រោះថ្នាក់ និង
- ពិនិត្យជាមួយអង្គការរបស់អ្នក ទាក់ទងនឹងការដាក់សញ្ញារបស់អង្គការ។




រូបភាពទី 4.3
កុំចាកចេញពីផ្លូវដែលមានសុវត្ថិភាព (នៅបាល់កង់)។
រូបថតរបស់ UNMAS/Thomas Enke

## 4.1.1.2 ដើរត្រឡប់តាមផ្លូវដដែល

ការដើរត្រឡប់តាមផ្លូវដដែល គឺជានីតិវិធីមួយសម្រាប់ចាកចេញពីតំបន់មានមីន ដោយដើរត្រឡប់មកតាមផ្លូវដែលអ្នកបានចូលមក ឲ្យត្រូវតាមគន្លងជើងរបស់អ្នកដែរ។ ការដើរត្រឡប់តាមផ្លូវដដែល មិនមែនជាជម្រើសដែលមានសុវត្ថិភាពក្នុងការចាកចេញពីចម្ការមីនឡើយ ពីព្រោះវាមិនទំនងថាដានជើងរបស់អ្នកអាចមើលឃើញពិតប្រាកដវិញទេ លើកលែងតែអ្នកដើរនៅលើដីភក់ ឬព្រិល។ ទោះបីជានៅពេលដែលអ្នកអាចមើលឃើញដានជើងក៏ដោយ ក៏នីតិវិធីនេះមានគ្រោះថ្នាក់បំផុតដែរ ពីព្រោះអ្នកអាចជានឹងជំពប់ជើង ដួល ឬដាក់ជើងរបស់អ្នកមិនត្រូវតាមគន្លងចាស់។ ត្រូវប្រុងប្រយ័ត្នផងដែរថា អាចមានខ្សែអន្ទាក់/គ្រាប់បែកបង្កៃដែលមានតង់ស្យុងទាបដែលពុំបានមើលឃើញនៅតាមផ្លូវទៅកាន់ភូមិសាស្ត្រនោះដែលអាចមានគេប៉ះពាល់ ហើយបណ្តាលឲ្យមីននោះផ្ទុះឡើង។

នៅបណ្តាប្រទេសមួយចំនួន ការរង់ចាំជំនួយមកដល់ អាចជាពុំអាចអនុវត្តបាន ឬមានសុវត្ថិភាពឡើយ។ បើអ្នកចង់រៀនសូត្រអំពីវិធីដើរត្រឡប់តាមផ្លូវដដែលរបស់អ្នកដើម្បីចាកចេញពីចម្ការមីន ត្រូវតែប្រឹក្សាយោបល់ជាមួយអ្នកឯកទេសមកពីមជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីន ហើយត្រូវតែរៀនសូត្រអំពីនីតិវិធីត្រឹមត្រូវតាមរយៈការហ្វឹកហាត់ជាក់ស្តែង។

ត្រូវរក្សាឲ្យបញ្ជីរាយនាមមនុស្សទំនាក់ទំនងគ្រាមានអាសន្ន ថ្មីជានិច្ច!

ដឹងពីរបៀបរាយការណ៍អំពីគ្រោះអាសន្ន៖ អ្វី កន្លែងណា ពេលណា? តើមានជនរងគ្រោះប៉ុន្មាននាក់?

### 4.1.1.3 ការចាក់រុកដី

ការចាក់រុកដី គឺជាវិធីមួយផ្សេងទៀតក្នុងការចាកចេញពីតំបន់មានមីន ដោយកំណត់ទីតាំងដីដែលមានសុវត្ថិភាពដែលត្រូវដើរទៅកាន់តំបន់សុវត្ថិភាព។ កំណត់រកទីតាំងដីដែលគ្មានមីនតាមរយៈការចាក់រុកដីដោយកូនកាំបិត ឬវត្ថុផ្សេងទៀតដែលស្រដៀងគ្នានេះ។ ការចាក់រុកដី គឺជាបច្ចេកទេសដែលពិបាក ចំណាយពេលយូរ និងប្រថុយនឹងគ្រោះថ្នាក់ខ្លាំងបំផុតដែលត្រូវបានគេបង្រៀនដល់អ្នកបោសសម្អាតមីនអាជីព ហើយទាមទារឲ្យមានការហ្វឹកហាត់ជាច្រើន។ ការចាក់រុកដី ត្រូវធ្វើឡើងដោយហ្មត់ចត់ និងដោយការយកចិត្តទុកដាក់។ វាទាមទារឲ្យមានចំណេះដឹងពិស្តារអំពីវិធីរាវរកមីន និងប្រភេទមីន និងបរិក្ខារដែលសមស្រប។ គួរពិចារណាប្រើប្រាស់ការចាក់រុកដីតែនៅពេលដែលអ្នកបានទទួលការហ្វឹកហ្វឺនអាជីព និងមានការទទួលស្គាល់ប៉ុណ្ណោះ ហើយពុំមានជម្រើសផ្សេងក្រៅពីជម្រើសទាំងឡាយដែលបានរៀបរាប់ខាងលើឡើយ ឧទាហរណ៍៖

- បើអ្នកស្ថិតនៅក្នុងតំបន់មានមីន ហើយពុំអាចរកជំនួយបាន
- បើអ្នកស្ថិតនៅក្នុងតំបន់មានមីន ហើយស្ថិតក្រោមការវាយប្រហារផ្ទាល់
- បើមានបុគ្គលណាម្នាក់រងរបួស ហើយមិនអាចចាកចេញពីចម្ការមីន ហើយពុំអាចរកបានជំនួយផ្សេងទៀត។

ស្ថានភាពបែបនេះ មិនទំនងជាកើតឡើងទាល់តែសោះ។ ពិនិត្យជាមួយគោលការណ៍ស្តីពីការចាក់រុកដីរបស់អង្គការអ្នក!

## 4.1.2 នីតិវិធីគ្រាមានអាសន្ននៅក្នុងរថយន្ត

បើអ្នកមានហេតុផលណាមួយដែលជឿជាក់ថាអ្នកបានបើកបរចូលទៅក្នុងតំបន់មានមីន ដូចជា រថយន្តមួយទៀតដែលធ្វើឲ្យមីនផ្ទុះ ដោយឃើញមានមីន ឬ សញ្ញាមីន ឬបើរថយន្តបានបុកប៉ះគ្រាប់មីន គួរប្រតិបត្តិតាមជំហានទាំងឡាយដូចតទៅ៖

**ឈ** ឈប់ចលនាភ្លាមៗ។ ឈប់រថយន្ត! កុំព្យាយាមត្រឡប់ក្រោយចេញពីតំបន់នោះ ហើយកុំកម្រើកដៃចង្កូត។ តាំងចិត្តឲ្យស្ងប់ ហើយ(បើអាចធ្វើបាន) ត្រូវនៅក្នុងរថយន្តនោះ។

**ជូ** ជូនដំណឹង និងព្រមានអ្នកដែលនៅជុំវិញខ្លួនអ្នក។ ទូរស័ព្ទសុំជំនួយ ប៉ុន្តែរក្សាឲ្យអ្នកដទៃទៀតនៅឆ្ងាយ។ ប្រើស៊ីផ្លេរថយន្តដើម្បីហៅជំនួយ។

**ក** កត់ចំណាំតំបន់នោះ។ តើអ្នកអាចមើលឃើញអ្វីខ្លះទៀត៖ មីន ខ្សែអន្ទាក់/គ្រាប់បែកបង្កៃ សញ្ញាមីន? ប្រើភ្នែកកំណត់រកទីតាំងតំបន់សុវត្ថិភាពដែលនៅជិតបំផុត៖ កន្លែងចុងក្រោយដែលអ្នកបានដឹងថាអ្នកស្ថិតនៅលើផ្ទៃដីដែលមានសុវត្ថិភាព ដូចជា ផ្លូវក្រាលកៅស៊ូ ផ្លូវលំដែលមានការប្រើប្រាស់ច្រើន។

**វា** វាយតម្លៃសកម្មភាពរបស់អ្នក។ ត្រៀមគ្រប់គ្រងស្ថានការណ៍។

**កុំ** កុំកម្រើក បើពុំមានការបញ្ជាក់ប្រាប់ណាមួយអំពីតំបន់សុវត្ថិភាព ឬបើអ្នកមិនអាចឈានទៅដល់វាដោយពុំបានដើរជាន់លើដីដែលមិនបានស្គាល់។ រង់ចាំជំនួយមកដល់។

- នៅពេលរថយន្តប៉ះទង្គិចមីន ឬសំណល់ជាតិផ្ទុះពីសង្គ្រាម សភាវគតិដំបូងរបស់អ្នកដែលរួចផុតជីវិត អាចជាការប្រញាប់ប្រញាល់ចេញក្រៅរថយន្ត។ ទោះជាយ៉ាងណា បើរថយន្តនោះមិនឆេះ ឬមិនធ្លាក់ចូលទៅក្នុងស្ថានភាពដែលគំរាមកំហែងដល់អាយុជីវិតទេនោះ ត្រូវនៅក្នុងរថយន្តជានិច្ច។ វាជាការទំនងណាស់ដែលថា នឹងមានមីនច្រើនជាងនេះ រួមទាំងមីនប្រឆាំង





រូបភាពទី 4.4
ការចាក់រុកដី គឺជានីតិវិធីដែលមានគ្រោះថ្នាក់ដែលតម្រូវឲ្យមានជំនាញ និងបទពិសោធន៍ល្អៗ (នៅបាល់កង់)។ រូបថត/កងកម្លាំងអាល្លឺម៉ង់

រូបភាពទី 4.5
ចាកចេញពីរថយន្តតែក្នុងករណីដែលមានគ្រោះអាសន្នប៉ុណ្ណោះ ឃើញនៅពេលហ្វឹកហ្វឺននៅអាល្លឺម៉ង់។ រូបថត/កងកម្លាំងអាល្លឺម៉ង់

មនុស្ស ឬសំណល់ជាតិផ្ទុះពីសង្គ្រាមនៅក្នុងតំបន់នោះ។ បើអ្នកអាចធ្វើបាន សូមផ្តល់ការសង្គ្រោះបឋមដល់អ្នកធ្វើដំណើរដទៃទៀតដែលត្រូវការការសង្គ្រោះនៅក្នុងរថយន្តនោះ។ តាំងចិត្តឲ្យស្ងប់។

- ប្រសិនបើអ្នកបានអនុវត្តតាមនីតិវិធីដែលបញ្ជាក់ក្នុងប័ណ្ណធ្វើដំណើរ វាគ្រាន់តែជាបញ្ហាពេលវេលាប៉ុណ្ណោះ មុនពេលដែលបុគ្គលិកដែលមានសមត្ថភាពគ្រប់គ្រាន់បានមកជួយអ្នក។ ទោះបីជាអ្នកស្ថិតនៅក្រៅតំបន់សេវាទំនាក់ទំនងតាមវិទ្យុ ហើយអ្នកមិនអាចប្រកាន់ខ្ជាប់តាមគម្រោងពេលដែលបានព្រមព្រៀងសម្រាប់ការត្រួតពិនិត្យតាមវិទ្យុទាក់ទង (ដោយសារតែរងរបួស ឬខូចខាតគ្រឿងបរិក្ខារ) ក៏ដោយ ក៏ក្រុមជម្លៀសគួរតែស្ថិតនៅតាមផ្លូវទៅជួយដល់អ្នកបានដែរ (បើអ្នកមាននីតិវិធីគ្រាមានអាសន្នត្រឹមត្រូវនៅនឹងកន្លែង)។
- នៅក្នុងស្ថានភាពដែលអ្នកត្រូវតែចាកចេញពីរថយន្ត (ឧទាហរណ៍ បើរថយន្តរបស់អ្នកកំពុងឆេះ) សូមកុំប៉ះពាល់ដី រហូតទាល់តែដានកង់រថយន្តរបស់អ្នកបែរមុខត្រឡប់ទៅរកផ្លូវដែលអ្នកបានមក។ ដើរនៅលើដានកង់រថយន្តរហូតទាល់តែអ្នកបានឈានដល់ដីដែលមានសុវត្ថិភាព។ បើមានអ្នកដទៃទៀតនៅក្នុងរថយន្ត ត្រូវចាកចេញពីរថយន្តនោះតែម្តង ដោយរក្សាឲ្យមានចន្លោះយ៉ាងហោចណាស់ប្រាំម៉ែត្រពីមនុស្សម្នាក់ទៅម្នាក់ទៀត។
- ត្រូវដឹងពីខ្សែអន្ទាក់/គ្រាប់បែកបង្កប់។ សំបកកង់ត្រូវរុញខ្សែលួសទៅនឹងដី ដើម្បីកុំឲ្យមិនផ្ទុះឡើង។ តាមរយៈការឈានជើងត្រឡប់ក្រោយវិញ ខ្សែលួសនោះអាចត្រូវបានគ្រវែងចោល។
- រកអ្នកឯកទេសបោសសម្អាតមីនឲ្យមកយករថយន្តចេញពីចម្ការមីនវិញ។ បើពុំដូច្នោះទេ ចាកចេញពីវា។
- នៅពេលបានចេញពីតំបន់មានមីន ត្រូវធ្វើឲ្យប្រាកដថា អ្នកបានរាយការណ៍អំពីករណីគ្រោះថ្នាក់នោះជូនអាជ្ញាធរឲ្យបានត្រឹមត្រូវ។



រូបភាពទី 4.6
គ្រឿងផ្ទុះកែច្នៃដែលមានរំសេវផ្ទុះផលិតក្នុងស្រុកប្រហែល 25 គក្រ គឺជារំសេវធំល្មមអាចគ្រវែងចោលរថពាសដែកទៅម្ខាងទៀតបាន (នៅអាហ្វហ្គានីស្ថាន)។ រូបថតរបស់ UNMAS/Thomas Enke

### 4.1.2.1 ការត្រឡប់ក្រោយតាមដានផ្លូវរបស់អ្នក

ការត្រឡប់ក្រោយតាមដានផ្លូវរបស់អ្នក គឺជានីតិវិធីមួយសម្រាប់យករថយន្តចេញពីតំបន់មានមីន ដោយបើករថយន្តត្រឡប់ក្រោយឲ្យត្រូវលើដានផ្លូវរបស់អ្នកនៅពេលអ្នកចូលមកកាន់តំបន់នោះ។ វិធីនេះ មានហានិភ័យខ្លាំងបំផុត បើអ្នកមិនអាចកាច់ចង្កូតរថយន្តឲ្យបានចំដានផ្លូវ ឬបើដានផ្លូវមិនច្បាស់។ វាប្រហែលជាពុំអាចធ្វើទៅបានឡើយ បើមានឧបសគ្គរាំងនៅតាមផ្លូវ ឬបើកង់រថយន្តរបស់អ្នកធ្លាយ។

**បំផ្ទុះដោយការបញ្ជា**

ដំណើរការមួយដែលជនទីពីរបំផ្ទុះមីនដោយប្រើតេឡេបញ្ជា។ គេហៅជននេះថាជាអ្នកបំផ្ទុះ។

**បំផ្ទុះដោយជនរងគ្រោះ**

បំផ្ទុះឡើងដោយមានមនុស្សម្នាក់ដែលបានដើរជាន់ពីលើ ឬបើកបរពីលើគ្រឿងផ្ទុះកែច្នៃនោះ។

## 4.2 នីតិវិធីគ្រាមានអាសន្នករណីមានការវាយប្រហារដោយគ្រឿងផ្ទុះកែច្នៃ

ការវាយប្រហារដោយគ្រឿងផ្ទុះកែច្នៃ កើតឡើងគ្រប់ទីកន្លែង ប៉ុន្តែជួនកាលមានតម្រុយមួយចំនួនដូចមានសរសេរនៅខាងលើ។ បើអ្នកប្រទះឃើញគ្រឿងផ្ទុះកែច្នៃនៅពេលអ្នកធ្វើដំណើរ (បើអ្នកកំពុងស្ថិតនៅចំណុចគ្រោះថ្នាក់ខ្លាំង ឬអ្នកមានការពាក់ព័ន្ធនៅក្នុងការវាយប្រហារ) ជាការសំខាន់ណាស់ដែលអ្នកត្រូវប្រតិកម្មតបដោយចិត្តស្ងប់ និងមានសុវត្ថិភាព។

### 4.2.1 ការរកឃើញគ្រឿងផ្ទុះកែច្នៃ

គ្រឿងផ្ទុះកែច្នៃ អាចបំផ្ទុះដោយជនរងគ្រោះ ឬដោយបញ្ជា។ គ្រឿងផ្ទុះកែច្នៃដែលបំផ្ទុះដោយជនរងគ្រោះ នាំឲ្យមាននីតិវិធីដូចគ្នានឹងការស្ថិតនៅក្នុងចម្ការមីនដែរ ព្រោះគ្រឿងផ្ទុះកែច្នៃអាចត្រូវបានបំផ្ទុះដោយខ្សែអន្ទាក់/គ្រាប់បែកបង្កៃ ចានសម្ពាធ ឬមីនប្រឆាំងមនុស្ស។ គ្រឿងផ្ទុះកែច្នៃដែលបំផ្ទុះដោយការបញ្ជា ត្រូវការខ្សែដែលមើលឃើញមួយ និងសញ្ញាសម្គាល់បន្ថែមមួយទៀត។ បើអាចធ្វើបាន

កុំដើរនៅក្នុងតំបន់មានខ្សែដែលមើលឃើញ ហើយលាក់បាំងខ្លួនអ្នក។ នៅក្នុងករណីទាំងពីរនេះ ត្រូវតែគោរពតាមជំហានទាំងឡាយខាងក្រោម (គឺជំហាន 5C)៖

- បញ្ជាក់៖ កុំប៉ះពាល់ ធ្វើការកត់ចំណាំក្នុងខួរក្បាល (ម៉ាស៊ីនថតឌីជីថល) ដាក់សញ្ញាសម្គាល់ (បើអាចធ្វើបាន) និងដកខ្លួនចេញពីផ្លូវដែលអ្នកបានឈានជើងដើរចូលមក។ ត្រូវដឹងពីខ្សែអន្ទាក់/គ្រាប់បែកបង្កៃ ចានសម្ពាធ និងមីនប្រឆាំងមនុស្ស។
- កុំឲ្យមានអ្នកមកក្បែរតំបន់នោះ៖ ប្រើការណែនាំអំពីចម្ងាយត្រូវជម្លៀសខ្លួន (ឧបសម្ព័ន្ធ A5.1) ឬនៅចម្ងាយអប្បបរមា 300 ម៉ែត្រ។
- ទូរស័ព្ទហៅអាជ្ញាធរពាក់ព័ន្ធ (មេភូមិ នគរបាល យោធា ឬអង្គការបោសសម្អាតមីនដែលនៅជិតបំផុត)។ ប្រើទម្រង់របាយការណ៍ប្រាំបួនជាន់ថ្នាក់សម្រាប់ការបញ្ជូនព័ត៌មាន (ឧបសម្ព័ន្ធ A5.2)។
- ឡោមព័ទ្ធ៖ បង្ការកុំឲ្យចរាចរណ៍ដោយរថយន្ត និងដោយថ្មើរជើងចូលមកកាន់គ្រឿងផ្ទុះកែច្នៃនោះ។
- គ្រប់គ្រង៖ គ្រប់គ្រងទីតាំងនោះរហូតទាល់តែមានអាជ្ញាធរពាក់ព័ន្ធមកដល់កន្លែងកើតហេតុ។

ជាការសំខាន់ណាស់ដែលត្រូវរក្សាសន្តិសុខខ្លួនអ្នក។ មើលការប្រព្រឹត្តរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ហើយត្រូវដឹងពីគ្រឿងផ្ទុះកែច្នៃបន្ទាប់បន្សំ ក៏ដូចជាគ្រឿងផ្ទុះកែច្នៃនៅក្នុងខ្សែសង្វាក់ជារង្វង់[13]។



រូបភាពទី 4.7
ចំណែកដែលសេសសល់នៃគ្រឿងផ្ទុះកែច្នៃសម្រាប់បំផ្ទុះលើរថយន្ត (VBIED) (នៅអាហ្វហ្គានីស្ថាន)។
រូបថតរបស់ UNMAS/Thomas Enke

[13] គ្រឿងផ្ទុះប្រភេទពិសេស មានផ្ទុកទៅដោយរំសេវធំៗពីរឬបីក្នុងមួយជួរ (អាចបែកខ្ចាយក្នុងចម្ងាយលើសពីមួយរយម៉ែត្រ) បំផ្ទុះដោយគ្រាន់តែចុចកុងតាក់តែម្តងប៉ុណ្ណោះ។

## 4.2.2 បន្ទុះនៃគ្រឿងផ្ទុះកែច្នៃ

ករណីមានបន្ទុះដែលមិនដឹង ឬបន្ទុះនៃគ្រឿងផ្ទុះកែច្នៃ អ្នកចាំបាច់ត្រូវតែការពារសន្តិសុខខ្លួនអ្នក។ គ្រឿងផ្ទុះកែច្នៃបន្ទាប់បន្សំ ក៏ដូចជាគ្រោះថ្នាក់ទាំងឡាយដែលកើតចេញពីគ្រឿងដែលផ្ទុះ (ឧ. រថយន្តដែលកំពុងឆេះ ខ្សែបញ្ជូនថាមពលដែលគេបានបំផ្លាញចោល) គឺជាការគំរាមកំហែងសំខាន់ៗ។ ការពារសន្តិសុខខ្លួនអ្នកដោយត្រួតពិនិត្យក្នុងចម្ងាយ 5/25 ម (ដូចមានពន្យល់នៅក្នុង ឧបសម្ព័ន្ធ A3) ដើម្បីឲ្យមានមជ្ឈដ្ឋានជុំវិញប្រកបដោយសុវត្ថិភាព។ បន្ទាប់ពីធ្វើបែបនេះហើយ ត្រូវគោរពតាមជំហាន 5 C ម្តងទៀត៖



ប្រទេសលីបង់
រូបថតរបស់ UNMAS/Marc Vaillant

- បញ្ជាក់៖ បញ្ជាក់ឲ្យច្បាស់អំពីស្ថានភាពចេញពីចំណុចមានសុវត្ថិភាព។
- កុំឲ្យមានអ្នកមកក្បែរតំបន់នោះ៖ ប្រើការណែនាំអំពីចម្ងាយត្រូវជម្លៀសខ្លួន (ឧបសម្ព័ន្ធ A4.1) ឬនៅចម្ងាយអប្បបរមា 300 ម៉ែត្រ។
- ទូរស័ព្ទហៅអាជ្ញាធរពាក់ព័ន្ធ (មេភូមិ នគរបាល យោធា ឬអង្គការបោសសម្អាតមីនដែលនៅជិតបំផុត)។ ប្រើទម្រង់របាយការណ៍ប្រាំបួនជាន់ថ្នាក់ សម្រាប់ការបញ្ជូនព័ត៌មាន (ឧបសម្ព័ន្ធ A5.2)។
- ហ៊ុមព័ទ្ធ៖ បង្ការកុំឲ្យចរាចរណ៍ដោយរថយន្ត និងដោយថ្មើរជើងចូលមកកាន់គ្រឿងផ្ទុះកែច្នៃនោះ។

- គ្រប់គ្រង៖ គ្រប់គ្រងទីតាំងនោះរហូតទាល់តែមានអាជ្ញាធរ និងក្រុមសង្គ្រោះពាក់ព័ន្ធមកដល់កន្លែងកើតហេតុ។

កុំរត់ទៅកាន់កន្លែងផ្ទុះ។ កុំប៉ះពាល់ផ្នែកណាមួយនៃសមាសភាពគ្រឿងផ្ទុះកែច្នៃដែលបានគ្រវែងចោលមក ឬគោលដៅ។ ជូនដំណឹងដល់អាជ្ញាធរពាក់ព័ន្ធអំពីការរកឃើញរបស់អ្នក។



លីប៊ី

រូបថតរបស់ UNMAS/Giovanni Diffidenti




## ផ្នែកទី 5

# ការជួយជនរងគ្រោះ

# ការជួយ ជនរងគ្រោះ

ក្នុងករណីដែលអ្នកបានឃើញហេតុការណ៍គ្រោះថ្នាក់ដូចដែលបានបរិយាយពីខាងលើ អ្នកអាចចាំបាច់ត្រូវការការផ្ដល់ជំនួយពីតំបន់មានសុវត្ថិភាព។ ផ្នែកនេះផ្ដល់នូវទិដ្ឋភាពទូទៅស្ដីពីវិធានការមូលដ្ឋានមួយចំនួនដែលត្រូវធ្វើ បើអ្នកបានឃើញហេតុការណ៍គ្រោះថ្នាក់នោះ និងបើពុំអាចរកជំនួយបាន។ ផ្នែកនេះពុំមែនជាការជំនួសឲ្យការបណ្ដុះបណ្ដាលស្ដីពីការសង្គ្រោះបឋម ឬជំនួសឲ្យការប្រើប្រាស់អ្នកឯកទេសផ្នែកវេជ្ជសាស្ត្រ និងបោសសម្អាតមីនដែលបានទទួលការបណ្ដុះបណ្ដាលឡើយ។



រូបភាពទី 5.1
ទូរស័ព្ទរកជំនួយ (មន្ត្រី MINURSO ធ្វើលំហាត់ហ្វឹកហ្វឺននៅស្មារ៉ា) កត់ចំណាំជំហរជេកផ្អៀង (នៅដែនដីសាហារ៉ាខាងលិច)។ រូបថតរបស់ UN

## ករណីមានគ្រោះថ្នាក់កើតឡើង អ្នកគួរតែធ្វើដូចខាងក្រោម៖

- តាំងចិត្តឲ្យស្ងប់!
- កុំប្រញាប់ប្រញាល់ចូលទៅជិតជនរងគ្រោះ។
- កុំព្យាយាមសង្គ្រោះគាត់នៅតំបន់ដែលអាចជាចម្ការមីន ឬតំបន់ដែលគ្មានសន្តិសុខ។
- និយាយទៅកាន់ជនរងគ្រោះ ព្រមានប្រាប់កុំឲ្យគាត់កម្រើក ណែនាំអំពីរបៀបផ្ដល់ការសង្គ្រោះបឋមដោយខ្លួនឯង ណែនាំប្រាប់គាត់ថា កំពុងតែមានអ្នកមកជួយហើយ។
- កត់ចំណាំពេលវេលា និងទីតាំង និងចំនួនកន្លែងដែលរងរបួស។
- ទូរស័ព្ទសុំជំនួយ។ រៀបចំសម្រាប់ជំនួយក្នុងការបោសសម្អាតមីន និងការជម្លៀសទៅព្យាបាល។ ប្រើប្រាស់ទម្រង់ប្រាំបួនជាន់ថ្នាក់ (ឧបសម្ព័ន្ធ A5.2)។
- ត្រៀមរៀបចំកញ្ចប់សង្គ្រោះបឋម។
- រង់ចាំជំនួយមកដល់។

## 5.1 ការជម្លៀសចេញពីកន្លែងកើតហេតុបន្ទុះដែលគេមិនស្គាល់

នៅពេលគ្រោះថ្នាក់ដែលមានបន្ទុះកើតឡើង ជនរងគ្រោះកំពុងស្ថិតនៅក្នុងតំបន់មានគ្រោះថ្នាក់។

នៅក្នុងករណីបែបនេះ មានជម្រើសតិចបំផុត សម្រាប់ផ្តល់ការសង្គ្រោះ។ ជនរងគ្រោះនឹងត្រូវបានជម្លៀសចេញពីតំបន់នោះដោយក្រុមបោសសម្អាតមីន ឬក្រុមកម្ទេចសំណល់ជាតិផ្ទុះមុនពេលទទួលជំនួយផ្នែកពេទ្យ។ នៅក្នុងការទូរស័ព្ទសុំជំនួយ អ្នកត្រូវត្រៀមរៀបចំសម្រាប់ការបោសសម្អាតមីន ឬការកម្ទេចសំណល់ជាតិផ្ទុះ និងការសង្គ្រោះបឋម ដូច្នេះត្រូវប្រាកដថាមានបញ្ជីរាយនាមមនុស្សទំនាក់ទំនងគ្រាមានអាសន្ន (ប្រេកង់ស៊ែវិទ្យុទាក់ទង សញ្ញាទូរស័ព្ទ លេខទូរស័ព្ទ។ល។) និងទម្រង់ប្រាំបួនជាន់ថ្នាក់ (ឧបសម្ព័ន្ធ A5.2)។

បើជនរងគ្រោះស្ថិតនៅក្នុងចម្ការមីន ឬតំបន់ដែលញាំញីដោយយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ហើយមិនអាចរកជំនួយពីក្រុមបោសសម្អាតមីនដើម្បីយកជនរងគ្រោះចេញពីតំបន់ដែលមានមីនបានទេនោះ  ការចាក់រុកដីត្រូវបានគេប្រើជាវិធីមួយក្នុងការជម្លៀសខ្លួនជនរងគ្រោះ (សូមមើលផ្នែកទី 4)។

នៅក្នុងករណីផ្ទុះគ្រឿងផ្ទុះកៃច្នៃ ការគំរាមកំហែងនៃគ្រឿងផ្ទុះកៃច្នៃទីពីរ ឬការវាយប្រហារប្រភេទមួយផ្សេងទៀត (ដូចជា ការវាយប្រហារដោយលបបាញ់) មានកម្រិតខ្ពស់ណាស់។ ដូច្នេះ ត្រូវសង្កេតមើលតំបន់ជុំវិញដោយយកចិត្តទុកដាក់ (ខ្សែដែលមើលឃើញ)។ ពិនិត្យមើលផ្លូវលំទៅកាន់ទីតាំងផ្ទុះ ដោយប្រើការពិនិត្យក្នុងចម្ងាយ 5/25 ម (សូមមើល ឧបសម្ព័ន្ធ A3) ដើម្បីបង្កើតផ្លូវដែលមានសន្តិសុខសម្រាប់ដកថយ។ ប្រើរបាំងកុំឲ្យមើលឃើញពីអ្នកវាយប្រហារដែលអាចធ្វើឡើង និងបន្ទុះបន្ថែម។ ពិនិត្យមើលទីតាំងនោះដោយយកចិត្តទុកដាក់មុនពេលចាប់ផ្តើមមើលថែជនរងគ្រោះ។

# 5.2 ការផ្តល់ការសង្គ្រោះបឋម

បើគ្រោះថ្នាក់កើតឡើងនៅក្នុងរថយន្តនាំមុខ ហើយអ្នកកំពុងស្ថិតក្នុងរថយន្តមួយផ្សេងទៀតដែលកំពុងធ្វើដំណើរតាមក្រោយ អ្នកអាចនឹងជួបករណីគ្រោះថ្នាក់ដោយការដើរនៅក្នុងដានផ្លូវរបស់រថយន្ត។ ទោះជាយ៉ាងណា បន្ទុះពីមីនប្រឆាំងរថយន្ត ឬគ្រឿងផ្ទុះកៃច្នៃ ទំនងជាអាចធ្វើឲ្យរថយន្តក្រឡាប់ ហើយផ្លាស់ទីវាចេញឆ្ងាយពីដានផ្លូវរបស់វា។ នៅក្នុងករណីបែបនេះ តំបន់ជុំវិញគួរត្រូវបានចាត់ទុកថាមានមីន ហើយមិនគួរចូលទៅឡើយ។




រូបភាពទី 5.2
ជាការសំខាន់ណាស់ដែលត្រូវបញ្ឈប់ការហូរឈាម។ រូបថតរបស់

## 5.2. ការផ្តល់ការសង្គ្រោះបឋម

នៅពេលជនរងគ្រោះត្រូវបាននាំទៅកាន់កន្លែងដែលមានសុវត្ថិភាព ហើយបើពុំអាចរកបុគ្គលិកពេទ្យបានភ្លាមៗទេនោះ អ្នកគួរផ្តល់ការសង្គ្រោះបឋមគ្រាមានអាសន្នឲ្យអស់ពីសមត្ថភាព ទៅតាមអ្វីដែលអ្នកបានរៀន រហូតទាល់តែជំនួយផ្នែកពេទ្យបានមកដល់។

គោរពតាមវិធាន CAB និងវាយតម្លៃលទ្ធភាពនៃការរបួសឆ្អឹងខ្នង និងព្យាបាលផ្នែកក្បាល បើអាចធ្វើបាន[14]៖

| | |
|---|---|
| ដំណើរឈាមរត់ | ឃាត់ឈាមដែលហូរ |
| ផ្លូវដង្ហើម | បង្ការកុំឲ្យស្ទះផ្លូវដង្ហើម |
| ដំណកដង្ហើម | ជួយដល់ការដកដង្ហើម |




រូបភាពទី 5.3
ទាញក្បាលចុះក្រោម / លើកចង្កាឡើងលើ។ រូបថតរបស់ UN

រកមើលកន្លែងដែលមានឈាមហូរ។ កំណត់កន្លែងដែលមានឈាមហូរ និងឃាត់ឈាម។ មូលហេតុនៃការស្លាប់ដែលទូទៅ និងអាចបង្ការបានច្រើនបំផុត គឺ ការហូរឈាមរហូតដល់ស្លាប់។ ប្រើសម្ពាធដោយផ្ទាល់ជាជាងសម្ពាធដោយ

[14] តម្រុយខាងក្រោមនេះ គឺជាការដកស្រង់ចេញពីអត្ថបទបណ្តុះបណ្តាលអំពីការរៀបចំ និងប្រើប្រាស់ ETB នៅក្នុង អសប ចេញផ្សាយដោយនាយកដ្ឋានសុវត្ថិភាព និងសន្តិសុខ។

# 5.2 ការផ្តល់ការសង្គ្រោះបឋម

ប្រយោលសម្រាប់គ្រប់គ្រងការហូរឈាម ពិចារណាអំពីការប្រើប្រាស់ប្រដាប់ឃាត់ឈាម និងប្រើប្រាស់ខ្សែការ៉ូចងឃាត់ឈាមតាមចាំបាច់។ ការហូរឈាមនៅចុងដៃ ឬចុងជើង អាចបញ្ឈប់បានយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាពដោយប្រើខ្សែការ៉ូចងឃាត់ឈាមជាវិធានការបណ្តោះអាសន្នសម្រាប់អូសបន្លាយពេលវេលា។ លើសពីនេះទៀត បើអាចធ្វើបាន គួរផ្តល់ថ្នាំបំបាត់ការឈឺចាប់ ពីព្រោះការឈឺចាប់ដែលបណ្តាលមកពីខ្សែការ៉ូចងឃាត់ឈាមអាចមានកម្រិតច្រើនជាងការឈឺចាប់ពីរបួស។ ជាការចាំបាច់ណាស់ដែលត្រូវកត់សម្គាល់ការប្រើប្រាស់ខ្សែការ៉ូចងឃាត់ឈាម និងពេលវេលាដែលបានប្រើប្រាស់វា តាមរយៈការសរសេរកំណត់សម្គាល់ខ្លីមួយនៅលើថ្ងាសរបស់អ្នករបួស ដោយប្រើខ្មៅដៃមិនជ្រាបទឹក។ ខ្សែចងឃាត់ឈាម អាចប្រើសម្រាប់បន្ទាត់ពេលវេលា 6 ម៉ោង ហើយនៅក្នុងករណីនីមួយៗរហូតដល់ទៅ 16 ម៉ោង។ រហូតមកទល់នឹងពេលនេះ ការស្រាយក្រណាត់ចងឃាត់ឈាមអាចអនុញ្ញាតបានតែជាមួយនឹងការព្យាបាលវេជ្ជសាស្ត្របន្ថែមទៀតប៉ុណ្ណោះ[15]។

បើពុំអាចរកខ្សែការ៉ូចងឃាត់ឈាមបានទេនោះ ស្រាយក្រណាត់ដែលប៉ះនឹងកន្លែងរបួសចេញ។ សង្កត់នៅត្រង់សរសៃអាកទែរ នៅត្រង់ក្រលៀនដើម្បីឲ្យដឹងពីរបួសប្រអប់ជើង និងកំភួនជើង ឬនៅត្រង់រន្ធក្លៀកដើម្បីឲ្យដឹងពីរបួសនៅត្រង់ប្រអប់ដៃ និងដើមដៃ។ ប្រើបង់រុំរបួស ឬសម្ភារអ្វីមួយក៏បានឲ្យតែអាចរកបានដើម្បីធ្វើជាប៉ង់សឺម៉ង់ដោយសម្ពាធសម្រាប់របួស ហើយរឹតក្រណាត់ឲ្យចូលជ្រៅក្នុងរបួស។ បើនៅតែបន្តមានការហូរឈាមកាត់តាមប៉ង់សឺម៉ង់នោះ ត្រូវបន្ថែមសម្ភារ និងប្រើសម្ពាធដោយដៃឲ្យបានខ្លាំងទៅលើសរសៃអាកទែរ។

ពិនិត្យមើលផ្លូវដង្ហើមក្រែងលោមានការស្ទះដោយវត្ថុពីខាងក្រៅ។ បើជនរងគ្រោះសន្លប់បាត់ស្មារតី ត្រូវបើកផ្លូវដង្ហើមដោយទាញក្បាលចុះក្រោម / លើកចង្ការឡើងលើ។ សម្រាប់ស្ថានភាពដែលមានមនុស្សស្លាប់ច្រើន នៅពេលអ្នកត្រូវមើលថែអ្នករងគ្រោះជាច្រើនក្នុងពេលយ៉ាងឆាប់ ត្រូវបញ្ចូល (ឧបករណ៍បើកផ្លូវ

[15] Neitzel, Ladehof: Taktische Medizin, Springer 2012

ដង្ហើម Guedel) នៅពេលណាអាចធ្វើបាន (ឧ. បើអ្នកជំងឺពុំមានឆ្អឹងចំពោះឆ្អឹងមាត់)។

មើល ស្តាប់ និងស្ទាបដង្ហើម បើសន្លប់បាត់ស្មារតី។ ធ្វើបែបនេះមិនឲ្យលើសពី 10 វិនាទី។ វាយតម្លៃត្រួសៗទៅលើសង្វាក់ ជម្រៅ និងសំឡេងដង្ហើម។ ពិនិត្យមើលឲ្យដឹងថាតើទ្រូងទាំងសងខាងមានចលនាស្មើគ្នាដែរឬទេ។

វាយតម្លៃទៅលើការឆ្លើយតបរបស់ជនរងគ្រោះ។ មានកម្រិតបួនខុសៗគ្នា៖

- នៅដឹងខ្លួន និងនៅរវាសរវៃ៖ ជនរងគ្រោះផ្តល់ព័ត៌មានច្បាស់លាស់អំពីមនុស្ស ទីកន្លែង ពេលវេលា និងព្រឹត្តិការណ៍
- ពាក្យសម្តី៖ ជនរងគ្រោះឆ្លើយតបទៅនឹងការបញ្ជាដោយពាក្យសម្តី (“បើកភ្នែករបស់អ្នក” “កម្រើកម្រាមដៃ”)
- ការឈឺចាប់៖ ជនរងគ្រោះឆ្លើយតបទៅនឹងការក្តិចទងត្រចៀក ការរឹតដើមទ្រូង។
- ការមិនឆ្លើយតប៖ ជនរងគ្រោះមិនឆ្លើយតបនឹងការដាស់សតិដោយការឈឺចាប់។

វាយតម្លៃឡើងវិញទៅលើលទ្ធភាពនៃការរងរបួសឆ្អឹងខ្នង។ សួរជនរងគ្រោះថា៖ “ឈឺត្រង់ណា តើអ្នកអាចកម្រើកដៃ និងជើងរបស់អ្នកបានទេ?”។ បើអាចធ្វើបាន ប្រើឧបករណ៍ទម្រការពារ ក ក្រោយពីបានពិនិត្យមើល ក រួច។

អ្នកដែលមានសីតុណ្ហភាពរាងកាយទាប ងាយនឹងហូរឈាមច្រើន។ ការពារអ្នករងរបួសកុំឲ្យត្រូវនឹងខ្យល់ ភ្លៀង និងភាពត្រជាក់។ រក្សាឲ្យពួកគេស្ងប់ចិត្ត និងកក់ក្តៅ ប៉ុន្តែកុំឲ្យពួកគេត្រូវនឹងពន្លឺថ្ងៃដែលភ្លឺពេក។ គ្របដណ្តប់ឲ្យជនរងគ្រោះដោយប្រើភួយសង្គ្រោះបន្ទាន់ បើពួកគេរងារ ឬស្ថិតក្នុងស្ថានភាពស្តុក។ ដាក់ឲ្យអ្នកជំងឺសម្រាកក្នុងជំហរមួយដែលសមស្រប ធ្វើឲ្យមាន

# 5.2 ការផ្តល់ការសង្គ្រោះបឋម

ផាសុកភាព និងសម្លៀកបំពាក់រលុងៗ។ និយាយទៅកាន់ពួកគេ និងពន្យល់អំពីអ្វីដែលអ្នកកំពុងធ្វើ ហើយប្រាប់ថាជំនួយកំពុងតែមកដល់។

បន្ទាប់ពីការស្ទង់មើលជាលើកទីពីរ ត្រួតពិនិត្យមើលសញ្ញាជីវិតតាមពេលវេលាកំណត់មួយ។

ឲ្យអ្នកជំងឺបឺតទឹកក្តៅតិចៗ ឬភេសជ្ជៈផ្សេងទៀតដែលគ្មានជាតិអាល់កុល ដើម្បីជៀសវាងនូវការថយចុះកម្តៅរាងកាយ ប៉ុន្តែទាល់តែអ្នកជំងឺអាចនិយាយបានមានន័យថា ពុំមានអ្វីរាំងស្ទះផ្លូវដង្ហើម។



ប្រទេសលីប៊ី
រូបថតរបស់ UNMAS/Giovanni Diffidenti

# 5.2 ការផ្តល់ការសង្គ្រោះបឋម

នៅពេលអ្នកនាំអ្នកជំងឺទៅកាន់រថយន្ត ដឹកជញ្ជូនគាត់ភ្លាមៗទៅកាន់មន្ទីរពេទ្យពាក់ព័ន្ធដែលនៅជិតបំផុត។ ប្រើប្រាស់សេវាដឹកជញ្ជូនដែលល្អបំផុតតាមដែលអាចរកបាន ហើយផ្តាំផ្ញើឲ្យរកការដឹកជញ្ជូនផ្សេងទៀតដែលប្រសើរជាង (លឿនជាង) ឲ្យមកតាមពីក្រោយអ្នកនៅពេលវាមកដល់។

# 5.2 ការផ្តល់ការសង្គ្រោះបឋម

អំឡុងពេលដឹកជញ្ជូន ពិនិត្យមើលសញ្ញាជីវិតរបស់ជនរងគ្រោះតាមពេលវេលាកំណត់ និងធានាឲ្យបានថាមានការប្រើប្រាស់បង់រុំរបួសបានត្រឹមត្រូវសម្រាប់របួសធ្ងន់ធ្ងរទាំងអស់។ ត្រូវរក្សាការសង្កត់ដោយដៃទៅលើប៉ង់សឺម៉ង់ អំឡុងពេលធ្វើដំណើរដើម្បីបង្ការកុំឲ្យឈាមហូរ។



សាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ

រូបថតរបស់ UNMAS



# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ A1 ការប្រើប្រាស់កាតធ្វើដំណើរ

### A1.1 យន្តការត្រួតពិនិត្យតាមដានការផ្លាស់ទីបុគ្គលិក

ការប្រើប្រាស់កាតធ្វើដំណើរឲ្យបានខ្ជាប់ខ្ជួន គឺជាយន្តការមានប្រសិទ្ធភាពសម្រាប់ត្រួតពិនិត្យតាមដានការចល័តបុគ្គលិក និងជួយបង្កលក្ខណៈងាយស្រួលដល់ការចាត់វិធានការឆាប់រហ័ស និងត្រឹមត្រូវ បើពួកគេពុំបានឈានដល់គោលដៅ ឬទាន់ពេលកំណត់។ ឧទាហរណ៍អំពីកាតធ្វើដំណើរមានផ្តល់ជូននៅខាងក្រោម។

កាតធ្វើដំណើរ គួរតែត្រូវបានបំពេញដោយបុគ្គលិកទាំងអស់ដែលធ្វើដំណើរនៅក្នុងតំបន់ដែលអាចនឹងមានគ្រោះថ្នាក់ ហើយត្រូវប្រគល់បន្តឲ្យបុគ្គលិកដែលមានទំនួលខុសត្រូវតាមការចាត់តាំង។

អ្នកទទួលបានការចាត់តាំងដែលបានទទួលកាតធ្វើដំណើរ គួរចុះហត្ថលេខាលើវា ដើម្បីទទួលស្គាល់ថាបានទទួលវា។ បុគ្គលិកគួរដាក់វានៅក្នុងកន្លែងណាមួយដែលគេអាចមើលឃើញ ដូចជា ក្តារខៀនព័ត៌មាននៅលើជញ្ជាំងដែលគេអាចពិនិត្យមើលវាប្រចាំថ្ងៃ។

អ្នកទទួលបានការចាត់តាំងដែលបានទទួលកាតធ្វើដំណើរ គួរទទួលខុសត្រូវចំពោះការពិនិត្យមើលឲ្យដឹងថាតើបុគ្គលិកដែលកំពុងធ្វើដំណើរ



រូបភាពទី A1.1
ការបោសសម្អាតផ្លូវថ្នល់ (នៅស៊ូដង់ខាងត្បូង)។ រូបថតរបស់ UN

នោះបានត្រឡប់មកវិញដែរឬទេ ដោយប្រើម៉ោងមកដល់តាមការប៉ាន់ស្មាន ជាក់លាក់ (ETA) ហើយបើមិនដល់ទេនោះ គួរតែរាយការណ៍អំពីការមិន ទាន់មកដល់របស់បុគ្គលិកនោះជូនបុគ្គលិកថ្នាក់លើដែលជាអ្នកទទួល ខុសត្រូវ។

អ្នកដែលធ្វើដំណើរ ត្រូវតែរាយការណ៍ត្រឡប់មកវិញនៅពេលពួកគេ បានមកដល់ ហើយបើមានការយឺតយ៉ាវ ត្រូវពុះពារគ្រប់ឧបសគ្គក្នុងការ រាយការណ៍ត្រឡប់មកវិញអំពីមូលហេតុដែលបណ្តាលឲ្យមានការ យឺតយ៉ាវនោះ និង ETA ថ្មី។

ក្រោយពេលបញ្ចប់ការធ្វើដំណើរ កាតធ្វើដំណើរគួរត្រូវបានចុះហត្ថលេខា ដោយអ្នកទទួលបានការចាត់តាំង ហើយកាត់ធ្វើដំណើរនោះត្រូវយកចេញ ពីក្តារខៀនព័ត៌មាន និងទុកជាឯកសារ។

ព័ត៌មាននៅក្នុងកាតធ្វើដំណើរដែលបានបំពេញរួចដែលបញ្ជាក់ប្រាប់អំពី តំបន់ដែលញ៉ាំញីដោយប្រើមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម គួរតែត្រូវ បានបញ្ជូនទៅកាន់មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនក្នុងស្រុក ឬអាជ្ញាធរ ពាក់ព័ន្ធផ្សេងៗ។

## A1.2 ផែនទីបង្ហាញផ្លូវ



A1.2 –
Route Card

MISSION SECURITY CLEARANCE REQUEST • UNITED NATIONS

Should be sent to the Area Security Coordinator, Area Field Security Officer and Designated Official by the Team Leader at least 24 hours in advance

**Mission Details Section A**

Number of vehicles | Team Leader's Name
Purpose of visit | Agency

**Itinerary Section B**

| | City | Date | Hour | | City | Date | Hour |
|---|---|---|---|---|---|---|---|
| 1. DEP | | | | 3. DEP | | | |
| ARR | | | | ARR | | | |
| 2. DEP | | | | 4. DEP | | | |
| ARR | | | | ARR | | | |

**Vehicle Details 1 - Section C**

| Plate No. | Agency | HF Call Sign | HF Frequency | Sell-Call No. (for HF) | Cell/Satellite Phone No. |
|---|---|---|---|---|---|

| Name | Agency | Call Sign | Name | Agency | Call Sign |
|---|---|---|---|---|---|
| 1 | | | 3 | | |
| 2 | | | 4 | | |

**Vehicle Details 2 - Section D**

| Plate No. | Agency | HF Call Sign | HF Frequency | Sell-Call No. (for HF) | Cell/Satellite Phone No. |
|---|---|---|---|---|---|

| Name | Agency | Call Sign | Name | Agency | Call Sign |
|---|---|---|---|---|---|
| 1 | | | 3 | | |
| 2 | | | 4 | | |

**Vehicle Details 3 - Section E**

| Plate No. Phone No. | Agency | HF Call Sign | HF Frequency | Cell Phone No. | Satellite |
|---|---|---|---|---|---|

| Name | Agency | Call Sign | Name | Agency | Call Sign |
|---|---|---|---|---|---|
| 1 | | | 3 | | |
| 2 | | | 4 | | |

**Vehicle Details 4 - Section F**

| Plate No. Phone No. | Agency | HF Call Sign | HF Frequency | Cell Phone No. | Satellite |
|---|---|---|---|---|---|

| Name | Agency | Call Sign | Name | Agency | Call Sign |
|---|---|---|---|---|---|
| 1 | | | 3 | | |
| 2 | | | 4 | | |

**Vehicle Details 5 - Section G**

| Plate No. Phone No. | Agency | HF Call Sign | HF Frequency | Cell Phone No. | Satellite |
|---|---|---|---|---|---|

| Name | Agency | Call Sign | Name | Agency | Call Sign |
|---|---|---|---|---|---|
| 1 | | | 3 | | |
| 2 | | | 4 | | |

**Recommendation/Approval of the Area Security Coordinator Section H**

Name | Yes | Remarks (if any)
Signature | Agency | No.
Date: / /

## A 1.3 នីតិវិធីសម្រាប់ធ្វើដំណើរតាមផ្លូវគោក

ឯកសារខាងក្រោមនេះគ្រាន់តែជាអត្ថបទដកស្រង់ប៉ុណ្ណោះ វាពុំមានភាពជាក់លាក់ចំពោះការគំរាមកំហែងដោយគ្រាប់មីន/យុទ្ធញភ័ណ្ឌមិនទាន់ផ្ទុះ/គ្រឿងផ្ទុះកែច្នៃឡើយ។ ឯកសារនេះត្រូវបានផ្តល់ដោយ UNICEF។ វាស៊ីគ្នាជាមួយនឹងកាតធ្វើដំណើរ (សូមមើលទំព័រមុន)។

### A 1.3.1 ការត្រៀមបម្រុងមុនធ្វើដំណើរតាមផ្លូវគោក

ទោះបីជានៅក្នុងតំបន់ដែលជាទូទៅមានសន្តិសុខក៏ដោយ ការធ្វើដំណើរដោយរថយន្ត អាចមានគ្រោះថ្នាក់ដោយសារតែការគាំងខូចផ្នែកមេកានិច គ្រោះថ្នាក់ឧក្រិដ្ឋកម្មទូទៅ និងការលួចរថយន្ត។ ហានិភ័យនេះអាចកាត់បន្ថយបានយ៉ាងច្រើនដោយការធ្វើដំណើរ (ពេលណាអាចធ្វើបាន) ជាក្បួនរួមគ្នាជាមួយរថយន្តផ្សេងទៀត។

#### A 1.3.1.1 ទំនួលខុសត្រូវរបស់មេប្រធានក្រុម

រាល់បេសកម្មតាមផ្លូវគោក ត្រូវតែមានបុគ្គលម្នាក់ដែលធ្វើជាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងបេសកកម្មនោះ។ បុគ្គលនេះហៅថា៖ “ប្រធានក្រុម”។ មុនពេលចេញដំណើរ គួរចាត់វិធានការទាំងឡាយដូចតទៅ៖

- រៀបចំបញ្ជីរថយន្តទាំងអស់ដែលត្រូវប្រើប្រាស់ រួមទាំងស្លាកលេខ ឈ្មោះអ្នកបើកបរដែលត្រូវចាត់តាំងឲ្យបើកបររថយន្តនីមួយៗ និងទីកន្លែងរបស់រថយន្តដែលត្រូវស្ថិតនៅក្នុងក្បួន។
- នៅក្នុងករណីត្រូវប្រើវិធានការទប់ទល់ដោយអេឡិចត្រូនិច (ECM) រៀបចំផែនការទីកន្លែងរបស់រថយន្តនីមួយៗដើម្បីឲ្យពពុះ ECM ត្រួតស៊ីគ្នាលើក្បួន។

- ត្រៀមបម្រុងបញ្ជីឈ្មោះមនុស្សទាំងអស់នៅក្នុងក្បួន ហើយចាត់តាំងការទទួលខុសត្រូវ។
- ធានាឲ្យបានថាបានទទួលការឯកភាពផ្នែកសន្តិសុខ។
- ធានាឲ្យបានថា អ្នកមានព័ត៌មានពេញលេញទាក់ទងនឹងតំបន់ដែលត្រូវទៅ ក៏ដូចជាស្ថានភាពបច្ចុប្បន្ន (ភូមិសាស្ត្រ អាកាសធាតុ សេវាដែលអាចរកបាន បញ្ជីរាយនាមមនុស្សទំនាក់ទំនងនៅតាមផ្លូវ និងនៅត្រង់គោលដៅ។ល។)។
- នៅពេលធ្វើដំណើរទៅកាន់តំបន់នោះ ត្រូវធានាឲ្យបានថា អ្នកបានប្រឹក្សាជាមួយអាជ្ញាធរមូលដ្ឋាន (មេភូមិ នគរបាល បុគ្គលិកយោធា អង្គការបោសសម្អាតមីនដែលនៅជិតបំផុត ឬក្រុមសម្របសម្រួលការកម្ទេចសំណល់ជាតិផ្ទុះពហុជាតិសាសន៍ (MN EOD CC) / ការិយាល័យទំនាក់ទំនងថ្នាក់ជាតិសម្រាប់ការកម្ទេចសំណល់ជាតិផ្ទុះ (NPOC EOD) នៃក្រុមបេសកកម្មរក្សាសន្តិភាព សង្កេតការណ៍ ឬហ្វឹកហ្វឺន) ទាក់ទងនឹងចលនារបស់អ្នក ក៏ដូចជាស្ថានភាពសន្តិសុខផងដែរ។
- ពិនិត្យថាពិតជាមានដើម្បីជួយដល់អ្នកបាន ក្នុងករណីមានគ្រោះអាសន្ន (ដូចជា តម្រូវការសម្រាប់ការជម្លៀសទៅព្យាបាលជាដើម)។
- កំណត់ថាតើចាំបាច់ត្រូវមានកងកម្លាំងសន្តិសុខអមដំណើរដែរឬទេ។ បើមែន ត្រូវស្នើសុំពីចម្ងាយជាមុន ប៉ុន្តែយ៉ាងហោចណាស់ 48 ម៉ោង មុនគម្រោងចេញដំណើរនោះ។
- កំណត់មុំ និងចំណែកផ្លូវដែលមើលឃើញនៅចន្លោះអ្នកធ្វើដំណើរនៅក្នុងរថយន្ត និង
- ផ្តល់ព័ត៌មានសង្ខេបដល់អ្នកចូលរួមទាំងអស់។



រូបភាពទី A1.2
ដីរអិលនៅក្នុងស្ទឹងតូចមួយនៅស៊ូដង់ខាងត្បូង។ រូបថតរបស់ UN

### A 1.3.1.2 ការបង្កើតប្លង់ផ្លូវធ្វើដំណើរ

ជាការសំខាន់ណាស់ដែលត្រូវប្រមូលព័ត៌មានឲ្យបានច្រើនតាមដែលអាចធ្វើបានអំពីផ្លូវធ្វើដំណើរមុនពេលចេញ។

- ធ្វើការស្រាវជ្រាវរបស់អ្នក។ ស្វែងយល់ឲ្យអស់ពីលទ្ធភាពអំពីស្ថានភាពផ្លូវ ប្រឹក្សាជាមួយអ្នកដទៃទៀតដែលធ្លាប់ធ្វើដំណើរលើផ្លូវនោះកាលពីពេលថ្មីៗ
- ទទួលព័ត៌មានទាន់ហេតុការណ៍អំពីហានិភ័យសន្តិសុខដែលអាចកើតមានឡើង
- វាស់វែងផ្លូវដែលត្រូវធ្វើដំណើរ និងបែងចែកការធ្វើដំណើរទៅជាផ្នែកៗ។ កំណត់ម៉ោងមកដល់តាមការប៉ាន់ស្មានសម្រាប់ផ្នែកនីមួយៗ កំណត់ទុកជាមុននូវកន្លែងដែលក្បួននឹងត្រូវឈប់សម្រាក
- គួររៀបចំផែនការបម្រុង (សាមញ្ញ) សម្រាប់ ករណីមានការរងរបួស រថយន្តខូច។ល។
- នីតិវិធីសម្រាប់ការបញ្ឈប់ប្រតិបត្តិការ ត្រូវតែមានដាក់បញ្ចូលនៅក្នុងប្លង់ផ្លូវធ្វើដំណើរ
- កុំធ្វើដំណើរក្រោយពេលមេឃងងឹត ត្រូវធានាឲ្យបានថា រាល់ការកំណត់ពេលវេលាទាំងអស់នៅលើប្លង់ផ្លូវធ្វើដំណើររបស់អ្នកធ្វើឲ្យអ្នកអាចឈានដល់ទីតាំងដែលបានជ្រើសរើសបានល្អមុនពេលថ្ងៃលិច។
- ធានាឲ្យបានថា ទម្ងន់ និងកម្ពស់របស់រថយន្តមិនលើសពីលក្ខណៈបច្ចេកទេសរបស់ស្ពាន/ផ្លូវកាត់ពីក្រោមស្ពាន និង
- ប្រកាសប្រាប់ថាបានពន្យល់ដោយសង្ខេបអំពីក្បួនមុនពេលចេញដំណើរ។

### A 1.3.1.3 ការប្រាស្រ័យទាក់ទង

រថយន្តរបស់អង្គការសហប្រជាជាតិដែលប្រើប្រាស់នៅក្នុងបេសកកម្មតាមផ្លូវគោក ត្រូវមានវិទ្យុទាក់ទងប្រភេទប្រេកង់ខ្ពស់ (HF) និងប្រេកង់ខ្ពស់បំផុត (VHF)។ នៅក្នុងក្បួនដំណើរ ត្រូវតែមានវិទ្យុទាក់ទងប្រភេទ HF និង VHF។ វិទ្យុទាក់ទងប្រភេទ VHF ត្រូវតែមានបំពាក់នូវបណ្តាញប្រភេទ Simplex។ [នេះគឺជាប្រព័ន្ធនៃការប្រាស្រ័យទាក់ទងត្រង់ពីវិទ្យុទាក់ទងប្រភេទ VHF ទៅកាន់វិទ្យុទាក់ទងប្រភេទ VHF មួយទៀតដែលក្នុងករណីនេះគឺ ពីរថយន្តមួយទៅកាន់រថយន្តមួយទៀត។][16]

មុនពេលចេញដំណើរ ការរៀបចំផែនការប្រាស្រ័យទាក់ទងដូចខាងក្រោមនេះ មានសារៈសំខាន់ណាស់៖

- ពិនិត្យមើលគ្រឿងបរិក្ខារវិទ្យុទាក់ទង និងធានាឲ្យបានថា រថយន្តដំបូងគេ និងរថយន្តក្រោយគេមានវិទ្យុទាក់ទង
- ត្រូវដឹងផងដែរថា ការប្រើប្រាស់ ECM អាចរំខានដល់ ការប្រាស្រ័យទាក់ទងតាមវិទ្យុ។ ត្រូវតែរៀបចំឲ្យមានសញ្ញាបន្ថែម ដូចជា ភ្លើងបំភ្លឺខាងមុខ ឬដោយគ្រវីដៃ / ទង់
- បញ្ជាក់ពីប្រេកង់
- រក្សាគម្រោងពេលសម្រាប់ការត្រួតពិនិត្យវិទ្យុទាក់ទងជាមួយ ស្ថានីយ៍កណ្ដាល
- ធានាឲ្យបានថា អ្នកបានដឹងពីសញ្ញាហៅតាមវិទ្យុទាក់ទង លេខទូរស័ព្ទ ទំនាក់ទំនងតាមទូរស័ព្ទទាំងអស់[17] និងនីតិវិធីពិសេសៗដែលត្រូវ ប្រតិបត្តិតាម
- ធានាឲ្យបានថា អ្នកដែលប្រតិបត្តិការវិទ្យុទាក់ទងនៅក្នុងក្បួនបាន ដឹងពីអ្វីៗទាំងអស់ខាងលើ ហើយដឹងថាពួកគេត្រូវតែនិយាយឲ្យបាន ច្បាស់លាស់ និងស្របគ្នាតាមរលកធាតុអាកាស
- ការប្រាស្រ័យទាក់ទងតាមវិទ្យុ ត្រូវតែបង្កើតឡើងមុនពេលចេញដំណើរ ហើយត្រូវតែបញ្ជូនរបាយការណ៍អំពីទីតាំងតាមវិទ្យុទាក់ទងយ៉ាងហោច ណាស់រៀងរាល់មួយម៉ោងម្ដង ដើម្បីឲ្យមានភាពងាយស្រួលនៅពេលបាន ឆ្លងកាត់ទីតាំងទាំងឡាយដែលគេស្គាល់ច្រើន។ ស្ថានីយ៍កណ្ដាលចម្បង នឹងត្រូវទទួលគ្រប់របាយការណ៍តាមរថយន្ត ឬទីភ្នាក់ងារ។ នៅពេលចប់ បេសកកម្ម គួរជូនដំណឹងដល់ស្ថានីយ៍កណ្ដាល។

[16] “Simplex”: ការបញ្ជូនមិនកាត់តាម “Repeater” ទេ ហើយប្រើប្រេកង់ស៍តែមួយគត់។ “Duplex” ប្រើប្រេកង់ស៍ពីរគឺ ប្រេកង់ស៍មួយសម្រាប់បញ្ជូន និងមួយទៀតសម្រាប់ទទួល។ ប្រព័ន្ធនេះ មិន កាត់តាមរីភីទ័រ (repeater) ទេ ហើយផ្ដល់តែរយៈចម្ងាយបន្លាយបន្ថែមទៅកាន់ VHF។
[17] SELCAL - ការហៅខ្លួនឯង គឺជាលេខសម្រាប់ហៅវិទ្យុទាក់ទងនីមួយៗ – តាមធម្មតាគឺពីវិទ្យុ ទាក់ទង VHF មួយផ្សេងទៀត។

### A 1.3.1.4 ទំនួលខុសត្រូវរបស់អ្នកបើកបរ និងលក្ខខណ្ឌតម្រូវសម្រាប់រថយន្ត

បេសកកម្មអន្តរជាតិ ទាមទារឲ្យមានរថយន្តពីរគ្រឿងដែលអនុលោមតាមបទដ្ឋានសន្តិសុខអប្បបរមា (MOSS)។[18] នៅក្នុងករណីជាច្រើន សមាជិកបុគ្គលិកថ្នាក់ជាតិ អាចធ្វើដំណើរនៅក្នុងរថយន្តមួយគ្រឿងដែលអនុលោមតាមបទដ្ឋាន MOSS យកល្អត្រូវមានគ្នាបីនាក់នៅលើរថយន្ត។ នៅពេលខ្លះ មានលក្ខខណ្ឌតម្រូវដោយច្បាប់សម្រាប់បុគ្គលិកថ្នាក់ជាតិដែលត្រូវធ្វើដំណើរតាមរថយន្តពីរគ្រឿងដែលអនុលោមតាមបទដ្ឋាន MOSS តាមការតម្រូវពីលក្ខខណ្ឌសន្តិសុខ និងតាមសេចក្តីសម្រេចនៅក្នុងអង្គប្រជុំអន្តរក្រសួង។ ជាការសំខាន់ណាស់ដែលថា រថយន្តនៅក្នុងក្បួនត្រូវមានការថែទាំបានល្អ ហើយសមស្របសម្រាប់ការបើកបរនៅលើផ្លូវថ្នល់នោះ។ បុគ្គលិកគួរតែ៖

- ធានាឲ្យបានថា រថយន្តទាំងអស់មានលក្ខណៈសមស្របសម្រាប់ភូមិសាស្ត្រដែលត្រូវឆ្លងកាត់
- ពិនិត្យមើលឲ្យដឹងថា រថយន្តទាំងអស់សុទ្ធតែមានដាក់សញ្ញាសម្គាល់ត្រឹមត្រូវ (ពោលគឺ កំណត់ថាតើត្រូវប្រើទង់ ឬស្ទិកឃ័របិទរបស់អង្គការសហប្រជាជាតិ)
- ធានាឲ្យបានថា រថយន្តនីមួយៗមានបំពាក់មកជាមួយនូវកញ្ចប់សង្គ្រោះបឋម បំពង់ពន្លត់អគ្គីភ័យ ប៊ីដុងទឹក និងប៊ីដុងប្រេងឥន្ធនៈ កង់សាគួរ ដែកជួយ និងឧបករណ៍សមស្របផ្សេងៗ
- ពិនិត្យមើលឲ្យដឹងថា រថយន្តទាំងអស់មានស្ថានភាពល្អសម្រាប់ការធ្វើដំណើរ ហើយសុទ្ធតែមានគ្រឿងបរិក្ខារដែលចាំបាច់សម្រាប់ធ្វើការជួសជុលដូចជា ប្តូរសំបកកង់ដែលធ្លាយជាដើម
- ពិនិត្យមើលឲ្យដឹងថា រថយន្តទាំងអស់ចេញដំណើរដោយមានប្រេងពេញធុងប្រេង

[18] MOSS: ស្តង់ដារសន្តិសុខប្រតិបត្តិការអប្បបរមា គឺជាឯកសារគោលនយោបាយរបស់អង្គការសហប្រជាជាតិ។ គោលបំណងរបស់ MOSS គឺដើម្បីបង្កើតបាននូវលក្ខណៈវិនិច្ឆ័យស្តង់ដារផ្អែកលើជំនាញសម្រាប់ការរៀបចំសន្តិសុខអប្បបរមា ដើម្បីពង្រឹងសន្តិសុខបុគ្គលិក និងកាត់បន្ថយហានិភ័យដើម្បីឲ្យការចុះប្រតិបត្តិការនៅតាមមូលដ្ឋានរបស់ អសប អាចធ្វើទៅបាន។



រូបតាងទី A1.3
កំណាត់ផ្លូវចង្អៀត គឺជាឱកាសល្អសម្រាប់ការវាយឆ្មក់ (នៅបាល់កង់)។
រូបថតរបស់ UNMAS/Thomas Enke

- ធានាឲ្យបានថា ក្បួនដំណើរមានទំហំអាចគ្រប់គ្រងបានដែលសមាមាត្រជាមួយនឹងចំនួនអ្នកហែរហម (បើមាន)
- នៅតាមបណ្ដាប្រទេសដែលមានតំបន់ដែលគំរាមកំហែងដោយភេរវករ/សង្គ្រាម រថយន្តប្រតិបត្តិការដែលធ្វើដំណើរនៅក្នុងតំបន់ជម្លោះ ឬតំបន់ផ្សេងទៀតដែលមានគ្រោះថ្នាក់ក៏ត្រូវតែមានផងដែរនូវ៖
  - អាវក្រោះមួយកំប្លេសសម្រាប់អ្នកបើកបរ និងអ្នកធ្វើដំណើរម្នាក់ៗ
  - របាំងការពារគ្រាប់ផ្លោង និងស្រទាប់ធន់នឹងបន្ទុះដែលបំពាក់នៅលើបង្អួច
- ឧបករណ៍រារាំងសេវាក៏អាចជាត្រូវមានជាចាំបាច់ផងដែរ អាស្រ័យទៅលើការគំរាមកំហែងដោយគ្រឿងផ្ទុះនោះ។

### A 1.3.1.5 ព័ត៌មានសង្ខេប

ការជូនដំណឹងដល់អ្នកចូលរួមទាំងអស់អំពីស្ថានភាព/បេសកកម្មនៃការធ្វើដំណើរមុនពេលចេញដំណើរ មានសារៈសំខាន់ចាំបាច់ដូចតទៅ៖

- ផ្ដល់ព័ត៌មានសង្ខេបដល់អ្នកដែលចូលរួមទាំងអស់ ហើយត្រូវធានាឲ្យបានថា គ្រប់ៗគ្នាបានយល់ពីទំនួលខុសត្រូវរបស់ខ្លួន នីតិវិធីនៃក្បួនដំណើរ និងផែនការបម្រុង
- ធានាឲ្យបានថា ល្បឿនជាក់ស្ដែងនៃក្បួនដំណើរមានភាពសមស្របជាមួយនឹងស្ថានភាពផ្លូវ និងរថយន្តដែលយឺតជាងគេបំផុត
- កំណត់មុំ និងចំណែកផ្លូវដែលមើលឃើញនៅចន្លោះអ្នកធ្វើដំណើរនៅក្នុងរថយន្ត
- ផ្ដល់ដំបូន្មានចំពោះវិធានច្បាប់ទម្លាប់នៅក្នុងចរាចរណ៍ផ្លូវគោក
- និយាយអំពីហានិភ័យដែលអាចកើតឡើង
- ផ្ដល់សេចក្ដីណែនាំអំពី
  - នីតិវិធីនៅត្រង់ប៉ុស្តិ៍ត្រួតពិនិត្យផ្លូវការ និងរនាំងបិទផ្លូវ
  - វិធានការនៅក្នុងករណីរថយន្តខូច

## ករណីសិក្សា

កាលពីពីរបីឆ្នាំមុន រថយន្តម៉ាកឡង់គ្រីស័រមួយគ្រឿងដែលមានផ្ទុកអ្នកដំណើរពេញបានប៉ះទង្គិចនឹងមីនប្រឆាំងរថយន្តនៅអង់ហ្គោឡា ប៉ែកអាគ្នេយ៍ បានធ្វើឲ្យស្លាប់អ្នកដំណើរចំនួនប្រាំពីរនាក់ និងធ្វើឲ្យរបួសប្រាំមួយនាក់។

ខណៈពេលដែលបន្ទុះដំបូងបានកម្ទេចរថយន្ត គេជឿជាក់ថាអ្នកដែលបានស្លាប់មួយចំនួនអាចនឹងត្រូវបានការពារ បើអ្នកដំណើរទាំងនោះបានពាក់ខ្សែក្រវ៉ាត់ ពីព្រោះបន្ទុះបានគ្រវាត់រថយន្តទៅលើអាកាស ហើយធ្វើឲ្យអ្នកដំណើរប៉ះទង្គិចជាមួយផ្នែកខាងក្នុងនៃរថយន្ត។

  - ការចាត់វិធានការនៅក្នុងករណីមានការវាយប្រហារដោយគ្រឿងផ្ទុះកៃច្នៃ ការវាយឆ្មក់ ឬការប្រយុទ្ធគ្នា។
- បើក្បួនដំណើរ មានការហែរហមដោយកងកម្លាំងសន្តិសុខ មេបញ្ជាការក្បួនដំណើរត្រូវតែធានាឲ្យបានថា កងកម្លាំងហែរហមទទួលបានព័ត៌មានសង្ខេបអំពីផែនការក្បួនដំណើរ ផ្លូវធ្វើដំណើរ ល្បឿន និងសេចក្ដីលម្អិតផ្សេងៗ និង
- ករណីមានគ្រោះថ្នាក់ ត្រូវធានាឲ្យបានថា ក្បួនដំណើរដឹងថាត្រូវធ្វើអ្វីខ្លះ។

## A1.3.2 ទម្លាប់ក្នុងការចល័ត/ធ្វើដំណើរតាមផ្លូវគោក

ចរាចរណ៍ផ្លូវគោក ជាពិសេសនៅតាមទីប្រជុំជន អាចនឹងមានគ្រោះថ្នាក់ជាទីបំផុត។ សម្រាប់រថយន្តដែលនៅខាងក្រោយនៃក្បួនដំណើរនោះ វាអាចមានការលំបាកក្នុងការបើកបរតាមរថយន្តដែលនាំមុខក្បួន ពិបាកក្នុងការមើលឃើញរូបភាពច្បាស់លាស់អំពីស្ថានភាព និងពិបាកក្នុងការប្រតិកម្មតបទៅនឹងស្ថានភាពដែលមិនអាចប៉ាន់ស្មានដឹងមុន។

ដើម្បីកែលម្អ និងធានាសន្តិសុខដល់ការបើកបរនៅក្នុងក្បួន៖

- បើកបរដោយមានវិន័យ
- មានការរក្សាគម្លាតតាមការបញ្ជាពីរថយន្តមួយទៅរថយន្តមួយទៀត (ECM!) និង
- ប្រើខ្សែក្រវ៉ាត់ការពារសុវត្ថិភាពរបស់អ្នក

រថយន្តដែលនាំមុខក្បួនប្រកាសតាមវិទ្យុទាក់ទង៖

- ទិសផ្លូវដែលត្រូវបើកបរនៅត្រង់ផ្លូវបំបែក
- ការសង្កេតមើលជាពិសេសដូចជា វត្ថុរាំងដំណើរ ប៉ុស្ដិ៍ត្រួតពិនិត្យ កំណាត់ផ្លូវចង្អៀត (ការឈប់ដោយពុំបានរំពឹងទុក) និង



រូបភាពទី A2.1
ការបង្ហាញឲ្យឃើញពីរបាំងការពារគ្រាប់ផ្លោងនៅខាងក្រៅ និងខាងក្នុងទ្វាររថយន្ត។ ពុំមានឃើញអំបែងនៅផ្នែកខាងក្នុងនៃទ្វារទេ (នៅអាហ្វហ្គានីស្ថាន)។ រូបថត/កងកម្លាំងអាល្លឺម៉ង់

- ចំណុចជួបប្រជុំគ្នា ករណីមានគ្រោះអាសន្ន។

រថយន្តនៅក្រោយគេបំផុតប្រកាសតាមវិទ្យុទាក់ទងអំពី៖

- ការឆ្លងកាត់ផ្លូវបំបែក ចំណុចឈប់ និងកំណាត់ផ្លូវចង្អៀត
- ការប្រជែងចូលដោយចៃដន្យរបស់រថយន្តផ្សេងទៀតនៅក្នុងក្បួន និង
- បញ្ហាបច្ចេកទេស ការខូចរថយន្ត។

## ឧបសម្ព័ន្ធ A2 វិធានការផ្តល់ការការពារបន្ថែមដល់រថយន្ត

រថយន្តធម្មតាមិនអាចធន់នឹងបន្ទុះនៃមីនប្រឆាំងរថយន្ត (AV) ឬគ្រឿងផ្ទុះកែច្នៃបានឡើយ។ ដូច្នេះ ដំបូន្មានល្អបំផុតគឺ ត្រូវនៅឲ្យឆ្ងាយពីតំបន់ដែលរងផលប៉ះពាល់ដោយសារមីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ/គ្រឿងផ្ទុះកែច្នៃទាំងអស់គ្នា។ ដោយឡែក មិនត្រូវធ្វើដំណើរនៅលើផ្លូវដែលសង្ស័យថាមានវត្តមាននៃគ្រឿងផ្ទុះទាំងអស់នេះឡើយ។

ទោះបីជាមានគោលការណ៍ណែនាំសុវត្ថិភាពជាមូលដ្ឋាននេះក៏ដោយ ក៏អាចមានកាលៈទេសៈមួយចំនួនដែលសមស្រប និងអាចអនុវត្តបានក្នុងការទិញរថយន្ត “មានការការពារពីមីន” ឬដំឡើងឧបករណ៍ការពារបន្ថែមទៅលើរថយន្តដែលមានស្រាប់។ គួរស្វែងរកដំបូន្មានពីការិយាល័យកណ្តាលរបស់អ្នក និងបុគ្គលិកដែលមានលក្ខណៈសម្បត្តិសមស្រប។

វិធានការមួយចំនួនដែលអ្នកឯកទេសអាចនឹងផ្តល់ជាអនុសាសន៍ មានជាអាទិ៍៖

- ពិចារណាទិញរថយន្តដែលមានការការពារពីមីនដែលផលិតឡើងតម្រូវតាមគោលបំណង ឬតាមតម្រូវការ ឧទាហរណ៍៖ រថយន្តម៉ាក Casspir ឬ



រូបភាពទី A3.1
រាល់ពេលឈប់ម្តងៗ ធ្វើការពិនិត្យក្នុងចម្ងាយ 5/25 ម៉ែត្រ (នៅអាហ្វហ្គានីស្ថាន)។ រូបថតរបស់ UNMAS/Thomas Enke

Wolf។ ការផលិតផ្នែកខាងក្រោមរបស់រថយន្តឲ្យមានរាងជាអក្សរ V ផ្តល់នូវការការពារបានល្អបំផុតសម្រាប់ធ្វើឲ្យបន្ទុះផ្លាតចេញ។

- នៅក្នុងករណីលើកលែងមួយចំនួន អាចបន្ថែមការការពារទៅលើរថយន្តគ្មានពាសដែក។ ការការពារបន្ថែមពីលើនេះ នឹងមិនផ្តល់ការការពារដូចគ្នានឹងរថយន្តដែលមានការការពារពីមីនឡើយ ប៉ុន្តែវានឹងកាត់បន្ថយអានុភាពនៃបន្ទុះបានខ្លះ។ វិធានការទាំងនេះមានជាអាទិ៍៖
  - ការបំពាក់ "របាំងការពារគ្រាប់ផ្លោង" ឬបន្ទះដែកដូចជាប៉ូលីកាបូណាត ឬនីឡុង-សេរ៉ាមិក។ មុនពេលចាត់វិធានការណាមួយ ត្រូវវាយតម្លៃឲ្យបានគ្រប់ជ្រុងជ្រោយទៅលើគុណសម្បត្តិ និងគុណវិបត្តិនៃបច្ចេកវិទ្យានោះ។
  - ការបំពាក់ដែកកាងទ្រុងរថយន្ត។ ដែកកាងទ្រុងរថយន្តនៅផ្នែកខាងក្រោយ អាចមានការបំពាក់បន្ថែមបាន បើអ្នកដំណើរត្រូវតែអង្គុយនៅទីនោះ។ អ្នកដំណើរគួរតែអង្គុយនៅលើកៅអីពូកវែង និងពាក់ខ្សែក្រវ៉ាត់ការពារ យកល្អត្រូវជាខ្សែក្រវ៉ាត់ដែលមានខ្សែបួនទិស។ ធានាឲ្យបានថា កៅអីពូកវែងនៅផ្នែកខាងក្រោយយ៉ាងហោចណាស់ក៏មានបំពាក់ជាមួយនឹងខ្សែក្រវ៉ាត់ការពារ។
  - ការបំពាក់ស្រទាប់ធន់នឹងបន្ទុះ បង្អួចបាំងដែលមានស្រទាប់ធន់នឹងបន្ទុះ អាចបង្ការមិនឲ្យវាបាក់បែកនៅពេលមានបន្ទុះ។
- ការបំពាក់បំពង់ពន្លត់អគ្គីភ័យ និងផ្តល់ប្រអប់/កញ្ចប់គ្រឿងពេទ្យឲ្យដល់រថយន្តទាំងអស់។
- វិន័យតឹងរ៉ឹងក្នុងការផ្ទុកឥវ៉ាន់លើរថយន្ត។ សម្ភារដែលមិនបានចងរឹតឲ្យតឹងណែននៅក្នុងរថយន្ត អាចបង្កឲ្យមានរបួសកាន់តែខ្លាំងករណីមានគ្រោះថ្នាក់បន្ទាប់ពីបានប៉ះទង្គិចនឹងមីន។ មិនត្រូវកាន់ប៊ីដុងប្រេងនៅក្នុងរថយន្តឡើយ។
- ការបំពាក់រថយន្តជាមួយនឹងវិធានការណ៍ទប់ទល់ដោយអេឡិចត្រូនិច (ECM) ជួយការពារប្រឆាំងនឹងគ្រឿងផ្ទុះកៃច្នៃបញ្ជាដោយវិទ្យុ (RC-IEDs)។ ប៉ុន្តែការណ៍នេះសន្មត់ជាមុននូវការវាយតម្លៃត្រឹមត្រូវទៅលើភាពញឹកញាប់ និងការហ្វឹកហ្វឺនបានល្អរបស់បុគ្គលិក។

# ឧបសម្ព័ន្ធ A3 ការត្រួតពិនិត្យក្នុងចម្ងាយ 5/25 ម៉ែត្រ

បើអ្នកកំពុងបើកបរនៅក្នុងតំបន់ដែលមានការគំរាមកំហែងដោយគ្រឿងផ្ទុះកៃច្នៃ ហើយអ្នកត្រូវតែឈប់ (ទោះឈប់ដោយហេតុផលណាមួយក៏ដោយ) អ្នកត្រូវតែធ្វើការត្រួតពិនិត្យក្នុងចម្ងាយ 5/25 ម។ សម្រាប់ការឈប់រយៈពេលខ្លី អ្នកដំណើរត្រូវតែបោសសម្អាតចម្ងាយ 5 ម៉ែត្រជុំវិញរថយន្ត។ សម្រាប់ការឈប់អូសបន្លាយពេលយូរ ត្រូវធានាថាគ្មានអ្វីដែលបង្កបញ្ហាសន្តិសុខ ក្នុងបរិវេណជុំវិញរថយន្ត 25 ម៉ែត្រ។

មុនពេលអ្នកឈប់ ត្រូវតែមានការប្រុងប្រយ័ត្នខ្លាំងបំផុត។ រកមើលដងចបជីក និងរណ្ដៅនៅក្នុងដី ស្នាមជីកដី និងការប្រែប្រួលពណ៌នៅផ្ទៃខាងលើនៃដី។ មិនមែនត្រឹមតែកាកសំណល់ ឬសំរាមនោះទេ រាល់វត្ថុដែលងាយចាប់អារម្មណ៍ទាំងអស់សុទ្ធតែអាចមានគ្រោះថ្នាក់។ រកមើលដំបូល ជញ្ជាំង និងរថយន្តផ្សេងៗ។ យកចិត្តទុកដាក់ទៅលើភាពអាចមើលឃើញទៅកាន់ទីតាំងឈប់ សំចត និងខ្សែដែលមើលឃើញ។

ក្រោយពេលឈប់រថយន្ត កុំចាកចេញពីរថយន្ត ត្រូវធ្វើការសង្កេតជាប្រព័ន្ធ (360 ដឺក្រេ និងពីលើចុះក្រោម)។ រកមើលម្ដងទៀត ក្រែងលោមានដងចបជីក និងរណ្ដៅ និងរាល់វត្ថុផ្សេងៗទៀតដែលបានរៀបរាប់នៅខាងលើ។ អ្នកដំណើរគ្រប់រូបត្រូវទទួលខុសត្រូវចំពោះមុំសង្កេតមើល។

ឥឡូវចាកចេញពីរថយន្ត ប៉ុន្តែកុំពន្លត់ម៉ាស៊ីន។ អ្នកដំណើរពីចំហៀងខាងឆ្វេងគ្រប់គ្រងអ្នកដំណើរខាងឆ្វេង ចំណែកអ្នកដំណើរពីចំហៀងខាងស្ដាំគ្រប់គ្រងអ្នកដំណើរខាងស្ដាំ ប៉ុន្តែធ្វើការឲ្យត្រួតស៊ីគ្នា និងជាប្រព័ន្ធ។ បិទទ្វារ និងត្រួតពិនិត្យមើលរថយន្តក្រែងលោមានការខូចខាត និងគ្រឿងឧបករណ៍ដែលគួរឲ្យចាប់អារម្មណ៍ (រួមទាំងនៅក្រោមរថយន្ត)។ រុករកនៅជិតៗរថយន្ត។ តើមាន

## ករណីសិក្សា

អ៊ុយរ៉ានីញ៉ូមរឹង ត្រូវបានគេប្រើប្រាស់យ៉ាងច្រើននៅអំឡុងសង្គ្រាមឈូងសមុទ្រឆ្នាំ 1991។ គ្រាប់មូលធ្វើពីអ៊ុយរ៉ានីញ៉ូមរឹងស្ទើរតែមួយលានគ្រាប់ត្រូវបានគេបាញ់ដែលស្មើនឹង 340 តោន នៅបាល់កង់ដែលគេប៉ាន់ស្មានថាមានគ្រាប់ចំនួន 11 តោន ត្រូវបានគេបាញ់នៅចុងទសវត្សរ៍ឆ្នាំ 1990។

គ្រាប់ផលិតពីអ៊ុយរ៉ានីញ៉ូមរឹងប្រមាណជា 75 តោន ត្រូវបានប្រើប្រាស់ដោយកងទ័ពសហរដ្ឋអាមេរិកនៅក្នុងសង្គ្រាមឈូងសមុទ្រកាលពីពេលថ្មីៗទៅនេះ។
Christian Science Monitor, www.csmonitor.com/2003/0515/

ទោះជាយ៉ាងណា ទិន្នន័យសុខភាពអំពីផលប៉ះពាល់រយៈពេលវែងរបស់អ៊ុយរ៉ានីញ៉ូមរឹងនៅតែមានកម្រិត ហើយផលប៉ះពាល់ផ្នែកសុខភាពរបស់អ៊ុយរ៉ានីញ៉ូមមានកម្រិតខ្ពស់។

នរណាម្នាក់កំពុងសំឡឹងមើលសកម្មភាពរបស់អ្នកដែរឬទេ (អ្នកពិនិត្យរកអ្វីមួយ/អ្នកបំផ្ទុះ)?

សួរអ្នកដទៃ បើអ្នកមានការសង្ស័យ។

ចាប់ផ្តើមធ្វើការពិនិត្យក្នុងចម្ងាយ 5 ម៉ែត្រ។ រុករកក្នុងរង្វង់ 5 ម៉ែត្រជុំវិញរថយន្ត។ ធានាឲ្យបានថា អ្នកធ្វើការឲ្យជាន់គ្នា (បើមានមនុស្សលើសពីម្នាក់កំពុងឆែករក) ពួកគេត្រូវរកមើលអ្វីៗដែលគួរឲ្យចាប់អារម្មណ៍ដោយមានការយល់ឃើញខុសៗគ្នា។ មើលខាងក្រោមរថយន្ត (ម្តងទៀត!)។

ធ្វើការត្រួតពិនិត្យក្នុងចម្ងាយ 25 ម៉ែត្រ។ រុករកក្នុងរង្វង់ 25 ម៉ែត្រ។ ដើរជុំវិញគុម្ពឈើ និងចេញពីបរិវេណនោះ លាក់កំបាំងការឆែករកនោះ បើចាំបាច់។ រកមើលសញ្ញាសម្គាល់ និងសញ្ញានៃការវាយឆ្មក់។ កុំចូលទៅជិតរបស់ដែលគួរឲ្យសង្ស័យ។ ប្រើកែវយឺត និងម៉ាស៊ីនថតឌីជីថល ដើម្បីកំណត់អត្តសញ្ញាណវត្ថុឲ្យបានកាន់តែច្បាស់លាស់។



រូបភាពទី A4.1
ហានិភ័យមួយក្នុងចំណោមហានិភ័យជាច្រើននៃរថយន្តប្រយុទ្ធដែលត្រូវបានគេបោះបង់ និងបានបំផ្លាញចោលគឺ ការញុំាញីឬការធ្វើឲ្យប្រឡាក់ជាប់ដោយជាតិអ៊ុយរ៉ានីញ៉ូមនៃគ្រាប់ (នៅអាហ្វហ្គានីស្ថាន)។ រូបថតរបស់ UNMAS/Thomas Enke

# ឧបសម្ព័ន្ធ A4 ការគាំទ្របច្ចេកទេស

## A4.1 អ៊ុយរ៉ានីញ៉ូមរីង

អ៊ុយរ៉ានីញ៉ូមរីង (DU) មានលក្ខណៈហាប់ណែន គឺ 19,050 គក្រ/ម³ វាស្មើនឹងដង់ស៊ីតេរបស់សំណរ 1.67 ដង (11.340 គក្រ/ម³)។ នៅក្នុងល្បាយជាមួយនឹង 2 % នៃម៉ូលីបដែន ឬ0.75 % នៃទីតានីញ៉ូម និងប្រព្រឹត្តកម្មនៅសីតុណ្ហភាពពិសេស វានឹងមានសភាពរឹងខ្លាំង ដូចគ្នានឹងតង់ស្តែនកាប៊ីត (tungsten carbide) ដែរ។ DU មានតម្លៃថោក៖ វាមានតម្លៃស្មើនឹង 20 % នៃតម្លៃរបស់តង់ស្តែន។ អ៊ុយរ៉ានីញ៉ូមរីង មានជាតិពុល ហើយឆ្លងកាត់រយៈពេលវែងអាចមានផលប៉ះពាល់សុខភាពរយៈពេលវែង។

ក្នុងនាមជាអនុផលនៃការធ្វើឲ្យអ៊ុយរ៉ានីញ៉ូមកាន់តែរឹង DU មានតម្លៃថោកជាងបណ្ដាធាតុដែលគេកំពុងតេស្តសម្រាប់ធ្វើយុទ្ធភ័ណ្ឌដែលមានដង់ស៊ីតេខ្ពស់ដទៃទៀត រួមទាំងតង់ស្ដែននៅទសវត្សរ៍ឆ្នាំ 1960។ ក្នុងនាមជាបេក្ខភាពបន្ទាប់ដែលល្អជាងគេ តង់ស្ដែនត្រូវតែទទួលបានពីប្រទេសចិន។ ដោយមានឃ្លាំងស្តុក DUដែលគេប៉ាន់ស្មានថាមានទម្ងន់លើសពី 500,000 តោន វារឹតតែមានការសន្សំសំចៃថែមទៀតក្នុងការប្រើប្រាស់អ៊ុយរ៉ានីញ៉ូមរឹងជាជាងការស្តុកវាទុក។ ដូច្នេះ ចាប់ពីចុងទសវត្សរ៍ឆ្នាំ 1970 មក ស.រ.អ អតីតៈសហភាពសូវៀត ចក្រភពអង់គ្លេស និងបារាំងបានចាប់ផ្ដើមបម្លែងឃ្លាំងស្តុកអ៊ុយរ៉ានីញ៉ូមរឹងរបស់ពួកគេឲ្យទៅជាគ្រឿងទម្លុះថាមពលចលនា។

លើសពីនេះ អ៊ុយរ៉ានីញ៉ូមរឹងត្រូវបានគេប្រើនៅក្នុងការធ្វើបន្ទះដែកសម្រាប់រថក្រោះ និងរថយន្តយោធាផ្សេងៗ និងប្រើសម្រាប់ធ្វើជាគ្រឿងទប់លំនឹងយន្តហោះ និងនៅក្នុងមេបាតរបស់ទូកប្រណាំងផងដែរ។

នៅពេលប៉ះទង្គិចជាមួយនឹងគោលដៅរឹង ដូចជា រថពាសដែកជាដើម ច្រមុះនៃដងរបស់វានឹងប្រេះបែកដែលនៅតែរក្សាបាននូវភាពមុតស្រួចរបស់វា។ ការប៉ះទង្គិច និងការបញ្ចេញថាមពលកម្ដៅជាបន្តបន្ទាប់ ធ្វើឲ្យក្បាលគ្រាប់បែកខ្ទេចទៅជាផេះផង់ ហើយឆេះនៅពេលវាប៉ះខ្យល់ដោយសារតែលក្ខណៈងាយឆេះរបស់វា។ នៅពេលគ្រឿងទម្លុះ DU ឈានទៅដល់ផ្នែកខាងក្នុងនៃរថពាសដែក វាបង្កជាអណ្ដាតភ្លើងដែលតែងតែធ្វើឲ្យឆេះគ្រាប់រំសេវ និងឥន្ធនៈ ដោយសម្លាប់ក្រុមយានិក ហើយអាចបណ្ដាលឲ្យរថយន្តផ្ទុះឡើងថែមទៀតផង។

ដោយសារប្រព្រឹត្តិកម្មសីតុណ្ហភាពពិសេស ដើម្បីដុតរំលាយដែកនៅលើផ្ទៃរបស់គ្រាប់អ៊ុយរ៉ានីញ៉ូមរឹង វានឹងបញ្ចេញកម្ទេចអ៊ុយរ៉ាញ៉ូមរឹងដែលបានបាញ់ រហូតទាល់តែក្បាលគ្រាប់ទាំងមូលក្លាយទៅជាកម្ទេច។ ការណ៍នេះធ្វើឲ្យរាល់វត្ថុអនុស្សាវរីយ៍ផលិតពី DU មានគ្រោះថ្នាក់បំផុតចំពោះសុខភាព។

អ៊ុយរ៉ានីញ៉ូមរឹង មានកម្ទេចដែលជួនកាលគេអាចសម្គាល់វាថាជាកម្ទេចពណ៌ខ្មៅ ឬបៃតង ឬដូចគ្នានឹងលំអងភ្លើងដែរ។ បើកម្ទេច មិនអាចមើលឃើញទេនោះ កុំទាន់សន្មត់ថាគ្មានវត្តមានកម្ទេចអ៊ុយរ៉ានីញ៉ូមរឹងឲ្យសោះ។

អ៊ុយរ៉ានីញ៉ូមរឹង អាចត្រូវបានហឺតចូល លេបចូល ឬចូលទៅក្នុងរាងកាយយើងតាមរយៈស្នាមដាច់រលាត់។ ជាយូរយារណាស់មកហើយ ដោយសារតែអ៊ុយរ៉ានីញ៉ូមរឹងនៅតែស្ថិតក្រៅរាងកាយមនុស្ស អ្នកជំនាញបានចាត់ទុកថាវាជាគ្រោះថ្នាក់តូចតាច។

វិធានងាយៗមួយចំនួនសម្រាប់កម្រិតព្រំដែននៃការប៉ះនឹងអ៊ុយរ៉ានីញ៉ូមរឹងមានជាអាទិ៍៖

- កុំចូល ឬឡើងទៅលើ ឬជុំវិញគ្រឿងបរិក្ខារយោធាដែលខូចខាត
- កុំប៉ះពាល់ ឬចូលទៅជិតកម្ទេចសំណល់ពីយោធា សំបកគ្រាប់រំសេវយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងរថយន្តយោធាដែលបានខូចខាត ឬបានបោះបង់ចោល និង
- កុំប្រមូលវត្ថុអនុស្សាវរីយ៍ពីសង្គ្រាម។

បើអ្នកបានប៉ះពាល់ជាមួយនឹងអ៊ុយរ៉ានីញ៉ូមរឹង៖

- បាំងមាត់របស់អ្នក
- ចាកចេញពីបរិវេណនោះ
- លាងដៃ និងលុបមុខជាមួយសាប៊ូ និងទឹក និង
- បោកគក់សម្លៀកបំពាក់របស់អ្នក។

ព័ត៌មានច្រើនបន្ថែមទៀតអាចរកបាននៅ៖
en.wikipedia.org/wiki/Depleted_uranium
នៅពេលនេះ មានឯកសារយោងរាប់រយដែលបានភ្ជាប់មកជាមួយ។

## A4.2 អាវុធជីវសាស្ត្រ និងអាវុធគីមី

អាវុធជីវសាស្ត្រ ត្រូវបានបង្កើតឡើងដើម្បីបញ្ចេញមេរោគ ឬសារធាតុជីវសាស្ត្រដទៃទៀតដែលអាចធ្វើឲ្យអ្នកឈឺធ្ងន់ធ្ងរ ឬសម្លាប់អ្នក។ សារធាតុជីវសាស្ត្រ (សារធាតុបង្កជម្ងឺ) ជាច្រើន ត្រូវហឺតចូលតាមផ្លូវដង្ហើម ចូលទៅក្នុងរាងកាយតាមស្នាមដាច់រលាត់នៅក្នុងស្បែក ឬលេបវាចូលដើម្បីធ្វើឲ្យអ្នកឈឺ។ ភ្នាក់ងារជីវសាស្ត្រមួយចំនួន ដូចជា វីរុសជំងឺអុតធំអាចឆ្លងបាន ហើយបើអ្នកប៉ះពាល់វាអ្នកប្រថុយនឹងការចម្លងទៅឲ្យអ្នកដទៃផងដែរ។

អាវុធគីមី ត្រូវបានបង្កើតឡើងដើម្បីបញ្ចេញឧស្ម័ន វត្ថុរាវ ឬវត្ថុរឹងដែលមានជាតិពុលដែលអាចធ្វើឲ្យមនុស្សពុលតាមរយៈការហឺតចូល ឬប៉ះពាល់ជាមួយស្បែក និងបរិយាកាស។ អាវុធគីមីភាគច្រើនធ្វើឲ្យរលាកស្បែក។

អាវុធគីមី និងសព្វាវុធជីវសាស្ត្រ ត្រូវបានបាញ់រួមគ្នាដោយក្បាលគ្រាប់មីស៊ីល គ្រាប់រ៉ុក្កែត គ្រាប់បែកទម្លាក់ពីលើអាកាស គ្រាប់កាំភ្លើងធំមូល និងរថក្រោះបាញ់ផ្សែងទៅលើអាកាស។ លើសពីនេះ រោងចក្រជីវសាស្ត្រ និងរោងចក្រគីមីដែលគេបោះបង់ចោល និង/ឬបានបំផ្លាញចោល អាចបណ្តាលឲ្យមានហានិភ័យដែលមានការបង្កគ្រោះថ្នាក់ដូចគ្នា។

ខណៈដែលសារធាតុគីមី និងសារធាតុជីវសាស្ត្រ តាមធម្មតាតែងតែរសាយបាត់ភ្លាមៗនោះ ប្រព័ន្ធសព្វាវុធដែលគេបានបោះបង់ចោលក៏នៅតែអាចផ្ទុកនូវសារធាតុបង្កគ្រោះថ្នាក់ផងដែរ។ ដំបូន្មានល្អបំផុត គឺត្រូវនៅឲ្យឆ្ងាយពីឃ្លាំងទុកសព្វាវុធ និងយុទ្ធភ័ណ្ឌដែលគេបោះបង់ចោល វត្ថុរាវ និងដបដែលគួរឲ្យសង្ស័យ។

សញ្ញាដែលប្រាប់ថាអាចមានការគំរាមកំហែងដោយផ្នែកគីមី ឬជីវសាស្ត្រ៖

- ឧស្ម័នដែលផ្ទុកនៅលើយន្តហោះ
- វត្ថុរាវ និងដបដែលខុសពីធម្មតា

- ក្លិនខុសពីធម្មតា
- មនុស្សជាច្រើនដែលរងទុក្ខដោយសារការហូរទឹកភ្នែក កន្ត្រាក់ដៃជើង ឈ្លក់ ពិបាកដកដង្ហើម ឬបាត់បង់លំនឹងខ្លួន
- សត្វស្លាប ត្រី ឬសព្វពាហនៈតូចៗដែលឈឺ ឬងាប់ជាច្រើន ក៏ជាមូលហេតុនាំឲ្យមានការសង្ស័យផងដែរ និង
- ការចាប់ឈឺភ្លាមៗដោយអ្នក ឬសហការីរបស់អ្នក។

បើអ្នកបានដឹងពីសារធាតុផ្ទុកលើយន្តហោះនៅជិតៗដែលខុសពីធម្មតា ឬគួរឲ្យសង្ស័យ៖

- ប្រើម៉ាស CBRN
- ស្វែងរកខ្យល់ស្អាតភ្លាមៗ
- ព្យាយាមកំណត់តំបន់ដែលរងផលប៉ះពាល់ភ្លាមៗ និងកន្លែងដែលសារធាតុគីមីចេញមក
- ចាត់វិធានការគេចចេញជាបន្ទាន់។ នៅពីលើខ្យល់នៃសារធាតុបង្គ្រោះថ្នាក់ធំ។
- បាំងមាត់ និងច្រមុះដោយប្រើស្រទាប់ជាតិសរសៃដែលអាចច្រោះខ្យល់បាន ប៉ុន្តែនៅតែអាចដកដង្ហើមបាន
- បើសារធាតុនោះស្ថិតនៅក្នុងអគារដែលអ្នកស្ថិតនៅដែរនោះ ត្រូវចេញពីអគារនោះដោយមិនត្រូវឆ្លងកាត់តាមបរិវេណដែលរងការញ៉ាំញី ឬបំពុលនោះឡើយ (បើអាចធ្វើបាន)
- បើអ្នកមិនអាចចេញក្រៅអគារ ឬមិនអាចស្វែងរកខ្យល់ស្អាតដោយពុំចាំបាច់ឆ្លងកាត់តាមបរិវេណដែលអ្នកឃើញសញ្ញានៃការវាយប្រហារដោយគីមី យកល្អគួរតែចល័តឲ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន
- លាងសម្អាតជាមួយនឹងសាប៊ូ និងទឹក និង
- ទាក់ទងអាជ្ញាធរ (ឧ. ទីភ្នាក់ងារសកម្មភាពមីន មន្ត្រីសន្តិសុខនៃអង្គការសហប្រជាជាតិ មជ្ឈមណ្ឌលប្រតិបត្តិការយុទ្ធសាស្ត្រនៃក្រុមបេសកកម្មរក្សាសន្តិភាព សង្កេតការណ៍ ឬហ្វឹកហ្វឺន)។

បើទឹកភ្នែករបស់អ្នកកំពុងហូរ ស្បែករបស់អ្នកឡើងកន្ទួលរមាស់ ហើយអ្នកមានបញ្ហាក្នុងការដកដង្ហើម អ្នកប្រហែលជាបានប៉ះពាល់នឹងសារធាតុគីមីណាមួយហើយ។ បើអ្នកយល់ថាអ្នកបានប៉ះពាល់នឹងសារធាតុគីមីណាមួយ៖

- កុំផឹកទឹក ញ៉ាំអាហារ ឬជក់បារី
- ច្បូតចេញភ្លាម រួចលាងសម្អាត
- រកមើលទុយោទឹក ក្បាលទឹក ឬប្រភពទឹកណាមួយ រួចលាងសម្អាតជាមួយនឹងសាប៊ូ (បើអាចធ្វើបាន) ដោយត្រូវធ្វើឲ្យប្រាកដថា មិនបានត្រដុសសារធាតុគីមីនោះចូលទៅក្នុងស្បែកអ្នក និង
- ស្វែងរកការព្យាបាលសង្គ្រោះបន្ទាន់។

បើអ្នកយល់ថា អ្នកបានប៉ះពាល់នឹងភ្នាក់ងារជីវសាស្ត្រ៖

- កុំផឹកទឹក ឬញ៉ាំអាហារ
- ធ្វើអនាម័យ និងសម្អាតខ្លួនឲ្យបានល្អដើម្បីជៀសវាងការធ្វើឲ្យមេរោគរីករាលដាល
- លាងសម្អាតដៃរបស់អ្នកជាមួយនឹងសាប៊ូ និងជម្រះដោយទឹកឲ្យបានញឹកញាប់
- កុំញ៉ាំអាហារ ឬប្រើសម្ភាររួមគ្នាជាមួយអ្នកដទៃ
- បាំងមាត់ និងច្រមុះរបស់អ្នកនៅពេលក្អក ឬកណ្ដាស់
- ចែករំលែកព័ត៌មានទាក់ទងនឹងសុខភាពជាមួយអ្នកដទៃ ជាពិសេសអ្នកដែលអាចនឹងត្រូវការជំនួយក្នុងការយល់ពីស្ថានភាព និងវិធានការជាក់លាក់អ្វីខ្លះដែលត្រូវធ្វើ និង
- ស្វែងរកជំនួយពីវេជ្ជសាស្ត្រ។

សម្រាប់ព័ត៌មានលម្អិតបន្ថែមទៀត សូមមើលទំព័រ
en.wikipedia.org/wiki/CBRN_defense

# ឧបសម្ព័ន្ធ A5 ការណែនាំអំពីចម្ងាយត្រូវជម្លៀសខ្លួន



# ឧបសម្ព័ន្ធ A6 ទម្រង់ប្រាំបួនជាន់ថ្នាក់



# ឧបសម្ព័ន្ធ A7 សន្ទានុក្រម

សន្ទានុក្រមនេះ ផ្ដល់នូវការពន្យល់ងាយៗសម្រាប់ពាក្យបច្ចេកទេសមួយចំនួនដែលបានដាក់បញ្ចូលនៅក្នុងសៀវភៅក្បួននេះ។ គោលបំណងគឺដើម្បីជួយសម្រួលដល់អ្នកអាន និងដើម្បីកុំឲ្យជំនួស ឬកែប្រែតាមមធ្យោបាយណាមួយក្ដីទៅលើនិយមន័យច្បាប់ ឬបច្ចេកទេស ដូចគ្នានឹងនិយមន័យដែលឃើញមាននៅក្នុងអនុសញ្ញាឆ្នាំ 1980 ស្ដីពីគ្រឿងសព្វាវុធធម្មតាមួយចំនួន និងពិធីសារដែលបានភ្ជាប់មកជាឧបសម្ព័ន្ធរបស់វា ឬអនុសញ្ញាឆ្នាំ 1997 ស្ដីពីការហាមឃាត់ការប្រើប្រាស់ ស្តុកទុក ផលិត និងផ្ទេរមីនប្រឆាំងមនុស្ស និងស្ដីពីការបំផ្លាញវា (ជារឿយៗត្រូវបានគេហៅម្យ៉ាងទៀតថា សន្ធិសញ្ញាហាមប្រាមមីនប្រឆាំងមនុស្ស ឬសន្ធិសញ្ញា/អនុសញ្ញាទីក្រុងអូតាវ៉ា)។



រូបភាពទី A6.1
ចម្ការមីនដែលមិនទាន់បានបោសសម្អាតរយៈពេល 70 ឆ្នាំ ក្រោយសង្គ្រាមលោកលើកទីពីរ (នៅអាល្លឺម៉ង់) ថតរូបដោយ
Markus Schweiss

## គ្រឿងផ្ទុះកែច្នៃដែលគេបោះបង់ចោល (ABANDONED IED) (ហៅម្យ៉ាងទៀតថា សំណល់គ្រឿងផ្ទុះកែច្នៃ)

គ្រឿងផ្ទុះកែច្នៃដែលគេបោះបង់ចោល មានន័យថា គ្រឿងផ្ទុះគ្មានស្តង់ដារដែលមិនទាន់បានប្រើប្រាស់ ប៉ុន្តែលែងស្ថិតក្រោមការគ្រប់គ្រងរបស់កងកម្លាំងជាក់លាក់ណាមួយទៀតហើយ។ ដោយសារតែការប្រើប្រាស់រំសេវផ្ទុះផលិតក្នុងស្រុក គីប/ឆ្នូន និងផ្នែកផ្សេងទៀតនៃគ្រឿងផ្ទុះកែច្នៃដែលគេបោះបង់ចោល មានការបង្កគ្រោះថ្នាក់យ៉ាងខ្លាំង ហើយអាចនឹងគ្មានស្ថេរភាព។ វាអាចបំផ្ទុះដោយការប៉ះពាល់ ឬដោយសារការប្រែប្រួលលក្ខខណ្ឌនៃមជ្ឈដ្ឋានជុំវិញវា។ លើសពីនេះ គ្រឿងផ្ទុះកែច្នៃធ្លាប់ត្រូវបានគេប្រើដើម្បីការពារ សព្វាវុធ និងសំបកគ្រាប់រំសេវ (ដែលបោះបង់ចោល)។

## ABANDONED ORDNANCE (យុទ្ធភ័ណ្ឌដែលគេបោះបង់ចោល)

យុទ្ធភ័ណ្ឌដែលគេបោះបង់ចោល (AO) គឺជាយុទ្ធភ័ណ្ឌដែលពុំធ្លាប់បានប្រើប្រាស់ ប៉ុន្តែលែងស្ថិតក្រោមការគ្រប់គ្រងរបស់កងកម្លាំងជាក់លាក់ណាមួយ

ទៀតហើយ។ AO អាចមានជាអាទិ៍ គ្រាប់កាំភ្លើងត្បាល់មូល គ្រាប់បែក ដៃ គ្រាប់បែក គ្រាប់រ៉ុក្កែត គ្រាប់កាំភ្លើង គ្រាប់កាំភ្លើងធំមូល។ល។ ជួនកាល យុទ្ធភ័ណ្ឌដែលគេបោះបង់ចោល អាចរួមបញ្ចូលទាំងសំបកសព្វាវុធតូចៗ ដែលបានបាត់បង់នៅអំឡុងពេលប្រយុទ្ធគ្នា ហើយទើបតែឃើញនៅពេលក្រោយ កទៀត។

## មីនប្រឆាំងមនុស្ស (ANTI-PERSONNEL MINE)

គ្រាប់មីនដែលត្រូវបានរចនាឡើងដើម្បីបង្ករបួសស្នាម ឬសម្លាប់មនុស្សម្នាក់ ឬ ច្រើន។ មីនប្រឆាំងមនុស្ស តាមធម្មតាផ្ទុះនៅពេលមានគេដើរជាន់លើវា ឬនៅ ពេលខ្សែអន្ទាក់/គ្រាប់បែកបង្កៃមានគេរំខាន ប៉ុន្តែគេក៏អាចបំផ្ទុះវាដោយការ កំណត់ម៉ោង ឬដោយមធ្យោបាយទាំងឡាយដែលអាចគ្រប់គ្រងបានផងដែរ។ មីនប្រឆាំងមនុស្ស អាចធានាសន្តិសុខប្រឆាំងនឹងការដោះយកចេញ ហើយក៏ អាចឃើញមាននៅជាមួយគ្នានឹងមីនប្រឆាំងរថយន្តផងដែរ។

## មីនប្រឆាំងរថយន្ត(ANTI-VEHICLE MINE)

ដោយជាញឹកញាប់គេសំដៅទៅលើមីនប្រឆាំងរថក្រោះ មីនប្រឆាំងរថយន្តត្រូវ បានរចនាឡើងដើម្បីបំផ្លាញ ឬធ្វើឲ្យរថយន្ត រួមទាំងរថក្រោះប្រើការលែងកើត។ ដូចគ្នានឹងមីនប្រឆាំងមនុស្សដែរ មីនប្រឆាំងរថយន្តអាចត្រូវបានបំផ្ទុះដោយ កម្លាំងសម្ពាធ (ប៉ុន្តែវាត្រូវការទម្ងន់ច្រើនជាងធម្មតា) ឬដោយបញ្ជាពីចម្ងាយ ក៏ដូចជាដោយឥទ្ធិពលម៉ាញេទិច ឬតាមរយៈការរំខានពីដងមួល (ខ្សែអន្ទាក់/ គ្រាប់បែកបង្កៃបញ្ឈរមួយប្រភេទ)។ មីនប្រឆាំងរថយន្ត អាចធានាសន្តិសុខ ប្រឆាំងនឹងការដោះយកចេញ ហើយក៏អាចឃើញមាននៅជាមួយគ្នានឹងមីន ប្រឆាំងមនុស្សផងដែរ។

## អន្ទាក់/គ្រាប់បែកបង្កៃ (BOOBY TRAP)

គ្រឿងផ្ទុះ ឬមិនផ្ទុះដែលត្រូវបានគេលាក់ទុកដើម្បីបង្កឲ្យមានមនុស្សរងគ្រោះ នៅពេលវត្ថុដែលមើលទៅហាក់ដូចជាគ្មានគ្រោះថ្នាក់មានគេមករំខាន ឬធ្វើសកម្មភាពសុវត្ថិភាពតាមធម្មតា ដូចជា បើកទ្វារ ឬបើកទូរទស្សន៍។ អន្ទាក់/គ្រាប់បែកបង្កៃទាំងអស់ដែលប្រើរំសេវផ្ទុះ សុទ្ធតែត្រូវបានចាត់ទុកថាជាគ្រឿងផ្ទុះកែច្នៃ (IEDs)។

## មីនជះអំបែង (BOUNDING MINE)

មីនប្រឆាំងមនុស្សដែលបំផ្ទុះដោយខ្សែអន្ទាក់/គ្រាប់បែកបង្កៃ ឬសម្ពាធ ហើយផ្ទុះទៅលើអាកាសនៅកម្ពស់មួយដែលមិនអាចកំណត់ជាមុនបាន ដោយជះអំបែងទៅគ្រប់ទិសដៅ។

## សំណល់ជាតិផ្ទុះពីសង្គ្រាម (EXPLOSIVE REMNANTS OF WAR)

យុទ្ធភ័ណ្ឌទាំងអស់ដែលនៅសល់ក្រោយជម្លោះប្រដាប់អាវុធ ហើយមានសក្តានុពលផ្ទុះ។ ការណ៍នេះរួមមានទាំង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ យុទ្ធភ័ណ្ឌដែលគេបោះបង់ចោល អន្ទាក់/គ្រាប់បែកបង្កៃ គ្រឿងផ្ទុះកែច្នៃ និងក្នុងកាលៈទេសៈមួយចំនួន រថយន្ត និងគ្រឿងបរិក្ខារយោធាដែលគេបានបោះបង់ចោល ឬបានបំផ្លាញចោល។ នៅក្នុងភាសាច្បាប់អន្តរជាតិ សំណល់ជាតិផ្ទុះពីសង្គ្រាម (ERW) តាមធម្មតាពុំរាប់បញ្ចូលគ្រាប់មីនឡើយ ព្រោះគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមត្រូវបានគេដោះស្រាយក្រោមអនុសញ្ញាអន្តរជាតិពីរខុសគ្នា៖ សន្ធិសញ្ញាហាមប្រាមមីនប្រឆាំងមនុស្ស និងអនុសញ្ញាស្តីពីគ្រឿងសព្វាវុធធម្មតាមួយចំនួន (ពិធីសារទី V)។

## គីប/ឆ្នួន (FUSE)

គីប/ឆ្នួនគឺជាធាតុផ្សំនៃគ្រាប់រំសេវដំណើរការមុខងារដែលអនុញ្ញាតឲ្យគ្រាប់រំសេវផ្ទុះ ឬដំណើរការមុខងារតាមការរចនានៅពេលមានការប្រើប្រាស់។

## គ្រឿងផ្ទុះកែច្នៃ (IMPROVISED EXPLOSIVE DEVICE)

គ្រឿងផ្ទុះកែច្នៃ (IED) មាននិយមន័យថា គ្រឿងផ្ទុះមិនស្តង់ដារ តាមធម្មតាច្នៃប្រឌិតពីសម្ភារដែលអាចរកបានងាយៗ។ វារួមបញ្ចូលនូវរំសេវផ្ទុះ ឬភ្នាក់ងារ (CBRN) ផ្សេងទៀត ហើយមានអានុភាពបំផ្លាញ ធ្វើឲ្យស្លាប់ ឬពុលបាន។ គុណភាពខ្ពស់ ការផលិតជាស៊េរី ការផ្ទេរបច្ចេកវិទ្យា និងការអភិវឌ្ឍបន្ថែម ធ្វើឲ្យគ្រឿងផ្ទុះកែច្នៃបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរ។

## សកម្មភាពកម្ចាត់មីន (MINE ACTION)

សកម្មភាពដែលដោះស្រាយបញ្ហាការគំរាមកំហែងដោយសារគ្រាប់មីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងសំណល់គ្រឿងផ្ទុះកែច្នៃជូនដល់ជនស៊ីវិល។ សកម្មភាពកម្ចាត់មីន តាមធម្មតាដាក់បញ្ចូលនូវសកម្មភាពគាំទ្រគ្នាទៅវិញទៅមកដែលមានជាអាទិ៍៖

- ការអប់រំ និងលើកកម្ពស់ការយល់ដឹងអំពីហានិភ័យ
- ការគាំទ្រឲ្យហាមឃាត់គ្រាប់មីន និងសព្វាវុធផ្សេងៗដែលមានផលប៉ះពាល់មិនរើសមុខ
- ជំនួយដល់ជនរងគ្រោះដោយសារគ្រាប់មីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងសំណល់គ្រឿងផ្ទុះកែច្នៃ
- ការបោសសម្អាតមីន និងការកម្ទេចសំណល់ជាតិផ្ទុះ និង
- ការបំផ្លាញគ្រាប់មីនដែលបានស្តុកទុក។

សកម្មភាពកម្ចាត់មីន ជាទូទៅពុំរាប់បញ្ចូលនូវការដោះចេញ ឬការបំផ្លាញគ្រឿងផ្ទុះកែច្នៃឡើយ។ ជារឿយៗ ការគំរាមកំហែងបែបនេះត្រូវបានដោះស្រាយដោយកងកម្លាំងសន្តិសុខ ដូចជា នគរបាលជាដើម។

## មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីន (MINE ACTION CENTRE)

មជ្ឈមណ្ឌលដែលសម្របសម្រួល និងចាត់ចែងសកម្មភាពកម្ចាត់មីននៅក្នុង

ប្រទេសមួយ។ តាមធម្មតា រដ្ឋាភិបាល ឬអង្គការសហប្រជាជាតិ ដំណើរការមជ្ឈមណ្ឌលបែបនេះ។

## ការដាក់សញ្ញាសម្គាល់មីន (MINE MARKING)

ការដាក់សញ្ញាសម្គាល់ចម្ការមីនតាមការរៀបចំ។ សញ្ញាព្រមានប្រាប់អំពីគ្រាប់មីនដែលមានបទដ្ឋានត្រឹមត្រូវ និងងាយស្រួលមានគេស្គាល់បាន គេតែងតែដាក់នៅជុំវិញបរិវេណចម្ការមីន ដើម្បីព្រមានប្រាប់ប្រជាពលរដ្ឋឲ្យប្រុងប្រយ័ត្នចំពោះវត្តមាននៃមីន។

## សំណល់គ្រឿងផ្ទុះកែច្នៃ (REMNANT IED)

សូមមើល គ្រឿងផ្ទុះកែច្នៃដែលគេបោះបង់ចោល (ABANDONED IED)

## ដងមួល (TILT ROD)

ដង ឬបង្គោលដែលភ្ជាប់ទៅនឹងយន្តការគីប/ឆ្នួននៅលើផ្ទៃខាងលើរបស់មីន។ សម្ពាធដែលប្រើទៅលើដងមួល ធ្វើឲ្យមីនផ្ទុះឡើង។

## ខ្សែអន្ទាក់/គ្រាប់បែកបង្កៃ (TRIPWIRE)

ខ្សែលោហៈស្តើងដែលមិនរស់រវើក ឬគ្មានពណ៌ដែលអាចប្រើជាយន្តការសម្រាប់បំផ្ទុះមីនប្រឆាំងមនុស្ស ឬអន្ទាក់/គ្រាប់បែកបង្កៃ។ ខ្សែអន្ទាក់/គ្រាប់បែកបង្កៃតាមធម្មតាលាតសន្ធឹងនៅកម្ពស់ទាប លើដីបន្តិចដើម្បីឲ្យអ្នកដែលឆ្លងកាត់ "ដើរទាក់" ខ្សែនោះដែលធ្វើឲ្យផ្ទុះមីន។

## យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (UNEXPLODED ORDNANCE)

គ្រាប់បែកផ្ទុះដែលនៅមិនទាន់បានផ្ទុះ។ យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (UXO) អាចធ្លាប់បានបំផ្ទុះ ទម្លាក់ ឬបាញ់បង្ហោះឡើងរួចមកហើយ ប៉ុន្តែគាំងមិនផ្ទុះតាមគោលបំណង។

# ឧបសម្ព័ន្ធ A8 ពាក្យបំព្រួញដែលនិយមប្រើប្រាស់

| | |
|---|---|
| AN (FO) | អាម៉ូនីញ៉ូមនីត្រាត (ប្រេងឥន្ធនៈ) |
| ANS | ស្ករអាម៉ូនីញ៉ូមនីត្រាត |
| AP | គ្រាប់បាញ់ទម្លុះ |
| APDSFS | គ្រាប់បាញ់ទម្លុះមានលំនឹងពេលជ្រុះស្លាប |
| API | គ្រាប់បាញ់ទម្លុះឆេះ |
| APSE | គ្រាប់បាញ់ទម្លុះរថពាសដែកមានប្រសិទ្ធភាពបន្ទាប់បន្សំ |
| មីន AP | មីនប្រឆាំងមនុស្ស |
| មីន AT | មីនប្រឆាំងរថក្រោះ |
| មីន AV | មីនប្រឆាំងរថយន្ត |
| | |
| BI | ផ្ទុះឆេះ |
| BIP | បំផ្ទុះចោលនៅនឹងកន្លែង |
| Blank | គ្រាប់រំសេវសម្រាប់ហ្វឹកហ្វឺន |
| | |
| CEX | គ្រឿងផ្ទុះដែលលក់លើទីផ្សារ |
| CJEODC | ក្រុមសម្របសម្រួលការកម្ទេចសំណល់ជាតិផ្ទុះរួមគ្នា |
| CN/CS | គ្រាប់រំសេវប្រឆាំងកុប្បកម្ម (ឧ. ឧស្ម័នបង្ហូរទឹកភ្នែក) |
| CO-IED | គ្រឿងផ្ទុះកែច្នៃបញ្ជាដោយប្រតិបត្តិការ |
| CP | ការិយាល័យទំនាក់ទំនង |
| CP-IED | គ្រឿងផ្ទុះកែច្នៃបញ្ជាដោយទាញ |
| CW-IED | គ្រឿងផ្ទុះកែច្នៃបញ្ជាដោយខ្សែ |
| | |
| DIME | គ្រាប់រំសេវដែលមានជាតិលោហៈក្រាស់ |
| DFC | រំសេវកម្ទេចផ្ទាល់ |
| DFFC | រំសេវកម្ទេចបំណែកដាក់ផ្ទាល់ |

| | |
|---|---|
| DP | គោលបំណងពីរយ៉ាង (=HE/HEAT) |
| | |
| ECM | វិធានការទប់ទល់ដោយអេឡិចត្រូនិច |
| EFP | គ្រាប់ផ្លោងមានជាតិរំសេវ |
| EO | សំណល់ជាតិផ្ទុះ |
| EOD | ការកម្ទេចសំណល់ជាតិផ្ទុះ |
| EOD CC | ក្រុមសម្របសម្រួលការកម្ទេចសំណល់ជាតិផ្ទុះ |
| EOR | ការស្រាវជ្រាវសំណល់ជាតិផ្ទុះ |
| ERW | សំណល់ជាតិផ្ទុះពីសង្គ្រាម |
| | |
| FAE | គ្រឿងផ្ទុះដោយឥន្ធនៈ ឬខ្យល់ |
| FP | ចំណុចបំផ្ទុះ/បាញ់ចេញ |
| FRAG | គ្រាប់ជះអំបែង |
| | |
| HC | អិចសាក្លរ៉េតង់ (សមាសធាតុនៃផ្សែង) |
| HC-HQ | ទីបញ្ជាការជាន់ខ្ពស់ |
| HE | រំសេវផ្ទុះខ្លាំង |
| HEAT | គ្រាប់បាញ់បំបុករថក្រោះបាន |
| HEI | គ្រាប់បាញ់បញ្ឆេះ |
| HESH | ក្បាលគ្រាប់បាញ់ទម្លាយ |
| HME | គ្រឿងផ្ទុះធ្វើឡើងដោយសម្ភារៈប្រើប្រាស់នៅផ្ទះ |
| HVAP | គ្រាប់បាញ់ទម្លុះមានល្បឿនលឿន |
| | |
| I | គ្រាប់បែកឆេះ |
| IAAG | គ្រាប់បែកកៃច្នៃប្រឆាំងរថពាសដែក |
| IATG | គោលការណ៍ណែនាំបច្ចេកទេសគ្រាប់រំសេវអន្តរជាតិ |
| ICM | គ្រាប់បែកកៃច្នៃធម្មតា |
| ICP | ការិយាល័យទំនាក់ទំនងពេលមានករណីគ្រោះថ្នាក់ |

| | |
|---|---|
| IED | គ្រឿងផ្ទុះកែច្នៃ |
| IEDD | ការកម្ទេចគ្រឿងផ្ទុះកែច្នៃ |
| IID | គ្រឿងឆេះកែច្នៃ |
| ILLUM | ការបំភ្លឺ |
| IMAS | ស្តង់ដារអន្តរជាតិសកម្មភាពកម្ចាត់មីន |
| IR | អ៊ីនហ្វ្រារ៉េដ (Infra Red) |
| | |
| LC | ការបញ្ជាដោយភ្លើង |
| LCC-HQ | ទីបញ្ជាការជើងគោក |
| LMC-PP | ចានសម្ពាធប៉ះលោហៈទាប |
| | |
| MA-IED | គ្រឿងផ្ទុះកែច្នៃភ្ជាប់ដោយម៉ាញេទិច |
| MN EOD CC | ក្រុមស្របសម្រួលការកម្ទេចសំណល់ជាតិផ្ទុះពហុជាតិសាសន៍ |
| MILEX | រំសេវផ្ទុះយោធា |
| | |
| PB-IED | គ្រឿងផ្ទុះកែច្នៃដោយមនុស្ស |
| PC-IED | គ្រឿងផ្ទុះកែច្នៃបញ្ជាដោយក្បាលគ្រាប់ |
| PIR | អ៊ីនហ្វ្រារ៉េដអកម្ម (Passive Infra Red) |
| PP-... | ចានសម្ពាធ-... |
| PR-... | ការបញ្ចេញសម្ពាធ-... |
| PRAC | ការហ្វឹកហាត់ |
| PSSM | ការគ្រប់គ្រងសន្តិសុខរូបវ័ន្ត និងឃ្លាំងស្តុកគ្រាប់រំសេវ (ពាក្យរបស់ ស.រ.អ សម្រាប់ សំណល់ជាតិផ្ទុះពីសង្គ្រាម) |
| | |
| RC-IED | គ្រឿងផ្ទុះកែច្នៃបញ្ជាដោយវិទ្យុ |
| RDX | អិចសូសែន (រំសេវផ្ទុះខ្លាំង) |
| RFT | គន្លឹះបញ្ជាដោយវិទ្យុ |
| RSP | នីតិវិធីការពារសុវត្ថិភាព |

# A8 ពាក្យបំព្រួញដែលនិយមប្រើប្រាស់

| | |
|---|---|
| SALW | អាវុធធុនតូច និងសព្វាវុធធុនស្រាល |
| SBIED | ឧបករណ៍កែច្នៃសម្រាប់អ្នកធ្វើអត្តឃាត |
| SDC | រំសេវបំផ្លាញខ្លួនឯង |
| STANAG | កិច្ចព្រមព្រៀងគំរូនីយកម្មអង្គការណាតូ |
| SVBIED | គ្រឿងផ្ទុះកែច្នៃសម្រាប់បំផ្ទុះធ្វើអត្តឃាតដោយរថយន្ត |
| TO-IED | គ្រឿងផ្ទុះកែច្នៃប្រតិបត្តិការដោយកំណត់ម៉ោង |
| TPU | ឯកតាម៉ោង និងថាមពល |
| TTP | តាក់តិច បច្ចេកទេស នីតិវិធី |
| USBV | Unkonventionelle Spreng- und Brandvorrichtung<br>(គ្រឿងផ្ទុះ និងគ្រឿងឆេះកែច្នៃ) |
| UVIED | គ្រឿងផ្ទុះកែច្នៃសម្រាប់បំផ្ទុះក្រោមរថយន្ត |
| UXO | សំណល់ជាតិផ្ទុះមិនទាន់ផ្ទុះ |
| VBIED | គ្រឿងផ្ទុះកែច្នៃសម្រាប់បំផ្ទុះដោយរថយន្ត |
| VCP | ប៉ុស្តិ៍ត្រួតពិនិត្យរថយន្ត |
| VOIED | គ្រឿងផ្ទុះកែច្នៃប្រតិបត្តិការដោយជនរងគ្រោះ |
| VP | ចំណុចគ្រោះថ្នាក់ |
| WAM | ការគ្រប់គ្រងសព្វាវុធ និងគ្រាប់រំសេវ<br>(ពាក្យរបស់ អសប សម្រាប់ PSSM) |
| WP | ផូស្វ័រពណ៌ស (សមាសធាតុផ្សេង) |
| WET | ក្រុមរុករកសព្វាវុធ |
| WIT | ក្រុមស៊ើបការណ៍សព្វាវុធ<br>(អតីតៈនិយមន័យរបស់ WET) |

# ឧបសម្ព័ន្ធ A9 ប្រភពបន្ថែមទៀត នៃព័ត៌មាន

ព័ត៌មានទូទៅ៖

www.mineaction.org/unmas

www.gichd.org

www.peaceopstraining.org

www.jmu.edu/cisr/index.shtml

ដំបូន្មានបច្ចេកទេស៖

www.un.org/disarmament/un-saferguard/guide-lines

www.mineactionstandards.org

ព័ត៌មានពិសេសអំពីគ្រាប់រំសេវ៖

www.cat-uxo.com

www.rwd-mb3.de

www.lexpev.nl

and others...

# មនុស្សទំនាក់ទំនងគ្រា
# មានអាសន្ន

ប្រើចន្លោះទំនេរនេះដើម្បីសរសេរព័ត៌មានទំនាក់ទំនងលម្អិតដូចជា លេខទូរសព្ទ និង/ឬហ្វេកង់ស៍របស់៖

មន្ត្រីសន្តិសុខ មណ្ឌលសុខភាព បុគ្គលិកបន្ទប់វិទ្យុទាក់ទង
មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីន (ទីបញ្ជាការ) "នៅតាមមូលដ្ឋាន"។ល។

# ចំណាំ

# ចំណាំ

UNMAS

UNITED NATIONS
ផ្នែកសកម្មភាពកំចាត់មីននៃអង្គការសហប្រជាតិ(UNMAS)
NEW YORK, NY 10017 USA
អ៊ីមែល៖ MINEACTION@UN.ORG
វ៉ិបសាយ៖ WWW.MINEACTION.ORG